

# ដំណឹងល្អតាមសន្ដះ

# លូកា




ឆ្នាំចាត់គេឲ្យទៅ

ភូមិភាគ ភ្នំពេញ

# ដំណឹងល្អតាមសន្ដះ

# លូកា

អនុញ្ញាតឲ្យបោះពុម្ព

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

**អូលីវីយេ ឝ្មិតហាស្លេរ**

ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២

# ដំណឹងល្អតាមសន្ដ:លូកា

## ពាក្យលំនាំ

សន្ដ:លូកាជាគ្រូពេទ្យជាតិក្រិកមួយរូប។ លោកពុំបានស្គាល់ព្រះយេស៊ូដោយផ្ទាល់ខ្លួនលោកទេ ហើយលោកក៏ពុំមែនជាសាវ័កដំបូង ឬជាគ្រីស្ដទូតរបស់ព្រះអង្គដែរ តែលោកជាគ្រីស្ដបរិស័ទមួយរូបដែលជាសហការីរបស់គ្រីស្ដទូតប៉ូល ក្នុងពេលលោកធ្វើដំណើរទៅប្រកាសផ្សាយដំណឹងល្អនៅមជ្ឈឹមបូព៌ាប្រទេស។

សន្ដ:លូកាបានតែងគម្ពីរពីរក័ណ្ឌ គឺគម្ពីរ «ដំណឹងល្អលូកា» និងគម្ពីរ «កិច្ចការរបស់គ្រីស្ដទូត»។ លោកបានប្រមូលឯកសារផ្សេងៗស្ដីអំពីព្រះយេស៊ូ ហើយបានពិនិត្យមើលដោយហ្មត់ចត់តាមរបៀបអ្នកប្រាជ្ញក្នុងសម័យនោះ។ លោកបានតែងគម្ពីរនេះក្រោមការបំភ្លឺរបស់ព្រះវិញ្ញាណនៃព្រះអម្ចាស់។ សន្ដ:លូកាបានតែងគម្ពីរដំណឹងល្អនេះនៅចន្លោះគ.ស. ៨០-៩០។

### គោលបំណងសន្ដ:លូកា

សន្ដ:លូកាបានតែងគម្ពីរនេះសម្រាប់ឲ្យជនជាតិក្រិកអាន។ លោករ៉ាយរ៉ាប់ប្រវត្តិរបស់ព្រះយេស៊ូដោយចង់ពន្យល់ថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានណែនាំព្រះយេស៊ូ តាំងពីមុនព្រះអង្គប្រសូតមករហូតដល់ពេលព្រះអង្គសោយទិវង្គតនៅក្រុងយេរូសាឡឹម។ ក្រោយព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះវិញ្ញាណបានណែនាំក្រុមគ្រីស្ដបរិស័ទឲ្យប្រកាសផ្សាយដំណឹងល្អអំពីព្រះគ្រីស្ដ រហូតដល់ចុងកាត់មាត់ញកនៃផែនដី។

លោកប្រៀនប្រដៅអ្នកដែលជឿលើព្រះយេស៊ូឲ្យមានចិត្តមេត្តាករុណា ដូចព្រះជាម្ចាស់ដែលមានព្រះហឫទ័យមេត្តាករុណា។ លោកប្រៀនប្រដៅគេឲ្យចេះស្រឡាញ់រាប់អានជនជាតិដទៃ ជាពិសេសជាមួយជនជាតិដែលរស់នៅជិតខាង ឲ្យចេះអត់ទោសគ្នាទៅវិញទៅមក ឲ្យយកចិត្តទុកដាក់ជួយអ្នកក្រីក្រ និងសុខចិត្តលះបង់អ្វីៗទាំងអស់ដោយយល់ដល់ព្រះគ្រីស្ត។ អ្នកជឿព្រះយេស៊ូត្រូវយកចិត្តទុកដាក់អធិដ្ឋាន គឺនិយាយសារស័ព្ទជាមួយព្រះបិតាដោយស្និទ្ធស្នាល ត្រូវមានអំណរសប្បាយជានិច្ច ព្រោះមានព្រះវិញ្ញាណរបស់ព្រះគ្រីស្តគង់នៅជាមួយ និងត្រូវយល់ច្បាស់ថា ព្រះជាម្ចាស់សង្គ្រោះអ្នកជឿឥឡូវនេះ។

## គម្រោងរបស់គម្ពីរសន្តៈលូកា

- បុព្វកថា (១, ១-៤)
- កំណើតរបស់លោកយ៉ូហានបាទីស្ត និងព្រះយេស៊ូ (១, ៥-២,៥២)
- សេចក្ដីប្រកាសរបស់លោកយ៉ូហានបាទីស្ត (៣, ១-២០)
- ព្រះយេស៊ូទទួលពិធីជ្រមុជទឹក និងឈ្នះការល្បួង (៣, ២១-៤,១៣)។
- ព្រះយេស៊ូប្រកាសដំណឹងល្អនៅស្រុកកាលីឡេ (៤, ១៤-៩, ៥០)។
- ព្រះយេស៊ូយាងពីស្រុកកាលីឡេឆ្ពោះទៅក្រុងយេរូសាឡឹម (៩, ៥១-១៩, ២៧)។
- សប្ដាហ៍ចុងក្រោយនៅក្រុងយេរូសាឡឹម និងភូមិដែលនៅជុំវិញ (១៩, ២៨-២៣, ៥៦)។
- ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងបង្ហាញខ្លួនឲ្យអ្នក ជឿឃើញ (២៤, ១-៥៣)។

# ដំណឹងល្អតាមសន្ដ:លូកា

## បុព្វកថា

១ ¹សូមជម្រាបមកឯកឧត្ដមថេអូភីល សូមជ្រាប! មនុស្ស
ជាច្រើនខិតខំយកចិត្តទុកដាក់ កត់ត្រាទុកនូវហេតុ
ការណ៍ទាំងអំបាលម៉ាន ដែលកើតមានក្នុងចំណោមយើងខ្ញុំ។
²អស់អ្នកដែលបានឃើញផ្ទាល់នឹងភ្នែក តាំងពីដំបូងរៀងមក
ហើយទទួលមុខងារបម្រើព្រះបន្ទូល បានរៀបរាប់ហេតុការណ៍
ទាំងនោះបន្ដមកយើងខ្ញុំ។ ³ខ្ញុំបានពិនិត្យហេតុការណ៍ទាំង
នោះ តាំងពីដើមរៀងមកយ៉ាងហ្មត់ចត់ ហើយខ្ញុំក៏យល់ឃើញ
ថា គួរតែកត់ត្រាទុកតាមលំដាប់លំដោយ ផ្ញើមកជូនលោក។
⁴ខ្ញុំធ្វើដូច្នេះក្នុងគោលបំណងចង់ឲ្យលោកជ្រាបថា សេចក្ដីប្រៀន
ប្រដៅ ទាំងប៉ុន្មាន ដែលលោកបានទទួលពិតជាត្រឹមត្រូវមែន។

### ទេវទូតជូនដំណឹងអំពីកំណើតរបស់យ៉ូហានបាទីស្ដ

⁵នៅគ្រាដែលព្រះបាទហេរ៉ូដគ្រងរាជ្យក្នុងស្រុកយូដាមាន
បូជាចារ្យ *មួយរូបឈ្មោះ សាការី ជាសមាជិកក្រុមបូជាចារ្យអប៊ីយ៉ា
ភរិយាលោកឈ្មោះ អេលីសាបិត កើតក្នុងត្រកូលរបស់លោក
មហាបូជាចារ្យ *អរ៉ុន ⁶ស្វាមីភរិយាទាំងពីររូបនេះជាមនុស្សសុចរិត
ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ហើយគាត់គោរពតាមវិន័យ
និងបញ្ញត្តិទាំងប៉ុន្មានរបស់ព្រះអម្ចាស់ ឥតមានទាស់ត្រង់ណា
ឡើយ។ ⁷អ្នកទាំងពីរគ្មានកូនសោះ ព្រោះនាងអេលីសាបិតជា
ស្ត្រីអារ ហើយម្យ៉ាងទៀត អ្នកទាំងពីរក៏មានវ័យចាស់ណាស់ទៅ

ហើយផង។ ៩ថ្ងៃមួយលោកសាការីបំពេញមុខងារជាបូជាចារ្យតាម
វេនក្រុមរបស់លោក។ ៩គេបានជ្រើសរើសលោកដោយចាប់ឆ្នោត
តាមទំនៀមទម្លាប់របស់ក្រុមបូជាចារ្យ ឲ្យលោកចូលទៅដុតគ្រឿង
ក្រអូបនៅក្នុងទីសក្ការៈរបស់ព្រះអម្ចាស់។ ១០ពេលលោកដុតគ្រឿង
ក្រអូប ប្រជាជនច្រើនកុះករនៅខាងក្រៅកំពុងអធិដ្ឋាន *។ ១១រំពេច
នោះ លោកសាការីឃើញទេវទូត *របស់ព្រះអម្ចាស់មួយរូប ឈរ
នៅខាងស្ដាំអាសនៈសម្រាប់ដុតគ្រឿងក្រអូប។ ១២ឃើញដូច្នោះ
លោករន្ធត់ចិត្ត ហើយភ័យខ្លាចទៀតផង។ ១៣ទេវទូតក៏មានប្រសាសន៍
ទៅកាន់លោកថា៖ «កុំខ្លាចអីលោកសាការីអើយ! ព្រះអម្ចាស់
យល់ព្រមតាមពាក្យទូលអង្វររបស់លោកហើយ។ នាងអេលីសាបិត
ជាភរិយារបស់លោក នឹងបង្កើតកូនប្រុសមួយ លោកត្រូវដាក់
ឈ្មោះកូននោះថា "យ៉ូហាន"[ក]។ ១៤កូននោះនឹងធ្វើឲ្យលោកមាន
ចិត្តសប្បាយរីករាយ ហើយមនុស្សជាច្រើនអបអរសាទរនឹងកំណើត
កុមារនោះដែរ។ ១៥កូនរបស់លោកនឹងមានឋានៈដ៏ប្រសើរឧត្ដម
នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ មិនសេពសុរា ឬគ្រឿងស្រវឹង
ណាមួយសោះឡើយ។ កូននោះនឹងបានពោរពេញទៅដោយ
ព្រះវិញ្ញាណដ៏វិសុទ្ធ *តាំងពីក្នុងផ្ទៃម្ដាយមក។ ១៦កូននោះនឹងនាំ
ជនជាតិអ៊ីស្រាអែលជាច្រើន មករកព្រះអម្ចាស់ជាព្រះរបស់គេ
វិញ។ ១៧កូននោះនឹងមកមុនព្រះអង្គ ហើយមានវិញ្ញាណប្រកប
ដោយឫទ្ធានុភាពដូចលោកអេលីបានទទួល ដើម្បីបង្វែរចិត្តឪពុក
ទៅរកកូន[ខ] ព្រមទាំងបំបែរចិត្តមនុស្សរឹងទទឹងឲ្យត្រឡប់មកជា
មនុស្សសុចរិត និងរៀបចំប្រជារាស្ដ្រមួយជាស្រេច ទុកសម្រាប់
ទទួលព្រះអម្ចាស់»។

១៨លោកសាការីសួរទៅទេវទូត *ថា៖ «តើធ្វើម្ដេចឲ្យខ្ញុំដឹងថា
ការនោះពិតជាកើតឡើងមែន ព្រោះរូបខ្ញុំនេះចាស់ហើយ រីឯ

**ក**, «យ៉ូហាន» មានន័យថាព្រះជាម្ចាស់ប្រណីសន្ដោស។ កំណើតរបស់លោកយ៉ូហានបាទីស្ដ
ជាទីសម្គាល់ ទីមួយនៃការយាងមករបស់ព្រះមែស្ស៊ី។ • **ខ**, ម៉ាឡាគី៣,២៣-២៤។

ប្រពន្ធខ្ញុំសោត ក៏មានអាយុច្រើនទៀតផង»។ ១៩ទេវទូតតបវិញ
ថា៖ «ខ្ញុំឈ្មោះកាព្រីអែល ជាអ្នកបម្រើព្រះជាម្ចាស់ ព្រះអង្គបាន
ចាត់ខ្ញុំឲ្យនាំដំណឹងល្អនេះមកប្រាប់លោក ២០ប៉ុន្តែដោយលោក
ពុំព្រមជឿពាក្យខ្ញុំ លោកនឹងទៅជាមនុស្សគ និយាយពុំកើត រហូត
ដល់ថ្ងៃដែលហេតុការណ៍ទាំងនោះបានសម្រេចតាមពេលកំណត់»។
២១ក្នុងពេលជាមួយគ្នានោះ ប្រជាជនទន្ទឹងរង់ចាំលោកសាការី
ហើយងឿងឆ្ងល់ណាស់ ព្រោះលោកចូលទៅក្នុងទីសក្ការៈយូរ
ដូច្នេះ។ ២២កាលលោកចេញមកវិញ លោកពុំអាចនិយាយទៅ
គេបានឡើយ។ ប្រជាជនទាំងនោះយល់ថា ប្រាកដជាលោក
បានឃើញការអស្ចារ្យអ្វីមួយ នៅក្នុងទីសក្ការៈជាមិនខាន។ លោក
សាការីធ្វើតែកាយវិការឲ្យគេយល់ ព្រោះលោកនៅគនិយាយមិន
កើត។ ២៣លុះលោកសាការីបានបំពេញការងារតាមវេនចប់សព្វ
គ្រប់ហើយ លោកក៏វិលត្រឡប់ទៅផ្ទះវិញ។ ២៤ក្រោយមកនាង
អេលីសាបិតជាភរិយារបស់លោកក៏ចាប់មានផ្ទៃពោះ នាងលាក់
ខ្លួនអស់រយៈពេលប្រាំខែ។ នាងនឹកគិតថា៖ ២៥«ឥឡូវនេះព្រះ
អម្ចាស់បានប្រោសប្រណីដល់រូបខ្ញុំ ព្រះអង្គសព្វព្រះហឫទ័យឲ្យ
ខ្ញុំលែងខ្មាសមនុស្សលោកទៀតហើយ!»។

## ទេវទូតជូនដំណឹងអំពីកំណើតព្រះយេស៊ូ

២៦ប្រាំមួយខែក្រោយមក ព្រះជាម្ចាស់បានចាត់ទេវទូតកាព្រីអែល
ឲ្យទៅភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ ២៧ដើម្បីជួបនឹងស្ត្រី
ក្រមុំព្រហ្មចារីម្នាក់ជាគូដណ្ដឹងរបស់កំលោះម្នាក់ឈ្មោះ យ៉ូសែប
ដែលត្រូវជាញាតិវង្សព្រះបាទដាវីឌ ស្ត្រីក្រមុំនោះឈ្មោះ នាង
ម៉ារី។ ២៨ទេវទូតចូលទៅក្នុងផ្ទះនាងម៉ារី ហើយពោលទៅកាន់

នាងថា៖ «ចូរមានអំណរសប្បាយឡើង![ឝ] ព្រះអម្ចាស់គាប់ព្រះ
ហឫទ័យនឹងនាងហើយ ព្រះអង្គគង់ជាមួយនាង»។ ២៩ពេលឮ
ពាក្យនេះ នាងម៉ារីរន្ធត់យ៉ាងខ្លាំង នាងរិះគិតក្នុងចិត្តថា តើពាក្យ
ជម្រាបសួរនេះមានន័យដូចម្ដេច។ ៣០ទេវទូតពោលទៅកាន់នាង



ថា៖ «កុំខ្លាចអីម៉ារីអើយ! ដ្បិតព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹង
នាងហើយ។ ៣១នាងនឹងមានគភ៌សម្រាលបានបុត្រមួយ ដែល
នាងត្រូវថ្វាយព្រះនាមថា "យេស៊ូ"។ ៣២បុត្រនោះនឹងមានឋានៈ
ដ៏ប្រសើរឧត្ដម ហើយគេនឹងថ្វាយព្រះនាមថា "ព្រះបុត្រានៃព្រះ
ដ៏ខ្ពង់ខ្ពស់បំផុត"។ ព្រះជាម្ចាស់នឹងតាំងបុត្រនោះឲ្យគ្រងរាជ្យ
លើបល្ល័ង្ករបស់ព្រះបាទដាវីឌ ជាព្រះអយ្យកោរបស់ព្រះអង្គ ៣៣ទ្រង់
នឹងគ្រងរាជ្យលើប្រជារាស្ត្រអ៊ីស្រាអែល អស់កល្បជានិច្ច ហើយ
រាជ្យរបស់ព្រះអង្គនឹងនៅស្ថិតស្ថេរ ឥតមានទីបញ្ចប់ឡើយ»។
៣៤នាងម៉ារីសួរទៅទេវទូតថា៖ «តើធ្វើដូចម្ដេចនឹងឲ្យការនេះកើត
ឡើងបាន បើនាងខ្ញុំមិនរួមរស់ជាមួយបុរសណាផងដូច្នេះ?»។

ឝ, ជាពាក្យជម្រាបសួរ ប៉ុន្តែ មិនតាមរបៀបធម្មតា។ ពាក្យជម្រាបសួរនេះ នាំឲ្យយើងគិតទៅដល់សេចក្ដីដែលព្យាការីប្រកាសឲ្យអ្នកក្រុងយេរូសាឡឹម មានអំណរសប្បាយដោយព្រះជាម្ចាស់នឹងសង្គ្រោះក្រុងនេះ (សូផូនី ៣,១៤, សាការី ៩,៩)។ សន្តៈលូកាប្រើពាក្យជម្រាបសួរនេះ ប្រកាសពីការប្រសូតរបស់ព្រះយេស៊ូជាព្រះសង្គ្រោះ។

៣៥ទេវទូត *ឆ្លើយទៅនាងវិញថា៖ «ព្រះវិញ្ញាណដ៏វិសុទ្ធ *នឹងយាង
មកសណ្ឋិតលើនាង គឺឫទ្ធានុភាពរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុតនឹង
គ្របបាំងនាង។ ហេតុនេះគេនឹងថ្វាយព្រះនាមដល់បុត្រដ៏វិសុទ្ធ ដែល
ត្រូវប្រសូតមកនោះថា "ព្រះបុត្រារបស់ព្រះជាម្ចាស់"។ ៣៦ម្យ៉ាង ទៀត
នាងអេលីសាបិតជាញាតិរបស់នាង មានផ្ទៃពោះប្រាំមួយខែ
ហើយ ថ្វីដ្បិតតែគាត់មានវ័យចាស់ ថែមទាំងជាស្ត្រីអារទៀត
ផងក៏ដោយ ៣៧ព្រោះគ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតនោះ
ឡើយ»។ ៣៨នាងម៉ារីពោលទៅទេវទូតថា៖ «នាងខ្ញុំជាអ្នកបម្រើ
របស់ព្រះអម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ!»។
បន្ទាប់មក ទេវទូតចាកចេញពីនាងទៅ។

## នាងម៉ារីទៅសួរសុខទុក្ខនាងអេលីសាបិត

៣៩នៅគ្រានោះ នាងម៉ារីប្រញាប់ប្រញាល់ធ្វើដំណើរទៅកាន់
ភូមិមួយនៅតំបន់ភ្នំ ក្នុងស្រុកយូដា។ ៤០នាងបានចូលទៅក្នុងផ្ទះ
លោកសាការី ហើយជម្រាបសួរនាងអេលីសាបិត។ ៤១ពេលនាង
អេលីសាបិតឮនាងម៉ារីជម្រាបសួរ ទារកនៅក្នុងផ្ទៃនាងបម្រះឡើង
ហើយគាត់ក៏បានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ៤២រួចបន្លឺ
សំឡេងឡើងថា៖ «ព្រះជាម្ចាស់បានប្រទានពរដល់នាងលើស
ស្ត្រីនានា ហើយព្រះអង្គក៏ប្រទានពរដល់បុត្រនាងដែរ។ ៤៣តើរូប
ខ្ញុំនេះមានឋានៈអ្វី បានជាមាតាព្រះអម្ចាស់របស់ខ្ញុំមកសួរសុខ
ទុក្ខខ្ញុំដូច្នេះ?។ ៤៤កាលខ្ញុំបានឮពាក្យជម្រាបសួររបស់នាង ស្រាប់
តែកូននៅក្នុងផ្ទៃខ្ញុំបម្រះឡើង ដោយអំណរសប្បាយ ៤៥នាងពិត
ជាមានសុភមង្គលមែន ព្រោះនាងបានជឿព្រះបន្ទូលដែលព្រះ
អម្ចាស់ប្រាប់នាងមុខជាបានសម្រេចមិនខាន»។

## ទំនុកតម្កើងរបស់នាងម៉ារី

៤៦ ពេលនោះនាងម៉ារីថ្លែងឡើងថា៖
«ព្រលឹងខ្ញុំសូមលើកតម្កើងព្រះអម្ចាស់ *
៤៧ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង
ព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ
៤៨ ព្រះអង្គទតមើលមកខ្ញុំ
ដែលជាអ្នកបម្រើដ៏ទន់ទាបរបស់ព្រះអង្គ[ឃ]
អំណើះតទៅមនុស្សគ្រប់ជំនាន់នឹងពោលថា
ខ្ញុំជាអ្នកមានសុភមង្គលពិតមែន
៤៩ ព្រះដ៏មានឫទ្ធានុភាពបានសម្ដែង
ការប្រសើរអស្ចារ្យចំពោះរូបខ្ញុំ។
ព្រះនាមរបស់ព្រះអង្គពិតជាវិសុទ្ធ *មែន![ង]
៥០ ទ្រង់មានព្រះហឫទ័យមេត្តាករុណា
ដល់អស់អ្នកដែលកោតខ្លាចព្រះអង្គ
នៅគ្រប់ជំនាន់តរៀងទៅ
៥១ ទ្រង់បានសម្ដែងឫទ្ធិបារមី
កម្ចាត់មនុស្សដែលមានចិត្តឆ្មើងឆ្មៃ
៥២ ទ្រង់បានទម្លាក់អ្នកកាន់អំណាចចុះពីតំណែង
ហើយទ្រង់លើកតម្កើងមនុស្សទន់ទាបឡើង។
៥៣ ទ្រង់បានប្រទានសម្បត្តិយ៉ាងបរិបូណ៌
ដល់អស់អ្នកដែលស្រេកឃ្លាន
ហើយបណ្ដេញពួកអ្នកមាន
ឲ្យត្រឡប់ទៅវិញដោយដៃទទេ។
៥៤ ព្រះអង្គបានជួយប្រជារាស្ត្រអ៊ីស្រាអែល

---

**ឃ**, យើងអាចបកប្រែថា «ព្រះអង្គប្រោសប្រណីដល់រូបខ្ញុំ ជាអ្នកបម្រើដ៏ទន់ទាបរបស់ព្រះអង្គ» ឬ ព្រះអង្គទតមើលមកទុក្ខវេទនានៃអ្នកបម្រើរបស់ព្រះអង្គ។• **ង**, ឬ «ព្រះអង្គពិតជាព្រះជាម្ចាស់មែន!»។

ជាអ្នកបម្រើរបស់ព្រះអង្គ
ហើយតែងតែសម្ដែងព្រះហឫទ័យ
មេត្តាករុណា
៥៥ ដល់លោកអប្រាហាំ និងពូជពង្សរបស់លោក
ជានិច្ចតរៀងទៅ
ដូចទ្រង់បានសន្យាជាមួយបុព្វបុរសរបស់យើង
ឥតភ្លេចសោះឡើយ។
៥៦នាងម៉ារីបានស្នាក់នៅជាមួយនាងអេលីសាបិត អស់រយៈ
ពេលប្រមាណបីខែ ទើបនាងត្រឡប់ទៅផ្ទះវិញ។

## កំណើតលោកយ៉ូហានបាទីស្ដ

៥៧លុះនាងអេលីសាបិតគ្រប់ខែហើយ គាត់សម្រាលបានកូន
ប្រុសមួយ។ ៥៨អ្នកជិតខាង និងញាតិសន្ដាននាំគ្នាអបអរសាទរ
ជាមួយគាត់ ព្រោះគេបានឮដំណឹងថា ព្រះអម្ចាស់សម្ដែង
ព្រះហឫទ័យមេត្តាករុណាចំពោះគាត់យ៉ាងច្រើនអនេក។
៥៩ប្រាំបីថ្ងៃក្រោយមក គេធ្វើពិធីកាត់ស្បែក *ឲ្យទារកនោះ
ហើយចង់ដាក់ឈ្មោះថា "សាការី" ដូចឪពុកដែរ ៦០តែម្ដាយប្រាប់
ថា៖ «ទេ ត្រូវដាក់ឈ្មោះថា "យ៉ូហាន" វិញ»។ ៦១ពួកគេតបថា៖
«ក្នុងញាតិសន្ដានរបស់អ្នក គ្មាននរណាមានឈ្មោះហ្នឹងទេ»។
៦២គេធ្វើសញ្ញាសួរទៅលោកសាការីថា ចង់ដាក់ឈ្មោះអ្វីឲ្យកូន។
៦៣លោកសាការីសុំឲ្យគេយកក្ដារឆ្នួនមួយមក ហើយសរសេរថា
«កូននេះឈ្មោះ យ៉ូហាន»។ ពួកគេងឿងឆ្ងល់គ្រប់គ្នា។ ៦៤រំពេច
នោះស្រាប់តែលោកនិយាយបានដូចដើមវិញ រួចលោកបន្លឺសំឡេង
សរសើរព្រះជាម្ចាស់។ ៦៥អ្នកជិតខាងកោតស្ញប់ស្ញែង[ច]គ្រប់ៗគ្នា

ច, ពាក្យដើម «ភ័យខ្លាច»។ ពាក្យនេះសំដៅទៅលើ ការភ័យខ្លាចរបស់មនុស្សនៅពេលឃើញ
ព្រះជាម្ចាស់ សម្ដែងការអស្ចារ្យអ្វីមួយ។

ហើយព្រឹត្តិការណ៍នេះឮសុសសាយពេញតំបន់ភ្នំ ក្នុងស្រុកយូដា។
៦៦អស់អ្នកដែលបានឮក៏ចងចាំរឿងនេះទុកក្នុងចិត្ត ហើយដណ្ដឹង
សួរខ្លួនឯងថា៖ «តើថ្ងៃក្រោយ កូននេះនឹងទៅជាយ៉ាងណា?»
ដ្បិតព្រះបារមី[ឆ]របស់ព្រះអម្ចាស់តាមជួយថែរក្សាកូននេះ។

## ទំនុកតម្កើងរបស់លោកសាការី

៦៧ពេលនោះ លោកសាការីជាឪពុករបស់ទារក បានពោរ
ពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ* ហើយថ្លែងពាក្យក្នុងព្រះនាម
ព្រះអង្គថា៖

៦៨ «សូមលើកតម្កើងព្រះអម្ចាស់
ជាព្រះនៃជនជាតិអ៊ីស្រាអែល
ដ្បិតទ្រង់សព្វព្រះហឫទ័យយាងមក
រំដោះប្រជារាស្ត្ររបស់ព្រះអង្គ។
៦៩ ទ្រង់បានប្រទានព្រះសង្គ្រោះ
ដ៏មានឫទ្ធិមួយព្រះអង្គពីក្នុងចំណោម
ព្រះញាតិវង្សរបស់ព្រះបាទដាវីឌ
ជាអ្នកបម្រើព្រះអង្គមកឲ្យយើង។
៧០ ព្រះជាម្ចាស់ប្រទានព្រះសង្គ្រោះនេះមកយើង
ស្របនឹងព្រះបន្ទូលសន្យាថ្លែង តាមរយៈ
ព្យាការី*របស់ព្រះអង្គនៅជំនាន់ដើម
៧១ គឺព្រះអង្គសង្គ្រោះយើង
ឲ្យរួចពីកណ្ដាប់ដៃរបស់ខ្មាំងសត្រូវ និង
រួចពីអំណាចរបស់អស់អ្នកដែលស្អប់យើង។
៧២ ព្រះអង្គសម្ដែងព្រះហឫទ័យ

**ឆ**, ពាក្យដើម «ព្រះហស្តរបស់ព្រះជាម្ចាស់»។

មេត្តាករុណាដល់បុព្វបុរស *របស់យើង
ហើយគោរពតាមសម្ពន្ធមេត្រី *របស់ព្រះអង្គ
យ៉ាងស្មោះស្ម័គ្រ
៧៣ គឺព្រះអង្គបានសន្យាយ៉ាងមី◌ុងម៉ាត់ដល់
លោកអប្រាហាំ *ជាបុព្វបុរសរបស់យើងថា
៧៤ ទ្រង់នឹងរំដោះយើង
ឲ្យរួចពីកណ្ដាប់ដៃរបស់ខ្មាំងសត្រូវ
ដើម្បីយើងអាចគោរពបម្រើព្រះអង្គបាន
ដោយឥតភ័យខ្លាច
៧៥ ព្រមទាំងឲ្យយើងរស់នៅ បានបរិសុទ្ធ *
និងសុចរិត ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
ជារៀងរាល់ថ្ងៃរហូតអស់មួយជីវិត។
៧៦ ចំណែកឯកូនវិញ កូននឹងទៅជាព្យាការី *
របស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត
ព្រោះកូននឹងដើរមុខព្រះអម្ចាស់
ដើម្បីរៀបចំផ្លូវថ្វាយព្រះអង្គ។
៧៧ កូននឹងធ្វើឲ្យប្រជារាស្ត្ររបស់ព្រះអង្គដឹង
ថាព្រះអង្គសង្គ្រោះគេ
ដោយលើកលែងទោសឲ្យគេរួចពីបាប។
៧៨ ព្រះរបស់យើងមានព្រះហឫទ័យ
មេត្តាករុណាដ៏លើសលប់
ព្រះអង្គប្រទានថ្ងៃរះ[៨] ពីស្ថានលើមក
ដើម្បីរំដោះយើង
៧៩ និង ដើម្បីបំភ្លឺអស់អ្នកដែលស្ថិតនៅក្នុងទីងងឹត
ក្រោមអំណាចនៃសេចក្ដីស្លាប់

**៨**, «ថ្ងៃរះ» ចង់សំដៅទៅលើព្រះគ្រីស្ត ដែលជាពន្លឺដែលយាងមកបំភ្លឺមនុស្សលោក (សូមអាន ម៉ាថាយ៤,១៦)។

ព្រមទាំងតម្រង់ផ្លូវយើង
ឆ្ពោះទៅរកសេចក្ដីសុខសាន្ត»។

៨០កុមារយ៉ូហានមានវ័យចម្រើនឡើងជាលំដាប់ ទាំងខាងរូប
កាយ ទាំងខាងវិញ្ញាណ។ គាត់រស់នៅតែក្នុងវាលរហោស្ថាន រហូត
ដល់ថ្ងៃដែលគាត់បង្ហាញខ្លួនឲ្យប្រជារាស្ត្រអ៊ីស្រាអែលឃើញ។

## **កំណើតព្រះយេស៊ូ**

២ ១នៅគ្រានោះ ព្រះចៅអធិរាជរ៉ូម៉ាំង ព្រះនាមអូគូស្ត
មានព្រះរាជបញ្ជាឲ្យជំរឿនចំនួនប្រជាជនទាំងអស់
ក្នុងចក្រភពរ៉ូម៉ាំងទាំងមូល[ឈ]។ ២ការជំរឿនប្រជាជនលើកដំបូង
នេះ បានធ្វើឡើង ក្នុងអំឡុងពេលដែលលោកគីរីញូស ធ្វើជា
ទេសាភិបាលនៅស្រុកស៊ីរី។ ៣អ្នកស្រុកទាំងអស់ ត្រូវទៅចុះ
ឈ្មោះក្នុងបញ្ជីតាមស្រុកកំណើតរៀងៗខ្លួន។ ៤រីឯលោកយ៉ូសែប
ក៏ចេញដំណើរពីភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ ឆ្ពោះទៅ
ភូមិបេថ្លេហិម ក្នុងស្រុកយូដា ជាភូមិកំណើតរបស់ព្រះបាទដាវីឌ
ព្រោះលោកជាព្រះញាតិវង្សនឹងព្រះបាទដាវីឌ។ ៥លោកទៅចុះ
ឈ្មោះជាមួយនាងម៉ារី ជាភរិយាដែលមានផ្ទៃពោះ។៦ពេលអ្នក
ទាំងពីរនៅឯភូមិបេថ្លេហិម នាងម៉ារីគ្រប់ខែហើយ។ ៧នាងសម្រាល
បានបុត្រមួយ ជាបុត្រច្បង។ នាងរុំបុត្រនោះនឹងសំពត់ រួចដាក់
ឲ្យផ្ទំក្នុងស្នូកសត្វ ដ្បិតពុំមានសល់កន្លែងសំណាក់ក្នុងផ្ទះសោះ។

**ឈ**, ពាក្យដើម «ក្នុងពិភពលោកទាំងមូល»។

## ទេវទូតប្រកាសអំពីកំណើតព្រះយេស៊ូ ប្រាប់ពួកគង្វាល

៨ក្នុងស្រុកនោះ ពេលយប់មានពួកគង្វាលនៅមើលហ្វូងសត្វ
របស់គេតាមវាលស្មៅ។ ៩ពេលនោះ ទេវទូត* របស់ព្រះអម្ចាស់មក
ឈរនៅក្បែរពួកគេ សិរីរុងរឿងរបស់ព្រះអម្ចាស់ បានភ្លឺចិញ្ចែង
ចិញ្ចាចនៅជុំវិញគេ នាំឲ្យគេភ័យខ្លាចយ៉ាងខ្លាំង។ ១០ទេវទូតពោល
ទៅគេថា៖ «កុំខ្លាចអ្វីឡើយ ខ្ញុំនាំដំណឹងល្អមួយមកប្រាប់អ្នករាល់
គ្នា។ ដំណឹងនេះនឹងធ្វើឲ្យប្រជារាស្ត្រទាំងមូលមានអំណរដ៏លើស
លប់។ ១១យប់នេះ នៅក្នុងភូមិកំណើតរបស់ព្រះបាទដាវីឌ ព្រះ
សង្គ្រោះរបស់អ្នករាល់គ្នាប្រសូតហើយ គឺព្រះគ្រីស្ដជាអម្ចាស់។
១២នេះជាសញ្ញាសម្គាល់ឲ្យអ្នករាល់គ្នាដឹង គឺអ្នករាល់គ្នាមុខជាឃើញ
ទារកមួយទើបនឹងប្រសូត រុំដោយសំពត់ ផ្ដេកនៅក្នុងស្នូកសត្វ»។

១៣រំពេចនោះ មានទេវទូតច្រើនកុះករចុះពីស្ថានបរមសុខ*មក
រួមជាមួយទេវទូតនោះ ច្រៀងសរសើរព្រះជាម្ចាស់ថា៖ ១៤«សូម
លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ នៅស្ថានដ៏ខ្ពស់បំផុត
ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គបាន
ប្រកបដោយសេចក្ដីសុខសាន្តនៅលើផែនដី!»។

១៥លុះពួកទេវទូតត្រឡប់ទៅស្ថានបរមសុខវិញអស់ទៅ ពួក
គេបបួលគ្នាថា៖ «ទៅ! យើងនាំគ្នាទៅបេថ្លេហិម មើលហេតុការណ៍
ដែលកើតមាន ដូចព្រះអម្ចាស់បានសម្ដែងឲ្យយើងដឹងនោះមើល៍»។
១៦ពួកគេប្រញាប់ប្រញាល់នាំគ្នាធ្វើដំណើរទៅ ឃើញនាងម៉ារី
លោកយ៉ូសែប ព្រមទាំងព្រះឱរសផ្ទំក្នុងស្នូកសត្វ។ ១៧ពេលពួក
គង្វាលឃើញព្រះឱរសហើយ គេក៏រៀបរាប់អំពីសេចក្ដីដែលទេវទូត
បានប្រាប់អំពីព្រះឱរសនេះ។ ១៨អស់អ្នកដែលបានឮពួកគង្វាល
និយាយនឹកឆ្ងល់យ៉ាងខ្លាំង។ ១៩រីឯនាងម៉ារីវិញ នាងចងចាំហេតុ

ការណ៍ទាំងនេះទុកក្នុងចិត្ត ព្រមទាំងត្រិះរិះពិចារណាថែមទៀត
ផង។ ២០បន្ទាប់មក ពួកគង្វាលត្រឡប់ទៅវិញ ទាំងច្រៀងលើក
តម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះហេតុការណ៍ទាំងអស់
ដែលគេបានឃើញបានឮ ស្របតាមសេចក្ដីដែលទេវទូតបាន
ប្រាប់គេ ឥតមានខ្វះត្រង់ណាឡើយ។

២១ប្រាំបីថ្ងៃក្រោយមក ដល់ពេលកំណត់ធ្វើពិធីកាត់ស្បែក*
ថ្វាយព្រះឱរស គេថ្វាយព្រះនាមថា «យេស៊ូ» ជាព្រះនាមដែល
ទេវទូត*បានប្រាប់នាងម៉ារីមុនពេលមានផ្ទៃពោះ។

## ពិធីថ្វាយព្រះឱរសយេស៊ូនៅក្នុងព្រះវិហារ

២២លុះដល់ពេលកំណត់ដែលលោកយ៉ូសែប និងនាងម៉ារីត្រូវ
ធ្វើពិធីជម្រះកាយឲ្យបានបរិសុទ្ធ*តាមធម្មវិន័យ* លោកម៉ូសេ*[ញ]
អ្នកទាំងពីរ ក៏នាំព្រះឱរសទៅថ្វាយព្រះអម្ចាស់នៅក្រុងយេរូសាឡឹម
២៣ដ្បិតក្នុងធម្មវិន័យរបស់ព្រះអម្ចាស់ មានចែងទុកមកថា៖ *«កូន
ប្រុសច្បងទាំងអស់ ត្រូវទុកជាចំណែកថ្វាយព្រះអម្ចាស់»*។[ដ] ២៤អ្នក
ទាំងពីរថ្វាយយញ្ញបូជាតាមធម្មវិន័យរបស់ព្រះអម្ចាស់បានចែង
ទុកមក គឺថ្វាយ *"លលកមួយគូ ឬព្រាបស្ទាវពីរ"*[ឋ]។

២៥នៅក្រុងយេរូសាឡឹម មានបុរសម្នាក់ឈ្មោះស៊ីម្មាន ជាមនុស្ស
សុចរិត* គាត់គោរពកោតខ្លាចព្រះជាម្ចាស់ ព្រមទាំងទន្ទឹងរង់ចាំ
ពេលព្រះអង្គយាងមក សម្រាលទុក្ខប្រជារាស្ត្រអ៊ីស្រាអែល។
ព្រះវិញ្ញាណដ៏វិសុទ្ធ*សណ្ឋិតលើគាត់ ២៦ហើយសម្តែងឲ្យគាត់
ដឹងថាគាត់មិនត្រូវស្លាប់ ដរាបណាមិនទាន់បានឃើញព្រះគ្រីស្ត*
ដែលព្រះអម្ចាស់ចាត់ឲ្យមកទេនោះ។ ២៧ព្រះ វិញ្ញាណនាំលោក
តាស៊ីម្មានចូលក្នុងព្រះវិហារ*។ ពេលមាតាបិតានាំព្រះឱរសយេស៊ូ

---

ញ, ឬធម្មវិន័យដែលព្រះជាម្ចាស់ប្រទានមកតាមរយៈលោកម៉ូសេ។ • ដ, សេរីភាព (និក្ខមនំ)១៣,២។
• ឋ, លេវីវិន័យ១២,៨។

មកថ្វាយព្រះជាម្ចាស់តាមធម្មវិន័យ* [28]លោកតាស៊ីម៉ូនក៏យក
ព្រះឱរសមកបី រួចសរសើរតម្កើងព្រះជាម្ចាស់ថា៖

[29] «បពិត្រព្រះដ៏ជាចៅហ្វាយ!
ឥឡូវនេះព្រះអង្គបានសម្រេចតាម
ព្រះបន្ទូលសន្យាហើយ។
ដូច្នេះ សូមឲ្យទូលបង្គំ
ជាអ្នកបម្រើរបស់ព្រះអង្គ
លាចាកលោកនេះទៅ ដោយសុខសាន្តផងចុះ
[30] ដ្បិតភ្នែកទូលបង្គំបានឃើញការសង្គ្រោះ
[31] ដែលព្រះអង្គបានប្រទានមកឲ្យប្រជាជាតិទាំងអស់
[32] គឺជាពន្លឺដែលនាំឲ្យមនុស្ស
គ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គ
និងជាសិរីរុងរឿងរបស់អ៊ីស្រាអែល
ជាប្រជារាស្ត្រព្រះអង្គ»។

## ពាក្យទំនាយរបស់លោកស៊ីម៉ូន

[33]មាតាបិតារបស់ព្រះយេស៊ូ ងឿងឆ្ងល់នឹងសេចក្ដីដែល
លោកតាស៊ីម៉ូនមានប្រសាសន៍អំពីព្រះឱរសណាស់។[34]លោក
តាស៊ីម៉ូនជូនពរអ្នកទាំងពីរ ហើយនិយាយទៅកាន់នាងម៉ារីជា
មាតាថា៖ «ព្រះជាម្ចាស់បានចាត់បុត្រនេះមក ដើម្បីឲ្យជនជាតិ
អ៊ីស្រាអែលច្រើននាក់ដួល ឬងើបឡើងវិញ។ បុត្រនេះជាទីសម្គាល់
មួយ បង្ហាញអំពីការសង្គ្រោះរបស់ព្រះជាម្ចាស់ តែមានមនុស្សជា
ច្រើននឹងជំទាស់ប្រឆាំង។ [35]បុត្រនេះធ្វើឲ្យគំនិតលាក់កំបាំងរបស់
មនុស្សជាច្រើន លេចច្បាស់ឡើង រីឯនាងវិញ នាងនឹងឈឺចុក

ចាប់យ៉ាងខ្លាំង ដូចមានដាវមួយមកចាក់ទម្លុះដួងចិត្ត[ឪ] របស់នាង»។

## ពាក្យទំនាយរបស់យាយហាណ្ណា

៣៦មានព្យាការិនីម្នាក់ឈ្មោះ ហាណ្ណា ជាកូនរបស់លោក
ផានូអែល ក្នុងកុលសម្ព័ន្ធ *អេស៊ើរ។ គាត់រៀបការបានប្រាំពីរឆ្នាំ
ប្ដីគាត់ក៏ទទួលមរណភាពចោលទៅ ៣៧គាត់នៅមេម៉ាយរហូត
ឥឡូវនេះ គាត់មានវ័យចាស់ណាស់ទៅហើយ អាយុប៉ែតសិប
បួនឆ្នាំ។ គាត់មិនទៅណាឆ្ងាយពីព្រះវិហារ *ទេ គាត់នៅគោរព
បម្រើព្រះអង្គទាំងយប់ទាំងថ្ងៃ ដោយតមអាហារ និងអធិដ្ឋាន *ផង។
៣៨ពេលនោះ លោកយាយហាណ្ណាក៏នៅទីនោះដែរ គាត់សរសើរ
តម្កើងព្រះជាម្ចាស់ រួចតំណាលអំពីព្រះឱរសនោះប្រាប់អស់អ្នក
ដែលទន្ទឹងរង់ចាំព្រះជាម្ចាស់ យាងមកលោះក្រុងយេរូសាឡឹម។

## ព្រះឱរសត្រឡប់នៅភូមិណាសារ៉ែតវិញ

៣៩កាលមាតាបិតារបស់ព្រះយេស៊ូ បានបំពេញកិច្ចការទាំង
អស់ ស្របតាមធម្មវិន័យ *របស់ព្រះអម្ចាស់សព្វគ្រប់ហើយ គាត់
ក៏នាំគ្នាវិលត្រឡប់ទៅណាសារ៉ែត ជាភូមិរបស់គាត់ក្នុងស្រុកកាលីឡេ
វិញ។ ៤០ព្រះកុមារមានវ័យចម្រើនឡើងជាលំដាប់ មានកម្លាំងកាន់
តែមាំមួនឡើង និងពោរពេញទៅដោយព្រះប្រាជ្ញាញាណ។ ព្រះ
ជាម្ចាស់គាប់ព្រះហឫទ័យនឹងព្រះកុមារនេះណាស់។

---

**ឪ**, ពាក្យដើម: «ចាក់ទម្លុះព្រលឹង» ឬ «ចាក់ទម្លុះជីវិត»។

## ព្រះកុមារយេស៊ូនៅក្នុងព្រះវិហារ

៤១ជារៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យចម្លង* មាតាបិតារបស់
ព្រះយេស៊ូ តែងតែធ្វើដំណើរទៅក្រុងយេរូសាឡឹម។ ៤២លុះដល់
ព្រះយេស៊ូមានព្រះជន្មាយុដប់ពីរព្រះវស្សា មាតាបិតាក៏នាំព្រះអង្គ
ឡើងទៅចូលរួមក្នុងពិធីបុណ្យ តាមទំនៀមទម្លាប់។ ៤៣លុះពិធី
បុណ្យបានចប់សព្វគ្រប់ហើយ អ្នកទាំងពីរនាំគ្នាវិលត្រឡប់ទៅ
ផ្ទះវិញ។ រីឯព្រះកុមារយេស៊ូ គង់នៅក្រុងយេរូសាឡឹមនៅឡើយ
តែមាតាបិតាពុំបានដឹងទេ។ ៤៤គាត់នឹកស្មានថា ព្រះកុមារគង់
នៅក្នុងចំណោមអស់អ្នកដែលរួមដំណើរជាមួយគ្នា។ ក្រោយពី
បានធ្វើដំណើរអស់រយៈពេលមួយថ្ងៃ ទើបគាត់នាំគ្នាដើររកព្រះ
កុមារ ក្នុងចំណោមញាតិមិត្តទាំងអស់ ៤៥ប៉ុន្តែរកពុំឃើញសោះ
គាត់ក៏នាំគ្នាត្រឡប់ទៅក្រុងយេរូសាឡឹមវិញ ដើម្បីរកព្រះអង្គ
នៅទីនោះទៀត។ ៤៦បីថ្ងៃក្រោយមក មាតាបិតាឃើញព្រះយេស៊ូ
ក្នុងព្រះវិហារ* ព្រះអង្គគង់នៅកណ្ដាលចំណោមគ្រូអាចារ្យ*កំពុង
តែស្ដាប់គេនិយាយ ព្រមទាំងសួរសំណួរផ្សេងៗដល់គេផង។ ៤៧អស់
អ្នកដែលស្ដាប់ព្រះកុមារ នឹកឆ្ងល់ពីព្រះបន្ទូលឆ្លើយឆ្លងរបស់ព្រះ
អង្គ ប្រកបដោយព្រះប្រាជ្ញាញាណ។ ៤៨កាលមាតាបិតាបានឃើញ
ព្រះកុមារ ហើយគាត់នឹកឆ្ងល់យ៉ាងខ្លាំង។ មាតាសួរថា៖ «កូន
អើយ! ហេតុអ្វីបានជាកូនធ្វើដូច្នេះ? ឪពុកម្ដាយព្រួយចិត្តណាស់
ខំដើររកកូន»។ ៤៩ព្រះកុមារមានព្រះបន្ទូលតបថា៖ «ហេតុអ្វីបាន
ជាលោកឪពុកអ្នកម្ដាយរកកូនយ៉ាងហ្នឹង? តើលោកឪពុកអ្នក
ម្ដាយមិនជ្រាបថា កូនត្រូវនៅក្នុងដំណាក់ព្រះបិតារបស់កូនទេ
ឬ?»។ ៥០ប៉ុន្តែ មាតាបិតាពុំបានយល់អត្ថន័យនៃព្រះបន្ទូលរបស់
ព្រះកុមារឡើយ។

៥១បន្ទាប់មក ព្រះកុមារយេស៊ូ យាងត្រឡប់ទៅភូមិណាសារ៉ែត

ជាមួយមាតាបិតាវិញ ហើយធ្វើតាមឱវាទរបស់គាត់ទាំងពីរនាក់។
មាតារបស់ព្រះអង្គ ចងចាំហេតុការណ៍ទាំងអស់នោះ ទុកក្នុង
ចិត្ត។ [៥២]ព្រះយេស៊ូមានវ័យចម្រើនឡើង ហើយមានប្រាជ្ញាកាន់
តែវាងវៃ ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងជាទីគាប់ចិត្ត
មនុស្សផងទាំងពួង។

## លោកយ៉ូហានបាទីស្ដប្រៀនប្រដៅបណ្ដាជន

(ម៉ាថាយ ៣, ១-១២ ម៉ាកុស ១,១-៨ យ៉ូហាន ១,១៩-២៨)

៣ [១]នៅឆ្នាំទីដប់ប្រាំ នៃរជ្ជកាលព្រះចៅអធិរាជរ៉ូម៉ាំង
ព្រះនាមទីប៊ែរ លោកប៉ុនពីឡាតធ្វើជាទេសាភិបាល
នៅស្រុកយូដា ព្រះបាទហេរ៉ូដជាស្ដេចអនុរាជ * គ្រប់គ្រងស្រុក
កាលីឡេ ព្រះបាទភីលីពអនុជរបស់ព្រះបាទហេរ៉ូដ ជាស្ដេចអនុរាជ
គ្រប់គ្រងតំបន់អីុទូរេ និងតំបន់ត្រាខូនីត ព្រះបាទលីសាញ៉ាស
ជាស្ដេចអនុរាជគ្រប់គ្រងស្រុកអាប៊ីឡែន [២]លោកហាណ្ណា និង
លោកកៃផាសធ្វើជាមហាបូជាចារ្យ *។ ពេលនោះ ព្រះជាម្ចាស់
មានព្រះបន្ទូលមកកាន់លោកយ៉ូហាន ជាកូនរបស់លោកសាការី
នៅក្នុងវាលរហោស្ថាន *។ [៣]លោកយ៉ូហានធ្វើដំណើរគ្រប់ទីកន្លែង
ក្នុងតំបន់ទន្លេយ័រដាន់ ហើយប្រកាសឲ្យមនុស្សប្រែចិត្តគំនិត
ដោយទទួលពិធីជ្រមុជទឹក * ដើម្បីព្រះជាម្ចាស់លើកលែងទោស
ឲ្យរួចពីបាប។ [៤]លោកប្រកាសដូច្នេះស្របតាមសេចក្ដីដែលមាន
ចែងទុកក្នុងគម្ពីរព្យាការីអេសាយ[ឈ]ថា៖

*«មានសំឡេងបុរសម្នាក់ស្រែកឡើង*
*នៅវាលរហោស្ថានថា:*
*ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់*

ឈ,អសោយ ៤០,៣៥។

*ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ។*
៥ *ត្រូវបំពេញច្រកភ្នំទាំងអស់ឲ្យរាបស្មើ*
*និង ពង្រាបភ្នំតូចធំទាំងប៉ុន្មានឲ្យរាប*
*ត្រូវតម្រង់ផ្លូវកោងឲ្យត្រង់*
*ព្រមទាំងលុបផ្លូវរដិបរដុបឲ្យរាបស្មើដែរ*
៦ *នោះមនុស្សទាំងអស់នឹងឃើញការសង្គ្រោះ*
*របស់ព្រះជាម្ចាស់»។*

៧លោកយ៉ូហានតែងតែបន្ទោសមហាជន ដែលមកទទួល
ពិធីជ្រមុជទឹក *ពីលោកថា៖ «នែ៎ ពូជពស់វែកអើយ! តើនរណា
ប្រាប់ឲ្យអ្នករាល់គ្នា រត់គេចពីព្រះពិរោធរបស់ព្រះជាម្ចាស់[ណ] ដែល
ជិតមកដល់ដូច្នេះ?។ ៨ចូរប្រព្រឹត្តអំពើល្អ ដើម្បីបញ្ជាក់ថា អ្នក
រាល់គ្នា បានប្រែចិត្តគំនិតមែន។ កុំអាងខ្លួនថា មានលោកអប្រាហាំ
ជាបុព្វបុរស *នោះឡើយ ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់
ក៏អាចធ្វើឲ្យថ្មទាំងនេះ ទៅជាកូនចៅលោកអប្រាហាំបានដែរ។
៩ពូថៅនៅជិតគល់ឈើជាស្រេចហើយ ដើមឈើណាមិនផ្ដល់
ផ្លែល្អទេ ត្រូវកាប់រំលំបោះទៅក្នុងភ្លើង»។ ១០មហាជនសួរលោក
យ៉ូហានថា៖ «បើដូច្នេះ តើយើងត្រូវធ្វើអ្វីខ្លះ?»។ ១១លោកយ៉ូហាន
តបទៅពួកគេវិញថា៖ «អ្នកណាមានអាវពីរ ត្រូវចែកឲ្យអ្នកដែល
គ្មាន ហើយអ្នកដែលមានចំណីអាហារ ក៏ត្រូវចែកឲ្យអ្នកគ្មានដែរ»។
១២មានអ្នកទារពន្ធ *ខ្លះមកទទួលពិធីជ្រមុជទឹក *ហើយសួរលោក
ថា៖ «លោកគ្រូអើយ! តើយើងខ្ញុំត្រូវធ្វើអ្វីខ្លះ?»។ ១៣លោកឆ្លើយ
វិញថា៖ «កុំទារពន្ធហួសពីកម្រិត ដែលមានកំណត់ទុកនោះឡើយ»។
១៤មានទាហានមកសួរលោកថា៖ «ចុះយើងខ្ញុំវិញ តើត្រូវធ្វើអ្វីដែរ?»។
លោកឆ្លើយថា៖ «កុំចោទប្រកាន់ កុំសង្កត់សង្កិនយកប្រាក់ពីអ្នក
ណាឲ្យសោះ ត្រូវស្កប់ចិត្តតែនឹងប្រាក់ខែរបស់អ្នករាល់គ្នាប៉ុណ្ណោះ

---

**ណ**, ឬ ព្រះជាម្ចាស់វិនិច្ឆ័យទោស។

បានហើយ»។
១៥ប្រជាជននៅតែរង់ចាំ ហើយគេរិះគិតក្នុងចិត្តគ្រប់ៗគ្នាថា
ប្រហែលលោកនេះទេដឹងជាព្រះគ្រីស្ដ * !។ ១៦លោកយ៉ូហានមាន
ប្រសាសន៍ប្រាប់គេទាំងអស់គ្នាថា៖ «ខ្ញុំធ្វើពិធីជ្រមុជ *ឲ្យអ្នករាល់
គ្នាក្នុងទឹក ប៉ុន្តែ លោកដែលមានកម្លាំងខ្លាំងជាងខ្ញុំជិតមកដល់
ហើយ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែស្រាយខ្សែស្បែកជើង
ជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង លោក
នឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នា ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយ
ភ្លើងវិញ។ ១៧លោកកាន់ចង្អេរ លោកសម្អាតលានបោកស្រូវ
ដើម្បីអុំស្រូវយកគ្រាប់ល្អប្រមូលដាក់ជង្រុក រីឯសំដី[ឥ]វិញ លោក
នឹងដុតក្នុងភ្លើង ដែលឆេះពុំចេះរលត់ឡើយ»។ ១៨លោកយ៉ូហាន
ប្រកាសដំណឹងល្អ *ដល់ប្រជាជន ដោយពាក្យដាស់តឿនជាច្រើន
ទៀតផង។ ១៩លោកស្ដីបន្ទោសព្រះបាទហេរ៉ូដ ជាស្ដេចអនុរាជ
ថែមទៀត ព្រោះទ្រង់បានយកព្រះនាងហេរ៉ូឌីយ៉ាដា ដែលត្រូវជា
មហេសីរបស់អនុជ *ព្រះអង្គ មកធ្វើជាមហេសីរបស់ព្រះអង្គផ្ទាល់។
មិនតែប៉ុណ្ណោះសោត លោកយ៉ូហានស្ដីបន្ទោសព្រះបាទហេរ៉ូដ
ព្រោះទ្រង់បានធ្វើអំពើអាក្រក់ជាច្រើនផង។ ២០ទ្រង់បានធ្វើអំពើ
អាក្រក់មួយទៀត គឺចាប់លោកយ៉ូហានទៅដាក់ក្នុងមន្ទីរឃុំឃាំង។

## ព្រះយេស៊ូទទួលពិធីជ្រមុជទឹក

(មថ, ៣, ១៣-១៧ មក, ១, ៩-១១ យហ, ១, ៣២-៣៤)

២១ពេលប្រជាជនទាំងអស់ទទួលពិធីជ្រមុជទឹក រួចហើយ
ព្រះយេស៊ូក៏ទទួលពិធីជ្រមុជទឹកដែរ។ នៅពេលព្រះអង្គកំពុង
អធិដ្ឋាន * ស្រាប់តែផ្ទៃមេឃបើកចំហ ២២ហើយព្រះវិញ្ញាណដ៏វិសុទ្ធ *

ឥ, សំដី ឬ សណ្ដី: គ្រាប់ដំណាំតូចៗដែលស្កក។

យាងចុះមក មានរូបរាងដូចសត្វព្រាប សណ្ឋិតលើព្រះអង្គ។ មានព្រះសូរសៀងពីលើមេឃមកថា៖ «ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់»[៨]។

## បញ្ជីរាយនាមព្រះអយ្យកោរបស់ព្រះយេស៊ូ

(ម៉ាថាយ ១, ១-១៧)

២៣កាលព្រះយេស៊ូចាប់ផ្ដើមព្រះបរមកិច្ច ព្រះអង្គមានព្រះ
ជន្មាយុប្រមាណសាមសិបព្រះវស្សា។ តាមគេស្មានព្រះអង្គជា
បុត្ររបស់លោកយ៉ូសែប ដែលត្រូវជាបុត្រលោកអេលី ២៤លោក
អេលីជាបុត្រលោកម៉ាថាត់ លោកម៉ាថាត់ជាបុត្រលោកលេវី លោក
លេវីជាបុត្រលោកម៉ែលឃី លោកម៉ែលឃីជាបុត្រលោកយ៉ាណាយ
លោកយ៉ាណាយជាបុត្រលោកយ៉ូសែប ២៥លោកយ៉ូសែបជាបុត្រ
លោកម៉ាថាធី លោកម៉ាថាធីជាបុត្រលោកអម៉ូស លោកអម៉ូស
ជាបុត្រលោកណាអ៊ូម លោកណាអ៊ូមជាបុត្រលោកហែសលី
លោកហែសលីជាបុត្រលោកណាកាយ ២៦លោកណាកាយជា
បុត្រលោកម៉ាអាត លោកម៉ាអាតជាបុត្រលោកម៉ាថាធី លោក
ម៉ាថាធីជាបុត្រលោកសេមែន លោកសេមែនជាបុត្រលោកយ៉ូសិច
លោកយ៉ូសិចជាបុត្រលោកយ៉ូដា ២៧លោកយ៉ូដាជាបុត្រលោក
យ៉ូណាន់ លោកយ៉ូណាន់ជាបុត្រលោករេសា លោករេសាជាបុត្រ
លោកសូរ៉ូបាបែល លោកសូរ៉ូបាបែលជាបុត្រលោកសាឡាធីអែល
លោកសាឡាធីអែលជាបុត្រលោកនេរី ២៨លោកនេរីជាបុត្រលោក
ម៉ែលឃី លោកម៉ែលឃីជាបុត្រលោកអាត់ឌី លោកអាត់ឌីជា
បុត្រកូសាម លោកកូសាមជាបុត្រលោកអែលម៉ាដាម លោក
អែលម៉ាដាមជាបុត្រលោកអ៊ែរ ២៩លោកអ៊ែរជាបុត្រលោកយេស៊ូ

---

៨, មានឯកសារខ្លះសរសេរថា «ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង គឺយើងនេះហើយដែលបានបង្កើតព្រះអង្គនៅថ្ងៃនេះ» (ទំនុកតម្កើង ២,៧)។

លោកយេស៊ូជាបុត្រលោកអេលីអេស៊ើរ លោកអេលីអេស៊ើរជាបុត្រ
លោកយ៉ូរីម លោកយ៉ូរីមជាបុត្រលោកម៉ាថាត់ លោកម៉ាថាត់ជា
បុត្រលោកលេវី ៣០លោកលេវីជាបុត្រលោកស៊ីម៉ូន លោកស៊ីម៉ូន
ជាបុត្រលោកយូដា លោកយូដាជាបុត្រលោកយ៉ូសែប លោក
យ៉ូសែបជាបុត្រលោកយ៉ូណាម លោកយ៉ូណាមជាបុត្រលោក
អេលីយ៉ាគីម ៣១លោកអេលីយ៉ាគីមជាបុត្រលោកម៉េលា លោក
ម៉េលាជាបុត្រលោកមេណា លោកមេណាជាបុត្រលោកម៉ាតាថា
លោកម៉ាតាថាជាបុត្រលោកណាថាន់ លោកណាថាន់ជាបុត្រ
ស្ដេចដាវីឌ ៣២ស្ដេចដាវីឌជាបុត្រលោកយេសាយ លោកយេសាយ
ជាបុត្រលោកយ៉ូបេដ លោកយ៉ូបេដជាបុត្រលោកបូអូស លោក
បូអូសជាបុត្រលោកសាឡា លោកសាឡាជាបុត្រលោកណាសូន
៣៣លោកណាសូនជាបុត្រលោកអមីណាដាប លោកអមីណាដាប
ជាបុត្រលោកអាដមីន លោកអាដមីនជាបុត្រលោកអ៊័រនី លោក
អ៊័រនីជាបុត្រលោកអែសរ៉ូម លោកអែសរ៉ូមជាបុត្រលោកផារ៉េស
លោកផារ៉េសជាបុត្រលោកយូដា ៣៤លោកយូដាជាបុត្រលោក
យ៉ាកុប លោកយ៉ាកុបជាបុត្រលោកអ៊ីសាក លោកអ៊ីសាកជាបុត្រ
លោកអប្រាហាំ លោកអប្រាហាំជាបុត្រលោកតេរ៉ា លោកតេរ៉ា
ជាបុត្រលោកណាហ៊ោរ ៣៥លោកណាហ៊ោរជាបុត្រលោកសេរូក លោក
សេរូកជាបុត្រលោករ៉ាកៅ លោករ៉ាកៅជាបុត្រលោកពេឡេក លោក
ពេឡេកជាបុត្រលោកហេប៊ើរ លោកហេប៊ើរជាបុត្រលោកសេឡា
៣៦ លោកសាឡាជាបុត្រលោកកៃណាម លោកកៃណាមជាបុត្រ
លោកអារប៉ាកសាដ លោកអារប៉ាកសាដជាបុត្រលោកសិម លោក
សិមជាបុត្រលោកណូអេ លោកណូអេជាបុត្រលោកឡាម៉េក
៣៧លោកឡាម៉េកជាបុត្រលោកម៉ាធូសាឡា លោកម៉ាធូសាឡា
ជាបុត្រលោកហេណុក លោកហេណុកជាបុត្រលោកយ៉ារ៉េដ

លោកយ៉ារ៉េដជាបុត្រលោកម៉ាឡេឡេល លោកម៉ាឡេឡេលជា
បុត្រលោកកៃណាម ៣៨លោកកៃណាមជាបុត្រលោកអេណុស
លោកអេណុសជាបុត្រលោកសេថ លោកសេថជាបុត្រលោក
អដាំ ហើយលោកអដាំជាបុត្រព្រះជាម្ចាស់។

## ព្រះយេស៊ូឈ្នះការល្បួង

(ម៉ាថាយ ៤, ១-១១ ម៉ាកុស ១, ១២-១៣)

៤ ១ព្រះយេស៊ូបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ *
ព្រះអង្គយាងត្រឡប់ពីទន្លេយ័រដាន់មកវិញ ហើយ
ព្រះវិញ្ញាណនាំព្រះអង្គទៅវាលរហោស្ថាន។ ២នៅទីនោះព្រះអង្គ
ត្រូវមារ *សាតាំងល្បួងអស់រយៈពេលសែសិបថ្ងៃ។ ក្នុងអំឡុង
ពេលនោះ ព្រះអង្គពុំសោយអ្វីឡើយ។ លុះផុតពីពេលនោះទៅ
ទើបទ្រង់ឃ្លាន។ ៣មារ *ទូលព្រះអង្គថា៖ «ប្រសិនបើលោកពិត
ជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន សូមធ្វើឲ្យដុំថ្មនេះទៅជានំបុ័ង
មើល៍»។ ៤ព្រះយេស៊ូមានព្រះបន្ទូលតបទៅវិញថា៖ «ក្នុងគម្ពីរមាន
ចែងថា *មនុស្សមិនមែនរស់ដោយសារតែអាហារ*[ឆ] *ប៉ុណ្ណោះ
ទេ*[ជ]»។

៥មារនាំព្រះអង្គទៅកន្លែងមួយដ៏ខ្ពស់ ហើយចង្អុលបង្ហាញ
នគរទាំងប៉ុន្មាននៅលើផែនដី ឲ្យព្រះអង្គឃើញក្នុងមួយរយៈពេល
ដ៏ខ្លី។ ៦មារសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់អំណាច ព្រម
ទាំងភោគទ្រព្យរបស់នគរទាំងនោះឲ្យលោក ដ្បិតអ្វីៗទាំងអស់
ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់ឲ្យអ្នកណាក៏បានស្រេចតែនឹង
ចិត្តខ្ញុំ។ ៧ដូច្នេះប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ សម្បត្តិទាំង
នោះ នឹងបានជារបស់លោកហើយ»។ ៨ព្រះយេស៊ូមានព្រះបន្ទូល

---

**ឆ**, ពាក្យដើម«នំបុ័ង»។ • **ជ**,ទុតិយកថា៨,៣។

តបទៅវិញថា៖ «ក្នុងគម្ពីរមានចែងថា *"អ្នកត្រូវតែថ្វាយបង្គំព្រះអម្ចាស់ **
*ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គមួយប៉ុណ្ណោះ"*[ន]»។
៩បន្ទាប់មក មារនាំព្រះអង្គទៅក្រុងយេរូសាឡឹមដាក់ព្រះអង្គ
លើកំពូលព្រះវិហារ* ហើយទូលថា៖ «ប្រសិនបើលោកពិតជា
ព្រះបុត្រារបស់ព្រះជាម្ចាស់មែន សូមលោតទម្លាក់ខ្លួនចុះទៅ
ក្រោមមើល៍ ១០ដ្បិតក្នុងគម្ពីរមានចែងថា *"ព្រះជាម្ចាស់នឹងបញ្ជា*
*ឲ្យទេវទូត*ថែរក្សាលោក* ១១*ហើយទេវទូតទាំងនោះ នឹងចាំទ្រ*
*លោក មិនឲ្យជើងលោកប៉ះទង្គិចនឹងថ្មឡើយ"*[ប]»។ ១២ព្រះយេស៊ូ
មានព្រះបន្ទូលតបទៅមារវិញថា៖ «ក្នុងគម្ពីរមានចែងថា *កុំល្បង*
*លព្រះអម្ចាស់ ជាព្រះរបស់អ្នកឡើយ*[ផ]»។ ១៣លុះមារល្បងព្រះ
យេស៊ូសព្វបែបយ៉ាង ហើយវាក៏ថយចេញឆ្ងាយពីព្រះអង្គទៅ
រហូតដល់ពេលកំណត់។

## ព្រះយេស៊ូចាប់ផ្ដើមផ្សាយដំណឹងល្អ នៅស្រុកកាលីឡេ អ្នកភូមិណាសារ៉ែត បដិសេធមិនព្រមទទួលព្រះអង្គ

(មថ,៤,១២-១៧; ១៣,៥៣-៥៨ មក,១,១៤-១៥; ៦,១-៦)

១៤ព្រះយេស៊ូយាងត្រឡប់ទៅស្រុកកាលីឡេវិញ ប្រកបដោយ
ឫទ្ធានុភាពរបស់ព្រះវិញ្ញាណ ព្រះនាមព្រះអង្គឮល្បីល្បាញពាស
ពេញតំបន់នោះ។ ១៥ព្រះអង្គបង្រៀនអ្នកស្រុកក្នុងធម្មសាលា*
គេសរសើរតម្កើងសិរីរុងរឿងព្រះអង្គគ្រប់ៗគ្នា។
១៦ព្រះយេស៊ូយាងទៅភូមិណាសារ៉ែត ជាភូមិដែលព្រះអង្គ
គង់នៅកាលពីកុមារ។ នៅថ្ងៃសប្ប័ទ* ព្រះអង្គយាងទៅធម្មសាលា*
តាមទម្លាប់របស់ព្រះអង្គ។ ព្រះអង្គក្រោកឈរឡើង ដើម្បីអាន

**ន**,ទុតិយកថា៦,១៣-១៤។ • **ប**,ទំនុកតម្កើង៩១,១១-១២។ • **ផ**, ទុតិយកថា ៦,១៦។

គម្ពីរ។ [១៧]គេបានយកគម្ពីររបស់ព្យាការី*អេសាយមកថ្វាយព្រះអង្គ
ព្រះអង្គបើកគម្ពីរត្រង់អត្ថបទមួយដែលមានចែងថា៖



[១៨] *«ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ។*
*ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំ*
*ឲ្យនាំដំណឹងល្អ*ទៅប្រាប់ជនក្រីក្រ។*
*ព្រះអង្គបានចាត់ខ្ញុំឲ្យមកប្រកាសប្រាប់*
*ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាព*
*ហើយប្រាប់មនុស្សខ្វាក់ថា*
*គេនឹងមើលឃើញវិញ។*
*ព្រះអង្គបានចាត់ខ្ញុំឲ្យមករំដោះ*
*អស់អ្នកដែលត្រូវគេសង្កត់សង្កិន*
[១៩] *ព្រមទាំងប្រកាសអំពីឆ្នាំដែលព្រះអម្ចាស់*
*សម្តែងព្រះហឫទ័យមេត្តាករុណា[៣]»។*
[២០]លុះអានចប់ហើយ ព្រះយេស៊ូបិទគម្ពីរ ប្រគល់ទៅអ្នកថែ
រក្សា រួចទ្រង់គង់ចុះវិញ។ មនុស្សគ្រប់ៗរូបនៅក្នុងធម្មសាលា
សម្លឹងមើលព្រះអង្គ។ [២១]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ហេតុ
ការណ៍ដែលមានចែងទុកក្នុងគម្ពីរ ដូចអ្នករាល់គ្នាទើបនឹងស្តាប់

៣, អេសាយ ៦១,១-២។

អំបាញមិញ បានសម្រេចជារូបរាងនៅថ្ងៃនេះហើយ»។ ២២ឮដូច្នេះ
គេសើចសរសើរព្រះយេស៊ូគ្រប់ៗគ្នា ទាំងនឹកឆ្ងល់អំពីព្រះបន្ទូល
ប្រកបដោយព្រះហឫទ័យប្រណីសន្ដោស ដែលហូរចេញពីព្រះ
ឱស្ឋរបស់ព្រះអង្គ។ គេពោលថា៖ «អ្នកនេះមិនមែនជាកូនរបស់
ជាងយ៉ូសែបទេឬ?»។ ២៣ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ប្រហែលជាអ្នករាល់គ្នា ចង់យកសុភាសិតដែលថែងថា "គ្រូពេទ្យ
អើយ ចូរមើលជំងឺរបស់ខ្លួនឲ្យជាសិនទៅ" មកផ្ចាញ់ផ្ចាលខ្ញុំទេ
ដឹង! ឬមួយអ្នករាល់គ្នា ចង់និយាយមកខ្ញុំទៀតថា "យើងឮគេ
និយាយអំពីកិច្ចការទាំងអស់ដែលអ្នកធ្វើនៅក្រុងកាផានុម ចូរធ្វើ
ការដដែលនៅទីនេះ ជាស្រុកកំណើតរបស់អ្នកឲ្យយើងឃើញផង!"»។
២៤ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នា
ដឹងច្បាស់ថា មិនដែលមានព្យាការី*ណាម្នាក់ត្រូវគេគោរពនៅ
ក្នុងស្រុកកំណើតរបស់ខ្លួនឡើយ។ ២៥ខ្ញុំសុំបញ្ជាក់ថា នៅជំនាន់
លោកអេលី មេឃរាំងអស់រយៈពេលបីឆ្នាំកន្លះ បណ្ដាលឲ្យមាន
ទុរ្ភិក្សយ៉ាងខ្លាំងពេញទាំងស្រុក។ នៅស្រុកអ៊ីស្រាអែលមានស្ត្រី
មេម៉ាយជាច្រើន។ ២៦ក៏ប៉ុន្តែ ព្រះជាម្ចាស់ពុំបានចាត់ព្យាការីអេលី
ឲ្យទៅជួយស្ត្រីមេម៉ាយណាម្នាក់ នៅស្រុកអ៊ីស្រាអែលឡើយ គឺ
ព្រះអង្គបានចាត់លោកឲ្យទៅជួយស្ត្រីមេម៉ាយម្នាក់ ដែលរស់នៅ
ភូមិសារិបតា ក្នុងក្រុងស៊ីដូនវិញ[ក]។ ២៧នៅជំនាន់ព្យាការីអេលីសេ
មានមនុស្សឃ្លង់ជាច្រើន ក្នុងស្រុកអ៊ីស្រាអែល ប៉ុន្តែគ្មានអ្នកណា
ម្នាក់បានជាសោះឡើយ គឺមានតែលោកណាម៉ាន់ជាជនជាតិស៊ីរី
ម្នាក់ប៉ុណ្ណោះ[ខ]»។

២៨កាលបានឮព្រះបន្ទូលទាំងនេះ អ្នកនៅក្នុងធម្មសាលា*
ទាំងប៉ុន្មាន ខឹងព្រះយេស៊ូគ្រប់ៗគ្នា។ ២៩គេក្រោកឡើងចាប់ប្រអូស
ប្រទាញព្រះយេស៊ូ ចេញពីភូមិដែលសង់លើកំពូលភ្នំនាំ ឆ្ពោះ

---
**ក**, ១ ពង្សាវតារក្សត្រ ១៧។ • **ខ**, ២ ពង្សាវតារក្សត្រ ៥។

ទៅមាត់ជ្រោះ បម្រុងនឹងច្រានព្រះអង្គទម្លាក់ទៅក្រោម។ ៣០ប៉ុន្តែ
ព្រះអង្គយាងចេញពីកណ្ដាលចំណោមគេបាត់ទៅ។

## ព្រះយេស៊ូដេញខ្មោចចេញពីមនុស្សម្នាក់

(ម៉ាកុស ១, ២១-២៨)

៣១ព្រះយេស៊ូយាងទៅក្រុងកាផានុម ក្នុងស្រុកកាលីឡេ។
នៅទីនោះ ព្រះអង្គបង្រៀនបណ្ដាជនជារៀងរាល់ថ្ងៃសប្ប័ទ *។
៣២មនុស្សគ្រប់គ្នាងឿងឆ្ងល់យ៉ាងខ្លាំង អំពីបែបបទដែលព្រះអង្គ
បង្រៀន ព្រោះព្រះអង្គមានព្រះបន្ទូលប្រកបដោយអំណាច។
៣៣នៅក្នុងធម្មសាលា * មានបុរសម្នាក់ដែលខ្មោចចូល ស្រែក
ឡើងខ្លាំងៗថា៖ ៣៤«ព្រះយេស៊ូជាអ្នកភូមិណាសារ៉ែតអើយ! តើ
ព្រះអង្គចង់ធ្វើអ្វីយើង? ព្រះអង្គមកបំផ្លាញយើង! ខ្ញុំស្គាល់ព្រះអង្គ
ហើយ ព្រះអង្គជាព្រះដ៏វិសុទ្ធ *ដែលមកពីព្រះជាម្ចាស់»។ ៣៥ព្រះយេស៊ូ
គំរាមខ្មោចនោះថា៖ «ស្ងៀម ចេញពីអ្នកនេះទៅ!»។ ខ្មោចក៏ផ្ដួល



បុរសនោះ នៅកណ្ដាលចំណោមបណ្ដាជន រួចចេញទៅដោយ
ពុំមានធ្វើឲ្យគាត់ឈឺចាប់អ្វីឡើយ។ ៣៦មនុស្សម្នាក៏ភ័យស្រឡាំង
កាំង ហើយនិយាយគ្នាទៅវិញទៅមកថា៖ «ចុះពាក្យសម្ដីរបស់
លោកនេះ អីក៏ពូកែម្លេះ មើលលោកមានអំណាច និងឫទ្ធានុភាព
អាចបញ្ជាទៅខ្មោចឲ្យវាចេញ ហើយវាធ្វើតាម»។ ៣៧បន្ទាប់មក

ព្រះកិត្តិនាមរបស់ព្រះយេស៊ូ ល្បីខ្ចរខ្ចាយពាសពេញតំបន់នោះ។

## ព្រះយេស៊ូប្រោសអ្នកជំងឺជាច្រើនឲ្យបានជា

(ម៉ាថាយ ៨, ១៤-១៧ ម៉ាកុស ១, ២៩-៣៤)

៣៨ព្រះយេស៊ូយាងចេញពីធម្មសាលា* ទៅផ្ទះលោកស៊ីម៉ូន
ពេលនោះម្ដាយក្មេករបស់លោកស៊ីម៉ូនគ្រុនយ៉ាងខ្លាំង គេទូល
សូមព្រះអង្គមេត្តាប្រោសគាត់ឲ្យបានជា។ ៣៩ព្រះយេស៊ូឱនទៅ
លើអ្នកជំងឺ ព្រះអង្គគំរាមជំងឺគ្រុន ជំងឺគ្រុនក៏ចេញបាត់ទៅ ហើយ
ម្ដាយក្មេករបស់លោកស៊ីម៉ូនក៏បានជា។ រំពេចនោះ គាត់ក្រោក
ឡើងបម្រើភ្ញៀវ។

៤០នៅពេលថ្ងៃលិច អ្នកស្រុកទាំងអស់នាំបងប្អូន ដែលមាន
ជំងឺផ្សេងៗមករកព្រះយេស៊ូ។ ព្រះអង្គដាក់ព្រះហស្ដលើអ្នកទាំង
នោះ ហើយប្រោសគេឲ្យបានជាសះស្បើយគ្រប់ៗគ្នា។ ៤១មាន
ខ្មោចចេញពីមនុស្សជាច្រើនទាំងស្រែកថា៖ «ព្រះអង្គជាព្រះបុត្រា
របស់ព្រះជាម្ចាស់»។ ប៉ុន្តែ ព្រះយេស៊ូគំរាមខ្មោចទាំងនោះ មិនឲ្យ
និយាយជាដាច់ខាត ព្រោះពួកវាដឹងថាព្រះអង្គជាព្រះគ្រិស្ដ*។

៤២លុះព្រលឹមឡើង ព្រះយេស៊ូយាងចេញពីក្រុងទៅកន្លែង
ស្ងាត់។ បណ្ដាជននាំគ្នាដើររកព្រះអង្គ។ លុះជួបហើយគេឃាត់
ព្រះអង្គឲ្យនៅជាមួយ មិនចង់ឲ្យយាងចាកចោលគេឡើយ។ ៤៣ប៉ុន្តែ
ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំត្រូវនាំដំណឹងល្អ*អំពី
ព្រះរាជ្យ*របស់ព្រះជាម្ចាស់ ទៅក្រុងឯទៀតៗដែរ ដ្បិតព្រះអង្គ
បានចាត់ខ្ញុំឲ្យមកបំពេញការនេះឯង»។

៤៤បន្ទាប់មក ព្រះយេស៊ូប្រកាសដំណឹងល្អ*តាមធម្មសាលា*
នានាក្នុងស្រុកកាលីឡេ។

## ព្រះយេស៊ូត្រាស់ហៅសាវ័កបីរូប

(ម៉ាថាយ ៤, ១៨-២២ ម៉ាកុស ១, ១៦-២០)

៥ ១ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងកេនេសារ៉ែតមាន
បណ្ដាជនជាច្រើន ប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ដើម្បី
ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ២ព្រះអង្គទតឃើញទូកពីរ
ចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួនរបស់គេ។
៣ព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចទ្រង់សុំឲ្យ
គាត់ចេញទូកទៅឆ្ងាយពីច្រាំងបន្តិច។ ព្រះអង្គគង់បង្រៀនបណ្ដា
ជនពីក្នុងទូកនោះ។

៤លុះព្រះអង្គបង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូលទៅ
កាន់លោកស៊ីម៉ូនថា៖ «ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់
អួនចុះ»។ ៥លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ!
យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែ
បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់
លោកគ្រូ»។ ៦គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរ
តែធ្លាយអួន។ ៧គេបក់ដៃហៅមិត្តភក្ដិដែលនៅក្នុងទូកមួយទៀត
ឲ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំង
ពីរស្ទើរតែនឹងលិច។ ៨ពេលលោកសិលាឃើញដូច្នោះ គាត់ក្រាប
ទៀបព្រះបាទាព្រះយេស៊ូ ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ
សូមយាងឲ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប»។
៩លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់ និងអស់អ្នកដែលនៅ
ជាមួយភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាង
នេះ។ ១០រីឯលោកយ៉ាកុប និងលោកយ៉ូហាន ជាកូនលោកសេបេដេ
ដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះដែរ។ ប៉ុន្តែ
ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី! ពីពេល

នេះទៅមុខអ្នកនឹងនេសាទមនុស្សវិញ»។ [១១]ពេលទូកទៅដល់
មាត់ច្រាំងវិញ គេបោះបង់របស់របរទាំងអស់ចោល រួចនាំគ្នាដើរ
តាមព្រះយេស៊ូទៅ។

## ព្រះយេស៊ូប្រោសមនុស្សឃ្លង់ម្នាក់ឲ្យបានជា

(ម៉ាថាយ ៨, ១-៤ ម៉ាកុស ១, ៤០-៤៥)

[១២]ព្រះយេស៊ូគង់នៅក្នុងក្រុងមួយ មានមនុស្សឃ្លង់ម្នាក់ឃើញ
ព្រះអង្គ គាត់ចូលមករក ហើយក្រាបថ្វាយបង្គំ ឱនមុខដល់ដីទូល
ព្រះអង្គថា៖ «លោកម្ចាស់ ប្រសិនបើលោកមិនយល់ទាស់ទេ សូម
ប្រោសខ្ញុំប្របាទ ឲ្យបានជាស្អាតបរិសុទ្ធ *ផង»។ [១៣]ព្រះយេស៊ូ
លូកព្រះហស្ដទៅពាល់គាត់ ទាំងមានព្រះបន្ទូលថា៖ «ខ្ញុំយល់
ព្រមហើយ ចូរឲ្យបានជាស្អាតបរិសុទ្ធចុះ»។ រំពេចនោះ មនុស្ស
ឃ្លង់ក៏បានជាស្អាតបរិសុទ្ធភ្លាម។

[១៤]ព្រះយេស៊ូ មានព្រះបន្ទូលហាមគាត់ថា៖ «កុំនិយាយប្រាប់
នរណាឲ្យដឹងឡើយ ផ្ទុយទៅវិញ ត្រូវទៅបង្ហាញខ្លួនដល់លោក
បូជាចារ្យ * ហើយថ្វាយតង្វាយ ដូចលោកម៉ូសេ *បានបង្គាប់ទុក
ដើម្បីជាសក្ខីភាពបញ្ជាក់ថា អ្នកបានជាស្អាតបរិសុទ្ធមែន[យ]»។

[១៥]ព្រះកិត្តិនាមរបស់ព្រះយេស៊ូ ល្បីសុសសាយកាន់តែខ្លាំង
ឡើងៗ។ មហាជនជាច្រើន មកជុំគ្នាស្ដាប់ព្រះអង្គ ព្រមទាំងសូម
ព្រះអង្គប្រោសឲ្យខ្លួនបានជាពីជំងឺផ្សេងៗផង។ [១៦]រីឯព្រះយេស៊ូ
វិញ ព្រះអង្គយាងទៅទីស្ងាត់ ដើម្បីអធិដ្ឋាន *។

---

**យ**, សូមអាន លេវីវិន័យ ១៤,១-៣២។

## ព្រះយេស៊ូប្រោសមនុស្សខ្វិនម្នាក់ឲ្យបានជា

(ម៉ាថាយ ៩, ១-៨ ម៉ាកុស ២, ១-១២)

១៧ថ្ងៃមួយ ព្រះយេស៊ូកំពុងតែបង្រៀនបណ្ដាជន មានពួកខាង
គណៈផារីស៊ី* និងពួកធម្មាចារ្យ *អង្គុយស្ដាប់ព្រះអង្គដែរ។ អ្នកទាំង
នោះ ធ្វើដំណើរមកពីភូមិនានា ក្នុងស្រុកកាលីឡេ ស្រុក យូដា និង
ពីក្រុងយេរូសាឡឹម។ ព្រះយេស៊ូប្រកបដោយឫទ្ធានុភាព របស់
ព្រះអម្ចាស់ ទ្រង់ប្រោសអ្នកជំងឺឲ្យបានជា។ ១៨ពេលនោះ ស្រាប់
តែមានគេសែងមនុស្សខ្វិនដៃ ខ្វិនជើងម្នាក់មកដល់ គេមាន បំណង
នាំអ្នកខ្វិននោះចូលទៅជិតព្រះយេស៊ូ។ ១៩ប៉ុន្តែ ដោយមាន មនុស្ស
ច្រើនពេក គេពុំអាចចូលទៅជិតព្រះអង្គបានឡើយ។ ដូច្នេះ គេក៏
សែងអ្នកជំងឺឡើងទៅលើដំបូលផ្ទះ បកក្បឿងសម្រូតគាត់ចុះ



មកកណ្ដាលចំណោមមនុស្ស នៅចំពីមុខព្រះយេស៊ូ។ ២០ពេល
ព្រះយេស៊ូឈ្វេងយល់ជំនឿរបស់អ្នកទាំងនោះ ទ្រង់មានព្រះបន្ទូល
ទៅកាន់អ្នកពិការថា៖ «អ្នកអើយ ខ្ញុំអត់ទោសឲ្យអ្នករួចពីបាប
ហើយ!»។ ២១ពួកធម្មាចារ្យ និងពួកខាងគណៈផារីស៊ី ឮដូច្នោះ
រិះគិតក្នុងចិត្តថា៖ «អ្នកនេះមានឋានៈអ្វី បានជាហ៊ានពោលពាក្យ

ប្រមាថព្រះជាម្ចាស់ដូច្នេះ? ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ តើ
អ្នកណាអាចអត់ទោសឲ្យមនុស្សរួចពីបាបបាន?»។ ២២ព្រះយេស៊ូ
ឈ្វេងយល់ចិត្តគំនិតអ្នកទាំងនោះ ទើបទ្រង់មានព្រះបន្ទូលទៅ
គេថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នារិះគិតដូច្នេះ? ២៣បើខ្ញុំប្រាប់
អ្នកពិការនេះថា "ខ្ញុំអត់ទោសឲ្យអ្នករួចពីបាបហើយ" ឬថា "ចូរ
ក្រោកឡើងដើរទៅចុះ" តើឃ្លាមួយណាស្រួលនិយាយជាង?។
២៤ប៉ុន្តែ ខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា បុត្រមនុស្ស *មានអំណាចនឹង
អត់ទោសឲ្យមនុស្សនៅក្នុងលោកនេះរួចពីបាបបាន -ព្រះអង្គក៏
ងាកទៅរកអ្នកខ្វិន ហើយមានព្រះបន្ទូលថា -ចូរក្រោកឡើងយក
គ្រែស្នែងរបស់អ្នកដើរទៅផ្ទះវិញទៅ»។ ២៥រំពេចនោះ អ្នកខ្វិន
ក្រោកឡើងនៅមុខមនុស្សទាំងអស់ រួចយកគ្រែស្នែងដែលគេ
សែងខ្លួនមក ដើរត្រឡប់ទៅផ្ទះវិញ ទាំងលើកតម្កើងសិរីរុងរឿង
របស់ព្រះជាម្ចាស់ផង។ ២៦អស់អ្នកដែលនៅទីនោះស្ពុតស្មារតី
គ្រប់ៗគ្នា ហើយលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ គេ
ភ័យខ្លាចជាខ្លាំង ក៏និយាយគ្នាថា៖ «ថ្ងៃនេះយើងបានឃើញហេតុ
ការណ៍ចម្លែកអស្ចារ្យមែន!»។

## ព្រះយេស៊ូត្រាស់ហៅលោកលេវី

(ម៉ាថាយ ៩, ៩-១៣ ម៉ាកុស ២, ១៣-១៧)

២៧បន្ទាប់មក ព្រះយេស៊ូយាងចាកចេញពីទីនោះ ទ្រង់ទត
ឃើញអ្នកទារពន្ធ *ម្នាក់ ឈ្មោះលេវី អង្គុយនៅកន្លែងយកពន្ធ
ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «សុំអញ្ជើញមកតាមខ្ញុំ»។
២៨លោកលេវីក្រោកឡើង ទុកកិច្ចការទាំងអស់ចោល ហើយដើរ
តាមព្រះយេស៊ូទៅ។ ២៩លោកលេវីបានរៀបចំពិធីជប់លៀងមួយ

យ៉ាងធំ ថ្វាយព្រះអង្គនៅផ្ទះរបស់លោក។ មានអ្នកទារពន្ធ* ព្រម
ទាំងមនុស្សឯទៀតៗជាច្រើន ចូលរួមជាមួយដែរ។ ៣០ពួកខាង
គណៈផារីស៊ី* និងពួកធម្មាចារ្យ*ពីគណៈផារីស៊ី ទាស់ចិត្តយ៉ាង
ខ្លាំង គេនិយាយទៅកាន់ក្រុមសាវ័ក*របស់ព្រះអង្គថា៖ «ហេតុ
អ្វីបានជាអ្នករាល់គ្នា បរិភោគជាមួយអ្នកទារពន្ធ និងមនុស្សបាប
ដូច្នេះ?»។ ៣១ព្រះយេស៊ូតបទៅគេថា៖ «មនុស្សមានសុខភាពល្អ
មិនត្រូវការគ្រូពេទ្យឡើយ មានតែអ្នកជំងឺប៉ុណ្ណោះ ដែលត្រូវការ។
៣២ខ្ញុំមិនមែនមករកមនុស្សសុចរិតទេ គឺមករកមនុស្សបាប ដើម្បី
ឲ្យគេប្រែចិត្តគំនិត»។

## អំពីការតមអាហារ

(ម៉ាថាយ ៩, ១៤-១៧ ម៉ាកុស ២, ១៨-២២)

៣៣មានគេទូលសួរព្រះយេស៊ូថា៖ «ពួកសិស្សរបស់លោកយ៉ូហាន
និងពួកសិស្សខាងគណៈផារីស៊ី* តែងតែតមអាហារ និងសូត្រ
ធម៌ជាញឹកញាប់ ចុះហេតុដូចម្ដេចបានជាសិស្សរបស់លោកបែរ
ជានាំគ្នាបរិភោគដូច្នេះ?»។ ៣៤ព្រះយេស៊ូមានព្រះបន្ទូលតបទៅ
គេវិញថា៖ «ក្នុងពិធីមង្គលការ ពេលកូនកំលោះនៅជាមួយ តើ
ភ្ញៀវអាចតមអាហារកើតឬ?។ ទេ! គេមិនអាចតមបាន
ឡើយ។ ៣៥ថ្ងៃក្រោយ ពេលគេចាប់ស្វាមីយកទៅ ទើបភ្ញៀវ
ទាំងនោះតមអាហារ»។

៣៦ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នាថា៖ «ពុំដែលមាន
នរណាហែកសម្លៀកបំពាក់ថ្មី យកទៅប៉ះសម្លៀកបំពាក់ចាស់
នោះឡើយ ធ្វើដូច្នេះ សម្លៀកបំពាក់ថ្មីនឹងត្រូវរហែក ហើយ
ក្រណាត់ចាស់ និងក្រណាត់ថ្មីក៏មិនសមគ្នាដែរ។ ៣៧ពុំដែលមាន

នរណាច្រកស្រាទំពាំងបាយជូរថ្មី ទៅក្នុងថង់ស្បែកចាស់ឡើយ
បើធ្វើដូច្នេះ ស្រាថ្មីនឹងធ្វើឲ្យថង់ស្បែកចាស់នោះធ្លុះ បណ្ដាលឲ្យ
ស្រាហូរចេញ ហើយថង់ស្បែកក៏ត្រូវខូចខាតមិនខាន ៣៨ត្រូវច្រក
ស្រាថ្មីទៅក្នុងថង់ស្បែកថ្មី។ ៣៩កាលបើបានពិសាស្រាទំពាំងបាយ
ជូរចាស់ហើយ មិនដែលមាននរណាចង់ពិសាស្រាថ្មីទេ ព្រោះ
គេថា "ស្រាចាស់ឆ្ងាញ់ជាងស្រាថ្មី"»។

## ព្រះយេស៊ូមានអំណាចលើថ្ងៃសប្ប័ទ

(ម៉ាថាយ ១២, ១-៨ ម៉ាកុស ២, ២៣-២៨)

៦ ១មានថ្ងៃមួយជាថ្ងៃសប្ប័ទ * ព្រះយេស៊ូយាងកាត់វាល
ស្រែ សាវ័ក *របស់ព្រះអង្គនាំគ្នាបូតកួរស្រូវសាឡី មក
ឈ្លីបរិភោគ។ ២មានពួកខាងគណៈផារីស៊ី *ខ្លះ និយាយទៅសាវ័ក
ទាំងនោះថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នា ធ្វើការដែលបញ្ញត្តិហាម
មិនឲ្យធ្វើនៅថ្ងៃសប្ប័ទ *ដូច្នេះ?»។ ៣ព្រះយេស៊ូតបទៅគេវិញ
ថា៖ «ក្នុងគម្ពីរមានអត្ថបទមួយ ស្ដីអំពីការដែលព្រះបាទដាវីឌ
និងបរិពារបានប្រព្រឹត្តនៅពេលឃ្លាន ៤គឺស្ដេចបានយាងចូលទៅ
ក្នុងដំណាក់របស់ព្រះជាម្ចាស់ យកនំប៉័ងដែលគេតាំងថ្វាយព្រះ
ជាម្ចាស់មកសោយ ព្រមទាំងចែកឲ្យពួកបរិពារបរិភោគទៀតផង។
តាមវិន័យ* មានតែពួកបូជាចារ្យ *ប៉ុណ្ណោះ ដែលមានសិទ្ធិ
បរិភោគ នំប៉័ងនោះបាន។ តើអ្នករាល់គ្នា ធ្លាប់អានអត្ថបទនោះ
ឬទេ?»។ ៥ព្រះអង្គមានព្រះបន្ទូលទៅគេទៀតថា៖ «បុត្រ
មនុស្ស *ជាម្ចាស់លើថ្ងៃសប្ប័ទ *។

## ព្រះយេស៊ូប្រោសមនុស្សស្វិតដៃម្នាក់ឲ្យបានជា នៅថ្ងៃសប្ប័ទ

(ម៉ាថាយ ១២, ៩-១៤ ម៉ាកុស ៣, ១-៦)

៦នៅថ្ងៃសប្ប័ទ *មួយទៀត ព្រះយេស៊ូយាងចូលក្នុងធម្មសាលា *
ហើយទ្រង់បង្រៀនគេ។ នៅទីនោះ មានបុរសម្នាក់ស្វិតដៃស្ដាំ។
៧ពួកធម្មាចារ្យ * និងពួកខាងគណៈផារីស៊ី *តាមមើលព្រះយេស៊ូ
ក្រែងលោព្រះអង្គប្រោសអ្នកជំងឺនៅថ្ងៃសប្ប័ទ ព្រោះគេចង់រក
លេសចោទប្រកាន់ព្រះអង្គ។ ៨ព្រះយេស៊ូឈ្វេងយល់ចិត្តគំនិត
របស់ពួកគេ ទ្រង់ក៏មានព្រះបន្ទូលទៅកាន់បុរសស្វិតដៃនោះថា៖
«ចូរក្រោកឡើង មកឈរនៅកណ្ដាលគេឯណេះ!»។ បុរសនោះ
ក៏ក្រោកឈរឡើង។ ៩ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំ
សួរអ្នករាល់គ្នាថា នៅថ្ងៃសប្ប័ទ តើមនុស្សមានសិទ្ធិធ្វើអំពើល្អ
ឬធ្វើអំពើអាក្រក់? តើត្រូវសង្គ្រោះជីវិតមនុស្ស ឬធ្វើឲ្យវិនាស
អន្តរាយ?»។ ១០ព្រះអង្គបែរព្រះភ័ក្ត្រទតមើលមនុស្សទាំងអស់
ដែលនៅជុំវិញ រួចមានព្រះបន្ទូលទៅបុរសស្វិតដៃនោះថា៖ «ចូរ
លាតដៃមើល៍!»។ គាត់ក៏លាតដៃ ហើយដៃគាត់បានជាដូចដើម
វិញ។ ១១ពួកគេក្ដៅក្រហាយយ៉ាងខ្លាំង ហើយពិគ្រោះគ្នា គិតធ្វើ
យ៉ាងណា ដើម្បីប្រឆាំងនឹងព្រះយេស៊ូ។

## ព្រះយេស៊ូជ្រើសរើសគ្រីស្ដទូត *ដប់ពីររូប

(ម៉ាថាយ ១០, ១-៤ ម៉ាកុស ៣, ១៣-១៩)

១២នៅគ្រានោះ ព្រះយេស៊ូយាងឡើងទៅលើភ្នំ ដើម្បីអធិដ្ឋាន *។
ព្រះអង្គអធិដ្ឋានពេញមួយយប់។ ១៣លុះព្រលឹមឡើង ព្រះអង្គ

ត្រាស់ហៅសាវ័ក *មក ក្នុងចំណោមសាវ័កទាំងនោះ ព្រះអង្គ
ជ្រើសយកដប់ពីររូប ហើយប្រទានងារជាទូតរបស់ព្រះអង្គ ១៤គឺ
មានស៊ីម៉ូន ដែលទ្រង់ប្រទានឈ្មោះថាសិលា និងអន់ទ្រេជាប្អូន
របស់គាត់ យ៉ាកុប យ៉ូហាន ភីលីព បាថូឡូមេ ១៥ម៉ាថាយ ថូម៉ាស
យ៉ាកុបជាកូនរបស់លោកអាល់ផាយ ស៊ីម៉ូនហៅអ្នកជាតិនិយម៸
១៦យូដាជាកូនលោកយ៉ាកុប និងយូដាអ៊ីស្ការីយ៉ុត ដែលនឹង
ក្បត់ព្រះអង្គ។

## ព្រះយេស៊ូបង្រៀនបណ្ដាជន និងប្រោសអ្នកជំងឺឲ្យបានជា

(ម៉ាថាយ ៤, ២៣-២៥)

១៧ព្រះយេស៊ូយាងចុះពីលើភ្នំ ជាមួយសាវ័ក *ទាំងនោះ មក
ប្រថាប់នៅត្រង់កន្លែងមួយរាបស្មើ។ នៅទីនោះ មានសាវ័កជា
ច្រើន និងប្រជាជនពីស្រុកយូដា ពីក្រុងយេរូសាឡឹម ពីក្រុងទីរ៉ូស
និងក្រុងស៊ីដូននៅតាមមាត់សមុទ្រ មករង់ចាំព្រះអង្គយ៉ាងកក
កុញ។ ១៨គេនាំគ្នាមកស្ដាប់ព្រះអង្គ និងសូមព្រះអង្គប្រោសគេ
ឲ្យជាពីជំងឺ។ រីឯអស់អ្នកដែលមានខ្មោចចូល ក៏បានជាដែរ។
១៩បណ្ដាជនប្រជ្រៀតគ្នាចូលមកពាល់ព្រះយេស៊ូ ដ្បិតមានឫទ្ធា
នុភាពចេញពីព្រះអង្គមកប្រោសគេឲ្យជាគ្រប់ៗគ្នា។

## សុភមង្គល និងអពមង្គល

(ម៉ាថាយ ៥, ១-១២)

២០ព្រះយេស៊ូងើបព្រះភ័ក្ត្រទតមើលសាវ័ក *របស់ព្រះអង្គ ហើយ

ร, នៅជំនាន់នោះ ប្រទេសអ៊ីស្រាអែលស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ចក្រភពរ៉ូម៉ាំង។ ជនជាតិយូដាមួយក្រុម ដែលមានគំនិតជាតិនិយមបាននាំគ្នាធ្វើចលនាបំបះបំបោរប្រឆាំងនឹងអំណាចរ៉ូម៉ាំងនេះយ៉ាងខ្លាំង។

មានព្រះបន្ទូលថា៖

«អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ!
អ្នកមានសុភមង្គល* ហើយ
ដ្បិតអ្នករាល់គ្នាបានទទួលព្រះរាជ្យ*របស់
ព្រះជាម្ចាស់។
២១ អ្នករាល់គ្នាដែលកំពុងតែស្រេកឃ្លានអើយ!
អ្នកមានសុភមង្គលហើយ
ដ្បិតអ្នករាល់គ្នានឹងបានឆ្អែត។
អ្នករាល់គ្នាដែលកំពុងតែយំសោកអើយ!
អ្នកមានសុភមង្គលហើយដ្បិតអ្នករាល់គ្នានឹងបានត្រេកអរ។
២២ ប្រសិនបើមានគេស្អប់លែងរាប់រកអ្នករាល់គ្នា
ប្រសិនបើគេត្មះតិះដៀល បង្ខូចឈ្មោះអ្នករាល់គ្នា
ព្រោះតែបុត្រមនុស្ស*
អ្នករាល់គ្នាមានសុភមង្គលហើយ។
២៣ នៅគ្រានោះ ចូរមានអំណរសប្បាយឡើង ដ្បិតអ្នករាល់គ្នាទទួលរង្វាន់យ៉ាងធំ នៅស្ថានបរមសុខ*។
កាលពីជំនាន់មុន បុព្វបុរស*របស់គេក៏បានប្រព្រឹត្ត
ចំពោះពួកព្យាការីដូច្នោះដែរ។
២៤ ចំណែកឯអ្នករាល់គ្នាដែលជាអ្នកមានអើយ!
អ្នកនឹងត្រូវវេទនា ព្រោះអ្នករាល់គ្នាបាន
ទទួលការសម្រាលទុក្ខរួចស្រេចហើយ។
២៥ អ្នករាល់គ្នាដែលឆ្អែតនៅពេលនេះអើយ!
អ្នកនឹងត្រូវវេទនា
ដ្បិតអ្នករាល់គ្នានឹងស្រេកឃ្លានជាពុំខាន។

អ្នករាល់គ្នាដែលកំពុងតែត្រេកអរអើយ!
អ្នកនឹងត្រូវវេទនា ព្រោះអ្នករាល់គ្នា
នឹងកាន់ទុក្ខ ហើយយំសោកជាពុំខាន។
២៦ អ្នករាល់គ្នាដែលមនុស្សទាំងអស់កោត
សរសើរអើយ!
អ្នកត្រូវវេទនាហើយ
ព្រោះបុព្វបុរសរបស់គេក៏បានប្រព្រឹត្ត
ចំពោះពួកព្យាការីក្លែងក្លាយ
ដូច្នោះដែរ!»។

## សេចក្ដីស្រឡាញ់ចំពោះខ្មាំងសត្រូវ

(ម៉ាថាយ ៥, ៣៨-៤៨ និង ៧, ១២)

២៧«ខ្ញុំសុំប្រាប់អ្នករាល់គ្នា ដែលកំពុងស្ដាប់ខ្ញុំថា ចូរស្រឡាញ់
ខ្មាំងសត្រូវរបស់ខ្លួន និងធ្វើអំពើល្អដល់អស់អ្នកដែលស្អប់អ្នក
រាល់គ្នា ២៨ត្រូវជូនពរដល់អស់អ្នកដែលប្រទេចផ្ដាសាអ្នករាល់គ្នា
និងអង្វរព្រះជាម្ចាស់ សូមទ្រង់ប្រទានពរដល់អស់អ្នកដែលបៀត
បៀនអ្នករាល់គ្នា។ ២៩ប្រសិនបើមានគេទះកំផ្លៀងអ្នកម្ខាង ចូរបែរ
ឲ្យគេទះម្ខាងទៀតចុះ។ ប្រសិនបើគេយកអាវធំរបស់អ្នក ចូរឲ្យ
គេយកអាវក្នុងថែមទៀតទៅ។ ៣០បើមានអ្នកណាសុំអ្វីពីអ្នក ចូរ
ឲ្យគេទៅ ហើយបើគេរឹបអូសយកអ្វីដែលជារបស់អ្នក ចូរកុំទារ
ពីគេវិញឡើយ។ ៣១បើអ្នករាល់គ្នាចង់ឲ្យគេប្រព្រឹត្តចំពោះខ្លួនបែប
ណា ត្រូវប្រព្រឹត្តចំពោះគេបែបនោះដែរ។ ៣២បើអ្នករាល់គ្នាស្រឡាញ់
តែមនុស្សដែលស្រឡាញ់អ្នករាល់គ្នា តើនឹងមានគុណបំណាច់
អ្វី? សូម្បីតែមនុស្សបាប ក៏ចេះស្រឡាញ់គ្នាគេដែរ ៣៣ហើយបើ

អ្នករាល់គ្នាធ្វើអំពើល្អតែជាមួយមនុស្សណាដែលធ្វើអំពើល្អដល់
អ្នករាល់គ្នា តើនឹងមានគុណបំណាច់អ្វី? សូម្បីតែមនុស្សបាបក៏
ចេះធ្វើអំពើល្អដល់គ្នាគេដែរ។ ៣៤បើអ្នករាល់គ្នាឲ្យគេខ្ចី ដោយ
សង្ឃឹមថានឹងបានសំណងវិញ តើនឹងមានគុណបំណាច់អ្វី? សូម្បី
តែមនុស្សបាបក៏ឲ្យគ្នាគេខ្ចី ដើម្បីទទួលសំណងដូចដើមវិញដែរ។
៣៥ចូរស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន ហើយធ្វើល្អដល់គេ ព្រមទាំង
ឲ្យគេខ្ចីដោយកុំនឹកសង្ឃឹមចង់បានអ្វីវិញឲ្យសោះ ពេលនោះ អ្នក
រាល់គ្នានឹងទទួលរង្វាន់យ៉ាងធំ អ្នករាល់គ្នានឹងបានទៅជាកូនរបស់
ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត ដ្បិតព្រះអង្គក៏មានព្រះហឫទ័យ
សប្បុរសចំពោះជនអកតញ្ញូ និងជនកំណាចដែរ។ ៣៦ចូរមានចិត្ត
មេត្តាករុណា ដូចព្រះបិតារបស់អ្នករាល់គ្នាដែលមានព្រះហឫទ័យ
មេត្តាករុណា»។

## កុំថ្កោលទោសអ្នកដទៃ

(ម៉ាថាយ ៧, ១-៥)

៣៧«កុំថ្កោលទោសអ្នកដទៃឲ្យសោះ នោះព្រះជាម្ចាស់ក៏មិន
ថ្កោលទោសអ្នករាល់គ្នាដែរ។ កុំផ្ដន្ទាទោសអ្នកដទៃឲ្យសោះ នោះ
ព្រះជាម្ចាស់ក៏មិនផ្ដន្ទាទោសអ្នករាល់គ្នាដែរ។ ត្រូវលើកលែង
ទោសឲ្យអ្នកដទៃ នោះព្រះជាម្ចាស់នឹងលើកលែងទោសឲ្យអ្នក
រាល់គ្នា។ ៣៨ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹង
ប្រទានអំណោយដល់អ្នករាល់គ្នាដែរ ទ្រង់នឹងប្រទានមកយ៉ាង
បរិបូណ៌ហូរហៀរ។ ព្រះជាម្ចាស់នឹងវាល់ឲ្យអ្នកតាមរង្វាល់ដែល
អ្នកវាល់ឲ្យអ្នកដទៃ»។

៣៩ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នាទៅគេទៀតថា៖

«មនុស្សខ្វាក់ពុំអាចនាំមនុស្សខ្វាក់ម្នាក់ទៀតបានឡើយ។ បើធ្វើ
ដូច្នោះ មុខជាធ្លាក់រណ្ដៅទាំងពីរនាក់មិនខាន។ [៤០]ពុំដែលមាន
សិស្សណាធំជាងគ្រូឡើយ ប៉ុន្តែ សិស្សដែលបានទទួលចំណេះ
សព្វគ្រប់ អាចស្មើនឹងគ្រូបាន។ [៤១]ហេតុអ្វីបានជាអ្នកមើលឃើញ
ល្អងធូលីនៅក្នុងភ្នែករបស់បងប្អូនអ្នក តែមើលមិនឃើញធ្នឹម នៅ
ក្នុងភ្នែករបស់អ្នកផ្ទាល់ដូច្នេះ?។ [៤២]បើអ្នកមើលធ្នឹមនៅក្នុងភ្នែក
របស់អ្នកមិនទាំងឃើញផង ម្ដេចក៏ហ៊ាននិយាយទៅបងប្អូនថា
"ទុកឲ្យខ្ញុំផ្ដិតយកល្អងធូលីនេះចេញពីភ្នែកអ្នក?"។ មនុស្សមាន
ពុតអើយ! ចូរយកធ្នឹមចេញពីភ្នែកអ្នកជាមុនសិន ទើបអ្នកមើល
ឃើញច្បាស់ល្មមនឹងផ្ដិតយកល្អងធូលីចេញពីភ្នែករបស់បងប្អូន
អ្នកបាន»។

## ដើមឈើល្អ និងដើមឈើអាក្រក់

(ម៉ាថាយ ៧,១៦-២០ និង ១២, ៣៣-៣៥)

[៤៣] «ដើមឈើល្អ មិនដែលឲ្យផ្លែអាក្រក់ឡើយ ឯដើមឈើ
អាក្រក់វិញ ក៏មិនដែលឲ្យផ្លែល្អដែរ [៤៤]ដ្បិតគេស្គាល់ដើមឈើបាន
ដោយសារផ្លែវា។ ពុំដែលមាននរណាបេះផ្លែឧទុម្ពរ* ឬផ្លែទំពាំង
បាយជូរពីគុម្ពបន្លាឡើយ។ [៤៥]មនុស្សល្អតែងប្រព្រឹត្តអំពើល្អ ព្រោះ
ចិត្តរបស់គេល្អ រីឯមនុស្សអាក្រក់តែងប្រព្រឹត្តអំពើអាក្រក់ ព្រោះ
ចិត្តរបស់គេអាក្រក់ ដ្បិតមាត់របស់មនុស្សតែងស្រដីចេញមកនូវ
សេចក្ដីណាដែលមានពេញហូរហៀរនៅក្នុងដួងចិត្តរបស់ខ្លួន»។

## មនុស្សពីរនាក់សង់ផ្ទះ

(ម៉ាថាយ៧,២៤-២៧)

៤៦«ហេតុអ្វីបានជាអ្នករាល់គ្នាហៅខ្ញុំថា "ព្រះអម្ចាស់! ព្រះអម្ចាស់!"
តែមិនប្រព្រឹត្តតាមពាក្យខ្ញុំដូច្នេះ?។ ៤៧អ្នកដែលចូលមករកខ្ញុំ ស្តាប់
ពាក្យខ្ញុំ ហើយប្រព្រឹត្តតាមខ្ញុំ សុំបង្ហាញប្រាប់ឲ្យអ្នករាល់គ្នាដឹង
ថា គេប្រៀបបានទៅនឹងមនុស្សប្រភេទណា ៤៨អ្នកនោះប្រៀប
បាននឹងមនុស្សម្នាក់ដែលសង់ផ្ទះ។ គាត់ជីកដីយ៉ាងជ្រៅ ហើយ
ចាក់គ្រឹះលើផ្ទាំងថ្ម លុះទឹកជំនន់មកដល់ ទោះបីទឹកហូរមកប៉ះ
យ៉ាងណាក៏ដោយ ក៏មិនអាចធ្វើឲ្យផ្ទះនោះរង្គើបានដែរ ព្រោះ
គាត់បានសង់យ៉ាងមាំ។ ៤៩ចំណែកឯអ្នកដែលស្ដាប់ពាក្យខ្ញុំ តែ
មិនប្រព្រឹត្តតាម ប្រៀបបាននឹងមនុស្សម្នាក់ដែលសង់ផ្ទះ ដោយ
ពុំបានចាក់គ្រឹះ។ លុះទឹកហូរមកបោកផ្ទះនោះក៏រលំខូចខាតភ្លាម
គ្មានអ្វីសល់ឡើយ»។

## ព្រះយេស៊ូប្រោសអ្នកបម្រើរបស់ នាយទាហានរ៉ូម៉ាំងឲ្យបានជា

(ម៉ាថាយ ៨, ៥-១៣)

៧ ១កាលព្រះយេស៊ូមានព្រះបន្ទូលឲ្យប្រជាជនស្ដាប់
ចប់សព្វគ្រប់ហើយ ព្រះអង្គក៏យាងចូលទៅក្រុងកា
ផានុម។ ២នៅក្រុងនោះ មានអ្នកបម្រើសំណព្វចិត្តរបស់នាយ
ទាហានរ៉ូម៉ាំងម្នាក់ មានជំងឺជាទម្ងន់ជិតស្លាប់។ ៣ពេលនាយ
ទាហាននោះ ឮគេនិយាយអំពីព្រះយេស៊ូ គាត់ក៏ចាត់ចាស់ទុំនៃ
ជនជាតិយូដាខ្លះឲ្យទៅយាងព្រះអង្គមកប្រោសអ្នកបម្រើរបស់

គាត់។ ៤ចាស់ទុំទាំងនោះទៅគាល់ព្រះយេស៊ូ ទទូចអង្វរព្រះអង្គ
ថា៖ «នាយទាហាននោះជាមនុស្សម្នាក់ ដែលគួរតែលោកប្រោស
ប្រណីដល់គាត់ ៥ព្រោះគាត់ស្រឡាញ់ជាតិសាសន៍របស់យើង
ថែមទាំងបានសង់ធម្មសាលា *ឲ្យយើងផង»។ ៦ព្រះយេស៊ូយាង
ទៅជាមួយចាស់ទុំទាំងនោះ។ លុះយាងជិតដល់ហើយ នាយ
ទាហានចាត់មិត្តភក្ដិរបស់គាត់ឲ្យមកទូលថា៖ «លោកម្ចាស់! មិន
បាច់អញ្ជើញចូលផ្ទះខ្ញុំប្របាទទេ ដ្បិតខ្ញុំប្របាទមានឋានៈទន់ទាប
ណាស់ មិនសមនឹងទទួលលោកក្នុងផ្ទះខ្ញុំប្របាទឡើយ។ ៧ហេតុ
នេះហើយ បានជាខ្ញុំប្របាទមិនហ៊ានមកជួបលោកផ្ទាល់។
សូមលោកមេត្តាមានប្រសាសន៍តែមួយម៉ាត់ នោះអ្នកបម្រើ
របស់ខ្ញុំប្របាទនឹងជាសះស្បើយមិនខាន។ ៨ខ្ញុំប្របាទជាអ្នក
នៅក្រោមបញ្ជាគេ ហើយក៏មានកូនទាហានជាច្រើននៅក្រោម
បញ្ជាខ្ញុំប្របាទ ដែរ។ បើខ្ញុំប្របាទបញ្ជាអ្នកណាម្នាក់ឲ្យទៅ គេ
ប្រាកដជាទៅ បើប្រាប់ម្នាក់ទៀតឲ្យមកគេនឹងមក។ ពេលខ្ញុំ
ប្របាទប្រាប់អ្នកបម្រើឲ្យធ្វើការអ្វីមួយ គេនឹងធ្វើតាម»។ ៩កាល
ព្រះយេស៊ូទ្រង់ព្រះសណ្ដាប់ពាក្យទាំងនេះហើយ ព្រះអង្គស្ងើច
សរសើរនាយទាហាននោះណាស់។ ព្រះអង្គងាកទៅរកបណ្ដា
ជនដែលដើរតាមព្រះអង្គហើយមានព្រះបន្ទូលថា៖ «ខ្ញុំមិនដែល
ឃើញនរណា មានជំនឿបែបនេះឡើយ ទោះបីនៅស្រុកអ៊ីស្រាអែល
ក៏គ្មានផង»។ ១០មិត្តភក្ដិដែលនាយទាហានចាត់ឲ្យមក ក៏វិល
ត្រឡប់ទៅវិញ ឃើញអ្នកបម្រើបានជាសះស្បើយ។

## ព្រះយេស៊ូប្រោសកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់ ឲ្យរស់ឡើងវិញ

១១ក្រោយមកទៀត ព្រះយេស៊ូយាងឆ្ពោះទៅភូមិមួយឈ្មោះ
ណាអ៊ីន។ សាវ័ករបស់ព្រះអង្គ និងបណ្ដាជនជាច្រើនក៏ធ្វើដំណើរ
ទៅជាមួយព្រះអង្គដែរ។ ១២ពេលព្រះអង្គយាងមកជិតដល់ទ្វារ
កំពែងក្រុង មានគេដង្ហែសពយកទៅបញ្ចុះ។ បុគ្គលដែលស្លាប់
នោះ ជាកូនប្រុសតែមួយរបស់ស្ត្រីមេម៉ាយម្នាក់។ អ្នកស្រុកជា
ច្រើនបានមកជួយដង្ហែសពជាមួយគាត់។ ១៣កាលព្រះអម្ចាស់
ឃើញស្ត្រីមេម៉ាយនោះ ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរ
គាត់យ៉ាងខ្លាំង។ ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «សូមកុំយំ
អី!»។ ១៤ព្រះអង្គយាងចូលទៅជិត ទ្រង់ពាល់មឈូស ពួកអ្នក
សែងក៏នាំគ្នាឈប់។ ព្រះអង្គមានព្រះបន្ទូលថា៖ «អ្នកកំលោះ
អើយ! ចូរក្រោកឡើង»។ ១៥រំពេចនោះ បុគ្គលដែលស្លាប់ក៏ក្រោក
អង្គុយ ហើយចាប់ផ្ដើមនិយាយស្ដី។ ព្រះយេស៊ូប្រគល់អ្នកកំលោះ
ទៅម្ដាយវិញ។ ១៦គេស្ញែងខ្លាចទាំងអស់គ្នា ហើយលើកតម្កើង
សិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយពោលថា៖ «មានព្យាការីដ៏
ប្រសើរឧត្ដមមួយរូប បានមកនៅក្នុងចំណោមយើងហើយ ព្រះ
ជាម្ចាស់យាងមករំដោះប្រជារាស្ត្ររបស់ព្រះអង្គ»។

១៧ពាក្យដែលគេនិយាយអំពីព្រះយេស៊ូ បានលេចឮពាសពេញ
ក្នុងស្រុកយូដា និងតំបន់ជិតខាងទាំងមូល។

## លោកយ៉ូហានបាទីស្ដចាត់សិស្សទៅជួបព្រះយេស៊ូ

(ម៉ាថាយ ១១, ២-១៩)

១៨សិស្សរបស់លោកយ៉ូហាន បានរៀបរាប់ជូនលោកនូវហេតុ
ការណ៍ទាំងអស់នោះ។ លោកយ៉ូហានក៏ហៅសិស្សពីរនាក់មក
១៩រួចចាត់ឲ្យទៅទូលសួរព្រះយេស៊ូជាអម្ចាស់ថា៖ «តើលោកជា
ព្រះគ្រីស្ដ * ដែលត្រូវយាងមក ឬមួយយើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេង
ទៀត?»។ ២០អ្នកទាំងពីរទៅដល់ទូលសួរព្រះយេស៊ូថា៖ «លោក
យ៉ូហានបាទីស្ដចាត់ឲ្យយើងខ្ញុំមកសួរលោកថា តើលោកជាព្រះគ្រីស្ដ
ដែលត្រូវយាងមក ឬមួយក៏យើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេងទៀត?»។
២១នៅគ្រានោះ ព្រះយេស៊ូកំពុងប្រោសអ្នកជំងឺ និងមនុស្សពិការ
ច្រើននាក់ឲ្យបានជា ព្រះអង្គបណ្ដេញខ្មោចពីមនុស្សខ្មោចចូល
ព្រមទាំងប្រោសមនុស្សខ្វាក់ច្រើននាក់ ឲ្យមើលឃើញផង។
២២ព្រះអង្គមានព្រះបន្ទូលទៅសិស្សទាំងពីរនាក់នោះថា៖ «ចូរអ្នក
ទៅជម្រាបលោកយ៉ូហាននូវហេតុការណ៍ ដែលអ្នករាល់គ្នាបាន
ឃើញ និងបានឮ គឺមនុស្សខ្វាក់មើលឃើញ មនុស្សខ្វិនដើរ
បាន មនុស្សឃ្លង់ជាស្អាតបរិសុទ្ធ * មនុស្សថ្លង់ស្ដាប់ឮ មនុស្ស
ស្លាប់បានរស់ឡើងវិញ ហើយគេនាំដំណឹងល្អ *ទៅប្រាប់ជន
ក្រីក្រ[ឍ]។ ២៣អ្នកណាមិនរវាតចិត្តចេញពីជំនឿ ព្រោះតែខ្ញុំ អ្នក
នោះពិតជាមានសុភមង្គលហើយ!»។ ២៤ពេលសិស្សរបស់
លោកយ៉ូហានត្រឡប់ទៅវិញ ព្រះយេស៊ូមានព្រះបន្ទូលទៅ
មហាជនអំពីលោក យ៉ូហានថា៖ «តើអ្នករាល់គ្នាទៅវាលរហោ
ស្ថានរកមើលអ្វី? មើល ដើមត្រែងដែលត្រូវខ្យល់បក់នោះឬ?
២៥តើអ្នករាល់គ្នាទៅរកមើល អ្វី? មើលមនុស្សស្លៀកពាក់ល្អរុង
រឿងឬ? តាមធម្មតាអស់អ្នកដែលស្លៀកពាក់ល្អរុងរឿង ហើយ
មានជីវភាពខ្ពង់ខ្ពស់ គេរស់នៅក្នុងវាំងឯណោះ។ ២៦បើដូច្នេះ

---

**ឍ**, អេសាយ ៦១,១។

តើអ្នករាល់គ្នាទៅរកមើលអ្វី? រកមើលព្យាការី*ម្នាក់ឬ?។ ត្រូវ
ហើយ! ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងថា លោកនោះប្រសើរជាង
ព្យាការីទៅទៀត ២៧ដ្បិតក្នុងគម្ពីរមានចែងអំពីលោកយ៉ូហាន
ថា៖ "យើងចាត់ទូតយើងឲ្យទៅ មុនព្រះអង្គ ដើម្បីរៀបចំផ្លូវ
របស់ព្រះអង្គ"[ឞ]។ ២៨ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងថា បណ្ដា
មនុស្សដែលកើតមកក្នុងលោកនេះ[ឞ] ពុំមាន នរណាម្នាក់ ប្រសើរ
ជាងលោកយ៉ូហានឡើយ។ ប៉ុន្តែ អ្នកណាតូចជាងគេ នៅក្នុង
ព្រះរាជ្យរបស់ព្រះជាម្ចាស់ អ្នកនោះប្រសើរលើសលោក
យ៉ូហានទៅទៀត។ ២៩ប្រជាជនទាំងមូល និងអ្នកទារពន្ធ*បាន
ស្ដាប់លោកយ៉ូហាន ទទួលស្គាល់ថាព្រះជាម្ចាស់ ពិតជាមានព្រះ
ហឫទ័យសុចរិតមែន ហើយនាំគ្នាទទួលពិធីជ្រមុជ ទឹក*ពី
លោក។ ៣០រីឯពួកខាងគណៈផារីស៊ី* និងពួកធម្មាចារ្យ*មិន
ទទួលស្គាល់គម្រោងការ ដែលព្រះជាម្ចាស់បានរៀបចំសម្រាប់ គេ
នោះទេ គឺគេបដិសេធមិនព្រមទទួលពិធីជ្រមុជទឹកពីលោក
យ៉ូហាន។ ៣១តើខ្ញុំប្រដូចមនុស្សជំនាន់នេះ ទៅនឹងមនុស្សប្រភេទ
ណា? តើគេដូចនរណា? ៣២គឺគេប្រៀបបីដូចជាកូនក្មេងដែល
អង្គុយលេងនៅផ្សារ ហើយស្រែកដាក់គ្នាទៅវិញទៅមកថា "យើង
បានផ្លុំខ្លុយ តែពួកឯងមិនព្រមរាំ យើងបានស្មូតបទទំនួញ តែ
ពួកឯងក៏ពុំព្រមយំដែរ"។ ៣៣យ៉ាងណាមិញ លោកយ៉ូហានបាទីស្ដ
បានមក លោកតមអាហារ លោកតមសុរា តែអ្នករាល់គ្នាថា
លោកមានខ្មោចចូល។ ៣៤រីឯបុត្រមនុស្ស*ក៏បានមកដែរ លោក
បរិភោគអាហារ និងពិសាសុរា តែអ្នករាល់គ្នាថា "មើលចុះអ្នក
នេះគិតតែពីស៊ីផឹក ហើយសេពគប់ជាមួយពួកទារពន្ធ*និងមនុស្ស
បាប"។ ៣៥ប៉ុន្តែ អស់អ្នកដែលមានប្រាជ្ញាទទួលស្គាល់ថា ព្រះ
ប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ពិតជាល្អត្រឹមត្រូវមែន»។

---

**ឞ**, ម៉ាឡាគី៣,១។ • **ឞ**, ឃ្លាដើម: «ក្នុងបណ្ដាមនុស្សដែលកើតពីស្ត្រីមក»។

## ព្រះយេស៊ូលើកលែងទោសឲ្យស្ត្រីមានបាបម្នាក់

៣៦មានបុរសម្នាក់ខាងគណៈផារីស៊ី* បានយាងព្រះយេស៊ូទៅ
សោយព្រះស្ងោយ ព្រះអង្គក៏យាងទៅផ្ទះបុរសនោះ ហើយគង់
រួមតុជាមួយគាត់។ ៣៧នៅក្រុងនោះ មានស្ត្រីម្នាក់មានកេរ្តិ៍ឈ្មោះ
មិនល្អ។ ពេលឮថា ព្រះយេស៊ូគង់នៅក្នុងផ្ទះអ្នកខាងគណៈផារីស៊ី*
នោះ នាងយកដបថ្មកែវដាក់ប្រេងក្រអូបចូលមក។ ៣៨នាងនៅពី
ក្រោយព្រះយេស៊ូ ក្រាបទៀបព្រះបាទាព្រះអង្គ នាងយំសម្រក់
ទឹកភ្នែកជោកព្រះបាទាព្រះយេស៊ូ ហើយយកសក់មកជូត។ បន្ទាប់
មកនាងថើប រួចយកប្រេងក្រអូបមកចាក់ពីលើផង។ ៣៩ពេល
បុរសម្ចាស់ផ្ទះឃើញដូច្នោះ គាត់រិះគិតក្នុងចិត្តថា៖ «បើលោក
នេះពិតជាព្យាការី*មែន ច្បាស់ជាលោកជ្រាបថា ស្ត្រីដែលពាល់
លោកនេះជាស្ត្រីប្រភេទណាពុំខាន គឺនាងជាមនុស្សបាប»។
៤០ព្រះយេស៊ូមានព្រះបន្ទូលទៅបុរសខាងគណៈផារីស៊ីនោះថា៖
«លោកស៊ីម៉ូន ខ្ញុំចង់និយាយរឿងមួយជាមួយលោក»។ លោក
ស៊ីម៉ូនទូលតបទៅព្រះអង្គថា៖ «សូមលោកគ្រូមានប្រសាសន៍
មកចុះ»។ ៤១ព្រះយេស៊ូមានព្រះបន្ទូលថា៖ «មានមនុស្សពីរនាក់
ជំពាក់ប្រាក់គេ ម្នាក់ជំពាក់ប្រាំរយ ម្នាក់ទៀតហាសិប។ ៤២ដោយ
អ្នកទាំងពីរគ្មានប្រាក់សង ម្ចាស់ប្រាក់ក៏លុបបំណុលចោល ឈប់
ទារពីអ្នកទាំងពីរនោះទៅ។ ក្នុងចំណោមអ្នកទាំងពីរ តើអ្នកណា
ស្រឡាញ់ម្ចាស់បំណុលជាង?»។ ៤៣លោកស៊ីម៉ូនទូលឆ្លើយថា៖
«តាមយោបល់ខ្ញុំ គឺអ្នកដែលជំពាក់ប្រាក់ច្រើនជាង»។ ព្រះយេស៊ូ
មានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «លោកមានយោបល់ត្រឹម
ត្រូវមែន»។ ៤៤បន្ទាប់មក ព្រះអង្គបែរទៅរកស្ត្រីនោះរួចមានព្រះ
បន្ទូលទៅលោកស៊ីម៉ូនថា៖ «សូមមើលស្ត្រីនេះចុះ! ខ្ញុំបានចូល
មកក្នុងផ្ទះលោក តែលោកពុំបានយកទឹកមកលាងជើងខ្ញុំទេ រីឯ

នាងនាងបានសម្រក់ទឹកភ្នែកជោកជើងខ្ញុំ ព្រមទាំងយកសក់នាង
មកជូតទៀតផង។ ៤៥លោកមិនបានថើបខ្ញុំទេ រីឯនាងវិញតាំង
ពីខ្ញុំចូលមក នាងចេះតែថើបជើងខ្ញុំឥតឈប់ឈរសោះឡើយ។
៤៦លោកមិនបានយកប្រេង មកលាបក្បាលខ្ញុំទេ រីឯនាងវិញ នាង
បានចាក់ប្រេងក្រអូបលាបជើងខ្ញុំ។ ៤៧ហេតុនេះហើយ ខ្ញុំសុំប្រាប់
ឲ្យលោកដឹងថា នាងសម្ដែងសេចក្ដីស្រឡាញ់ជាខ្លាំងយ៉ាងនេះ
ព្រោះព្រះជាម្ចាស់បានប្រោសឲ្យនាងរួចពីបាបជាច្រើន។ រីឯអ្នក
ដែលព្រះជាម្ចាស់លើកលែងទោសឲ្យតិច ក៏សម្ដែងសេចក្ដីស្រឡាញ់
តិចដែរ»។ ៤៨ព្រះយេស៊ូមានព្រះបន្ទូលទៅស្ត្រីនោះថា៖ «ខ្ញុំអត់
ទោសឲ្យនាងបានរួចពីបាបហើយ»។ ៤៩អស់អ្នកដែលអង្គុយរួម
តុជាមួយ រិះគិតក្នុងចិត្តរៀងៗខ្លួនថា៖ «តើលោកនេះមានឋានៈ
អ្វីបានជាហ៊ានអត់ទោសឲ្យមនុស្សរួចពីបាបដូច្នេះ?»។ ៥០ព្រះ
យេស៊ូមានព្រះបន្ទូលទៅនាងទៀតថា៖ «ជំនឿរបស់នាងបាន
សង្គ្រោះនាងហើយ សូមអញ្ជើញទៅវិញដោយសុខសាន្តចុះ»។

## ស្ត្រីៗដែលបម្រើព្រះយេស៊ូ

៨ ១បន្ទាប់មកទៀត ព្រះយេស៊ូយាងទៅតាមក្រុង តាម
ភូមិនានា ទាំងប្រកាស និងផ្សព្វផ្សាយដំណឹងល្អ*
អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ គ្រីស្ដទូត*ទាំងដប់ពីររូបទៅជាមួយ
ព្រះអង្គ ២ហើយមានស្ត្រីខ្លះទៀត ដែលព្រះអង្គបានប្រោសឲ្យជា
ពីជំងឺ និងបណ្ដេញខ្មោចចេញក៏តាមទៅជាមួយដែរ គឺមាននាង
ម៉ារីជាអ្នកស្រុកម៉ាដាឡា ដែលព្រះអង្គបានដេញខ្មោចប្រាំពីរ
ចេញពីនាង ៣នាងយ៉ូហាណាភរិយារបស់យូសា ជាមហាតលិក
របស់ព្រះបាទហេរ៉ូដ នាងស៊ូសាណា ព្រមទាំងស្ត្រីឯទៀតៗជា

ច្រើន ដែលបានចំណាយធនធានរបស់ខ្លួន ដើម្បីទំនុកបម្រុង
ព្រះយេស៊ូ និងសាវ័ក *របស់ព្រះអង្គ។

## ប្រស្នាអំពីគ្រាប់ពូជ

(ម៉ាថាយ ១៣, ១-៩ ម៉ាកុស ៤, ១-៩)

៤មានបណ្ដាជនច្រើនកុះករចេញពីទីក្រុងនានា មករកព្រះយេស៊ូ
ព្រះអង្គមានព្រះបន្ទូលជាប្រស្នាដូចតទៅ៖
៥«មានបុរសម្នាក់ ចេញទៅព្រោះគ្រាប់ពូជ។ ពេលគាត់ព្រោះ
មានគ្រាប់ពូជខ្លះធ្លាក់ទៅលើផ្លូវ ត្រូវគេដើរជាន់ ហើយសត្វមក
ចឹកស៊ីអស់ទៅ។ ៦មានគ្រាប់ពូជខ្លះទៀត ធ្លាក់ទៅលើដីមានថ្ម
កាលពន្លកដុះឡើង ក៏ក្រៀមស្វិតទៅវិញ ព្រោះខ្វះទឹក។ ៧មាន
គ្រាប់ពូជខ្លះទៀត ធ្លាក់ទៅលើដីមានបន្លា។ បន្លាដុះឡើងជាមួយ
គ្រាប់ពូជ ហើយរួបរឹតពូជនោះមិនឲ្យដុះឡើងបាន។ ៨មានគ្រាប់
ពូជខ្លះទៀត ធ្លាក់ទៅលើដីមានជីជាតិល្អ គ្រាប់ពូជដុះឡើង ឲ្យ
ផលមួយជាមួយរយ»។ ព្រះយេស៊ូបន្លឺព្រះសូរសៀងថែមទៀត
ថា៖ «អស់អ្នកដែលឮពាក្យនេះ សូមយកទៅពិចារណាចុះ!»។

## ព្រះយេស៊ូពន្យល់ពាក្យប្រស្នាស្ដីអំពីគ្រាប់ពូជ

(ម៉ាថាយ ១៣, ១០-២៣ ម៉ាកុស ៤, ១០-២០)

៩សាវ័ក *របស់ព្រះយេស៊ូ ទូលសួរព្រះអង្គថា៖ «តើពាក្យប្រស្នា
នោះមានន័យដូចម្ដេច?»។ ១០ព្រះអង្គមានព្រះបន្ទូលតបថា៖
«ព្រះជាម្ចាស់បានប្រោសប្រទានឲ្យអ្នករាល់គ្នាយល់គម្រោងការដ៏លាក់
កំបាំងនៃព្រះរាជ្យ *របស់ព្រះអង្គ។ ចំពោះអ្នកដទៃ ព្រះអង្គ ប្រើជា

ពាក្យប្រស្នាវិញ។ ដូច្នេះ ទោះបីគេមើលក៏ពុំឃើញ ទោះបីគេ
ស្ដាប់ក៏ពុំយល់ដែរ[ហ]។ ១១រីឯប្រស្នានោះ មានន័យដូចតទៅ៖
គ្រាប់ពូជជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ១២មនុស្សខ្លះប្រៀប
បីដូចជាផ្លូវ ដែលគ្រាប់ពូជធ្លាក់ គេបានស្ដាប់ព្រះបន្ទូល តែមារ
សាតាំង *មកឆក់យកពីចិត្តគេ ដើម្បីកុំឲ្យគេជឿ និងកុំឲ្យគេរួច
ជីវិត។ ១៣មនុស្សខ្លះទៀត ប្រៀបបីដូចជាដីមានថ្ម កាលបាន
ស្ដាប់ព្រះបន្ទូល ហើយគេទទួលយកដោយអំណរ។ ប៉ុន្តែគេ
ជឿតែមួយភ្លែត ពុំទុកឲ្យព្រះបន្ទូលចាក់ឫសឡើយ គេបោះបង់
ចោល ជំនឿ នៅពេលណាមានការល្បួង។ ១៤គ្រាប់ពូជដែល
ធ្លាក់ទៅលើដីមានបន្លា ប្រៀបបីដូចជាអស់អ្នកដែលបានស្ដាប់
ព្រះបន្ទូល តែចិត្តខ្វល់ខ្វាយ ចិត្តលោភលន់ចង់បានទ្រព្យ
សម្បត្តិ និងចិត្តស្រើបស្រាលមករួបរឹតផលផ្លែមិនឲ្យទុំបាន
ឡើយ។ ១៥រីឯគ្រាប់ពូជធ្លាក់ទៅលើដីមានជីជាតិល្អ ប្រៀបបី
ដូចជាអស់អ្នកដែលស្ដាប់ ព្រះបន្ទូល ហើយចងចាំទុកយ៉ាងស្មោះ
អស់ពីចិត្ត រហូតដល់បាន បង្កើតផលផ្លែជាច្រើន ដោយចិត្ត
ស៊ូទ្រាំ»។

## ប្រស្នាអំពីចង្កៀង

(ម៉ាកុស ៤, ២១-២៥)

១៦ «ពុំដែលមាននរណាអុជចង្កៀង ហើយយកធុងមកគ្របពី
លើ ឬយកទៅដាក់ក្រោមគ្រែឡើយ។ គេតែងយកចង្កៀងទៅ
ដាក់លើជើងចង្កៀង ដើម្បីបំភ្លឺអស់អ្នកដែលចូលក្នុងផ្ទះ។ ១៧គ្រប់
ការលាក់កំបាំង នឹងត្រូវបើកឲ្យគេដឹង ហើយគ្រប់អាថ៌កំបាំងក៏
នឹងលេចមក ឲ្យមនុស្សគ្រប់គ្នាស្គាល់ច្បាស់ដែរ។ ១៨ដូច្នេះ ចូរ

---
**ហ**, អសោយ ៦,៩-១០។

ប្រុងប្រយ័ត្នអំពីរបៀបដែលអ្នករាល់គ្នាស្ដាប់ ព្រោះអ្នកណាមានហើយ ព្រះជាម្ចាស់នឹងប្រទានឲ្យថែមទៀត តែអ្នកណាដែលគ្មាន ព្រះអង្គនឹងហូតយកនូវអ្វីៗដែលខ្លួនស្មានថាមាននោះផង»។

## មាតា និងបងប្អូនរបស់ព្រះយេស៊ូ

(ម៉ាថាយ ១២, ៤៦-៥០ ម៉ាកុស ៣, ៣១-៣៥)

[១៩]មាតា និងបងប្អូនរបស់ព្រះយេស៊ូ នាំគ្នាមករកព្រះអង្គ ប៉ុន្តែ
មិនអាចចូលទៅជិតព្រះអង្គបានឡើយ ព្រោះមានមនុស្សច្រើន
ពេក។ [២០]មានគេទូលព្រះអង្គថា៖ «ម្ដាយលោក និងបងប្អូនលោក
នៅខាងក្រៅ ចង់ជួបលោក»។ [២១]ព្រះយេស៊ូមានព្រះបន្ទូលទៅ
គេថា៖ «អស់អ្នកដែលស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយ
ប្រតិបត្តិតាម គឺអ្នកនោះហើយ ជាម្ដាយ និងជាបងប្អូនរបស់ខ្ញុំ»។

## ព្រះយេស៊ូធ្វើឲ្យរលកស្ងប់

(ម៉ាថាយ ៨, ២៣-២៧ ម៉ាកុស ៤, ៣៥-៤១)

[២២]ថ្ងៃមួយ ព្រះយេស៊ូយាងចុះទូកជាមួយសាវ័ក ព្រះអង្គមាន
ព្រះបន្ទូលថា៖ «យើងនាំគ្នាឆ្លងទៅត្រើយម្ខាង»។ ពួកសាវ័កក៏
ចេញទូកទៅជាមួយព្រះអង្គ។ [២៣]ពេលឆ្លងទៅនោះ ព្រះយេស៊ូ
ផ្ទំលក់ ស្រាប់តែមានខ្យល់ព្យុះបក់បោកយ៉ាងខ្លាំង មកលើបឹង
បណ្ដាលឲ្យទឹកជះចូលពេញទូក ហើយទាំងអស់គ្នាស្ថិតក្នុងភាព
អាសន្ន។ [២៤]ពួកសាវ័កចូលទៅជិតព្រះយេស៊ូ ដាស់ព្រះអង្គថា៖
«ព្រះគ្រូ! ព្រះគ្រូ! យើងស្លាប់ឥឡូវហើយ»។ ព្រះយេស៊ូតើន
ឡើង មានព្រះបន្ទូលគំរាមខ្យល់ព្យុះ និងរលកយ៉ាងម៉ឺងម៉ាត់។

ខ្យល់ព្យុះ និងរលកក៏ស្ងប់ ហើយផ្ទៃទឹកក៏រាបស្មើដូចធម្មតាវិញ។
២៥ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសាវ័កថា៖ ជំនឿរបស់អ្នក
រាល់គ្នានៅឯណា?»។ ពួកសាវ័កភ័យស្ញប់ស្ញែង ព្រមទាំង
ស្ងើចសរសើរផង គេនិយាយគ្នាទៅវិញទៅមកថា៖ «តើលោក
នេះមានឋានៈអ្វី បានជាបញ្ជាទៅខ្យល់ និងទឹក ហើយខ្យល់
និងទឹកស្ដាប់តាមបង្គាប់លោកដូច្នេះ?»។

## ព្រះយេស៊ូប្រោសបុរសខ្មោចចូលម្នាក់

(ម៉ាថាយ ៨,២៨-៣៤ ម៉ាកុស ៥,១-២០)

២៦ព្រះយេស៊ូ និងសាវ័ក* បានមកដល់ក្រុងកេរ៉ាសា នៅត្រើយ
ម្ខាងទល់មុខស្រុកកាលីឡេ។ ២៧កាលព្រះអង្គយាងឡើងគោក
មានបុរសម្នាក់ចេញពីក្រុងមករកព្រះអង្គ។ គាត់មានខ្មោចចូល
ហើយមិនស្លៀកពាក់ មិនរស់នៅក្នុងផ្ទះតាំងពីយូរមកហើយ គឺ
គាត់ស្នាក់នៅតែតាមទីបញ្ចុះសព។ ២៨ពេលគាត់ឃើញព្រះយេស៊ូ
គាត់ក្រាបទៀបព្រះបាទាព្រះអង្គ ហើយស្រែកយ៉ាងខ្លាំងថា៖
«ឱព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ!
តើព្រះអង្គចង់ធ្វើអ្វីទូលបង្គំ? សូមមេត្តាកុំធ្វើទុក្ខទោសទូលបង្គំ
អី»។ ២៩ខ្មោចទូលអង្វរដូច្នេះ ព្រោះព្រះយេស៊ូបានបញ្ជាវាឲ្យចេញ
ពីបុរសនោះ ចូលគាត់ច្រើនលើកច្រើនសាមកហើយ។ គេបាន
យកច្រវាក់ចងដៃចងជើងគាត់ និងដាក់ខ្នោះទុកមួយកន្លែង តែ
គាត់កាច់ច្រវាក់បានហើយខ្មោចនាំគាត់ទៅទីស្មសាន។ ៣០ព្រះ
យេស៊ូមានព្រះបន្ទូលសួរថា៖ «ឯងឈ្មោះអី?»។ ខ្មោចឆ្លើយថា៖
«ទូលបង្គំឈ្មោះកងទ័ព»។ វាឆ្លើយដូច្នេះ ព្រោះមានខ្មោចជាច្រើន
ចូលក្នុងបុរសនោះ។ ៣១ខ្មោចទាំងនោះបានទទូចអង្វរព្រះយេស៊ូ

សូមកុំឲ្យព្រះអង្គបញ្ជូនពួកវាទៅនរកអវិចីឡើយ។ ៣២នៅក្បែរ
នោះ មានជ្រូកមួយហ្វូងធំកំពុងរកស៊ីតាមចង្កេះភ្នំ។ ពួកខ្មោចបាន
អង្វរព្រះអង្គ សូមអនុញ្ញាតឲ្យវាចូលក្នុងជ្រូកទាំងនោះ ព្រះយេស៊ូ
ក៏អនុញ្ញាតឲ្យ។ ៣៣ខ្មោចចេញពីបុរសនោះ ចូលទៅក្នុងជ្រូក ហ្វូង
ជ្រូកបោលចុះតាមជម្រាលភ្នំតម្រង់ទៅបឹងលង់ទឹកងាប់អស់ទៅ។
៣៤ពេលអ្នកថែរក្សាហ្វូងជ្រូក ឃើញហេតុការណ៍កើតឡើងដូច្នេះ
ក៏រត់យករឿងនេះទៅប្រាប់អ្នកនៅទីក្រុង និងអ្នកនៅស្រុកស្រែ។
៣៥មនុស្សម្នានាំគ្នាចេញទៅមើលហេតុការណ៍នោះ។ គេចូលមក
រកព្រះយេស៊ូ ឃើញបុរសដែលខ្មោចចូលពីមុនអង្គុយនៅទៀប
ព្រះបាទាព្រះអង្គ គាត់ស្លៀកពាក់ដឹងស្មារតីដូចធម្មតា គេក៏ស្ញែង
ខ្លាចព្រះអង្គ។ ៣៦អស់អ្នកដែលបានឃើញផ្ទាល់នឹងភ្នែក នាំគ្នា
រៀបរាប់អំពីរបៀបដែលព្រះយេស៊ូប្រោសបុរសខ្មោចចូលនោះ
ឲ្យបានជា។ ៣៧អ្នកស្រុកនៅតំបន់កេរ៉ាសាទាំងអស់អង្វរព្រះយេស៊ូ
ឲ្យចាកចេញពីស្រុកភូមិរបស់គេ ដ្បិតគេភ័យខ្លាចខ្លាំងណាស់។
ព្រះយេស៊ូក៏យាងចុះទូកត្រឡប់ទៅវិញ។ ៣៨បុរសដែលខ្មោចចូល
ពីមុននោះបានអង្វរសុំនៅជាមួយព្រះអង្គដែរ ប៉ុន្តែព្រះយេស៊ូមិន
យល់ព្រមទេ។ ព្រះអង្គមានព្រះបន្ទូលថា៖ ៣៩«ចូរអ្នកត្រឡប់ទៅ
ផ្ទះវិញចុះ ហើយរៀបរាប់ហេតុការណ៍ទាំងប៉ុន្មាន ដែលព្រះជាម្ចាស់
បានប្រោសដល់អ្នក»។ បុរសនោះចេញទៅប្រកាសប្រាប់ឲ្យអ្នក
ក្រុងដឹងអំពីការទាំងអស់ ដែលព្រះយេស៊ូបានប្រោសដល់គាត់។

## ព្រះយេស៊ូប្រោសស្ត្រីមានជំងឺធ្លាក់ឈាមឲ្យបានជា និងប្រោសកូនស្រីលោកយ៉ៃរ៉ូសឲ្យរស់ឡើងវិញ

(ម៉ាថាយ ៩, ១៨-២៦ ម៉ាកុស ៥, ២១-៤៣)

៤០ពេលព្រះយេស៊ូយាងត្រឡប់មកពីត្រើយម្ខាងវិញ បណ្ដា
ជននាំគ្នាមកទទួលព្រះអង្គ ព្រោះគេចាំមើលផ្លូវព្រះអង្គគ្រប់ៗ
គ្នា។ ៤១ មានអ្នកទទួលខុសត្រូវលើធម្មសាលា*ម្នាក់ ឈ្មោះយ៉ៃរ៉ូស
ចូលមកជិតព្រះយេស៊ូ ក្រាបទៀបព្រះបាទាព្រះអង្គ អង្វរសូម
ព្រះអង្គយាងទៅផ្ទះគាត់ ៤២ដ្បិតគាត់មានកូនស្រីតែមួយអាយុ
ប្រហែលដប់ពីរឆ្នាំ កំពុងឈឺជិតស្លាប់។ កាលព្រះយេស៊ូយាង
ទៅ នៅតាមផ្លូវមានមហាជនប្រជ្រៀតគ្នាជុំវិញព្រះអង្គ។ ៤៣ពេល
នោះ មានស្ត្រីម្នាក់កើតជំងឺធ្លាក់ឈាមដប់ពីរឆ្នាំមកហើយ នាង
បានចំណាយទ្រព្យសម្បត្តិដែលនាងមានទាំងប៉ុន្មាន ដើម្បីឲ្យ
គ្រូពេទ្យព្យាបាល តែគ្មានគ្រូពេទ្យណា អាចមើលនាងជាបាន
ឡើយ។ ៤៤នាងមកពីក្រោយព្រះយេស៊ូ ហើយពាល់ជាយព្រះ
ពស្ត្រព្រះអង្គ ស្រាប់តែឈាមឈប់ធ្លាក់មួយរំពេច។ ៤៥ព្រះយេស៊ូ
មានព្រះបន្ទូលសួរថា៖ «នរណាពាល់ខ្ញុំ?»។ គេប្រកែកគ្រប់គ្នា
ថា គេមិនបានពាល់ព្រះអង្គទេ។ លោកសិលាទូលថា៖ «ព្រះគ្រូ
អើយ បណ្ដាជនប្រជ្រៀតគ្នានៅជុំវិញព្រះគ្រូ ហើយគេប៉ះព្រះគ្រូ
ទាំងអស់គ្នា»។ ៤៦ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «មានម្នាក់
ពិតជាបានពាល់ខ្ញុំ ព្រោះខ្ញុំដឹងថាមានឫទ្ធានុភាពមួយចេញពីខ្លួន
ខ្ញុំទៅ»។ ៤៧ស្ត្រីនោះមកក្រាបទៀបព្រះបាទាព្រះយេស៊ូ ទាំងញ័រ
រន្ធត់ ព្រោះដឹងថាខ្លួនលាក់រឿងនេះមិនជិត។ នាងទូលព្រះអង្គ
នៅចំពោះមុខប្រជាជនទាំងមូល អំពីហេតុដែលនាំឲ្យនាងពាល់
ព្រះអង្គ ហើយនាងបានជាពីជំងឺភ្លាម។ ៤៨ព្រះយេស៊ូមានព្រះបន្ទូល
ទៅនាងថា៖ «កូនស្រីអើយ! ជំនឿរបស់នាងបានសង្គ្រោះនាង
ហើយ សូមអញ្ជើញទៅដោយសុខសាន្តចុះ»។

៤៩កាលព្រះយេស៊ូកំពុងតែមានព្រះបន្ទូលនៅឡើយ មាន
បុរសម្នាក់មកពីផ្ទះលោកយ៉ៃរ៉ូស ជម្រាបគាត់ថា៖ «កូនស្រីលោក

ផុតដង្ហើមទៅហើយ សូមកុំរំខានលោកគ្រូធ្វើអ្វីទៀត!»។ ៥០ព្រះ
យេស៊ូឮពាក្យបុរសនោះ ព្រះអង្គមានព្រះបន្ទូលទៅលោកយ៉ៃរ៉ូស
ថា៖ «កុំខ្លាចអី ឲ្យតែលោកជឿ កូនលោកនឹងបានរួចជីវិតពុំខាន»។
៥១លុះព្រះអង្គយាងទៅដល់ផ្ទះហើយ ព្រះអង្គមិនអនុញ្ញាតឲ្យ
អ្នកណាចូលជាមួយឡើយ លើកលែងតែលោកសិលា លោក
យ៉ូហាន លោកយ៉ាកុប និងឪពុកម្ដាយក្មេងស្រីនោះប៉ុណ្ណោះ។
៥២អ្នកដែលនៅទីនោះ យំសោកអាណិតក្មេងនោះគ្រប់ៗគ្នា តែ
ព្រះយេស៊ូមានព្រះបន្ទូលថា៖ «កុំយំអី នាងមិនស្លាប់ទេ នាងគ្រាន់
តែដេកលក់ទេតើ!»។ ៥៣គេចំអកដាក់ព្រះអង្គ ដ្បិតគេដឹង
ច្បាស់ថានាងបានស្លាប់ពិតមែន។ ៥៤ព្រះយេស៊ូចាប់ដៃក្មេងស្រី
នោះ ហើយបន្លឺព្រះសូរសៀងយ៉ាងខ្លាំងថា៖ «នាងអើយ! ក្រោក
ឡើង»។ ៥៥រំពេចនោះ ព្រលឹងនាងក៏ត្រឡប់មកវិញ ហើយនាង
ក្រោកឡើងភ្លាម។ ព្រះយេស៊ូសុំឲ្យគេយកចំណីអាហារ មកឲ្យ
នាងបរិភោគ។ ៥៦ឪពុកម្ដាយរបស់នាងងឿងឆ្ងល់ក្រៃលែង តែ
ព្រះយេស៊ូហាមគេមិនឲ្យប្រាប់នរណាដឹងរឿងនេះឡើយ។

## ព្រះយេស៊ូចាត់សាវ័កដប់ពីររូប ទៅប្រកាសដំណឹងល្អ

(ម៉ាថាយ ១០, ៥-១៥ ម៉ាកុស ៦, ៧-១៣)

៩ ១ព្រះយេស៊ូត្រាស់ហៅសាវ័ក *ទាំងដប់ពីររូបមកជួប
ជុំគ្នា ហើយទ្រង់ប្រទានឫទ្ធានុភាព ប្រទានអំណាច
ឲ្យគេបណ្ដេញអារក្សទាំងអស់ និងមើលជំងឺផ្សេងៗឲ្យបានជា។
២ព្រះអង្គចាត់គេឲ្យចេញទៅប្រកាសអំពីព្រះរាជ្យ *របស់ព្រះជាម្ចាស់
ព្រមទាំងមើលអ្នកជំងឺឲ្យបានជាផង។ ៣ទ្រង់មានព្រះបន្ទូលទៅ

គេថា៖ «ពេលអ្នករាល់គ្នាចេញដំណើរទៅ កុំយកអ្វីទៅជាមួយ
ឡើយ ទោះបីដំបងក្ដី ថង់យាមក្ដី ចំណីអាហារ ឬប្រាក់កាសក្ដី
ហើយក៏មិនត្រូវយកអាវពីរបន្លាស់ទៅដែរ។ ៤បើអ្នករាល់គ្នាចូល
ផ្ទះណា ចូរស្នាក់នៅផ្ទះនោះ រហូតដល់ពេលអ្នករាល់គ្នាចេញពី
ស្រុកនោះទៅ។ ៥បើភូមិណាគេមិនព្រមទទួលអ្នករាល់គ្នា ចូរចេញ
ពីភូមិនោះទៅ ទាំងរលាស់ធូលីដីចេញពីជើងអ្នករាល់គ្នាផង ទុក
ជាសញ្ញាព្រមានគេ[ឡ]»។ ៦ពួកសាវ័ក *នាំគ្នាចេញទៅធ្វើដំណើរ
ពីភូមិមួយទៅភូមិមួយ ទាំងផ្សព្វផ្សាយដំណឹងល្អ* និងមើលអ្នក
ជំងឺគ្រប់កន្លែងឲ្យបានជាផង។

## ព្រះបាទហេរ៉ូដនឹកឆ្ងល់អំពីព្រះយេស៊ូ

(ម៉ាថាយ ១៤, ១-១២ ម៉ាកុស ៦, ១៤-២៩)

៧កាលព្រះបាទហេរ៉ូដជាស្ដេចអនុរាជ* ជ្រាបហេតុការណ៍
ទាំងនោះ ហើយទ្រង់មិនដឹងជាត្រូវគិតយ៉ាងណា ដ្បិតមានអ្នក
ខ្លះនិយាយថា "លោកយ៉ូហានបាទីស្ដបានរស់ឡើងវិញហើយ"។
៨អ្នកខ្លះទៀតនិយាយថា "ព្យាការី*អេលី បានបង្ហាញខ្លួនឲ្យគេ
ឃើញ" ហើយអ្នកខ្លះទៀតនិយាយថា "មានព្យាការីមួយរូបពី
សម័យបុរាណបានរស់ឡើងវិញ"។ ៩រីឯព្រះបាទហេរ៉ូដមានរាជ
ឱង្ការថា៖ «យើងបានឲ្យគេកាត់កយ៉ូហានស្លាប់បាត់ទៅហើយ[អ]
ចុះបុរសដែលគេនិយាយថាបានធ្វើការអស្ចារ្យទាំងនោះ ជានរណា?»។
ព្រះបាទហេរ៉ូដមានបំណងចង់ជួបព្រះយេស៊ូ។

---

**ឡ**, សូមអានសេចក្ដីពន្យល់(ខ)នៅម៉ាថាយ ១០,១៤។ • **អ**, សូមអាន ម៉ាថាយ ១៤,១-១៣។

## ព្រះយេស៊ូប្រទាននំបុ័ងឲ្យមនុស្សប្រាំពាន់នាក់

(ម៉ាថាយ, ១៤, ១៣-២១ ម៉ាកុស, ៦, ៣០-៤៤ យ៉ូហាន, ៦, ១-១៤)

[១០] គ្រីស្តទូត *នាំគ្នាវិលត្រឡប់មកវិញ រៀបរាប់ទូលព្រះយេស៊ូ
នូវគ្រប់កិច្ចការទាំងអស់ដែលគេបានធ្វើ។ ព្រះអង្គនាំគេចេញ
ដាច់ឡែកពីមហាជន តម្រង់ទៅភូមិមួយឈ្មោះបេតសៃដា [១១]តែ
មហាជនដឹង ក៏នាំគ្នាទៅតាមព្រះអង្គ។ ព្រះយេស៊ូទទួលពួកគេ
ហើយមានព្រះបន្ទូលអំពីព្រះរាជ្យ *របស់ព្រះជាម្ចាស់ឲ្យគេស្ដាប់
ព្រមទាំងប្រោសអ្នកជំងឺឲ្យបានជាផង។

[១២]ដល់ថ្ងៃជិតលិច សាវ័កទាំងដប់ពីររូបចូលទៅទូលព្រះអង្គ
ថា៖ «សូមព្រះអង្គប្រាប់ឲ្យបណ្ដាជនចេញទៅរកម្ហូបអាហារ រក
កន្លែងស្នាក់តាមផ្ទះ តាមភូមិជិតៗនេះទៅ ព្រោះទីនេះស្ងាត់ណាស់»។
[១៣]ព្រះយេស៊ូមានព្រះបន្ទូលតបវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូប
អាហារឲ្យគេបរិភោគទៅ»។ ពួកសាវ័កទូលព្រះអង្គថា៖ «យើងខ្ញុំ
មាននំបុ័ងតែប្រាំដុំ និងត្រីងៀតពីរកន្ទុយប៉ុណ្ណោះ ធ្វើម្ដេចនឹង
គ្រាន់ មានតែទៅទិញអាហារសម្រាប់ប្រជាជនទាំងនេះ!»។ [១៤]នៅ
ទីនោះ មានមនុស្សប្រុសប្រមាណប្រាំពាន់នាក់។ ព្រះយេស៊ូមាន
ព្រះបន្ទូលទៅកាន់សាវ័កថា៖ «ចូរអ្នករាល់គ្នាប្រាប់គេឲ្យអង្គុយ
ចុះជាក្រុមៗ ក្នុងមួយក្រុមហាសិបនាក់»។ [១៥]ពួកសាវ័កក៏ធ្វើតាម
គឺប្រាប់គេឲ្យអង្គុយចុះទាំងអស់គ្នា។ [១៦]ព្រះយេស៊ូយកនំបុ័ងទាំង
ប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ទ្រង់ងើបព្រះភ័ក្ត្រឡើងលើ
សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានឲ្យសាវ័ក ដើម្បី
ឲ្យគេចែកបណ្ដាជនបរិភោគ។ [១៧]គេបានបរិភោគឆ្អែតគ្រប់ៗគ្នា
រួចប្រមូលនំបុ័ងដែលនៅសល់ បានពេញដប់ពីរល្អី។

## លោកសិលាប្រកាសថាព្រះយេស៊ូជាព្រះគ្រីស្ត

(ម៉ាថាយ ១៦, ១៣-១៩ ម៉ាកុស ៨, ២៨-២៩)

១៨ថ្ងៃមួយ ពេលព្រះយេស៊ូនៅអធិដ្ឋាន*ដាច់ឡែកពីបណ្ដាជន
ពួកសាវ័ក*ក៏នៅជាមួយព្រះអង្គដែរ។ ព្រះអង្គមានព្រះបន្ទូល
សួរគេថា៖ «តើមហាជនទាំងឡាយថាខ្ញុំជានរណា?»។ ១៩ពួក
សាវ័កទូលឆ្លើយថា៖ «អ្នកខ្លះថា លោកគ្រូជាលោកយ៉ូហានបាទីស្ដ
អ្នកខ្លះថា លោកជាព្យាការីអេលី ហើយអ្នកខ្លះទៀតថា លោក
ជាព្យាការីមួយរូបពីសម័យបុរាណដែលរស់ឡើងវិញ»។ ២០ព្រះ
យេស៊ូសួរទៀតថា៖ «ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នាថាខ្ញុំជា
នរណាដែរ?»។ លោកសិលាទូលព្រះអង្គថា៖ «លោកជាព្រះ
គ្រីស្ដ* ដែលព្រះជាម្ចាស់ចាត់ឲ្យមក»។ ២១ព្រះយេស៊ូក៏ហាមប្រាម
គេ មិនឲ្យនិយាយប្រាប់អ្នកណាជាដាច់ខាត។

២២ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «បុត្រមនុស្ស*ត្រូវរងទុក្ខ
វេទនាយ៉ាងខ្លាំង។ ពួកព្រឹទ្ធាចារ្យ* ពួកនាយកបូជាចារ្យ* ពួក
ធម្មាចារ្យ* នឹងបោះបង់លោកចោល ថែមទាំងសម្លាប់លោក
ទៀតផង។ ប៉ុន្តែបីថ្ងៃក្រោយមក លោកនឹងរស់ឡើងវិញ»។

២៣បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅគេទាំងអស់គ្នាថា៖
«បើអ្នកណាចង់មកតាមក្រោយខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវ
លីឈើឆ្កាងរបស់ខ្លួនរៀងរាល់ថ្ងៃ ហើយមកតាមខ្ញុំចុះ ២៤ដ្បិត
អ្នកណាចង់បានរួចជីវិត អ្នកនោះនឹងបាត់បង់ជីវិតពុំខាន ប៉ុន្តែ
អ្នកណាបាត់បង់ជីវិត ព្រោះតែខ្ញុំ អ្នកនោះនឹងបានរួចជីវិតវិញ។
២៥បើមនុស្សម្នាក់បានពិភពលោកទាំងមូលមកធ្វើជាសម្បត្តិរបស់
ខ្លួន តែត្រូវស្លាប់បាត់បង់ជីវិតនោះ មានប្រយោជន៍អ្វី។ ២៦បើអ្នក
ណាខ្មាសអៀនមិនហ៊ានទទួលស្គាល់ខ្ញុំ មិនហ៊ានទទួលពាក្យរបស់
ខ្ញុំទេ លុះដល់បុត្រមនុស្ស*យាងមក ប្រកបដោយសិរីរុងរឿង

របស់ព្រះអង្គ ព្រមទាំងសិរីរុងរឿងរបស់ព្រះបិតា និងរបស់ទេវទូត* ដ៏វិសុទ្ធ* ទ្រង់ក៏នឹងខ្មាសអៀនមិនហ៊ានទទួលស្គាល់អ្នកនោះវិញដែរ។ ២៧ប្រាកដមែន ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា មនុស្សខ្លះដែលនៅទីនេះនឹងមិនស្លាប់ទេ មុនបានឃើញព្រះរាជ្យ*របស់ព្រះជាម្ចាស់»។

## សិរីរុងរឿងរបស់ព្រះយេស៊ូ

(ម៉ាថាយ ១៧, ១-៨ ម៉ាកុស ៩, ២-៨)

២៨ប្រមាណជាប្រាំបីថ្ងៃក្រោយពីព្រះយេស៊ូមានព្រះបន្ទូលទាំងនោះមក ព្រះអង្គនាំលោកសិលា លោកយ៉ូហាន និងលោកយ៉ាកុប ឡើងទៅលើភ្នំ ដើម្បីអធិដ្ឋាន*។ ២៩ពេលកំពុងអធិដ្ឋានស្រាប់តែព្រះភ័ក្ត្ររបស់ព្រះអង្គ ប្រែជាមានរស្មី ហើយព្រះពស្ត្ររបស់ព្រះអង្គ ត្រឡប់ជាមានពណ៌សត្រចះត្រចង់។ ៣០ពេលនោះមានបុរសពីរនាក់ គឺលោកម៉ូសេ និងព្យាការីអេលី សន្ទនាជាមួយព្រះយេស៊ូ។ ៣១លោកទាំងពីរលេចមក ប្រកបដោយសិរីរុងរឿង ហើយមានប្រសាសន៍អំពីដំណើរដែលព្រះអង្គត្រូវសោយទិវង្គតនៅក្រុងយេរូសាឡឹម។ ៣២លោកសិលា និងមិត្តភក្តិរបស់លោកសម្រាន្តលង់លក់។ លុះភ្ញាក់ឡើង គេឃើញសិរីរុងរឿងរបស់ព្រះយេស៊ូ និងឃើញលោកទាំងពីរឈរជាមួយព្រះអង្គ។ ៣៣កាលលោកម៉ូសេ និងព្យាការីអេលី កំពុងតែចាកចេញពីព្រះយេស៊ូទៅ លោកសិលាទូលព្រះអង្គថា៖ «ព្រះគ្រូ! យើងខ្ញុំបាននៅទីនេះប្រសើរណាស់ យើងខ្ញុំនឹងសង់ជម្រកបី គឺមួយសម្រាប់ព្រះគ្រូ មួយសម្រាប់លោកម៉ូសេ និងមួយទៀតសម្រាប់ព្យាការីអេលី»។ លោកសិលាមានប្រសាសន៍ទាំងពុំដឹងថា ខ្លួននិយាយ

អ្វីឡើយ។ ³⁴កាលលោកសិលាកំពុងតែមានប្រសាសន៍ ស្រាប់តែមានពពក*មកគ្របបាំងគេទាំងអស់គ្នា ធ្វើឲ្យសាវ័កភ័យខ្លាចក្រៃលែង ដោយមានពពកមកគ្របបាំងដូច្នេះ។ ³⁵មានព្រះសូរសៀងបន្លឺពីក្នុងពពកមកថា៖ «ព្រះអង្គនេះជាបុត្រដែលយើងបានជ្រើសរើស ចូរស្ដាប់ព្រះអង្គចុះ!»។ ³⁶បន្ទាប់ពីបានឮព្រះសូរសៀងនេះហើយ គេឃើញតែព្រះយេស៊ូមួយព្រះអង្គប៉ុណ្ណោះ។ នៅគ្រានោះ សាវ័កឥតបាននិយាយអំពីហេតុការណ៍ ដែលគេបានឃើញប្រាប់អ្នកណាសោះឡើយ។

## ព្រះយេស៊ូដេញខ្មោចចេញពីក្មេងម្នាក់

(ម៉ាថាយ ១៧, ១៤-១៨ ម៉ាកុស ៩, ១៤-២៧)

³⁷នៅថ្ងៃបន្ទាប់ ព្រះយេស៊ូយាងចុះពីលើភ្នំជាមួយសាវ័កមកវិញ ពេលនោះ មានបណ្ដាជនយ៉ាងច្រើនមករកព្រះអង្គ។ ³⁸មានបុរសម្នាក់ស្រែកពីកណ្ដាលចំណោមបណ្ដាជនមកថា៖ «លោកគ្រូអើយ! សូមមេត្តាប្រោសប្រណីដល់កូនប្រុសខ្ញុំប្របាទផង ព្រោះខ្ញុំប្របាទមានកូនតែមួយនេះគត់។ ³⁹ពេលខ្មោចចូលម្ដងៗ វាស្រែករើបម្រះ ប្រកាច់ប្រកិន បែកពពុះមាត់។ លុះធ្វើបាបវាយ៉ាងធ្ងន់ហើយ ខ្មោចក៏ចេញទៅទុកឲ្យកូនខ្ញុំប្របាទនៅគ្រាំគ្រា។ ⁴⁰ខ្ញុំប្របាទបានអង្វរសាវ័ករបស់លោកឲ្យដេញខ្មោចនោះដែរ ប៉ុន្តែគេមិនអាចដេញវាចេញបានសោះ»។ ⁴¹ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «នែ៎ពួកមនុស្សអាក្រក់មិនព្រមជឿអើយ! តើត្រូវឲ្យខ្ញុំទ្រាំនៅជាមួយអ្នករាល់គ្នាដល់ពេលណាទៀត? ចូរនាំកូនរបស់អ្នកមកណេះមើល៍»។ ⁴²ពេលក្មេងនោះដើរចូលមកជិតព្រះយេស៊ូ ស្រាប់តែខ្មោចផ្ដួលវា ធ្វើឲ្យវាប្រកាច់ប្រកិនយ៉ាងខ្លាំង។ ព្រះយេស៊ូ

មានព្រះបន្ទូលគំរាមទៅខ្មោច ព្រះអង្គប្រោសក្មេងនោះឲ្យបាន
ជា ហើយប្រគល់ទៅឲ្យឪពុកវាវិញ។ [៤៣]មនុស្សគ្រប់គ្នាស្ញើចអំពី
មហិទ្ធិឫទ្ធិដ៏ខ្លាំងពូកែរបស់ព្រះជាម្ចាស់។

## ព្រះយេស៊ូមានព្រះបន្ទូលអំពីព្រះអង្គសោយទិវង្គត

(ម៉ាថាយ ១៧, ២២-២៣ ម៉ាកុស ៩, ៣០-៣២)

នៅពេលមនុស្សគ្រប់ៗគ្នា កំពុងកោតស្ញប់ស្ញែងនឹងការទាំង
ប៉ុន្មានដែលព្រះអង្គបានធ្វើ ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសាវ័ក
ថា៖ [៤៤]«ចូរត្រងត្រាប់ស្ដាប់ពាក្យទាំងនេះ ហើយចងចាំទុកក្នុង
ចិត្ត គឺបុត្រមនុស្ស *នឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃរបស់មនុស្ស
លោកជាមិនខាន»។ [៤៥]ពួកសាវ័កពុំបានយល់ព្រះបន្ទូលនេះទេ
ព្រោះព្រះជាម្ចាស់មិនទាន់សម្ដែងអត្ថន័យឲ្យគេយល់ ប៉ុន្តែ ពួក
គេមិនហ៊ានទូលសួរព្រះអង្គអំពីរឿងនេះឡើយ។

## អ្នកដែលធំជាងគេ

(ម៉ាថាយ ១៨,១-៥ ម៉ាកុស ៩, ៣៣-៣៧)

[៤៦]ខណៈនោះ ពួកសាវ័ក *ជជែកគ្នាចង់ដឹងថា ក្នុងចំណោម
ពួកគេ នរណាធំជាងគេ។ [៤៧]ព្រះយេស៊ូឈ្វេងយល់គំនិតរបស់
គេ ក៏យកក្មេងម្នាក់មកឲ្យឈរក្បែរព្រះអង្គ [៤៨]រួចមានព្រះបន្ទូល
ទៅគេថា៖ «អ្នកណាទទួលក្មេងនេះក្នុងនាមខ្ញុំ ក៏ដូចជាបានទទួល
ខ្ញុំដែរ ហើយអ្នកណាទទួលខ្ញុំ ក៏ដូចជាបានទទួលព្រះអង្គដែល
បានចាត់ខ្ញុំឲ្យមកនោះដែរ ដ្បិតអ្នកណាមានឋានៈទាបជាងគេក្នុង
ចំណោមអ្នករាល់គ្នា គឺអ្នកនោះហើយជាអ្នកធំជាងគេ»។

## អ្នកណាមិនជំទាស់នឹងយើងអ្នកនោះជាពួកយើង!

(ម៉ាកុស ៩,៣៨-៤០)

៣៩លោកយ៉ូហានទូលព្រះអង្គថា៖ «ព្រះគ្រូ! យើងខ្ញុំបានឃើញ
បុរសម្នាក់ដេញខ្មោចក្នុងនាមព្រះគ្រូ។ យើងខ្ញុំបានឃាត់គាត់ ព្រោះ
គាត់មិនមកតាមព្រះគ្រូដូចយើងខ្ញុំ»។ ៥០ព្រះយេស៊ូមានព្រះបន្ទូល
ទៅគាត់វិញថា៖ «កុំឃាត់គេអី ដ្បិតអ្នកណាមិនជំទាស់នឹងអ្នក
រាល់គ្នា អ្នកនោះនៅខាងអ្នករាល់គ្នាហើយ»។

## ព្រះយេស៊ូយាងកាត់តាមស្រុកសាម៉ារី

៥១លុះជិតដល់ថ្ងៃកំណត់ ដែលព្រះយេស៊ូត្រូវយាងចាកចេញ
ពីលោកនេះទៅ ព្រះអង្គសម្រេចព្រះហឫទ័យ យាងទៅក្រុង
យេរូសាឡឹម ៥២ព្រះអង្គបានចាត់អ្នកខ្លះឲ្យទៅមុន។ អ្នកទាំង
នោះចេញដំណើរទៅដល់ភូមិមួយរបស់អ្នកស្រុកសាម៉ារី ដើម្បី
រៀបចំកន្លែងថ្វាយព្រះអង្គ។ ៥៣ប៉ុន្តែអ្នកស្រុកពុំព្រមទទួលព្រះអង្គ
ឲ្យស្នាក់ឡើយ ព្រោះព្រះអង្គយាងឆ្ពោះទៅក្រុងយេរូសាឡឹម។
៥៤សាវ័កយ៉ាកុប និងយ៉ូហានឃើញដូច្នោះ ក៏ទូលព្រះអង្គថា៖
«បពិត្រព្រះអម្ចាស់! តើព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំហៅ
រន្ទះភ្លើង មកកម្ទេចអ្នកទាំងនេះឬ?»។ ៥៥ព្រះយេស៊ូបែរទៅរក
គេ ហើយស្ដីបន្ទោសគេយ៉ាងខ្លាំង។ ៥៦បន្ទាប់មកព្រះអង្គយាង
ឆ្ពោះទៅកាន់ភូមិមួយផ្សេងទៀតជាមួយសាវ័ក*។

## លក្ខណសម្បត្តិរបស់អ្នកដែលចង់តាមព្រះយេស៊ូ

(ម៉ាថាយ ៨,១៩-២២)

៥៧កាលព្រះយេស៊ូកំពុងយាងតាមផ្លូវជាមួយសាវ័ក មានបុរស
ម្នាក់ទូលព្រះអង្គថា៖ «ខ្ញុំប្របាទសុខចិត្តទៅតាមលោក ទោះបី
លោកអញ្ជើញទៅទីណាក៏ដោយ»។ ៥៨ព្រះយេស៊ូមានព្រះបន្ទូល
តបទៅគាត់វិញថា៖ «សត្វកញ្ជ្រោងមានរូងរបស់វា បក្សាបក្សី
ក៏មានសំបុករបស់វាដែរ ប៉ុន្តែ បុត្រមនុស្ស *គ្មានទីជម្រកសម្រាក
សោះឡើយ»។ ៥៩ព្រះអង្គមានព្រះបន្ទូលទៅម្នាក់ទៀតថា៖ «សុំ
អញ្ជើញមកតាមខ្ញុំ»។ ប៉ុន្តែអ្នកនោះទូលព្រះអង្គថា៖ «សូមលោក
មេត្តាអនុញ្ញាតឲ្យខ្ញុំប្របាទទៅបញ្ចុះសពឪពុកសិន»។ ៦០ព្រះយេស៊ូ
មានព្រះបន្ទូលតបទៅគាត់វិញថា៖ «ទុកឲ្យមនុស្សស្លាប់បញ្ចុះ
សពគ្នាគេចុះ។ រីឯអ្នកវិញ ចូរទៅផ្សាយដំណឹងអំពីព្រះរាជ្យ*
របស់ព្រះជាម្ចាស់»។ ៦១មានម្នាក់ទៀតទូលព្រះអង្គថា៖ «លោក
ម្ចាស់! ខ្ញុំប្របាទសុខចិត្តទៅតាមលោកដែរ ប៉ុន្តែសូមអនុញ្ញាត
ឲ្យខ្ញុំប្របាទទៅជម្រាបលាក្រុមគ្រួសារសិន»។ ៦២ព្រះយេស៊ូមាន
ព្រះបន្ទូលទៅគាត់វិញថា៖ «អ្នកណាកាន់នង្គ័ល ហើយបែរជាងាក
មើលក្រោយ អ្នកនោះគ្មានសារប្រយោជន៍អ្វីដល់ព្រះរាជ្យ*របស់
ព្រះជាម្ចាស់ឡើយ»។

## ព្រះយេស៊ូចាត់សាវ័ក ៧២ រូប ទៅផ្សាយដំណឹងល្អ

១០ ១ក្រោយមក ព្រះអម្ចាស់ជ្រើសយកសាវ័ក*
ចិតសិបពីររូបទៀត ហើយចាត់គេពីរៗនាក់ឲ្យ
ទៅតាមភូមិ តាមស្រុកនានា ដែលព្រះអង្គបម្រុងនឹងយាងទៅ។
២ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ស្រូវដែលត្រូវច្រូតមានច្រើន
ណាស់ តែអ្នកច្រូតមានតិចពេក។ ហេតុនេះ ចូរអង្វរម្ចាស់ស្រែ

ឲ្យចាត់អ្នកច្រូត មកក្នុងស្រែរបស់លោក។ ៣ចូរនាំគ្នាទៅចុះ!
ខ្ញុំចាត់អ្នករាល់គ្នាទៅ ដូចឲ្យកូនចៀមទៅកណ្ដាលហ្វូងចចក។
៤កុំយកថង់ប្រាក់ ថង់យាម ឬស្បែកជើងទៅជាមួយឡើយ ហើយ



ក៏កុំជម្រាបសួរអ្នកណាតាមផ្លូវដែរ។ ៥ពេលអ្នករាល់គ្នាចូលទៅ
ក្នុងផ្ទះណាមួយ មុនដំបូងត្រូវពោលថា "សូមព្រះជាម្ចាស់ប្រទាន
សេចក្ដីសុខសាន្ត ដល់មនុស្សក្នុងផ្ទះនេះ"[ក]។ ៦បើនៅក្នុងផ្ទះនោះ
មានមនុស្សណាចូលចិត្តសេចក្ដីសុខសាន្ត នោះគេនឹងបានសុខ
សាន្ត ដូចពាក្យអ្នករាល់គ្នាជាមិនខាន។ បើគ្មានអ្នកណាចូលចិត្ត
សេចក្ដីសុខសាន្តទេ សេចក្ដីសុខសាន្តនឹងវិលត្រឡប់មកអ្នករាល់
គ្នាវិញ។ ៧ចូរស្នាក់នៅផ្ទះនោះ ហើយបរិភោគម្ហូបអាហារ ដែល
គេជូនអ្នករាល់គ្នាចុះ ព្រោះអ្នកធ្វើការតែងតែទទួលប្រាក់ឈ្នួល។
មិនត្រូវចេញពីផ្ទះមួយទៅនៅផ្ទះមួយទៀតឡើយ។ ៨បើអ្នករាល់
គ្នាចូលទៅភូមិណា ហើយមានគេទទួលអ្នករាល់គ្នា ត្រូវបរិភោគ
ម្ហូបអាហារដែលគេរៀបជូនចុះ។ ៩ត្រូវប្រោសអ្នកជំងឺក្នុងភូមិនោះ
ឲ្យបានជា ហើយប្រាប់អ្នកភូមិថា៖ "ព្រះរាជ្យ *របស់ព្រះជាម្ចាស់

**ក**, ជាពាក្យជម្រាបសួរ។ សូមអានសេចក្ដីពន្យល់នៅ ម៉ាថាយ ១០,១២។

នៅជិតអ្នករាល់គ្នាហើយ"។ ១០ប៉ុន្តែកាលបើអ្នករាល់គ្នាចូលទៅ
ភូមិណាមួយ ហើយគេមិនព្រមទទួលអ្នករាល់គ្នាទេ ត្រូវចេញ
ទៅប្រកាសតាមទីផ្សារថា៖ ១១"សូម្បីតែធូលីដី ដែលជាប់ជើង
យើង ក៏យើងរលាស់ឲ្យអ្នករាល់គ្នាវិញដែរ ប៉ុន្តែ សូមជ្រាបថា
ព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយហើយ"។ ១២ខ្ញុំសុំប្រាប់
អ្នករាល់គ្នាថា នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោស អ្នកក្រុង
សូដុមទទួលទោសស្រាលជាងអ្នកភូមិនោះ។

១៣អ្នកក្រុងខូរ៉ាស៊ីនអើយ! អ្នកត្រូវវេទនាជាពុំខាន។ អ្នកក្រុង
បេតសៃដាអើយ! អ្នកក៏ត្រូវវេទនាដែរ។ ប្រសិនបើអ្នកក្រុងទីរ៉ូស
និងអ្នកក្រុងស៊ីដូនបានឃើញការអស្ចារ្យ ដូចអ្នករាល់គ្នាឃើញ
នៅទីនេះ ម្លេះសមអ្នកក្រុងទាំងនោះនឹងប្រែចិត្តគំនិត ហើយ
ស្លៀកបាវអង្គុយក្នុងផេះខជាមិនខាន។ ១៤ហេតុនេះហើយ បាន
ជានៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក អ្នកក្រុង
ទីរ៉ូស និងអ្នកក្រុងស៊ីដូនទទួលទោសស្រាលជាងអ្នករាល់គ្នា។
១៥អ្នកក្រុងកាផានុមអើយ! កុំនឹកស្មានថា អ្នកនឹងបានថ្កើងឡើង
ដល់ស្ថានសួគ៌ឡើយ អ្នកនឹងធ្លាក់ទៅស្ថាននរកវិញ»។

១៦ព្រះយេស៊ូមានព្រះបន្ទូលទៅសាវ័កទៀតថា៖ «អ្នកណា
ស្ដាប់អ្នករាល់គ្នា ក៏ដូចជាស្ដាប់ខ្ញុំដែរ។ អ្នកណាបដិសេធមិនទទួល
អ្នករាល់គ្នា ក៏ដូចជាបដិសេធមិនទទួលខ្ញុំដែរ ហើយអ្នកណាមិន
ទទួលខ្ញុំ ក៏ដូចជាមិនទទួលព្រះអង្គដែលចាត់ខ្ញុំឲ្យមកនោះដែរ»។

## ពួកសាវ័កវិលត្រឡប់មកវិញ

១៧ពួកសាវ័ក * ទាំងចិតសិបពីររូប ត្រឡប់មកវិញទាំងត្រេកអរ
ហើយទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ ដោយសារព្រះនាម

---
**ខ**, ទីសម្គាល់អំពីការកាន់ទុក្ខ ដោយទទួលស្គាល់អំពើបាបរបស់ខ្លួន។

ព្រះអង្គ  សូម្បីតែខ្មោចក៏ចុះចូលក្រោមអំណាចយើងខ្ញុំដែរ»។
១៨ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំឃើញមារសាតាំង*ធ្លាក់
ចុះពីលើមេឃមក ដូចផ្លេកបន្ទោរ។ ១៩ខ្ញុំបានឲ្យអ្នករាល់គ្នាមាន
អំណាចដើរជាន់ពស់ និងខ្យាដំរី ព្រមទាំងបង្ក្រាបឫទ្ធិអំណាច
គ្រប់យ៉ាងរបស់មារសត្រូវផង គ្មានអ្វីអាចធ្វើទុក្ខអ្នករាល់គ្នាបាន
ឡើយ ២០ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ កុំត្រេកអរនឹងឃើញ
ខ្មោចចុះចូលអ្នករាល់គ្នា គឺត្រូវត្រេកអរដោយអ្នករាល់គ្នាមានឈ្មោះ
កត់ទុកនៅស្ថានបរមសុខវិញ»។

## ព្រះយេស៊ូមានព្រះហឫទ័យរីករាយ

(ម៉ាថាយ ១១, ២៥-២៧ និង ១៣, ១៦-១៧)

២១ខណៈនោះ ព្រះវិញ្ញាណបានធ្វើឲ្យព្រះយេស៊ូមានព្រះហឫ
ទ័យរីករាយយ៉ាងខ្លាំង។ ព្រះអង្គមានព្រះបន្ទូលថា៖ «បពិត្រព្រះ
បិតាជាអម្ចាស់នៃស្ថានបរមសុខ* និងជាអម្ចាស់នៃផែនដី ទូល
បង្គំសូមសរសើរតម្កើងព្រះអង្គ ព្រោះទ្រង់បានសម្ដែងការទាំង
នេះឲ្យមនុស្សតូចតាចយល់ តែទ្រង់លាក់មិនឲ្យអ្នកប្រាជ្ញ និង
អ្នកចេះដឹងយល់ទេ។ មែនហើយ! ព្រះអង្គសព្វព្រះហឫទ័យ
សម្រេចដូច្នេះ។ ២២ព្រះបិតារបស់ខ្ញុំបានប្រគល់អ្វីៗទាំងអស់មក
ខ្ញុំ។ គ្មាននរណាស្គាល់ព្រះបុត្រាក្រៅពីព្រះបិតា ហើយក៏គ្មាន
នរណាស្គាល់ព្រះបិតា ក្រៅពីព្រះបុត្រា និងអ្នកដែលព្រះបុត្រា
សព្វព្រះហឫទ័យសម្ដែងឲ្យស្គាល់នោះដែរ»។

២៣បន្ទាប់មក ព្រះយេស៊ូបែរទៅរកសាវ័ក* ហើយមានព្រះ
បន្ទូលដាច់ឡែកពីគេថា៖ «អ្នករាល់គ្នាមានសុភមង្គល*ហើយ
ព្រោះអ្នករាល់គ្នាបានឃើញហេតុការណ៍ទាំងអស់នេះ! ២៤ខ្ញុំសុំ

បញ្ជាក់ប្រាប់អ្នករាល់គ្នាថា មានព្យាការី និងស្ដេចជាច្រើន ចង់ឃើញហេតុការណ៍ដែលអ្នករាល់គ្នាឃើញនេះដែរ តែមិនបានឃើញ ហើយគេចង់ឮសេចក្ដីដែលអ្នករាល់គ្នាបានឮនេះដែរ តែមិនបានឮសោះ»។

## ពាក្យប្រស្នាអំពីអ្នកស្រុកសាម៉ារីម្នាក់មានចិត្តសប្បុរស

[២៥]ពេលនោះ មានធម្មាចារ្យម្នាក់ក្រោកឈរទូលសួរព្រះយេស៊ូ
ក្នុងគោលបំណងចង់ចាប់កំហុសព្រះអង្គថា៖ «លោកគ្រូ! តើខ្ញុំត្រូវ
ធ្វើអ្វីខ្លះ ដើម្បីឲ្យបានទទួលជីវិតអស់កល្បជានិច្ច?»។ [២៦]ព្រះយេស៊ូ
មានព្រះបន្ទូលទៅគាត់ថា៖ «តើក្នុងធម្មវិន័យមានចែងទុកមក
ដូចម្ដេចខ្លះ? ពេលលោកអាន តើលោកយល់យ៉ាងណា?»។
[២៧]គាត់ទូលឆ្លើយទៅព្រះយេស៊ូថា៖ «ត្រូវស្រឡាញ់ព្រះអម្ចាស់



ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីកម្លាំង
និងអស់ពីប្រាជ្ញា ហើយត្រូវស្រឡាញ់បងប្អូនឯទៀតៗ ឲ្យបាន

ដូចស្រឡាញ់ខ្លួនឯងដែរ»[ឆ]។ ២៨ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់
ថា៖ «លោកឆ្លើយត្រឹមត្រូវល្អណាស់ សុំធ្វើដូច្នេះទៅ នោះលោក
នឹងមានជីវិតអស់កល្បជាមិនខាន»។ ២៩ប៉ុន្តែធម្មាចារ្យនោះចង់
បង្ហាញថា សំណួររបស់គាត់ជាសំណួរត្រឹមត្រូវ គាត់ក៏សួរព្រះ
យេស៊ូទៀតថា៖ «តើនរណាជាបងប្អូនរបស់ខ្ញុំ?»។ ៣០ព្រះយេស៊ូ
មានព្រះបន្ទូលថា៖ «មានបុរសម្នាក់ធ្វើដំណើរចុះពីក្រុងយេរូសាឡឹម
ឆ្ពោះទៅក្រុងយេរីខូ។ គាត់ធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ពួកចោរ
វាប្លន់គាត់ថែមទាំងវាយដំគាត់ឲ្យរបួសជាទម្ងន់ រួចនាំគ្នារត់បាត់
អស់ទៅ ទុកគាត់ចោលនៅស្ដូកស្ដឹងបាត់ស្មារតីមិនដឹងខ្លួន។ ៣១ពេល
នោះមានបូជាចារ្យ *មួយរូប ធ្វើដំណើរចុះតាមផ្លូវនោះ។ គាត់
ឃើញបុរសនោះ ក៏ដើរវាងហួសទៅ។ ៣២មានម្នាក់ពីក្រុមលេវី*
ដើរមកដល់កន្លែងនោះដែរ។ គាត់ឃើញបុរសនោះ ក៏ដើរវាង
ហួសទៅ។ ៣៣គាប់ជួនជាមានអ្នកស្រុកសាម៉ារីម្នាក់ធ្វើដំណើរមក
តាមផ្លូវនោះដែរ គាត់ឃើញបុរសនោះ គាត់មានចិត្តអាណិត
អាសូរពន់ពេកណាស់។ ៣៤គាត់ចូលទៅជិតអ្នករបួស យកប្រេង
និងស្រាចាក់ពីលើមុខរបួស រុំរបួសឲ្យ រួចគាត់លើកអ្នករបួស
ដាក់លើជំនិះរបស់គាត់ នាំទៅផ្ទះសំណាក់ ហើយថែទាំអ្នករបួស
នោះ។ ៣៥ស្អែកឡើង គាត់យកប្រាក់ប្រគល់ឲ្យម្ចាស់ផ្ទះសំណាក់
ទាំងផ្ដាំថា "សូមថែទាំបុរសនេះផង ប្រសិនបើអ្នកចំណាយលើស
ពីប្រាក់នេះ ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំនឹងជូនបង្គ្រប់"។ ៣៦ក្នុង
ចំណោមមនុស្សទាំងបីនាក់ តើលោកយល់ថា អ្នកណាចាត់ទុក
ខ្លួនជាបងប្អូននឹងបុរស ដែលធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ពួក
ចោរប្លន់នោះ?»។ ៣៧ធម្មាចារ្យ *ឆ្លើយថា៖ «គឺអ្នកដែលមានចិត្ត
មេត្តាករុណាចំពោះគាត់»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖
«សុំលោកអញ្ជើញទៅចុះ ហើយប្រព្រឹត្តឲ្យបានដូចអ្នកនោះទៅ»។

**ឆ**, សូមអាន ទុតិយកថា ៦,៥ ; លេវីវិន័យ ១៩,១៨។

## ព្រះយេស៊ូគង់នៅផ្ទះនាងម៉ាថា និងនាងម៉ារី

[38]កាលព្រះយេស៊ូធ្វើដំណើរជាមួយពួកសាវ័ក ព្រះអង្គយាង
ចូលក្នុងភូមិមួយ។ មានស្ត្រីម្នាក់ឈ្មោះម៉ាថា បានទទួលព្រះអង្គ
ឲ្យស្នាក់ក្នុងផ្ទះនាង។ [39]នាងមានប្អូនស្រីម្នាក់ឈ្មោះម៉ារី អង្គុយ
នៅទៀបព្រះបាទាព្រះអម្ចាស់* ស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គ។
[40]រីឯនាងម៉ាថាវិញ នាងមានកិច្ចការរវល់ជាច្រើន ដើម្បីបម្រើ
ព្រះអង្គ។ នាងចូលមកទូលថា៖ «បពិត្រព្រះអម្ចាស់! ប្អូនខ្ញុំម្ចាស់
ទុកឲ្យខ្ញុំម្ចាស់បម្រើព្រះអង្គតែម្នាក់ឯង តើព្រះអង្គមិនអើពើទេឬ?
សូមទ្រង់ប្រាប់ឲ្យនាងមកជួយខ្ញុំម្ចាស់ផង»។ [41]ព្រះអម្ចាស់មាន
ព្រះបន្ទូលទៅនាងថា៖ «ម៉ាថា! ម៉ាថាអើយ! នាងមានកង្វល់
ហើយរវល់នឹងកិច្ចការច្រើនណាស់ [42]ប៉ុន្តែ មានកិច្ចការតែមួយ
គត់ដែលចាំបាច់ ម៉ារីបានជ្រើសយកចំណែកដ៏ល្អវិសេសនោះ
ហើយ មិនត្រូវយកចេញពីនាងទេ»។

## ព្រះយេស៊ូបង្រៀនសាវ័កអំពីរបៀបអធិដ្ឋាន*

(ម៉ាថាយ ៦, ៩-១៣ និង ៧, ៧-១១)

# ១១

[1]មានមួយថ្ងៃ ព្រះយេស៊ូអធិដ្ឋាននៅកន្លែងមួយ។
កាលព្រះអង្គអធិដ្ឋានរួចហើយ មានសាវ័ក*
ម្នាក់ទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! សូមបង្រៀនយើងខ្ញុំ
ឲ្យចេះអធិដ្ឋានដូចលោកយ៉ូហានបានបង្រៀនសិស្សរបស់លោក
នោះផង»។ [2]ព្រះយេស៊ូមានព្រះបន្ទូលទៅពួកគេថា៖

«ពេលអ្នករាល់គ្នាអធិដ្ឋាន ត្រូវពោលថា៖
ឱព្រះបិតាអើយ សូមសម្ដែងព្រះបារមី
ឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ

សូមឲ្យព្រះរាជ្យ *ព្រះអង្គបានមកដល់។
៣ សូមប្រទានអាហារដែលយើងខ្ញុំត្រូវការ
ជារៀងរាល់ថ្ងៃ។
៤ សូមអត់ទោសយើងខ្ញុំឲ្យរួចពីបាប
ដ្បិតយើងខ្ញុំអត់ទោសឲ្យអស់អ្នកដែល
បានប្រព្រឹត្តខុសនឹងយើងខ្ញុំ។
សូមកុំបណ្ដោយឲ្យយើងខ្ញុំចាញ់
ការល្បួងឡើយ»។

៥ព្រះអង្គមានព្រះបន្ទូលទៅគេទៀតថា៖ «ក្នុងចំណោមអ្នក
រាល់គ្នា បើម្នាក់មានមិត្តសម្លាញ់មករកទាំងពាក់កណ្ដាលអធ្រាត្រ
ហើយពោលថា "សម្លាញ់អើយ! ឲ្យគ្នាខ្ចីនំបុ័ងបីដុំសិនមក ៦ព្រោះ
មានមិត្តភក្ដិទើបនឹងធ្វើដំណើរមកដល់ ហើយគ្មានអ្វីទទួលគេ
សោះ"។ ៧អ្នកនៅក្នុងផ្ទះឆ្លើយមកវិញថា "កុំរំខានគ្នាធ្វើអ្វី គ្នាបាន
ខ្ទាស់ទ្វារទៅហើយ ម៉្យាងទៀត កូនចៅគ្នាកំពុងដេកលក់ គ្នាមិន
អាចក្រោកទៅយកនំបុ័ងឲ្យសម្លាញ់ឯងបានទេ"។ ៨ខ្ញុំសុំប្រាប់
អ្នករាល់គ្នាថា ម្ចាស់ផ្ទះប្រាកដជាក្រោកទៅយកនំបុ័ងព្រមទាំង
អ្វីៗ ដែលមិត្តសម្លាញ់របស់គាត់ត្រូវការមិនខាន។ គាត់ក្រោក
ទៅយកដូច្នេះ មិនមែនមកពីគាត់យោគយល់មិត្តសម្លាញ់ទេ គឺ
មកពីមិត្តសម្លាញ់នោះចេះតែរំខានមិនឈប់។ ៩រីឯខ្ញុំវិញ ខ្ញុំសុំ
ប្រាប់អ្នករាល់គ្នាថា ចូរសូមនោះព្រះជាម្ចាស់នឹងប្រទានឲ្យ ចូរ
ស្វែងរកគង់តែនឹងឃើញ ចូរគោះទ្វារ នោះព្រះអង្គនឹងបើកឲ្យ
អ្នករាល់គ្នាជាពុំខាន ១០ដ្បិតអ្នកណាសូម អ្នកនោះរមែងតែងតែ
ទទួល អ្នកណាស្វែងរករមែងតែងតែឃើញ ហើយគេតែងតែ
បើកទ្វារឲ្យអ្នកដែលគោះ។ ១១ក្នុងចំណោមអ្នករាល់គ្នា បើកូនសុំ
ត្រីមិនដែលមានឪពុកណាយកពស់អសិរពិសឲ្យវាទេ ១២បើកូន

សុំពងមាន់ ក៏មិនដែលមានឪពុកណាយកខ្យាដំរីឲ្យវាដែរ។ ១៣សូម្បី
តែអ្នករាល់គ្នាដែលជាមនុស្សអាក្រក់ ក៏ចេះឲ្យរបស់ល្អៗទៅកូន
ចុះចំណង់បើព្រះបិតាដែលគង់នៅស្ថានបរមសុខ * តើព្រះអង្គនឹង
ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ *ឲ្យអស់អ្នកដែលទូលសូមពីព្រះអង្គ
យ៉ាងណាទៅទៀត»។

## ព្រះយេស៊ូឆ្លើយតបនឹងពួកអ្នកចោទប្រកាន់ព្រះអង្គ

(ម៉ាថាយ ១២,២២-៣០,៤៣-៤៥ ម៉ាកុស ៣,២០-២៧)

១៤ព្រះយេស៊ូកំពុងបណ្ដេញខ្មោចចេញពីមនុស្សគម្នាក់។ លុះ
ខ្មោចចេញផុតទៅ មនុស្សគនោះនិយាយបាន ហើយមហាជន
ក៏ស្ងើចសរសើរក្រៃលែង។ ១៥ប៉ុន្តែ មានអ្នកខ្លះនិយាយថា៖ «អ្នក
នេះដេញខ្មោចបានដូច្នេះ ព្រោះបេលសេប៊ូលជាស្ដេចខ្មោចបាន
ប្រគល់អំណាចឲ្យគាត់»។ ១៦មានអ្នកខ្លះទៀតចង់ចាប់កំហុស
ព្រះអង្គ ក៏សូមឲ្យព្រះអង្គសម្តែងទីសម្គាល់មួយបញ្ជាក់ថា ព្រះអង្គ
បានទទួលអំណាចមកពីព្រះជាម្ចាស់។ ១៧ព្រះយេស៊ូឈ្វេងយល់
ចិត្តគំនិតរបស់គេ ទ្រង់មានព្រះបន្ទូលទៅគេថា៖ «នគរណាក៏
ដូចជានគរណាដែរ ប្រសិនបើពលរដ្ឋបាក់បែកទាស់ទែងគ្នាឯង
នគរនោះមុខជាត្រូវវិនាស ហើយផ្ទះទាំងប៉ុន្មានមុខជារលំសង្កត់
លើគ្នាមិនខាន។ ១៨យ៉ាងណាមិញ ប្រសិនបើមារសាតាំង *បាក់
បែកទាស់ទែងគ្នាឯង ធ្វើម្ដេចនឹងឲ្យរាជ្យរបស់វានៅស្ថិតស្ថេរបាន!
ខ្ញុំនិយាយដូច្នេះ ព្រោះអ្នករាល់គ្នាថា ខ្ញុំដេញខ្មោចដោយអំណាច
បេលសេប៊ូល។ ១៩ប្រសិនបើខ្ញុំដេញខ្មោចដោយអំណាចបេល
សេប៊ូលមែន តើកូនចៅរបស់អ្នករាល់គ្នាដេញខ្មោចដោយអំណាច
នរណាវិញ?។ ដូច្នេះ កូនចៅរបស់អ្នករាល់គ្នានឹងដាក់ទោស

អ្នករាល់គ្នា។ ²⁰ផ្ទុយទៅវិញ បើខ្ញុំដេញខ្មោច ដោយឫទ្ធានុភាព
របស់ព្រះជាម្ចាស់ នោះបានសេចក្ដីថា ព្រះរាជ្យ *របស់ព្រះអង្គ
មកដល់អ្នករាល់គ្នាហើយ។ ²¹បើមនុស្សណាម្នាក់ខ្លាំងពូកែ មាន
អាវុធការពារផ្ទះរបស់ខ្លួន ទ្រព្យសម្បត្តិរបស់គេនឹងបានគង់វង្ស។
²²ប៉ុន្តែ បើមានម្នាក់ទៀតខ្លាំងពូកែជាង មកវាយយកជ័យជម្នះ
បាន គេនឹងដកហូតគ្រឿងអាវុធ ព្រមទាំងរឹបអូសទ្រព្យសម្បត្តិ
ពីអ្នកនោះ យកទៅចែកឲ្យអ្នកផ្សេងថែមទៀតផង។ ²³អ្នកណា
មិននៅខាងខ្ញុំ អ្នកនោះប្រឆាំងនឹងខ្ញុំ ហើយអ្នកណាមិនជួយ
ប្រមូលផ្ដុំជាមួយខ្ញុំទេ អ្នកនោះជាអ្នកកម្ចាត់កម្ចាយ។ ²⁴កាល
បើខ្មោចចេញពីមនុស្សណាម្នាក់ហើយ វាតែងស្វែងរកទីជម្រក
នៅវាលហួតហែង តែប្រសិនបើវារកពុំឃើញទេនោះ វាមុខជា
និយាយថា "អញនឹងវិលត្រឡប់ទៅផ្ទះ ដែលអញទើបនឹងចេញ
មក"។ ²⁵លុះទៅដល់ឃើញផ្ទះនោះបោសស្អាត ហើយតុបតែង
ល្អ ²⁶វានឹងចេញទៅបបួលខ្មោចប្រាំពីរទៀត ដែលសុទ្ធតែអាក្រក់
ជាងវា មកចូលអ្នកនោះ បណ្ដាលឲ្យគាត់រឹងរឹតតែអាក្រក់លើស
ដើមទៅទៀត»។

## សុភមង្គលដ៏ពិតប្រាកដ

²⁷កាលព្រះយេស៊ូកំពុងតែមានព្រះបន្ទូលដូច្នេះ មានស្ត្រីម្នាក់
បន្លឺសំឡេងចេញពីចំណោមបណ្ដាជន ទូលព្រះអង្គថា៖ «ស្ត្រី
ដែលបានបង្កើតលោក ព្រមទាំងបានបំបៅលោក ពិតជាមាន
សុភមង្គល *មែន!»។ ²⁸ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលតបថា៖
«អ្នកណាស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអនុវត្តតាម
គឺអ្នកនោះហើយដែលមានសុភមង្គលពិតមែន»។

## ទីសម្គាល់របស់លោកយ៉ូណាស

(ម៉ាថាយ ១២, ៣៨-៤២)

២៩ខណៈនោះ មហាជនប្រជុំគ្នាយ៉ាងច្រើនកុះករ ព្រះអង្គ
មានព្រះបន្ទូលថា៖ «មនុស្សជំនាន់នេះអាក្រក់ណាស់ គេចង់តែ
ឃើញទីសម្គាល់ដ៏អស្ចារ្យ ប៉ុន្តែ ព្រះជាម្ចាស់មិនប្រទានទីសម្គាល់
ណាផ្សេង ក្រៅពីទីសម្គាល់របស់ព្យាការី*យ៉ូណាសឡើយ។
៣០លោកយ៉ូណាសបានធ្វើជាទីសម្គាល់ឲ្យអ្នកក្រុងនីនីវេឃើញ
យ៉ាងណា[ឃ] បុត្រមនុស្សក៏នឹងធ្វើជាទីសម្គាល់ឲ្យមនុស្សជំនាន់
នេះ ឃើញយ៉ាងនោះដែរ។ ៣១នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យ
ទោសមនុស្សលោក មហាក្សត្រីយ៍ស្រុកខាងត្បូងនឹងក្រោកឡើង
ជាមួយមនុស្សជំនាន់នេះ ព្រមទាំងចោទប្រកាន់គេផង ព្រោះ
កាលពីជំនាន់ដើម ព្រះនាងបានយាងមកពីតំបន់ដាច់ស្រយាល
នៃផែនដី ដើម្បីស្ដាប់ព្រះបន្ទូលរបស់ស្ដេចសាឡូម៉ូនដែលប្រកប
ដោយប្រាជ្ញាឈ្លាសវៃ[ង]។ រីឯនៅទីនេះមានម្នាក់ប្រសើរលើស
ស្ដេចសាឡូម៉ូនទៅទៀត។ ៣២នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យ
ទោសមនុស្សលោក អ្នកក្រុងនីនីវេនឹងក្រោកឡើងជាមួយមនុស្ស
ជំនាន់នេះ ព្រមទាំងចោទប្រកាន់ពួកគេផង ព្រោះកាលពីជំនាន់
ដើម អ្នកក្រុងនីនីវេបានប្រែចិត្តគំនិត[ច] នៅពេលឮសេចក្ដីដែល
លោកយ៉ូណាសប្រកាស។ រីឯនៅទីនេះមានម្នាក់ប្រសើរលើស
លោកយ៉ូណាសទៅទៀត!»។

---

**ឃ**, នៅខ៣២មានពន្យល់ថាលោកយ៉ូណាសជាទីសម្គាល់សម្រាប់អ្នកក្រុងនីនីវេតាមរយៈសេចក្ដីដែលលោកប្រកាសអំពីការវិនិច្ឆ័យទោសក្រុងនោះ (យ៉ូណាស៣, ៣-៤)។ • **ង**, ១ពង្សាវតារក្សត្រ១០,១-១៣។ • **ច**, យ៉ូណាស ៣,៥-១០។

## ពាក្យប្រស្នាស្ដីអំពីចង្កៀង

(ម៉ាថាយ ៥, ១៥,៦, ២២-២៣)

៣៣«ពុំដែលមាននរណាអុជចង្កៀង យកទៅលាក់ទុក ឬយក
ធុងគ្របពីលើឡើយ។ គេតែងយកចង្កៀងទៅដាក់លើជើងចង្កៀង
ដើម្បីបំភ្លឺអស់អ្នកដែលចូលទៅក្នុងផ្ទះ។ ៣៤ភ្នែកជាចង្កៀងរបស់
រូបកាយ បើភ្នែកអ្នកនៅភ្លឺល្អ រូបកាយអ្នកទាំងមូលក៏ភ្លឺដែរ តែ
បើភ្នែកអ្នកងងឹតវិញ រូបកាយអ្នកក៏ងងឹតដែរ។ ៣៥ហេតុនេះ ត្រូវ
ប្រយ័ត្នកុំឲ្យពន្លឺនៅក្នុងខ្លួនអ្នកត្រឡប់ទៅជាភាពងងឹតឡើយ។
៣៦ប្រសិនបើរូបកាយរបស់អ្នកទាំងមូលមានពន្លឺ ឥតងងឹតត្រង់
ណាទេនោះ រូបកាយរបស់អ្នកទាំងមូលនឹងភ្លឺចិញ្ចែងចិញ្ចាច ដូច
ចង្កៀងបំភ្លឺអ្នកដែរ»។

## ពុតត្បុតរបស់ពួកធម្មាចារ្យ និងពួកខាងគណៈផារីស៊ី

(ម៉ាថាយ ២៣, ១-៣៦ ម៉ាកុស ១២, ៣៨-៤០)

៣៧កាលព្រះយេស៊ូកំពុងតែមានព្រះបន្ទូល មានបុរសម្នាក់
ខាងគណៈផារីស៊ី * បានសូមយាងព្រះអង្គទៅសោយព្រះស្ងោយ
នៅផ្ទះគាត់។ ព្រះអង្គក៏យាងចូលទៅរួមតុជាមួយគាត់។ ៣៨អ្នក
ខាងគណៈផារីស៊ីនោះងឿងឆ្ងល់ក្រៃលែង ព្រោះឃើញព្រះយេស៊ូ
មិនលាងព្រះហស្ដមុនពេលសោយ។

៣៩ព្រះអម្ចាស់ក៏មានព្រះបន្ទូលទៅគាត់ថា៖ «ពួកអ្នកខាង
គណៈផារីស៊ីអើយ អ្នករាល់គ្នាសម្អាតពែង និងចានតែផ្នែកខាង
ក្រៅប៉ុណ្ណោះ ប៉ុន្តែផ្នែកខាងក្នុងរបស់អ្នករាល់គ្នា ពោរពេញទៅ
ដោយចិត្តកេងប្រវ័ញ្ច និងគំនិតអាក្រក់។ ៤០មនុស្សឆោតល្ងង់អើយ!

ព្រះជាម្ចាស់បានបង្កើតខាងក្រៅ តើព្រះអង្គមិនបានបង្កើតខាង
ក្នុងដែរទេឬ? ៤១ចូរយកអ្វីៗនៅក្នុងចានធ្វើទានដល់ជនក្រីក្រទៅ
នោះប្រដាប់ប្រដាទាំងអស់នឹងបានស្អាតបរិសុទ្ធ* សម្រាប់ឲ្យ
អ្នករាល់គ្នាប្រើប្រាស់[ឆ]។

៤២ពួកផារីស៊ីអើយ អ្នករាល់គ្នានឹងត្រូវវេទនាជាមិនខាន ព្រោះ
អ្នករាល់គ្នាយកជីរអង្កាម ជីរលីងល័ខ និងបន្លែគ្រប់មុខ មួយភាគ
ដប់មកថ្វាយព្រះជាម្ចាស់ ប៉ុន្តែ អ្នករាល់គ្នាធ្វេសប្រហែសមិនបាន
ប្រព្រឹត្តតាមសេចក្តីសុចរិត* ហើយមិនបានស្រឡាញ់ព្រះអង្គឡើយ
គឺការនេះហើយដែលអ្នករាល់គ្នាត្រូវប្រព្រឹត្ត ឯការដទៃទៀត ក៏
អ្នករាល់គ្នាមិនត្រូវបំភ្លេចចោលដែរ។

៤៣ពួកផារីស៊ីអើយ! អ្នករាល់គ្នាត្រូវវេទនាជាមិនខាន ព្រោះ
អ្នករាល់គ្នាចូលចិត្តអង្គុយនៅកន្លែងកិត្តិយសក្នុងធម្មសាលា*
ហើយចូលចិត្តឲ្យគេឱនកាយគោរពអ្នករាល់គ្នានៅតាមផ្សារ។
៤៤អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាប្រៀបបាននឹង
ផ្នូរខ្មោច ដែលគេមើលមិនឃើញ ហើយត្រូវគេដើរជាន់ដោយ
មិនដឹងខ្លួន»។

៤៥មានធម្មាចារ្យម្នាក់ទូលព្រះអង្គថា៖ «លោកគ្រូ! លោកមាន
ប្រសាសន៍ដូច្នេះបានសេចក្តីថា លោកត្មះតិះដៀលយើងខ្ញុំ»។
៤៦ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ពួកធម្មាចារ្យអើយ អ្នករាល់
គ្នាក៏នឹងត្រូវវេទនាដែរ ព្រោះអ្នករាល់គ្នាបានបង្កើតវិន័យតឹងរឹង
យកមកផ្ទុកលើមនុស្ស ហើយអ្នករាល់គ្នាមិនជួយគេទេ សូម្បីតែ
បន្តិចក៏មិនជួយផង។ ៤៧អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះ
អ្នករាល់គ្នាបានសង់ផ្នូរឲ្យព្យាការី* ដែលបុព្វបុរស*របស់អ្នករាល់
គ្នាបានសម្លាប់។ ៤៨អ្នករាល់គ្នាធ្វើដូច្នេះ បញ្ជាក់ថាអ្នករាល់គ្នា
សមគំនិតនឹងអំពើដែលបុព្វបុរសរបស់អ្នករាល់គ្នាបានប្រព្រឹត្ត

**ឆ**, យើងអាចបកប្រែតាមរបៀបម៉្យាងទៀតថា:"ចូរធ្វើទានពីក្នុងចិត្តមកវិញនោះអ្វីៗទាំងអស់នឹងបាន ស្អាតបរិសុទ្ធសម្រាប់អ្នករាល់គ្នា"។

គឺគេបានសម្លាប់ពួកព្យាការី ហើយអ្នករាល់គ្នាបានសង់ផ្នូរ។ ⁴⁹ហេតុ
នេះហើយបានជាព្រះជាម្ចាស់ប្រកបដោយព្រះប្រាជ្ញាញាណមាន
ព្រះបន្ទូលថា "យើងនឹងចាត់ព្យាការី* ព្រមទាំងទូតរបស់យើង
ជាច្រើនឲ្យទៅរកគេ តែគេនឹងសម្លាប់ខ្លះ ព្រមទាំងបៀតបៀន
ខ្លះទៀតផង"។ ⁵⁰ដូច្នេះមនុស្សជំនាន់នេះនឹងត្រូវទទួលទោស
ពីព្រោះបុព្វបុរសរបស់គេ បានសម្លាប់ព្យាការី តាំងតែពីកំណើត
ពិភពលោកមក ⁵¹គឺចាប់តាំងពីលោកអបិល រហូតដល់លោក
សាការីដែលត្រូវគេសម្លាប់ នៅត្រង់ចន្លោះទីអាសនៈ និងទីសក្ការៈ។
ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា មនុស្សជំនាន់នេះនឹងត្រូវទទួល
ទោស ព្រោះតែឃាតកម្មទាំងនោះជាមិនខាន។
⁵²ពួកធម្មាចារ្យ*អើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះ
អ្នករាល់គ្នាបានបិទទ្វារមាគ៌ា មិនឲ្យគេចូលទៅស្គាល់ព្រះជាម្ចាស់។
អ្នករាល់គ្នាមិនត្រឹមតែមិនបានចូលខ្លួនឯងប៉ុណ្ណោះទេ គឺថែម
ទាំង ឃាត់អស់អ្នកដែលចង់ចូល មិនឲ្យគេចូលទៀតផង»។
⁵³ពេលព្រះយេស៊ូយាងចាកចេញពីទីនោះទៅ ពួកធម្មាចារ្យ
និងពួកខាងគណៈផារីស៊ី នាំគ្នាប្រឆាំងនឹងព្រះអង្គយ៉ាងខ្លាំង ហើយ
ដេញដោលសួរព្រះអង្គអំពីរឿងផ្សេងៗជាច្រើន ⁵⁴ដែលសុទ្ធសឹង
តែជាកលល្បិចរកចាប់កំហុសព្រះអង្គ។

## ព្រះយេស៊ូទូន្មានសាវ័កកុំឲ្យភ័យបារម្ភ

(ម៉ាថាយ ១០, ២៦-៣៣, ១៩-២០ និង ១២, ៣២)

**១២** ¹ខណៈនោះ មានមហាជនរាប់ម៉ឺននាក់ជួបជុំ
គ្នាណែនណាន់តាន់តាប់ ស្ទើរតែដើរជាន់គ្នា។
មុនដំបូង ព្រះយេស៊ូមានព្រះបន្ទូលទៅសាវ័ក*ថា៖ «ចូរអ្នករាល់

គ្នាប្រយ័ត្ននឹងមេម្សៅរបស់ពួកខាងគណៈផារីស៊ី គឺពុតត្បុតរបស់
គេ។ ២ការលាក់កំបាំងទាំងអស់នឹងត្រូវលាតត្រដាងឲ្យគេឃើញ
ហើយអាថ៌កំបាំងទាំងប៉ុន្មាន ក៏នឹងត្រូវបើកឲ្យគេដឹងដែរ។ ៣ហេតុ
នេះហើយបានជាអ្វីៗដែលអ្នករាល់គ្នានិយាយក្នុងទីងងឹត មុខជា
គេឮនៅក្នុងពន្លឺថ្ងៃ ហើយអ្វីៗដែលអ្នករាល់គ្នាខ្សឹបដាក់ត្រចៀក
នរណាម្នាក់នៅក្នុងបន្ទប់ មុខជាត្រូវអ្នកដទៃយកទៅប្រកាសយ៉ាង
ខ្លាំង នៅលើដំបូលផ្ទះមិនខាន។

៤ខ្ញុំសុំប្រាប់អ្នករាល់គ្នា ជាមិត្តសម្លាញ់របស់ខ្ញុំថា ចូរកុំខ្លាច
អស់អ្នកដែលសម្លាប់បានត្រឹមតែរូបកាយ ហើយមិនអាចធ្វើអ្វី
ដល់អ្នករាល់គ្នាថែមទៀតនោះឡើយ។ ៥ខ្ញុំសុំប្រាប់ឲ្យដឹងថា អ្នក
រាល់គ្នាត្រូវខ្លាចនរណា គឺត្រូវខ្លាចព្រះជាម្ចាស់ ដ្បិតព្រះអង្គមាន
អំណាចផ្ដាច់ជីវិត ហើយបោះទៅក្នុងភ្លើងនរកថែមទៀតផង។ មែន!
ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា គឺព្រះអង្គនេះហើយដែលអ្នករាល់គ្នា
ត្រូវខ្លាច។ ៦ធម្មតាគេលក់ចាបប្រាំថ្លៃពីរសេន ទោះបីថោកយ៉ាង
នេះក៏ដោយ ក៏ព្រះជាម្ចាស់ឥតភ្លេចចាបណាមួយសោះឡើយ។
៧សូម្បីតែសក់នៅលើក្បាលរបស់អ្នករាល់គ្នា ក៏ព្រះអង្គរាប់អស់
ដែរ។ ដូច្នេះកុំខ្លាចអ្វីឡើយ ព្រោះអ្នករាល់គ្នាមានតម្លៃលើសចាប
ជាច្រើនទៅទៀត។ ៨ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្នកណាទទួល
ស្គាល់ខ្ញុំ នៅចំពោះមុខមនុស្សលោក បុត្រមនុស្ស*នឹងទទួល
ស្គាល់អ្នកនោះ នៅចំពោះមុខពួកទេវទូត*របស់ព្រះជាម្ចាស់ដែរ។
៩រីឯអ្នកណាបដិសេធមិនទទួលស្គាល់ខ្ញុំនៅចំពោះមុខមនុស្សលោក
បុត្រមនុស្សក៏នឹងបដិសេធមិនទទួលស្គាល់អ្នកនោះ នៅចំពោះ
មុខពួកទេវទូតរបស់ព្រះជាម្ចាស់ដែរ។ ១០អ្នកណាពោលពាក្យ
ទាស់នឹងបុត្រមនុស្ស ព្រះជាម្ចាស់នឹងលើកលែងទោសឲ្យបាន
ប៉ុន្តែ អ្នកណាពោលពាក្យទាស់នឹងព្រះវិញ្ញាណដ៏វិសុទ្ធ* ព្រះអង្គ

មិនលើកលែងទោសឲ្យឡើយ។ ¹¹កាលណាគេបញ្ជូនអ្នករាល់
គ្នាទៅវិនិច្ឆ័យទោសក្នុងធម្មសាលា ឬនៅមុខចៅក្រម និងអ្នក
កាន់អំណាច មិនត្រូវភ័យបារម្ភអំពីរបៀបដែលអ្នករាល់គ្នាត្រូវ
ឆ្លើយការពារខ្លួន ឬសេចក្ដីដែលអ្នករាល់គ្នាត្រូវនិយាយនោះឡើយ
¹²ដ្បិតព្រះវិញ្ញាណដ៏វិសុទ្ធ នឹងបំភ្លឺអ្នករាល់គ្នាឲ្យដឹងសេចក្ដីដែល
ត្រូវនិយាយនៅពេលនោះឯង»។

## ប្រស្នាអំពីអ្នកមានដ៏ល្ងង់ម្នាក់

¹³ក្នុងចំណោមបណ្ដាជន មានបុរសម្នាក់ទូលព្រះយេស៊ូថា៖
«លោកគ្រូ! សូមលោកប្រាប់បងខ្ញុំ ឲ្យយកកេរមត៌កមកចែកខ្ញុំ
ផង»។ ¹⁴ព្រះយេស៊ូមានព្រះបន្ទូលតបទៅបុរសនោះថា៖ «តើ
នរណាបានតែងតាំងខ្ញុំឲ្យធ្វើជាចៅក្រមចែកទ្រព្យសម្បត្តិរបស់
អ្នករាល់គ្នា?»។ ¹⁵បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅបណ្ដា
ជនថា៖ «ចូរប្រយ័ត្នកុំលោភលន់ចង់បានទ្រព្យសម្បត្តិឲ្យសោះ។
ទោះបីមនុស្សមានសម្បត្តិបរិបូណ៌យ៉ាងណាក៏ដោយ ក៏ជីវិតគេ
មិនអាស្រ័យនៅលើទ្រព្យសម្បត្តិឡើយ»។ ¹⁶ព្រះអង្គមានព្រះ
បន្ទូលជាពាក្យប្រស្នាទៅគេថា៖ «មានបុរសម្នាក់ជាសេដ្ឋីដីធ្លីរបស់
គាត់ បានផ្ដល់ភោគផលយ៉ាងបរិបូណ៌។ ¹⁷គាត់រិះគិតក្នុងចិត្តថា
"ខ្ញុំគ្មានកន្លែងដាក់ភោគផលទាំងអស់របស់ខ្ញុំទេ តើខ្ញុំត្រូវធ្វើដូច
ម្ដេច?"។ ¹⁸គាត់គិតទៀតថា "ខ្ញុំត្រូវតែធ្វើយ៉ាងនេះ គឺរុះជង្រុក
ទាំងប៉ុន្មានរបស់ខ្ញុំចោល ហើយសង់ជង្រុកឲ្យធំៗជាង រួចខ្ញុំប្រមូល
ស្រូវ ព្រមទាំងភោគផលទាំងអស់ មកដាក់ក្នុងជង្រុកថ្មីនោះ។
¹⁹បន្ទាប់មក ខ្ញុំនឹងនិយាយប្រាប់ខ្លួនខ្ញុំថា ឱខ្ញុំអើយ! មានសម្បត្តិ
យ៉ាងច្រើនបរិបូណ៌ បម្រុងទុកចិញ្ចឹមជីវិតសម្រាប់ច្រើនឆ្នាំ ខ្ញុំត្រូវ

សម្រាកគិតតែស៊ីផឹកសប្បាយទៅ!"។ ២០ប៉ុន្តែ ព្រះជាម្ចាស់មាន
ព្រះបន្ទូលទៅកាន់សេដ្ឋីនោះថា៖ "នែ៎មនុស្សឆោតល្ងង់អើយ! យប់
នេះ យើងនឹងផ្ដាច់ជីវិតអ្នកហើយ ដូច្នេះ ទ្រព្យសម្បត្តិដែលអ្នក
បានប្រមូលទុកសម្រាប់ខ្លួនអ្នក នឹងបានទៅជារបស់នរណាវិញ?"។
២១អ្នកណាប្រមូលទ្រព្យសម្បត្តិទុកសម្រាប់តែខ្លួនឯង ហើយគ្មាន
សម្បត្តិសួគ៌នៅក្នុងខ្លួន អ្នកនោះប្រៀបបីដូចជាសេដ្ឋីនោះដែរ»។

## ត្រូវពឹងផ្អែកលើព្រះជាម្ចាស់ និងស្វែងរកសម្បត្តិសួគ៌

(ម៉ាថាយ ៦, ១៩-៣៤)

២២ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សាវ័ក*ថា៖ «ហេតុនេះ
ហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នា កុំឲ្យខ្វល់ខ្វាយអំពីម្ហូបអាហារ
សម្រាប់ចិញ្ចឹមជីវិត ឬអំពីសម្លៀកបំពាក់សម្រាប់បិទបាំងរូបកាយ
ឡើយ ២៣ដ្បិតជីវិតមានតម្លៃលើសម្ហូបអាហារ ហើយរូបកាយមាន
តម្លៃលើសសម្លៀកបំពាក់ទៅទៀត។ ២៤ចូរមើលក្អែក វាមិនដែល
សាបព្រោះ មិនដែលច្រូតកាត់ គ្មានឃ្លាំង គ្មានជង្រុកសោះ ប៉ុន្តែ
ព្រះជាម្ចាស់ចិញ្ចឹមវា រីឯអ្នករាល់គ្នាវិញ មានតម្លៃលើសបក្សា
បក្សីច្រើនណាស់។ ២៥ក្នុងចំណោមអ្នករាល់គ្នា ទោះបីខំខ្វល់ខ្វាយ
យ៉ាងណាក៏ដោយ ក៏គ្មាននរណាអាចនឹងបង្កើនអាយុរបស់ខ្លួនឲ្យ
វែងបានឡើយ សូម្បីតែបន្តិច ក៏មិនបានដែរ។ ២៦ដូច្នេះ បើអ្នករាល់
គ្នាពុំអាចសម្រេចការដ៏តូចបំផុតនេះបានផង ចុះហេតុ ដូចម្ដេច
បានជាខ្វល់ខ្វាយអំពីរឿងផ្សេងៗទៀត។ ២៧ចូរគិតមើល ផ្កាដុះ
ឡើងយ៉ាងណា វាមិនដែលនឿយហត់នឹងធ្វើការ ឬត្បាញរវៃ
ឡើយ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា សូម្បីតែព្រះបាទសាឡូម៉ូន
កាលពីជំនាន់ដែលទ្រង់មានសិរីរុងរឿងដ៏ប្រសើរបំផុតនោះ ក៏

ទ្រង់គ្មានព្រះភូសាល្អស្មើនឹងផ្កាមួយទងនេះផង។ ២៨មនុស្សមាន
ជំនឿតិចអើយ! ប្រសិនបើព្រះជាម្ចាស់ផ្ដល់សម្រស់ឲ្យផ្កាដែល
រីកនៅតាមវាលថ្ងៃនេះ ហើយស្អែកត្រូវគេដុតចោលយ៉ាងហ្នឹង
ទៅហើយ តើព្រះអង្គនឹងទំនុកបម្រុងអ្នករាល់គ្នាលើសនេះយ៉ាង
ណាទៅទៀត? ២៩ដូច្នេះ ចូរអ្នករាល់គ្នា កុំគិតតែពីស្វែងរកគ្រឿង
បរិភោគនោះឡើយ ៣០ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះ ដែល
ខំស្វះស្វែងរករបស់ទាំងនោះ។ រីឯអ្នករាល់គ្នាវិញ ព្រះបិតារបស់
អ្នករាល់គ្នា ទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ។ ៣១ចូរខំ
ស្វែងរកព្រះរាជ្យ*របស់ព្រះជាម្ចាស់វិញ ទើបព្រះអង្គប្រទានរបស់
ទាំងនោះ មកអ្នករាល់គ្នាថែមទៀតផង»។

៣២«កុំខ្លាចអីក្រុមដ៏តូចរបស់ខ្ញុំអើយ! ព្រះបិតារបស់អ្នករាល់
គ្នា សព្វព្រះហឫទ័យប្រទានព្រះរាជ្យមកឲ្យអ្នករាល់គ្នាហើយ។
៣៣ចូរលក់ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នា យកប្រាក់ចែកជាទាន
ដល់ជនក្រីក្រចុះ។ ចូរប្រមូលទ្រព្យដែលមិនចេះពុក ជាសម្បត្តិ
ដែលមិនចេះរលាយ ទុកសម្រាប់ខ្លួននៅស្ថានបរមសុខ* ជាស្ថាន
ដែលគ្មានចោរប្លន់ ឬកណ្ដៀរស៊ីឡើយ។ ៣៤ទ្រព្យសម្បត្តិរបស់អ្នក
រាល់គ្នានៅកន្លែងណា ចិត្តរបស់អ្នករាល់គ្នា ក៏នៅកន្លែងនោះដែរ»។

## ការប្រុងប្រៀបខ្លួន

៣៥«ចូរប្រុងប្រៀបខ្លួន ហើយទុកឲ្យចង្កៀងរបស់អ្នករាល់គ្នា
នៅឆេះ។ ៣៦ចូរប្រព្រឹត្តឲ្យបានដូចពួកអ្នកបម្រើ ដែលរង់ចាំម្ចាស់
វិលត្រឡប់មកពីជប់លៀងវិញ គឺនៅពេលមកដល់លោកគោះ
ទ្វារ អ្នកបម្រើទៅបើកជូនភ្លាម។ ៣៧ពេលម្ចាស់ត្រឡប់មកដល់
ឃើញអ្នកបម្រើណានៅរង់ចាំលោក អ្នកបម្រើនោះមានសុភមង្គល

ហើយ។ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា លោកនឹងឲ្យអ្នក
បម្រើអង្គុយបរិភោគ ហើយលោករៀបចំខ្លួនបម្រើគេវិញ។ [៣៨]បើ
លោកវិលមកវិញនៅពាក់កណ្ដាលអធ្រាត្រ ឬជិតភ្លឺ ហើយឃើញ
អ្នកបម្រើទាំងនោះនៅរង់ចាំដូច្នេះ ពួកគេប្រាកដជាមានសុភមង្គល។
[៣៩]អ្នករាល់គ្នាដឹងហើយថា បើម្ចាស់ផ្ទះដឹងចោរចូលមកប្លន់ថ្មើរ
ណា គាត់នឹងមិនបណ្ដោយឲ្យវាចូលមកក្នុងផ្ទះគាត់បានឡើយ។
[៤០]រីឯអ្នករាល់គ្នាវិញ ចូរត្រៀមខ្លួនជានិច្ច ដ្បិតបុត្រមនុស្ស*នឹង
មកដល់ នៅវេលាដែលអ្នករាល់គ្នាពុំបានគិត»។

## ប្រស្នាអំពីអ្នកបម្រើស្មោះត្រង់ និងអ្នកបម្រើមិនស្មោះត្រង់

(ម៉ាថាយ ២៤,៤៥-៥១)

[៤១]លោកសិលាទូលសួរព្រះយេស៊ូថា៖ «បពិត្រព្រះអម្ចាស់!
តើព្រះអង្គមានព្រះបន្ទូលជាពាក្យប្រស្នានេះ សម្រាប់ប្រៀនប្រដៅ
យើងខ្ញុំតែប៉ុណ្ណោះ ឬមួយសម្រាប់ប្រៀនប្រដៅមនុស្សគ្រប់ៗ
រូប ដែរ?»។ [៤២]ព្រះអម្ចាស់មានព្រះបន្ទូលតបថា៖ «បើអ្នកបម្រើ
ណា មានចិត្តស្មោះត្រង់ ហើយប៉ិនប្រសប់ ម្ចាស់មុខជាផ្ទុកផ្ដាក់
ឲ្យគាត់មើលខុសត្រូវលើអ្នកបម្រើឯទៀតៗ ក្នុងការចែកម្ហូបអាហារ
ឲ្យគេ តាមពេលកំណត់ជាមិនខាន។ [៤៣]ពេលម្ចាស់ត្រឡប់មក
ដល់ផ្ទះវិញ ឃើញអ្នកបម្រើកំពុងបំពេញកិច្ចការរបស់ខ្លួនដូច្នេះ
អ្នកបម្រើនោះប្រាកដជាមានសុភមង្គល។ [៤៤]ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា ម្ចាស់មុខជាផ្ទុកផ្ដាក់ឲ្យគាត់មើលខុសត្រូវ
លើទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់លោកថែមទៀតផង។ [៤៥]ផ្ទុយ
ទៅវិញ ប្រសិនបើអ្នកបម្រើនឹកក្នុងចិត្តថា "ម្ចាស់អញក្រមកដល់
ណាស់" គាត់ក៏វាយអ្នកបម្រើទាំងប្រុសទាំងស្រីឯទៀតៗ ហើយ

ស៊ីផឹកស្រវឹង។ ៤៦ពេលម្ចាស់វិលត្រឡប់មកដល់ផ្ទះវិញ នៅថ្ងៃ
ដែលអ្នកបម្រើនោះមិនបានរង់ចាំ ឬនៅពេលដែលគាត់មិនដឹង
លោកនឹងធ្វើទោសគាត់ជាទម្ងន់ ហើយឲ្យគាត់ទទួលទោសរួម
ជាមួយពួកអ្នកមិនជឿដែរ។

៤៧អ្នកបម្រើណាស្គាល់ចិត្តម្ចាស់ តែមិនបានត្រៀមខ្លួន ហើយ
មិនធ្វើតាមចិត្តលោក អ្នកបម្រើនោះនឹងត្រូវរំពាត់យ៉ាងច្រើន។
៤៨ផ្ទុយទៅវិញ អ្នកបម្រើណាមិនស្គាល់ចិត្តម្ចាស់របស់ខ្លួន ហើយ
ប្រព្រឹត្តខុសឆ្គងសមនឹងទទួលទោស អ្នកបម្រើនោះនឹងត្រូវរំពាត់
តែបន្តិចទេ។ បើគេឲ្យអ្វីច្រើនទៅអ្នកណា គេនឹងទារពីអ្នកនោះ
វិញច្រើនដែរ។ បើគេផ្ទុកផ្ដាក់កិច្ចការច្រើនដល់អ្នកណា គេនឹង
ទារពីអ្នកនោះវិញរឹងរឹតតែច្រើនថែមទៀត»។

## ការបាក់បែកគ្នាព្រោះជំនឿ

(ម៉ាថាយ ១០, ៣៤-៣៦)

៤៩«ខ្ញុំមកដើម្បីនាំភ្លើងមកផែនដី។ ប្រសិនបើភ្លើងនោះឆេះ
ខ្ញុំស្ងប់ចិត្តហើយ[ខ]។ ៥០ខ្ញុំត្រូវទទួលពិធីជ្រមុជ[ឈ]ម្យ៉ាង។ ខ្ញុំតានតឹង
ក្នុងចិត្តក្រៃលែង ចង់តែឲ្យពិធីនោះបានសម្រេចឆាប់ៗ។ ៥១កុំនឹក
ស្មានថា ខ្ញុំមកដើម្បីផ្ដល់សន្តិភាពឲ្យផែនដីនេះឡើយ គឺខ្ញុំបាន
នាំការបាក់បែកមកទេតើ។ ៥២ចាប់ពីពេលនេះតទៅ ឧបមាថា
ក្នុងផ្ទះមួយមានគ្នាប្រាំនាក់ អ្នកទាំងប្រាំនឹងត្រូវបាក់បែកគ្នា គឺបី
នាក់បែកចេញពីពីរនាក់ ពីរនាក់បែកចេញពីបីនាក់ ៥៣ឪពុកនឹង
បែកចេញពីកូនប្រុស កូនប្រុសបែកចេញពីឪពុកម្ដាយ បែកចេញ

**ខ**, យើងអាចបកប្រែម្យ៉ាងទៀតថា: «ខ្ញុំមិនប្រាថ្នាអ្វីក្រៅពីចង់ឲ្យភ្លើងនោះបានឆេះរួចស្រេចនោះទេ»។
• **ឈ**, សម្រាប់ជនជាតិយូដាពិធីជ្រមុជទឹកជាពិធីមួយដែលគេធ្វើឡើង ដើម្បីឲ្យខ្លួនបានបរិសុទ្ធ។ ពិធីជ្រមុជក្នុង អត្ថបទនេះព្រះយេស៊ូចង់មានព្រះបន្ទូលអំពីការសោយទិវង្គតរបស់ព្រះអង្គ ដើម្បីប្រោសមនុស្សឲ្យបានបរិសុទ្ធរួចពីបាប។

ពីកូនស្រី កូនស្រីបែកចេញពីម្ដាយ ម្ដាយក្មេកបែកចេញពីកូនប្រសាស្រី កូនប្រសាស្រីបែកចេញពីម្ដាយក្មេក»។

## ត្រូវយល់ហេតុការណ៍ផ្សេងៗ

(ម៉ាថាយ១៦, ២-៣)

[៥៤]ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់មហាជនទៀតថា៖ «កាលណាអ្នករាល់គ្នាឃើញពពករសាត់ពីទិសខាងលិចមក អ្នករាល់គ្នាពោលភ្លាមថា ជិតភ្លៀងហើយ ហើយក៏ភ្លៀងមែន។ [៥៥]កាលណាមានខ្យល់បក់ពីទិសខាងត្បូង អ្នករាល់គ្នាថា មុខជាក្ដៅហើយ ហើយក៏ក្ដៅមែន។ [៥៦]មនុស្សមានពុតអើយ! អ្នករាល់គ្នាចេះយល់ហេតុការណ៍ផ្សេងៗនៅលើផែនដី និងនៅលើមេឃបាន ចុះហេតុដូចម្ដេចបានជាពុំយល់ហេតុការណ៍នាសម័យបច្ចុប្បន្ននេះផង?»។

## ត្រូវសម្រុះសម្រួលរឿងរ៉ាវ មុនថ្ងៃព្រះជាម្ចាស់វិនិច្ឆ័យទោស

(ម៉ាថាយ ៥, ២៥-២៦)

[៥៧]«ហេតុអ្វីបានជាអ្នករាល់គ្នាមិនពិចារណាដោយខ្លួនឯង នូវអំពើសុចរិតដែលអ្នករាល់គ្នាត្រូវប្រព្រឹត្ត? [៥៨]ប្រសិនបើអ្នកធ្វើដំណើរទៅតុលាការជាមួយគូវិវាទ នៅតាមផ្លូវអ្នកត្រូវខំសម្រុះសម្រួលជាមួយអ្នកនោះឲ្យហើយទៅ ក្រែងលោគេបញ្ជូនអ្នកទៅដល់ចៅក្រម ចៅក្រមបញ្ជូនអ្នកទៅនគរបាល ហើយនគរបាលយកអ្នកទៅដាក់គុក។ [៥៩]ខ្ញុំសុំប្រាប់អ្នកថា ដរាបណាអ្នកមិនបានបង់ប្រាក់ពិន័យគ្រប់ចំនួន ឥតខ្វះមួយសេនទេនោះ អ្នកនឹងមិនរួចខ្លួនឡើយ»។

## ត្រូវកែប្រែចិត្តគំនិត

១៣ ១ពេលនោះ មានអ្នកខ្លះមកទូលព្រះយេស៊ូ
អំពីអ្នកស្រុកកាលីឡេ ដែលលោកពីឡាត
បានសម្លាប់ នៅពេលគេកំពុងតែថ្វាយយញ្ញបូជា។ ២ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេវិញថា៖ «តើអ្នករាល់គ្នាស្មានថា អ្នកស្រុក
កាលីឡេទាំងនោះ ជាមនុស្សបាបច្រើនជាងអ្នកស្រុកកាលីឡេ
ឯទៀតៗ ឬបានជាគេស្លាប់របៀបនេះ? ៣ទេ មិនមែនទេ! ខ្ញុំសុំ
ប្រាប់អ្នករាល់គ្នាថា បើអ្នករាល់គ្នាមិនកែប្រែចិត្តគំនិតទេ អ្នករាល់
គ្នានឹងត្រូវវិនាសអន្តរាយដូចគេមិនខាន។ ៤ចុះមនុស្សដប់ប្រាំបី
នាក់ដែលបានស្លាប់ ដោយប៉មស៊ីឡោមរលំសង្កត់លើ តើអ្នក
រាល់គ្នាស្មានថា អ្នកទាំងនោះមានទោសធ្ងន់ជាងអ្នកក្រុងយេរូ
សាឡឹមឯទៀតៗឬ? ៥ទេ មិនមែនទេ! ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា
បើអ្នករាល់គ្នាមិនកែប្រែចិត្តគំនិតទេ អ្នករាល់គ្នានឹងត្រូវវិនាស
អន្តរាយដូច្នោះដែរ»។

## ប្រស្នាស្ដីអំពីឧទុម្ពរគ្មានផ្លែ

៦បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នានេះទៅគេថា៖
«មានឧទុម្ពរ *មួយដើមដុះក្នុងចម្ការបុរសម្នាក់។ ម្ចាស់ចម្ការមក
រកបេះផ្លែពីដើមឧទុម្ពរនោះ តែគ្មានផ្លែសោះ ៧គាត់ក៏ប្រាប់អ្នក
ថែចម្ការថា៖ «មើល៍ ខ្ញុំមករកបេះផ្លែឧទុម្ពរនេះបីឆ្នាំហើយ តែមិន
ឃើញមានផ្លែសោះ។ ចូរកាប់វាចោលទៅ ទុកនាំតែខាតដីទេ!»។
៨អ្នកថែចម្ការឆ្លើយតបថា៖ «សូមលោកទុកវាមួយឆ្នាំទៀតសិន
ចាំខ្ញុំជ្រួយដីជុំវិញ ហើយដាក់ជី។ ៩ប្រហែលជាឆ្នាំក្រោយនឹង
មានផ្លែ បើមិនផ្លែទេ សឹមកាប់វាចោលទៅចុះ!»។

## ព្រះយេស៊ូប្រោសស្ត្រីពិការម្នាក់ឲ្យជា

១០ថ្ងៃមួយ ជាថ្ងៃសប្ប័ទ* ព្រះយេស៊ូកំពុងតែប្រៀនប្រដៅ
គេក្នុងធម្មសាលា*។ ១១នៅទីនោះ មានស្ត្រីម្នាក់ត្រូវខ្មោចធ្វើឲ្យ
ពិការអស់រយៈពេលដប់ប្រាំបីឆ្នាំមកហើយ នាងកោងខ្នងងើប
ត្រង់ពុំកើត។ ១២ពេលព្រះយេស៊ូទតឃើញស្ត្រីនោះ ព្រះអង្គហៅ
នាងមក ហើយមានព្រះបន្ទូលថា៖ «នាងអើយ! នាងបានជា
សះស្បើយហើយ»។ ១៣ព្រះអង្គដាក់ព្រះហស្តលើនាង នាងក៏
ឈរត្រង់វិញបានមួយរំពេច ព្រមទាំងលើកតម្កើងសិរីរុងរឿងរបស់
ព្រះជាម្ចាស់ផង។ ១៤ប៉ុន្តែ អ្នកទទួលខុសត្រូវលើធម្មសាលា ទាស់
ចិត្តណាស់ ដោយឃើញព្រះយេស៊ូប្រោសអ្នកជំងឺឲ្យបានជានៅ
ថ្ងៃសប្ប័ទដូច្នេះ។ គាត់ក៏និយាយទៅកាន់បណ្ដាជនថា៖ «យើង
មានសិទ្ធិធ្វើការបានចំនួនប្រាំមួយថ្ងៃ។ ដូច្នេះ ចូរអ្នករាល់គ្នាមក
រកព្យាបាលខ្លួនក្នុងថ្ងៃទាំងនោះចុះ កុំមកថ្ងៃសប្ប័ទឡើយ!»។
១៥ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់អ្នកទទួលខុសត្រូវលើសាលា
ប្រជុំនោះថា៖ «មនុស្សមានពុតអើយ! តើអ្នករាល់គ្នាមិនស្រាយ
គោ ឬលាបញ្ចេញពីក្រោលដឹកទៅផឹកទឹកនៅថ្ងៃសប្ប័ទទេឬអី?។
១៦ឯស្ត្រីនេះជាពូជពង្សរបស់លោកអប្រាហាំ មារសាតាំងបានចង
នាងអស់រយៈពេលដប់ប្រាំបីឆ្នាំមកហើយ តើមិនគួរឲ្យខ្ញុំស្រាយ
ចំណងនាងនៅថ្ងៃសប្ប័ទទេឬអី?»។ ១៧កាលព្រះអង្គមានព្រះ
បន្ទូលដូច្នោះហើយ អ្នកប្រឆាំងនឹងព្រះអង្គអៀនខ្មាសយ៉ាងខ្លាំង
រីឯបណ្ដាជនទាំងមូលវិញ គេរីករាយនឹងការអស្ចារ្យទាំងប៉ុន្មាន
ដែលព្រះអង្គបានធ្វើ។

## ប្រស្នាស្តីអំពីគ្រាប់ពូជល្អិត និងមេម្សៅ

(ម៉ាថាយ ១៣, ៣១-៣៣ ម៉ាកុស ៤, ៣០-៣២)

[18]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «តើព្រះរាជ្យព្រះជាម្ចាស់ប្រៀបបានទៅនឹងអ្វីខ្លះ? តើខ្ញុំប្រដូចព្រះរាជ្យព្រះជាម្ចាស់ទៅនឹងអ្វី?។ [19]ព្រះរាជ្យព្រះជាម្ចាស់ប្រៀបបីដូចជាគ្រាប់ពូជម៉្យាងដ៏ល្អិត ដែលបុរសម្នាក់យកទៅដាំក្នុងចម្ការរបស់ខ្លួន។ គ្រាប់នោះក៏ដុះឡើង បានទៅជាដើមឈើមួយ ហើយបក្សាបក្សីមកធ្វើសំបុកស្នាក់អាស្រ័យនៅតាមមែករបស់វា»។[20]ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «តើខ្ញុំប្រដូចព្រះរាជ្យព្រះជាម្ចាស់ទៅនឹងអ្វី?។ [21]ព្រះរាជ្យព្រះជាម្ចាស់ប្រៀបបីដូចជាមេម្សៅ ដែលស្ត្រីម្នាក់យកទៅលាយជាមួយនឹងម្សៅពីរតៅ ធ្វើឲ្យម្សៅនោះដោរឡើង»។

## ទ្វារចង្អៀត

(ម៉ាថាយ ៧, ១៣-១៤, ២១-២៣)

[22]ព្រះយេស៊ូធ្វើដំណើរឆ្ពោះទៅក្រុងយេរូសាឡឹម កាត់តាមក្រុង តាមភូមិនានា ព្រមទាំងប្រៀនប្រដៅអ្នកស្រុកផង។ [23]មានបុរសម្នាក់ទូលសួរព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! អ្នកដែលព្រះជាម្ចាស់សង្គ្រោះ មានចំនួនតិចទេឬ?»។ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ [24]«ចូរខំប្រឹងចូលតាមទ្វារចង្អៀត។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា មានមនុស្សជាច្រើនខំចូលដែរ ក៏ប៉ុន្តែគេមិនអាចចូលបានឡើយ។ [25]កាលណាម្ចាស់ផ្ទះក្រោកទៅបិទទ្វារជិត ហើយអ្នករាល់គ្នានឹងឈរនៅខាងក្រៅ គោះទ្វារផ្ទះទាំងអង្វរថា "ឱព្រះអម្ចាស់អើយ សូមបើកទ្វារឲ្យយើងខ្ញុំផង"។ ម្ចាស់ផ្ទះនឹងតបមកអ្នករាល់គ្នាថា "យើងមិនដឹងថាអ្នករាល់គ្នាមកពីណាទេ!"។

២៦អ្នករាល់គ្នា មុខជាជម្រាបលោកថា "យើងខ្ញុំធ្លាប់បរិភោគជាមួយ
ព្រះអង្គ ហើយព្រះអង្គក៏ធ្លាប់ប្រៀនប្រដៅយើងខ្ញុំ នៅតាមភូមិ
ដែរ"។ ២៧លោកនឹងប្រាប់អ្នករាល់គ្នាវិញថា "ពួកអ្នកប្រព្រឹត្តអំពើ
ទុច្ចរិតអើយ! ចូរថយចេញឲ្យឆ្ងាយពីយើងទៅ យើងមិនដឹងថា
អ្នករាល់គ្នាមកពីណាទេ!"។ ២៨កាលអ្នករាល់គ្នាឃើញលោក
អប្រាហាំ លោកអ៊ីសាក លោកយ៉ាកុប និងព្យាការី *ទាំងឡាយ
ស្ថិតនៅក្នុងព្រះរាជ្យ *ព្រះជាម្ចាស់ តែព្រះអង្គចោលអ្នករាល់គ្នា
ឲ្យនៅខាងក្រៅ អ្នករាល់គ្នានឹងយំសោកខឹងសង្កៀតធ្មេញ។ ២៩មាន
មនុស្សមកពីទិសទាំងបួន ចូលរួមពិធីជប់លៀងក្នុងព្រះរាជ្យព្រះ
ជាម្ចាស់។ ៣០ពេលនោះអ្នកខ្លះដែលនៅខាងក្រោយនឹងត្រឡប់
ទៅនៅខាងមុខ រីឯអ្នកខ្លះដែលនៅខាងមុខនឹងត្រឡប់ទៅនៅ
ខាងក្រោយវិញ»។

## អ្នកក្រុងយេរូសាឡឹមបដិសេធមិនទទួលព្រះយេស៊ូ

(ម៉ាថាយ ២៣, ៣៧-៣៩)

៣១នៅពេលនោះ មានពួកខាងគណៈផារីស៊ី *ខ្លះមកទូលព្រះ
យេស៊ូថា៖ «សូមលោកអញ្ជើញទៅកន្លែងផ្សេងទៅ ព្រោះស្ដេច
ហេរ៉ូដចង់សម្លាប់លោក»។ ៣២ព្រះយេស៊ូមានព្រះបន្ទូលតបវិញ
ថា៖ «ចូរអ្នករាល់គ្នាទៅប្រាប់ស្ដេចកំហូច[ញ]នោះថា ថ្ងៃនេះ និង
ថ្ងៃស្អែកខ្ញុំបណ្ដេញខ្មោច ខ្ញុំមើលអ្នកជំងឺឲ្យជា លុះដល់ខានស្អែក
ខ្ញុំនឹងបញ្ចប់កិច្ចការរបស់ខ្ញុំ។ ៣៣ប៉ុន្តែនៅថ្ងៃនេះ ស្អែក និងខាន
ស្អែក ខ្ញុំត្រូវតែបន្តដំណើររបស់ខ្ញុំទៅមុខទៀត ដ្បិតមិនគួរឲ្យ
ព្យាការី *ស្លាប់នៅខាងក្រៅក្រុងយេរូសាឡឹមឡើយ។
៣៤អ្នកក្រុងយេរូសាឡឹម អ្នកក្រុងយេរូសាឡឹមអើយ! អ្នក

---

ញ, ពាក្យដើម ៖ កញ្ជ្រោង។

រាល់គ្នាបានសម្លាប់ពួកព្យាការី ហើយយកដុំថ្មគប់សម្លាប់អស់
អ្នកដែលព្រះជាម្ចាស់បានចាត់ឲ្យមករកអ្នករាល់គ្នា។ ច្រើនលើក
ច្រើនសាមកហើយ ដែលខ្ញុំចង់ប្រមូលផ្ដុំអ្នករាល់គ្នា ដូចមេមាន់
ក្រុងកូនវានៅក្រោមស្លាប តែអ្នករាល់គ្នាពុំព្រមសោះ។ ³⁵ផ្ទះ
របស់អ្នករាល់គ្នានឹងត្រូវបោះបង់ចោល។ ខ្ញុំសុំប្រាប់អ្នករាល់គ្នា
ថា អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀតហើយ រហូតដល់ពេលអ្នក
រាល់គ្នាពោលថា៖

"សូមព្រះជាម្ចាស់ប្រទានពរដល់
ព្រះអង្គដែលយាងមក ក្នុងនាម
ព្រះអម្ចាស់!"[ឌ]»។

## ព្រះយេស៊ូប្រោសអ្នកជំងឺម្នាក់ឲ្យបានជា នៅថ្ងៃសប្ប័ទ

**១៤** ¹មានថ្ងៃមួយជាថ្ងៃសប្ប័ទ* ព្រះយេស៊ូយាង
ទៅសោយព្រះស្ងោយ នៅផ្ទះរបស់មេដឹកនាំ
ខាងគណៈផារីស៊ី*ម្នាក់ អស់អ្នកដែលនៅផ្ទះនោះ តាមឃ្លាំមើល
ព្រះអង្គ។ ²មានបុរសម្នាក់កើតទាច ឈរនៅមុខព្រះអង្គ។ ³ព្រះយេស៊ូ
មានព្រះបន្ទូលសួរទៅពួកបណ្ឌិតខាងវិន័យ* និងពួកខាងគណៈ
ផារីស៊ី*ថា៖ «តើយើងមានសិទ្ធិមើលអ្នកជំងឺឲ្យបានជានៅថ្ងៃ
សប្ប័ទឬទេ?»។ ⁴គេនៅស្ងៀមទាំងអស់គ្នា ព្រះយេស៊ូហៅអ្នក
ជំងឺមក ហើយប្រោសគាត់ឲ្យជា រួចឲ្យគាត់ត្រឡប់ទៅវិញ។ ⁵បន្ទាប់
មកព្រះអង្គមានព្រះបន្ទូលថា៖ «ក្នុងចំណោមអ្នករាល់គ្នា បើអ្នក
ណាម្នាក់មានកូន ឬគោធ្លាក់អណ្ដូង ទោះបីថ្ងៃនោះជាថ្ងៃសប្ប័ទ
ក៏ដោយ ក៏អ្នកនោះស្រង់វាឡើងជាបន្ទាន់មិនខាន»។ ⁶គេពុំអាច
ឆ្លើយតបនឹងព្រះអង្គ អំពីសេចក្ដីទាំងនេះបានឡើយ។

---
ឌ, ទំនុកតម្កើង ១១៨,២៦។

## កុំចង់បានកន្លែងកិត្តិយស

៧ព្រះយេស៊ូសង្កេតឃើញភ្ញៀវៗចេះតែរើសកន្លែងកិត្តិយស អង្គុយ ព្រះអង្គក៏មានព្រះបន្ទូលជាប្រស្នាទៅគេថា៖ ៨«បើមានគេអញ្ជើញអ្នកទៅជប់លៀងក្នុងពិធីមង្គលការណាមួយ សុំកុំទៅអង្គុយកន្លែងដែលគេបម្រុងទុកសម្រាប់ភ្ញៀវកិត្តិយស ក្រែងលោគេបានអញ្ជើញភ្ញៀវម្នាក់ទៀត មានឋានៈខ្ពស់ជាងអ្នក។ ៩ប្រសិនបើម្ចាស់ផ្ទះបានអញ្ជើញអ្នកផង អញ្ជើញភ្ញៀវមានឋានៈខ្ពស់នោះផង គាត់មុខជាសុំឲ្យអ្នកទុកកន្លែងកិត្តិយស ជូនអ្នកមានឋានៈខ្ពស់ជាមិនខាន។ ពេលនោះ អ្នកនឹងត្រូវអាម៉ាស់មុខ ហើយទៅអង្គុយកន្លែងអន់ជាងគេវិញ។ ១០ដូច្នេះ បើមានគេអញ្ជើញអ្នក ចូរទៅអង្គុយកន្លែងអន់ជាងគេសិន លុះដល់ម្ចាស់ផ្ទះពោលមកកាន់អ្នកថា៖ "សម្លាញ់អើយ! សូមអ្នកមកអង្គុយនៅកន្លែងខាងមុខនេះវិញ" ពេលនោះ អ្នកនឹងមានកិត្តិយសនៅចំពោះមុខភ្ញៀវទាំងអស់ ដែលអង្គុយរួមតុជាមួយអ្នកជាមិនខាន។ ១១អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ។ រីឯអ្នកដែលបន្ទាប ខ្លួននឹងត្រូវគេលើកតម្កើងវិញ»។

## ត្រូវអញ្ជើញអ្នកក្រីក្រមកបរិភោគ

១២បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់អ្នកដែលបានយាងព្រះអង្គមកសោយព្រះស្ងោយនោះថា៖ «កាលណាអ្នកអញ្ជើញភ្ញៀវមកជប់លៀង ទោះបីថ្ងៃត្រង់ក្ដី ល្ងាចក្ដី កុំអញ្ជើញមិត្តភក្ដិ បងប្អូន ញាតិសន្ដានរបស់អ្នក ឬអ្នកជិតខាងដែលមានសម្បត្តិស្ដុកស្ដម្ភនោះឡើយ ដ្បិតអ្នកទាំងនោះអញ្ជើញអ្នកតបស្នងវិញបាន។ ១៣ផ្ទុយទៅវិញ ពេលណាអ្នកធ្វើពិធីជប់លៀង

ត្រូវអញ្ជើញអ្នកក្រីក្រ មនុស្សពិការ ខ្វិន ខ្វាក់។ ១៤ធ្វើដូច្នេះ អ្នក
នឹងមានសុភមង្គលជាមិនខាន ដ្បិតអ្នកទាំងនោះ ពុំអាចតបស្នង
អ្នកបានឡើយ គឺព្រះជាម្ចាស់វិញទេ ដែលនឹងតបស្នងជូនអ្នក
នៅពេលមនុស្សសុចរិតរស់ឡើងវិញ»។

## ប្រស្នាស្ដីអំពីអ្នកក្រីក្រជប់លៀងជំនួសភ្ញៀវ

(ម៉ាថាយ ២២, ១-១០)

១៥ក្រោយបានឮព្រះបន្ទូលទាំងនេះហើយ បុរសម្នាក់ដែល
អង្គុយរួមតុជាមួយព្រះយេស៊ូ ទូលព្រះអង្គថា៖ «អ្នកណាបាន
ចូលរួមពិធីជប់លៀងក្នុងព្រះរាជ្យ*របស់ព្រះជាម្ចាស់ អ្នកនោះ
ប្រាកដជាមានសុភមង្គល*ហើយ!»។

១៦ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «មានបុរសម្នាក់រៀប
ពិធីជប់លៀងមួយយ៉ាងធំ ហើយលោកបានអញ្ជើញភ្ញៀវជាច្រើន។
១៧លុះដល់ម៉ោងជប់លៀង លោកចាត់អ្នកបម្រើឲ្យទៅប្រាប់ភ្ញៀវ
ថា៖ "ម្ហូបអាហារបានរៀបចំស្រេចហើយ សូមអញ្ជើញមក!"។
១៨ប៉ុន្តែភ្ញៀវទាំងនោះ ដោះសាបន្តបន្ទាប់គ្នាម្នាក់និយាយទៅកាន់
អ្នកបម្រើថា៖ "ខ្ញុំទើបនឹងទិញដីចម្ការមួយកន្លែង ខ្ញុំត្រូវតែចេញ
ទៅមើលឥឡូវនេះ សូមមេត្តាអភ័យទោសឲ្យខ្ញុំផង"។ ១៩ម្នាក់
និយាយថា "ខ្ញុំទើបនឹងទិញគោប្រាំនឹម ខ្ញុំត្រូវតែទៅទឹមវាសាក
លមើល សូមមេត្តាអភ័យទោសឲ្យខ្ញុំផង"។ ២០ម្នាក់ទៀតពោល
ថា "ខ្ញុំទើបនឹងរៀបការប្រពន្ធ ខ្ញុំពុំអាចទៅចូលរួមក្នុងពិធីជប់លៀង
បានឡើយ"។ ២១អ្នកបម្រើវិលទៅជួបម្ចាស់របស់ខ្លួនវិញ ហើយ
ជម្រាបលោកតាមដំណើររឿង។ ម្ចាស់ផ្ទះក៏ខឹងលោកប្រាប់ទៅ
អ្នកបម្រើថា "ចូរប្រញាប់ចេញទៅតាមទីផ្សារ ទៅតាមផ្លូវនានា

ក្នុងទីក្រុង ហើយប្រមូលមនុស្សក្រីក្រ មនុស្សពិការ និងមនុស្ស
ខ្វាក់ខ្វិនមក"។ ២២បន្តិចក្រោយមក អ្នកបម្រើជម្រាបចៅហ្វាយ
វិញថា "លោកម្ចាស់! ខ្ញុំបាទបានធ្វើតាមបង្គាប់របស់លោកហើយ
តែកន្លែងអង្គុយនៅមានសល់ទៀត"។ ២៣ម្ចាស់ផ្ទះប្រាប់ទៅអ្នក
បម្រើទៀតថា "ចូរទៅតាមផ្លូវស្រុកស្រែ តាមកៀនរបង ហើយ
បង្ខំមនុស្សម្នាឲ្យចូលមកពេញផ្ទះខ្ញុំ។ ២៤ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា
ក្នុងចំណោមអស់អ្នកដែលខ្ញុំបានអញ្ជើញកាលពីមុននោះ គ្មាន
នរណាម្នាក់បានបរិភោគក្នុងពិធីជប់លៀងរបស់ខ្ញុំឡើយ!"»។

## អំពីរបៀបដើរតាមព្រះយេស៊ូ

(ម៉ាថាយ ១០, ៣៧-៣៨)

២៥មានមហាជនជាច្រើន ធ្វើដំណើរជាមួយព្រះយេស៊ូ។ ព្រះអង្គ
បែរព្រះភ័ក្ត្រទៅរកគេ ហើយមានព្រះបន្ទូលថា៖ ២៦«បើអ្នកណា
ចង់មកតាមខ្ញុំ តែមិនស្រឡាញ់ខ្ញុំខ្លាំងជាងឪពុកម្ដាយ ប្រពន្ធកូន
បងប្អូនប្រុសស្រី និងជីវិតខ្លួនទេ អ្នកនោះពុំអាចធ្វើជាសាវ័ករបស់
ខ្ញុំបានឡើយ។ ២៧អ្នកណាមិនលីឈើឆ្កាងរបស់ខ្លួនមកតាមខ្ញុំទេ
អ្នកនោះក៏ពុំអាចធ្វើជាសាវ័ករបស់ខ្ញុំបានដែរ។

២៨ក្នុងចំណោមអ្នករាល់គ្នា ប្រសិនបើនរណាម្នាក់ចង់សង់
ផ្ទះថ្មធំមួយ អ្នកនោះត្រូវអង្គុយគិតគូរមើលថ្លៃសង់ជាមុនសិន
ដើម្បីឲ្យដឹងថា តើខ្លួនមានប្រាក់ល្មមនឹងបង្ហើយសំណង់ ឬយ៉ាង
ណា ២៩ក្រែងលោចាក់គ្រឹះហើយ តែមិនអាចបង្ហើយបាន មនុស្ស
ម្នាឃើញ មុខជាសើចចំអកឲ្យមិនខាន។ ៣០គេនឹងពោលថា "មើល
បុរសនេះសង់ផ្ទះ តែមិនអាចបង្ហើយបានទេ!"។

៣១ម្យ៉ាងទៀត ប្រសិនបើមានស្ដេចមួយអង្គចេញទៅធ្វើសឹក

សង្គ្រាមតទល់នឹងស្ដេចមួយអង្គទៀត ទ្រង់ត្រូវគង់គិតគូរជាមុន
សិនថា បើទ្រង់មានទ័ពមួយម៉ឺននាក់ តើទ្រង់អាចតទល់នឹងបច្ចា
មិត្តដែលមានគ្នាពីរម៉ឺននាក់បានឬយ៉ាងណា ៣២បើឃើញថា មិន
អាចតទល់បានទេនោះ ទ្រង់នឹងចាត់រាជទូតឲ្យទៅសុំចរចារក
សន្តិភាព ក្នុងពេលដែលស្ដេចមួយអង្គទៀតនៅឆ្ងាយនៅឡើយ។
៣៣ដូច្នេះ ក្នុងចំណោមអ្នករាល់គ្នា បើអ្នកណាមិនលះបង់អ្វីៗ
ទាំងអស់ដែលខ្លួនមានទេ អ្នកនោះមិនអាចធ្វើជាសាវ័ក*របស់
ខ្ញុំបានឡើយ»។

## កុំឲ្យបាត់ជាតិប្រៃ

(ម៉ាថាយ ៥, ១៣ ម៉ាកុស ៩, ៥០)

៣៤«អំបិលជារបស់មួយសំខាន់ណាស់។ ប៉ុន្តែ បើវាបាត់ជាតិ
ប្រៃហើយ តើធ្វើម្ដេចនឹងឲ្យវាប្រៃវិញបាន?។ ៣៥វាគ្មានសារ
ប្រយោជន៍អ្វីទៀតទេ ទោះបីយកទៅលាយដី ឬលាយដីក៏មិន
កើតដែរ មានតែចាក់ចោលទៅខាងក្រៅប៉ុណ្ណោះ។ អស់អ្នក
ដែល ឮពាក្យនេះ សូមយកទៅពិចារណាចុះ!»។

## ប្រស្នាអំពីចៀមដែលបាត់ហើយរកឃើញវិញ

(ម៉ាថាយ ១៨, ១២-១៤)

១៥ ១មានអ្នកទារពន្ធ* និងមនុស្សបាបទាំងអស់
នាំគ្នាចូលមកជិតព្រះយេស៊ូ ស្ដាប់ព្រះបន្ទូល
របស់ព្រះអង្គ។ ២ពួកខាងគណៈផារីស៊ី* និងពួកធម្មាចារ្យ*រអ៊ូ
រទាំថា៖ «មើល៍! អ្នកនេះរាក់ទាក់នឹងមនុស្សបាប ព្រមទាំងបរិភោគ

ជាមួយគេផង!»។ ៣ព្រះយេស៊ូមានព្រះបន្ទូលទៅគេជាប្រស្នានេះ
ថា៖ ៤«ក្នុងចំណោមអ្នករាល់គ្នា ឧបមាថាមានម្នាក់មានចៀមមួយ
រយក្បាល បើគាត់បាត់ចៀមមួយ គាត់មុខជាទុកចៀមកៅសិប
ប្រាំបួនចោលនៅទីវាល ហើយទៅតាមរកចៀមដែលបាត់នោះ
រហូតទាល់តែបានឃើញវិញ។ ៥កាលរកឃើញហើយ គាត់ត្រេកអរ
ណាស់ គាត់ក៏លើកចៀមដាក់លើ ក ៦ត្រឡប់មកផ្ទះវិញ ហៅ
មិត្តភក្តិ និងអ្នកជិតខាងប្រាប់ថា "សូមជួយអរសប្បាយជាមួយ
ខ្ញុំផង ដ្បិតចៀមរបស់ខ្ញុំដែលបាត់ទៅនោះ ឥឡូវនេះ ខ្ញុំរកឃើញ
វិញហើយ"។ ៧ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់នៅស្ថាន
បរមសុខ មានអំណរសប្បាយ ដោយមានមនុស្សបាបតែម្នាក់
កែប្រែចិត្តគំនិតខ្លាំងជាង ព្រះអង្គសប្បាយនឹងមនុស្សសុចរិតកៅ
សិបប្រាំបួននាក់ ដែលមិនត្រូវការកែប្រែចិត្តគំនិត»។

## ប្រស្នាអំពីប្រាក់ដួងដែលបាត់ហើយរកឃើញវិញ

៨«ម្យ៉ាងទៀត ឧបមាថាស្ត្រីម្នាក់ មានប្រាក់ដប់ដួង* ហើយ
បាត់មួយដួង គាត់មុខជាអុជចង្កៀងបោសផ្ទះ រកប្រាក់នោះ គ្រប់
កៀនកោះ រហូតទាល់តែបានឃើញវិញ។ ៩លុះរកឃើញហើយ
គាត់ក៏ហៅមិត្តភក្តិ និងអ្នកជិតខាងប្រាប់ថា "សូមជួយអរសប្បាយ
ជាមួយខ្ញុំផង ដ្បិតប្រាក់ដួង*ដែលខ្ញុំបាត់នោះ ឥឡូវនេះ ខ្ញុំរក
ឃើញវិញហើយ"។ ១០ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ទេវទូត*របស់
ព្រះជាម្ចាស់នឹងមានអំណរសប្បាយជាខ្លាំង ដោយមានមនុស្ស
បាបតែម្នាក់កែប្រែចិត្តគំនិត»។

## ប្រស្នាអំពីកូនពៅដែលបាត់ហើយរកឃើញវិញ

១១ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «មានបុរសមួយរូបមាន
កូនប្រុសពីរនាក់។ ១២កូនពៅនិយាយទៅឪពុកថា "លោកឪពុក!
សូមចែកកេរមត៌កឲ្យកូនមក"។ ឪពុកក៏ចែកមត៌កឲ្យកូន។ ១៣ប៉ុន្មាន
ថ្ងៃក្រោយមក កូនពៅប្រមូលទ្រព្យសម្បត្តិ រួចចាកចេញទៅស្រុក
ឆ្ងាយ។ នៅស្រុកនោះ កូនពៅបានខ្ជះខ្ជាយ បង្ហិនទ្រព្យសម្បត្តិ
របស់ខ្លួនអស់ទៅ។ ១៤ពេលចាយវាយទ្រព្យសម្បត្តិអស់ហើយ
ជួនជាកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុក កូនពៅនោះចាប់ផ្ដើម
ខ្វះខាត។ ១៥គាត់ក៏ទៅស៊ីឈ្នួលអ្នកស្រុកម្នាក់ គេប្រើគាត់ឲ្យមើល
ជ្រូកតាមស្រែចម្ការ។ ១៦គាត់ចង់ចម្អែតក្រពះនឹងចំណីដែលគេ
ដាក់ឲ្យជ្រូកស៊ីនោះណាស់ តែគ្មានអ្នកណាឲ្យបរិភោគឡើយ។
១៧ពេលនោះ កូនពៅភ្ញាក់ខ្លួន ហើយរិះគិតក្នុងចិត្តថា "អ្នកបម្រើ
របស់ឪពុកអញ សុទ្ធតែមានម្ហូបអាហារបរិភោគហូរហៀរទាំង
អស់គ្នា រីឯនៅទីនេះវិញ អញសឹងតែដាច់ពោះស្លាប់។ ១៨អញ
ត្រូវតែវិលត្រឡប់ទៅរកឪពុកអញវិញ ហើយជម្រាបគាត់ថា លោក
ឪពុក កូនបានប្រព្រឹត្តអំពើបាប ខុសនឹងព្រះហឫទ័យរបស់ព្រះ
ជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ។
១៩មិនគួរឲ្យលោកឪពុករាប់ខ្ញុំនេះ ជាកូនទៀតទេ សូមលោកឪពុក
ចាត់ទុកកូនជាអ្នកបម្រើចុះ"។ ២០លុះគិតដូច្នោះហើយ កូនពៅ
ក៏វិលត្រឡប់ទៅរកឪពុកវិញ។ កាលឪពុកឃើញកូនពីចម្ងាយ
គាត់មានចិត្តអាណិតអាសូរក្រៃលែង ក៏រត់ទៅទទួលកូន ហើយ
ឱបថើបទៀតផង។ ២១កូនពៅជម្រាបឪពុកថា៖ "លោកឪពុក
កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់
កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ មិនគួរឲ្យ
លោកឪពុករាប់ខ្ញុំនេះ ជាកូនទៀតទេ"។ ២២ឪពុកប្រាប់ពួកអ្នក

បម្រើថា "ចូរទៅយកសម្លៀកបំពាក់ល្អៗបំផុត មកពាក់ឲ្យកូនខ្ញុំ
ជាប្រញាប់ ហើយយកចិញ្ចៀន និងស្បែកជើងមកពាក់ឲ្យផង។
២៣ចូរយកកូនគោ ដែលយើងបានបំប៉នទុក មកកាប់ជប់លៀង
ឲ្យសប្បាយចុះ ២៤ដ្បិតកូនខ្ញុំនេះ បានស្លាប់ទៅហើយ តែឥឡូវ
រស់ឡើងវិញ វាវង្វេងបាត់ តែឥឡូវនេះ ខ្ញុំរកឃើញវិញហើយ"។
គេនាំគ្នាជប់លៀងយ៉ាងសប្បាយ។



២៥ពេលនោះ កូនច្បងនៅឯចម្ការ។ កាលគាត់ត្រឡប់មក
ជិតដល់ផ្ទះវិញ ឮស្នូរតូរ្យតន្ត្រី និងចម្រៀងរបាំ ២៦គាត់ហៅអ្នក
បម្រើម្នាក់មកសួរថា មានការអ្វីកើតឡើង។ ២៧អ្នកបម្រើឆ្លើយថា
"ប្អូនលោកត្រឡប់មកវិញហើយ។ ឪពុករបស់លោក ឲ្យគេកាប់
កូនគោដែលយើងបំប៉ននោះ ព្រោះកូនពៅរបស់លោកបានត្រឡប់
មកវិញដោយសុខសាន្ត"។ ២៨កូនច្បងខឹងណាស់ មិនព្រមចូល
ផ្ទះទេ ឪពុកចេញមកអង្វរឲ្យចូល។ ២៩កូនច្បងនិយាយទៅឪពុក
ថា "ខ្ញុំបាននៅបម្រើលោកជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើ
ខុសនឹងបង្គាប់របស់លោកត្រង់ណាឡើយ តែលោកមិនដែល
ឲ្យកូនពពែ ដើម្បីឲ្យខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែសោះ
សូម្បីតែមួយក៏មិនដែលផង។ ៣០ពេលកូនលោកត្រឡប់មកវិញ

លោកបានកាប់កូនគោបំប៉នទទួលវា មើល៍វានេះ បានបំផ្លាញ
ទ្រព្យសម្បត្តិលោកទាំងអស់ជាមួយស្រីញី"។ ៣១ឪពុកនិយាយ
ទៅកូនថា "កូនអើយ ឯងនៅជាមួយឪពុកជានិច្ចរហូតណាកូន
អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ។ ៣២យើងត្រូវ
តែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯង ដែលបានស្លាប់ទៅនោះ
ឥឡូវនេះរស់ឡើងវិញហើយ។ វាបានវង្វេងបាត់ តែឥឡូវនេះ
យើងរកឃើញវិញហើយ"»។

## ប្រស្នាអំពីអ្នកបម្រើមិនទោកបញ្ឆោត

១៦ ១ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សាវ័ក*ថា៖
«មានសេដ្ឋីមួយរូប បានប្រគល់មុខងារឲ្យអ្នក
បម្រើម្នាក់ មើលខុសត្រូវលើទ្រព្យសម្បត្តិរបស់លោក។ មានគេ
មកជម្រាបលោកថា អ្នកនោះបានចាយវាយទ្រព្យសម្បត្តិលោក
យ៉ាងខ្ជះខ្ជាយ។ ២សេដ្ឋីក៏ហៅអ្នកមើលខុសត្រូវមកប្រាប់ថា "ចូរគិត
បញ្ជីយកមកឲ្យខ្ញុំ អ្នកមិនអាចមើលខុសត្រូវលើទ្រព្យសម្បត្តិ ខ្ញុំត
ទៅទៀតបានឡើយ ព្រោះសេចក្ដីដែលខ្ញុំបានឮគេនិយាយអំពី
អ្នកមិនល្អសោះ"។ ៣អ្នកបម្រើនោះរិះគិតក្នុងចិត្តថា "ចៅហ្វាយ
លែងឲ្យអញទទួលខុសត្រូវលើទ្រព្យសម្បត្តិលោកទៀតហើយ។
តើអញគិតទៅធ្វើការអ្វីវិញហ្ន៎? អញគ្មានកម្លាំងនឹងកាប់គាស់ដី
ទេ បើដើរសុំទានខ្មាសគេ។ ៤អ៊ុំ! នឹកឃើញហើយ គួរធ្វើយ៉ាង
នេះ ដើម្បីអ្នកស្រុកទទួលអញឲ្យស្នាក់នៅផ្ទះគេ នៅ ពេលអញ
ឈប់កាន់កាប់ការងារនេះ"។ ៥គាត់ក៏ហៅកូនបំណុល របស់ចៅ
ហ្វាយឲ្យចូលមកម្នាក់ម្ដងៗ គាត់សួរអ្នកទីមួយថា "តើអ្នក ជំពាក់
ចៅហ្វាយខ្ញុំប៉ុន្មាន?"។ ៦កូនបំណុលនោះឆ្លើយថា "ប្រេងមួយ

រយប៉ោត"។ អ្នកបម្រើប្រាប់ថា "នេះនែ៎! យកបញ្ជីរបស់អ្នក ហើយអង្គុយចុះ សរសេរយ៉ាងប្រញាប់ ដាក់ថា ជំពាក់ហាសិប
ប៉ោត"។
7បន្ទាប់មក គាត់សួរម្នាក់ទៀតថា "តើអ្នកជំពាក់ចៅហ្វាយខ្ញុំប៉ុន្មានដែរ?"។ កូនបំណុលនោះឆ្លើយថា "ស្រូវប្រាំរយថាំង"។ អ្នកបម្រើប្រាប់ថា "នែ៎! យកបញ្ជីរបស់អ្នក ហើយសរសេរ ដាក់ថា ជំពាក់បួនរយថាំង"។
8ម្ចាស់ក៏សរសើរអ្នកបម្រើ ដែលប៉ិនប្រសប់បោកបញ្ឆោត។ មនុស្សក្នុងលោកនេះ តែងតែប៉ិនប្រសប់រកស៊ីជាមួយគ្នា ជាងអស់អ្នកដែលស្គាល់ពន្លឺរបស់ព្រះជាម្ចាស់ទៅទៀត»។

## សម្បត្តិលោកីយ៍ និងសម្បត្តិសួគ៌

9«ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ចូរយកទ្រព្យសម្បត្តិលោកីយ៍ដែលបញ្ឆោតចិត្តនេះទៅធ្វើទាន ដើម្បីឲ្យមានមិត្តភក្តិច្រើន។ ពេលណាទ្រព្យនេះរលាយសូន្យទៅ មិត្តភក្តិទាំងនោះ នឹងទទួលអ្នករាល់គ្នានៅក្នុងដំណាក់របស់ព្រះជាម្ចាស់។
10អ្នកណាស្មោះត្រង់ក្នុងកិច្ចការដ៏តូច អ្នកនោះក៏ស្មោះត្រង់ក្នុងកិច្ចការធំដុំដែរ។ អ្នកណាបោកបញ្ឆោតក្នុងកិច្ចការដ៏តូច អ្នកនោះក៏តែងបោកបញ្ឆោតក្នុងកិច្ចការធំដុំដែរ។
11ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់ក្នុងរបៀបប្រើប្រាស់ទ្រព្យសម្បត្តិលោកីយ៍ ដែលបញ្ឆោតចិត្តនេះទេ ព្រះជាម្ចាស់ក៏ពុំអាចប្រគល់ទ្រព្យសម្បត្តិដ៏ពិតប្រាកដ មកអ្នករាល់គ្នាបានដែរ។
12ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់នឹងទ្រព្យសម្បត្តិអ្នកដទៃផង ធ្វើម្ដេចឲ្យព្រះជាម្ចាស់ប្រទានទ្រព្យសម្បត្តិដែលព្រះអង្គបម្រុងទុកសម្រាប់អ្នករាល់គ្នា មកអ្នករាល់គ្នាបាន!
13គ្មានអ្នកណាអាចបម្រើម្ចាស់ពីរនាក់បានទេ ព្រោះអ្នកនោះនឹង

ស្អប់ម្នាក់ ស្រឡាញ់ម្នាក់ ស្មោះត្រង់នឹងម្នាក់ មើលងាយម្នាក់ទៀតពុំខាន។ អ្នករាល់គ្នាពុំអាចគោរពបម្រើព្រះជាម្ចាស់ផង គោរពបម្រើទ្រព្យសម្បត្តិលោកីយ៍ផងបានឡើយ»។

## វិន័យ និងព្រះរាជ្យរបស់ព្រះជាម្ចាស់

(ម៉ាថាយ ១១,១២-១៣, ៥,៣១-៣២ ម៉ាកុស ១០,១១-១២)

១៤កាលពួកខាងគណៈផារីស៊ី*ឮដូច្នោះ គេក៏ចំអកឲ្យព្រះយេស៊ូ ដ្បិតពួកគេស្រឡាញ់ប្រាក់ណាស់។ ១៥ព្រះយេស៊ូមានព្រះបន្ទូលទៅគេថាៈ «អ្នករាល់គ្នាតែងតែសម្តែងឫកពាឲ្យមនុស្សលោកឃើញថា អ្នករាល់គ្នាជាជនសុចរិត ប៉ុន្តែ ព្រះជាម្ចាស់ឈ្វេងយល់ចិត្តអ្នករាល់គ្នា។ អ្វីៗដែលមនុស្សលោកយល់ឃើញថា ល្អប្រសើរ ព្រះជាម្ចាស់ចាត់ទុកថា ជាការគួរឲ្យស្អប់ខ្ពើម។ ១៦គម្ពីរវិន័យ* និងគម្ពីរព្យាការី* បានប្រៀនប្រដៅមនុស្សតាំងពីដើមរៀងមករហូតដល់លោកយ៉ូហានបាទីស្ដមកដល់។ ប៉ុន្តែ តាំងពីពេលនោះមក មនុស្សម្នាបានឮដំណឹងល្អ* អំពីព្រះរាជ្យ*ព្រះជាម្ចាស់ ហើយគ្រប់គ្នាខំប្រឹងចូល។ ១៧ផ្ទៃមេឃផែនដីនឹងរលាយសូន្យទៅ តែវិន័យមិនរលាយឡើយ សូម្បីតែតួអក្សរមួយដ៏តូចក៏មិនរលាយបាត់ផង។

១៨បុរសណាលែងភរិយា ហើយទៅរៀបការនឹងស្ត្រីម្នាក់ទៀត បុរសនោះបានប្រព្រឹត្តអំពើផិតក្បត់។ រីឯបុរសណារៀបការនឹងស្ត្រីប្ដីលែង បុរសនោះក៏បានប្រព្រឹត្តអំពើផិតក្បត់ដែរ»។

## បុរសអ្នកមាន និងឡាសារជាអ្នកក្រ

១៩«មានបុរសម្នាក់ជាអ្នកមាន គាត់ប្រើសុទ្ធតែសម្លៀកបំពាក់
ល្អៗ ធ្វើពីក្រណាត់សំពត់ថ្លៃៗ។ គាត់រស់នៅដោយសប្បាយ មាន
ម្ហូបអាហារឆ្ងាញ់ៗបរិបូណ៌រាល់ថ្ងៃ។ ២០មានបុរសម្នាក់ទៀតជា
អ្នកក្រ ឈ្មោះឡាសារ គាត់កើតដំបៅពេញខ្លួន ហើយតែងដេក
នៅមាត់ទ្វាររបងផ្ទះអ្នកមាននោះ។ ២១អ្នកឡាសារចង់បរិភោគ
កម្ទេចម្ហូបអាហារ ដែលជ្រុះពីតុអ្នកមាននោះណាស់ ហើយក៏



មានឆ្កែមកលិទ្ធដំបៅគាត់ទៀតផង។ ២២ថ្ងៃមួយ អ្នកក្រនោះស្លាប់
ទៅ ពួកទេវទូត*នាំគាត់យកទៅដាក់ក្បែរលោកអប្រាហាំនៅស្ថាន
បរមសុខ។ រីឯអ្នកមានក៏ស្លាប់ដែរ គេយកសពគាត់ទៅបញ្ចុះ
ក្នុងផ្នូរ។ ២៣នៅស្ថានមនុស្សស្លាប់ អ្នកមាននោះរងទុក្ខទារុណ
កម្មយ៉ាងខ្លាំង គាត់ងើបមុខទៅលើ ឃើញលោកអប្រាហាំពីចម្ងាយ
ហើយឃើញអ្នកឡាសារនៅក្បែរលោកដែរ។ ២៤គាត់ស្រែកអង្វរ
លោកអប្រាហាំថា "លោកឪពុកអើយ! សូមអាណិតមេត្តាខ្ញុំផង។
សូមលោកឪពុកប្រាប់ឡាសារឲ្យយកចម្រាមដៃជ្រលក់ទឹកបន្តក់

លើអណ្ដាតខ្ញុំបន្តិច ព្រោះនៅក្នុងភ្លើងនេះ ខ្ញុំឈឺចុកចាប់ណាស់"។
២៥លោកអប្រាហាំមានប្រសាសន៍ថា "កូនអើយ! ចូរនឹកចាំថា
កាលកូនមានជីវិតនៅឡើយ កូនស្គាល់តែសប្បាយ រីឯឡាសារ
វិញ គ្នាស្គាល់តែទុក្ខ។ ឥឡូវនេះ ឡាសារបានសុខក្សេមក្សាន្ត
ហើយ តែកូនវិញ កូនត្រូវឈឺចុកចាប់។ ២៦ម៉្យាងទៀត មានលំហ
មួយយ៉ាងធំខណ្ឌយើងពីអ្នករាល់គ្នា ទោះបីអ្នកណាចង់ឆ្លងពីស្ថាន
នេះទៅរកអ្នករាល់គ្នា ក៏ឆ្លងមិនបានឡើយ ទោះបីមានអ្នកណា
ចង់ឆ្លងពីអ្នករាល់គ្នាមករកយើង ក៏ឆ្លងមិនបានដែរ"។ ២៧អ្នកមាន
នោះអង្វរថា "លោកឪពុកអើយ! សូមលោកឪពុកមេត្តាចាត់ឡាសារ
ឲ្យទៅផ្ទះឪពុកខ្ញុំផង ២៨ខ្ញុំមានបងប្អូនប្រាំនាក់។ សូមឲ្យឡាសារ
ទៅប្រាប់គេឲ្យដឹងខ្លួន កុំឲ្យគេមកកន្លែងរងទុក្ខទារុណកម្មនេះ"។
២៩លោកអប្រាហាំឆ្លើយថា "បងប្អូនរបស់កូន បានឮពាក្យប្រៀន
ប្រដៅរបស់លោកម៉ូសេ និងពាក្យប្រៀនប្រដៅរបស់ពួកព្យាការី
ហើយ ឲ្យគេធ្វើតាមពាក្យលោកទាំងនោះចុះ"។ ៣០អ្នកមានតប
ទៅលោកអប្រាហាំថា "ទេ! លោកឪពុកទាល់តែមានអ្នកណាម្នាក់
ពីចំណោមមនុស្សស្លាប់ទៅប្រាប់គេ ទើបគេកែប្រែចិត្តគំនិត"។
៣១ប៉ុន្ដែ លោកអប្រាហាំឆ្លើយតបវិញថា "ប្រសិនបើគេមិនធ្វើតាម
ពាក្យប្រៀនប្រដៅរបស់លោកម៉ូសេ និងពាក្យប្រៀនប្រដៅរបស់
ព្យាការីទេ ទោះបីមានមនុស្សស្លាប់បានរស់ឡើងវិញ ទៅប្រាប់
គេក៏ដោយ ក៏គេមិនព្រមជឿដែរ"»។

## កុំនាំគេប្រព្រឹត្តអំពើបាប

(ម៉ាថាយ ១៨, ៦-៧,២១-២២ ម៉ាកុស ៩, ៤២)

**១៧** ១ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកសាវ័ក *
ថា៖ «មានមូលហេតុជាច្រើន ដែលតែងតែ
បណ្ដាលឲ្យមនុស្សប្រព្រឹត្តអំពើបាប។ ប៉ុន្តែ អ្នកណានាំគេឲ្យ
ប្រព្រឹត្តអំពើបាប អ្នកនោះត្រូវវេទនាហើយ។ ២ចំពោះអ្នកនោះ
ប្រសិនបើគេយកត្បាល់ថ្មយ៉ាងធំ មកចងកទម្លាក់ទៅក្នុងសមុទ្រ
ប្រសើរជាងទុកឲ្យគាត់នៅរស់ ហើយនាំមនុស្សតូចតាចណាម្នាក់
ប្រព្រឹត្តអំពើបាប។ ៣ដូច្នេះ អ្នករាល់គ្នាត្រូវប្រយ័ត្នខ្លួន! ប្រសិនបើ
បងប្អូនណាធ្វើអ្វីខុសចំពោះអ្នក ចូរស្ដីប្រដៅគាត់ផង តែបើគាត់
កែប្រែចិត្តគំនិត ចូរអត់ទោសឲ្យគាត់ទៅ។ ៤ប្រសិនបើគាត់ធ្វើអ្វី
ខុសចំពោះអ្នកប្រាំពីរដងក្នុងមួយថ្ងៃ ហើយបើគាត់ត្រឡប់មករក
អ្នកទាំងប្រាំពីរដង ដោយពោលថា "ខ្ញុំស្ដាយដោយបានធ្វើខុស"
ចូរអត់ទោសឲ្យគាត់ទៅ»។

## អំពីជំនឿ

៥ពួកគ្រីស្ដទូត *ទូលព្រះអម្ចាស់ថា៖ «សូមព្រះអង្គប្រទានជំនឿ
មកយើងខ្ញុំថែមទៀត»។ ៦ព្រះអម្ចាស់មានព្រះបន្ទូលឆ្លើយថា៖
«ប្រសិនបើអ្នករាល់គ្នាមានជំនឿប៉ុនគ្រាប់ពូជមួយដ៏ល្អិត ហើយ
បើអ្នករាល់គ្នានិយាយទៅកាន់ដើមឈើនេះថា "ចូររំលើងឫសឯង
ទៅដុះក្នុងសមុទ្រទៅ!" វាមុខជាស្ដាប់បង្គាប់អ្នករាល់គ្នាមិនខាន»។

## ភារកិច្ចរបស់អ្នកបម្រើ

⁷«ក្នុងចំណោមអ្នករាល់គ្នា ឧបមាថា នរណាម្នាក់មានអ្នក
បម្រើទៅភ្ជួរស្រែ ឬឃ្វាលហ្វូងសត្វ។ ពេលអ្នកបម្រើនោះវិល
ត្រឡប់មកពីស្រែវិញ ម្ចាស់មិនដែលនិយាយថា "សូមអញ្ជើញ
មកពិសាបាយ"ទេ។ ⁸ផ្ទុយទៅវិញ ម្ចាស់តែងតែនិយាយទៅកាន់
អ្នកបម្រើថា "ចូររៀបចំបាយទឹកឲ្យខ្ញុំ រួចទៅផ្លាស់ខោអាវមកបម្រើ
ខ្ញុំ ពេលខ្ញុំបរិភោគ ចាំខ្ញុំបរិភោគរួច សឹមអ្នកបរិភោគតាមក្រោយ"។
⁹ម្ចាស់មិនដែលអរគុណអ្នកបម្រើ ដែលបានធ្វើតាមបង្គាប់ខ្លួន
នោះឡើយ។ ¹⁰រីឯអ្នករាល់គ្នាវិញ ក៏ដូច្នោះដែរ កាលណាអ្នករាល់គ្នា
បានបំពេញតាមព្រះបញ្ជារបស់ព្រះជាម្ចាស់សព្វគ្រប់ហើយ ចូរពោល
ថា "យើងខ្ញុំគ្រាន់តែជាអ្នកបម្រើធម្មតាប៉ុណ្ណោះ គឺយើង ខ្ញុំបាន
បំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើ"»។

## ព្រះយេស៊ូប្រោសមនុស្សឃ្លង់ដប់នាក់ឲ្យបានជា

¹¹កាលព្រះយេស៊ូកំពុងយាងឆ្ពោះទៅក្រុងយេរូសាឡឹម ព្រះអង្គ
យាងកាត់តាមស្រុកសាម៉ារី និងស្រុកកាលីឡេ។ ¹²ពេលព្រះអង្គ
យាងចូលក្នុងភូមិមួយ មានមនុស្សឃ្លង់ដប់នាក់មករកព្រះអង្គ។
គេឈរពីចម្ងាយ ¹³ស្រែកឡើងថា៖ «លោកគ្រូយេស៊ូអើយ! សូម
អាណិតមេត្តាយើងខ្ញុំផង»។ ¹⁴ព្រះយេស៊ូទតមើលគេ ហើយមាន
ព្រះបន្ទូលថា៖ «ចូរអ្នករាល់គ្នាទៅបង្ហាញខ្លួនឲ្យពួកបូជាចារ្យ*
ឃើញចុះ»។ ពេលអ្នកទាំងនោះចេញដំណើរទៅ គេក៏បានជា
ស្អាតបរិសុទ្ធ*ទាំងអស់គ្នា។ ¹⁵ពេលឃើញខ្លួនបានជាសះស្បើយ
ដូច្នេះ មានម្នាក់ក្នុងចំណោមអ្នកទាំងនោះ ត្រឡប់មកវិញទាំង
លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយបន្លឺសំឡេងខ្លាំងៗ

ផង។ ១៦គាត់ក្រាបទៀបព្រះបាទាព្រះយេស៊ូ ឱនក្បាលដល់ដី
ហើយអរព្រះគុណព្រះអង្គ អ្នកនោះជាអ្នកស្រុកសាម៉ារី។ ១៧ព្រះយេស៊ូ
មានព្រះបន្ទូលថា៖ «តើទាំងដប់នាក់មិនបានជាស្អាតបរិសុទ្ធគ្រប់ៗ
គ្នាទេឬ ចុះប្រាំបួននាក់ទៀតនៅឯណា? ១៨មានតែជនបរទេស
ម្នាក់វិលត្រឡប់មកវិញ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជា
ម្ចាស់!»។ ១៩ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ទៀតថា៖ «ចូរក្រោក
ឡើងអញ្ជើញទៅចុះ ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ»។

## ទីសម្គាល់អំពីព្រះរាជ្យព្រះជាម្ចាស់

(ម៉ាថាយ ២៤, ២៣-២៨, ៣៧-៤១)

២០ពួកខាងគណៈផារីស៊ី *ទូលសួរព្រះយេស៊ូថា ព្រះជាម្ចាស់
នឹងយាងមកគ្រងរាជ្យនៅពេលណា។ ព្រះអង្គមានព្រះបន្ទូល
តបទៅគេថា៖ «ព្រះរាជ្យព្រះជាម្ចាស់មិនមែនមកតាមបែបដែល
មនុស្សអាចមើលឃើញនឹងភ្នែកបានឡើយ។ ២១គេពុំអាចពោល
ថា "ព្រះរាជ្យព្រះជាម្ចាស់នៅទីនេះ ឬព្រះរាជ្យព្រះជាម្ចាស់នៅទី
នោះ" បានទេ។ ចូរដឹងថា ព្រះរាជ្យព្រះជាម្ចាស់ស្ថិតនៅកណ្ដាល
ចំណោមអ្នករាល់គ្នាហើយ»។ ២២បន្ទាប់មកព្រះអង្គមានព្រះបន្ទូល
ទៅកាន់សាវ័ក *ថា៖ «ពេលក្រោយអ្នករាល់គ្នាចង់ឃើញថ្ងៃដែល
បុត្រមនុស្ស *យាងមក សូម្បីតែមួយថ្ងៃ ក៏បានដែរ តែអ្នករាល់
គ្នាពុំឃើញឡើយ។ ២៣ពេលមានគេប្រាប់អ្នករាល់គ្នាថា "ព្រះអង្គ
នៅទីនេះឬនៅទីនោះ" កុំរត់ទៅឲ្យសោះ។ ២៤បុត្រមនុស្សនឹង
យាងមក ប្រៀបបីដូចជាផ្លេកបន្ទោរ ភ្លឺឆ្វាច ឆូតកាត់ពីជើងមេឃ
ម្ខាងទៅជើងមេឃម្ខាង។ ២៥ប៉ុន្ដែ បុត្រមនុស្សត្រូវតែរងទុក្ខវេទនា
យ៉ាងខ្លាំងជាមុនសិន ហើយមនុស្សសម័យឥឡូវនេះ នឹងបោះបង់

លោកចោល។ [២៦]នៅគ្រាដែលបុត្រមនុស្សយាងមក ក៏ដូចនៅ
ជំនាន់លោកណូអេ *ដែរ។ [២៧]កាលណោះមនុស្សម្នាគិតតែស៊ីផឹក
រៀបការប្ដីប្រពន្ធ រហូតដល់ថ្ងៃលោកណូអេចូលក្នុងទូកធំ ហើយ
ទឹកជំនន់ឡើងលិចបំផ្លាញមនុស្សអស់[ឋ]។ [២៨]នៅគ្រាបុត្រមនុស្ស
យាងមក ក៏ដូចកាលនៅជំនាន់លោកឡុត *[ឌ]ដែរ កាលណោះ
មនុស្សម្នាស៊ីផឹក លក់ដូរ ដាំដំណាំ និងសង់ផ្ទះ។ [២៩]ប៉ុន្តែ នៅថ្ងៃ
ដែលលោកឡុតចាកចេញពីក្រុងសូដុម មានភ្លើង និងស្ពាន់ធ័រ បង្អុរ
ពីលើមេឃមក ដូចភ្លៀងបំផ្លាញអ្នកក្រុងទាំងអស់គ្នាទៅ។ [៣០]នៅ
ថ្ងៃដែលបុត្រមនុស្សបង្ហាញខ្លួន ក៏នឹងមានហេតុការណ៍ដូច្នោះ
ដែរ។ [៣១]នៅថ្ងៃនោះ អ្នកនៅលើដំបូលផ្ទះ ហើយមានរបស់របរ
ទុកនៅក្នុងផ្ទះ កុំចុះទៅយកឡើយ។ រីឯអ្នកនៅចម្ការ ក៏ដូច្នោះ
ដែរ កុំវិលត្រឡប់ទៅផ្ទះវិញឲ្យសោះ។ [៣២]ចូរនឹកចាំអំពីរឿងដែល
កើតមានដល់ភរិយាលោកឡុត។ [៣៣]អ្នកដែលខំរក្សាជីវិតរបស់
ខ្លួន នឹងបាត់បង់ជីវិត រីឯអ្នកដែលបាត់បង់ជីវិត នឹងបានរួចជីវិត
វិញ។ [៣៤]ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា នៅយប់នោះ បើ មានពីរនាក់
ដេកលើគ្រែជាមួយគ្នា ព្រះជាម្ចាស់យកម្នាក់ទៅទុក ម្នាក់ទៀត
ឲ្យនៅ។ [៣៥]បើស្ត្រីពីរនាក់កិនស្រូវជាមួយគ្នា ព្រះជាម្ចាស់ យក
ម្នាក់ទៅទុក ម្នាក់ទៀតឲ្យនៅ។ {[៣៦]បើមានបុរសពីរនាក់នៅ ក្នុង
ចម្ការ ព្រះជាម្ចាស់យកម្នាក់ទៅទុក ម្នាក់ទៀតឲ្យនៅ}»។

[៣៧]ពួកសាវ័ក *ទូលសួរព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់ តើ
ហេតុការណ៍ទាំងនេះនឹងកើតមាននៅទីណា?»។ ព្រះអង្គមាន
ព្រះបន្ទូលតបថា៖ «សាកសពនៅទីណា ត្មាតក៏នឹងមកជុំគ្នានៅ
ទីនោះដែរ»។

---

**ឋ**, កំណើតពិភពលោក (លោកុប្បត្តិ)៦-៧។ • **ឌ**, កំណើតពិភពលោក(លោកុប្បត្តិ) ១៩។

## ប្រស្នាអំពីចៅក្រម និងស្ត្រីមេម៉ាយ

១៨ [១]បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នា
ពន្យល់សាវ័ក*ឲ្យដឹងថា ត្រូវតែអធិដ្ឋានជានិច្ច
មិនត្រូវរសាយចិត្តឡើយ៖
[២]«នៅក្នុងក្រុងមួយ មានចៅក្រមម្នាក់ជាមនុស្សមិនកោតខ្លាច
ព្រះជាម្ចាស់ ហើយមិនកោតក្រែងនរណាឡើយ។ [៣]មានស្ត្រី
មេម៉ាយម្នាក់នៅក្នុងក្រុងនោះដែរ គាត់តែងមកអង្វរចៅក្រមថា
"សូមលោករកយុត្តិធម៌ឲ្យនាងខ្ញុំផង"។ [៤]ប៉ុន្តែ ចៅក្រមមិនព្រម
កាត់ក្ដីឲ្យភ្លាមៗទេ លោកចេះតែពន្យារពេលយ៉ាងយូរ។ ក្រោយ
មក លោកនឹកក្នុងចិត្តថា "ទោះបីអញមិនកោតខ្លាចព្រះជាម្ចាស់
មិនកោតក្រែងនរណាក៏ដោយ [៥]ក៏អញត្រូវតែកាត់ក្ដីឲ្យស្ត្រីមេម៉ាយ
នេះដែរ ព្រោះគាត់ចេះតែមករំអុកអញគ្រប់ពេលវេលា។ បើអញ
មិនកាត់ក្ដីឲ្យគាត់ទេ មុខជាគាត់មករំខានអញមិនចេះចប់មិនចេះ
ហើយ"»។
[៦]ព្រះអម្ចាស់មានព្រះបន្ទូលបន្ថែមទៀតថា៖ «ចូរពិចារណា
ពាក្យរបស់ចៅក្រមដ៏អាក្រក់នេះចុះ។ [៧]ចំណង់បើព្រះជាម្ចាស់
វិញ ព្រះអង្គរឹតតែរកយុត្តិធម៌ឲ្យអស់អ្នក ដែលព្រះអង្គបានជ្រើស
រើស ហើយដែលអង្វរព្រះអង្គទាំងយប់ទាំងថ្ងៃ ព្រះអង្គគ្រាន់តែ
បង្អង់ប៉ុណ្ណោះ[៣៩]។ [៨]ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះអង្គនឹងរកយុត្តិ
ធម៌ ឲ្យគេក្នុងរយៈពេលដ៏ខ្លី។ ប៉ុន្តែ ពេលបុត្រមនុស្ស*មកដល់
តើលោកឃើញមនុស្សមានជំនឿនៅលើផែនដីនេះឬទេ?»។

---

៣៩, យើងអាចបកប្រែម៉្យាងទៀតថា:«,,,ព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ចំពោះគេ»។

## បុរសម្នាក់ខាងគណៈផារីស៊ី និងអ្នកទារពន្ធ

៩ព្រះអង្គមានព្រះបន្ទូលជាប្រស្នាមួយទៀត ទៅកាន់អ្នកខ្លះ
ដែលនឹកស្មានថា ខ្លួនជាមនុស្សសុចរិត ហើយបែរជាមើលងាយ
អ្នកដទៃ។ ១០ព្រះអង្គមានព្រះបន្ទូលថា៖ «មានបុរសពីរនាក់ឡើង
ទៅអធិដ្ឋាន *ក្នុងព្រះវិហារ *។ ម្នាក់ខាងគណៈផារីស៊ី* ម្នាក់ទៀត
ជាអ្នកទារពន្ធ *។ ១១បុរសខាងគណៈផារីស៊ីឈរអធិដ្ឋានក្នុងចិត្ត



ថា "បពិត្រព្រះជាម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ព្រោះ
ទូលបង្គំមិនដូចជនឯទៀតៗទេ អ្នកទាំងនោះសុទ្ធតែជាចោរ ជា
មនុស្សទុច្ចរិត ជាមនុស្សប្រព្រឹត្តអំពើផិតក្បត់ ហើយទូលបង្គំក៏
មិនដូចអ្នកទារពន្ធនេះដែរ ១២ទូលបង្គំតមអាហារពីរដងក្នុងមួយ
អាទិត្យ ហើយទូលបង្គំថ្វាយរបស់អ្វីៗទាំងអស់ដែលទូលបង្គំរក
បានមួយភាគដប់ដល់ព្រះអង្គ"។ ១៣រីឯអ្នកទារពន្ធ គាត់ឈរនៅ
ពីចម្ងាយមិនទាំងហ៊ានងើបមុខផង។ គាត់គក់ទ្រូងទូលថា "ឱ
ព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំជាមនុស្សបាបផង"។
១៤ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់ប្រោសអ្នកទារពន្ធនេះឲ្យ

បានសុចរិត ហើយគាត់ត្រឡប់ទៅផ្ទះវិញ រីឯបុរសខាងគណៈផារីស៊ី
មិនបានសុចរិតទេ។ អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេ
បន្ទាបចុះ រីឯអ្នកដែលបន្ទាបខ្លួននឹងត្រូវគេលើកតម្កើងវិញ»។

## ព្រះយេស៊ូប្រទានពរឲ្យក្មេងៗ

(ម៉ាថាយ ១៩, ១៣-១៥ ម៉ាកុស ១០, ១៣-១៦)

១៥មានមនុស្សម្នាបីទារក មកឲ្យព្រះយេស៊ូដាក់ព្រះហស្តលើវា។
ឃើញដូច្នោះ ពួកសាវ័ក*ស្ដីបន្ទោសគេ ១៦តែព្រះយេស៊ូសុំឲ្យ
គេយកទារកទាំងនោះមកជិតព្រះអង្គ រួចទ្រង់មានព្រះបន្ទូលថា៖
«ទុកឲ្យក្មេងៗមករកខ្ញុំចុះ កុំឃាត់ពួកវាឡើយ ដ្បិតមានតែអ្នក
មានចិត្តដូចក្មេងទាំងនេះទេ ទើបចូលទៅក្នុងព្រះរាជ្យ*ព្រះជា
ម្ចាស់បាន។ ១៧ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណា
មិនព្រមទទួលព្រះរាជ្យព្រះជាម្ចាស់ ដូចក្មេងតូចមួយទេ អ្នកនោះ
ចូលក្នុងព្រះរាជ្យព្រះអង្គមិនបានឡើយ»។

## អ្នកមានម្នាក់ចង់បានជីវិតអស់កល្បជានិច្ច

(ម៉ាថាយ ១៩, ១៦-៣០ ម៉ាកុស ១០, ១៧-៣១)

១៨មាននាម៉ឺនម្នាក់ ទូលសួរព្រះយេស៊ូថា៖ «លោកគ្រូដ៏សប្បុរស
អើយ! តើខ្ញុំត្រូវធ្វើអ្វី ដើម្បីឲ្យបានទទួលជីវិតអស់កល្បជានិច្ចទុក
ជាមត៌ក?»។ ១៩ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ហេតុអ្វីបាន
ជាលោកថាខ្ញុំសប្បុរសដូច្នេះ? ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ
គ្មាននរណាម្នាក់សប្បុរសឡើយ។ ២០លោកស្គាល់វិន័យ*ស្រាប់
ហើយថា "កុំប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់មនុស្ស កុំលួចទ្រព្យ

សម្បត្តិគេ កុំនិយាយកុហកធ្វើឲ្យគេមានទោស ចូរគោរពមាតា
បិតា"[ណ]។ ២១បុរសនោះទូលព្រះយេស៊ូថា "ខ្ញុំបានប្រតិបត្តិតាម
វិន័យទាំងនេះតាំងតែពីក្មេងមក"។ ២២ព្រះយេស៊ូឮដូច្នេះ ទ្រង់
មានព្រះបន្ទូលថា៖ «នៅសល់កិច្ចការមួយទៀតដែលលោកមិន
ទាន់ធ្វើ គឺត្រូវយកអ្វីៗទាំងអស់ដែលលោកមានទៅលក់ ហើយ
ចែកឲ្យជនក្រីក្រ។ ធ្វើដូច្នេះ លោកនឹងបានសម្បត្តិសួគ៌ រួចសឹម
អញ្ជើញមកតាមខ្ញុំចុះ»។ ២៣ពេលនាម៉ឺននោះឮដូច្នេះ គាត់ព្រួយ
ចិត្តយ៉ាងខ្លាំង ដ្បិតគាត់ជាអ្នកមានស្ដុកស្ដម្ភ។ ២៤កាលព្រះយេស៊ូ
ឃើញគាត់ព្រួយចិត្ត ព្រះអង្គមានព្រះបន្ទូលថា៖ «អ្នកមានពិបាក
នឹងចូលទៅក្នុងព្រះរាជ្យ*ព្រះជាម្ចាស់ណាស់ ២៥សត្វអូដ្ឋចូល
តាមប្រហោងម្ជុល ងាយជាងអ្នកមានចូលក្នុងព្រះរាជ្យព្រះជាម្ចាស់
ទៅទៀត»។ ២៦អស់អ្នកដែលឮព្រះបន្ទូលរបស់ព្រះអង្គ ពោល
ឡើងថា៖ «បើដូច្នេះ តើអ្នកណាអាចទទួលការសង្គ្រោះបាន?»។
២៧ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា៖ «ការអ្វីដែលមនុស្សធ្វើពុំ
កើត ព្រះជាម្ចាស់ធ្វើកើតទាំងអស់»។ ២៨លោកសិលាទូលព្រះអង្គ
ថា៖ «ព្រះអង្គទតឃើញស្រាប់ហើយ អ្វីៗដែលយើងខ្ញុំមាន យើង
ខ្ញុំបានលះបង់ចោលទាំងអស់ ហើយមកតាមព្រះអង្គ»។ ២៩ព្រះ
យេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹង
ច្បាស់ថា អ្នកណាលះបង់ផ្ទះសម្បែង ប្រពន្ធកូន ឪពុកម្ដាយ និង
បងប្អូន ដោយយល់ដល់ព្រះរាជ្យព្រះជាម្ចាស់ ៣០អ្នកនោះនឹង
ទទួលបានយ៉ាងច្រើនលើសលប់នៅពេលឥឡូវនេះ ព្រមទាំង
មានជីវិតអស់កល្បជានិច្ចនៅពេលខាងមុខថែមទៀតផង»។

**ណ**, សេរីភាព (និក្ខមនំ) ២០,១២-១៦។

## ព្រះយេស៊ូប្រកាសអំពីព្រះអង្គសោយទិវង្គត

(ម៉ាថាយ ២០,១៧-១៩ ម៉ាកុស ១០, ៣២-៣៤)

៣១ព្រះយេស៊ូនាំសាវ័ក*ទាំងដប់ពីររូប ចេញទៅជាមួយព្រះអង្គ។
ទ្រង់មានព្រះបន្ទូលទៅគេថា៖ «ឥឡូវនេះ យើងឡើងទៅក្រុង
យេរូសាឡឹម អ្វីៗទាំងអស់ដែលព្យាការី*បានចែងទុកអំពីបុត្រ
មនុស្ស*នឹងកើតមាននៅទីនោះ ៣២គេនឹងបញ្ជូនលោកទៅក្នុង
កណ្ដាប់ដៃរបស់សាសន៍ដទៃ ពួកនោះនឹងចំអក ត្មះតិះដៀល
លោក ព្រមទាំងស្ដោះទឹកមាត់ដាក់លោកផង។ ៣៣គេនឹងយក
រំពាត់វាយលោក រួចប្រហារជីវិតលោក។ ប៉ុន្ដែបីថ្ងៃក្រោយមក
លោកនឹងរស់ឡើងវិញ»។ ៣៤ពួកសាវ័កពុំបានយល់ព្រះបន្ទូល
នោះទេ ហើយក៏មិនដឹងថា ព្រះយេស៊ូមានព្រះបន្ទូលអំពីរឿងអ្វី
ផង ព្រោះអត្ថន័យនៅលាក់កំបាំងនៅឡើយ។

## ព្រះយេស៊ូប្រោសមនុស្សខ្វាក់ម្នាក់ឲ្យបានភ្លឺ

(ម៉ាថាយ ២០, ២៩-៣៤ ម៉ាកុស ១០, ៤៦-៥២)

៣៥កាលព្រះយេស៊ូយាងមកជិតដល់ក្រុងយេរីខូ មានមនុស្ស
ខ្វាក់ម្នាក់អង្គុយសុំទាននៅតាមផ្លូវ។ ៣៦ពេលគាត់ឮស្នូរបណ្ដាជន
ដើរតាមនោះ គាត់សួរគេថា មានរឿងអ្វី ៣៧គេប្រាប់គាត់ថា ព្រះយេស៊ូ
ជាអ្នកភូមិណាសារ៉ែត យាងមកតាមផ្លូវនោះ។ ៣៨មនុស្សខ្វាក់ក៏
ស្រែកឡើងថា៖ «ឱព្រះយេស៊ូជាព្រះរាជវង្សព្រះបាទដាវីឌអើយ!
សូមអាណិតមេត្ដាទូលបង្គំផង!»។ ៣៩ពួកអ្នកដែលដើរខាងមុខ
បានឃាត់គាត់ឲ្យនៅស្ងៀម ប៉ុន្ដែ គាត់ស្រែករឹតតែខ្លាំងឡើងៗ
ថា៖ «ឱព្រះរាជវង្សព្រះបាទដាវីឌអើយ សូមអាណិតមេត្ដាទូល
បង្គំផង!»។ ៤០ព្រះយេស៊ូក៏ឈប់ ហើយបញ្ជាគេឲ្យនាំគាត់ចូល

មកជិតព្រះអង្គ។ លុះមនុស្សខ្វាក់ដើរចូលមក ព្រះយេស៊ូមាន
ព្រះបន្ទូលសួរគាត់ថា៖ ៤១«តើអ្នកចង់ឲ្យខ្ញុំធ្វើអ្វី?»។ គាត់ទូល
ព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! សូមព្រះអង្គប្រោសឲ្យភ្នែកទូល
បង្គំបានភ្លឺឡើងវិញផង»។ ៤២ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់
ថា៖ «ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ ចូរឲ្យភ្នែកអ្នកបាន
ភ្លឺឡើងវិញចុះ»។ ៤៣រំពេចនោះ គាត់មើលឃើញវិញភ្លាម ហើយ
គាត់ក៏តាមព្រះយេស៊ូ ទាំងលើកតម្កើងសិរីរុងរឿងរបស់ព្រះជា
ម្ចាស់។ ប្រជាជនទាំងមូលបានឃើញហេតុការណ៍នោះ គេសរសើរ
តម្កើងព្រះជាម្ចាស់ទាំងអស់គ្នា។

## ព្រះយេស៊ូ និងលោកសាខេ

១៩ ១ព្រះយេស៊ូមកដល់ក្រុងយេរីខូ ហើយយាងកាត់
ទីក្រុង។ ២មានបុរសម្នាក់ឈ្មោះសាខេ ជាមេ
លើអ្នកទារពន្ធ* គាត់មានទ្រព្យសម្បត្តិយ៉ាងច្រើន។ ៣គាត់ ចង់
ឃើញព្រះយេស៊ូមានភិនភាគយ៉ាងណា ប៉ុន្តែ ដោយមានមនុស្ស



ច្រើនពេក ហើយដោយគាត់មានមាឌតូចទៀតផងនោះ គាត់
មើលព្រះអង្គមិនឃើញទេ។ ៤គាត់រត់ទៅខាងមុខ ឡើងដើម ឈើ
មួយដើម ចាំមើលព្រះយេស៊ូ ព្រោះព្រះអង្គត្រូវយាងកាត់តាម
នោះ។ ៥កាលព្រះយេស៊ូយាងមកដល់ ព្រះអង្គងើបព្រះភ័ក្ត្រ
ឡើង ហើយមានព្រះបន្ទូលទៅគាត់ថា៖ «លោកសាខេអើយ!
សូមអញ្ជើញចុះមកជាប្រញាប់ ដ្បិតថ្ងៃនេះ ខ្ញុំត្រូវស្នាក់នៅផ្ទះ
លោក»។ ៦លោកសាខេក៏ចុះមកជាប្រញាប់ ហើយទទួលព្រះ
យេស៊ូដោយអំណរ។ ៧កាលមនុស្សទាំងអស់ឃើញដូច្នោះ គេ
រអ៊ូរទាំថា៖ «មើល៍! លោកនេះទៅស្នាក់នៅផ្ទះមនុស្សបាប!»។
៨លោកសាខេក្រោកឈរឡើង ទូលព្រះអម្ចាស់ថា៖ «បពិត្រ
ព្រះអម្ចាស់! ទូលបង្គំនឹងចែកទ្រព្យសម្បត្តិរបស់ទូលបង្គំចំនួន
ពាក់កណ្ដាលដល់មនុស្សក្រីក្រ ហើយប្រសិនបើទូលបង្គំទារពន្ធ
ពីអ្នកណាហួសកម្រិត ទូលបង្គំនឹងសងអ្នកនោះវិញ មួយជាបួន»។
៩ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ថ្ងៃនេះការសង្គ្រោះបាន
មកដល់ផ្ទះនេះហើយ[ឆ] ដ្បិតបុរសនេះជាពូជពង្សរបស់លោក
អប្រាហាំដែរ។ ១០បុត្រមនុស្សបានមក ដើម្បីស្វែងរក និងសង្គ្រោះ
មនុស្សដែលវិនាសបាត់បង់»។

## ប្រស្នាអំពីប្រាក់ណែន

(ម៉ាថាយ ២៥, ១៤-៣០)

១១កាលព្រះយេស៊ូយាងមកជិតដល់ក្រុងយេរូសាឡឹមហើយ
ព្រះអង្គមានព្រះបន្ទូលជាប្រស្នាមួយទៀត ទៅកាន់អស់អ្នកដែល
ស្ដាប់ព្រះអង្គ ដ្បិតអ្នកទាំងនោះនឹកស្មានថា ព្រះរាជ្យ *ព្រះជា
ម្ចាស់នឹងមកដល់ភ្លាមៗនេះជាមិនខាន។ ១២ព្រះអង្គមានព្រះបន្ទូល

**ឆ**, យើងអាចប្រែថា «ព្រះជាម្ចាស់បានសង្គ្រោះអ្នកនៅក្នុងផ្ទះនេះ» ក៏បាន។

ថា៖ «មានបុរសម្នាក់ ជាអ្នកមានត្រកូលខ្ពស់ ចេញដំណើរទៅ
ស្រុកឆ្ងាយ ដើម្បីនឹងទទួលរាជាភិសេក។ កាលណាទទួលរាជា
ភិសេកហើយ លោកនឹងត្រឡប់មកវិញ។ ១៣មុនពេលចេញដំណើរ
ទៅ លោកបានហៅអ្នកបម្រើរបស់លោកដប់នាក់មកប្រគល់ប្រាក់
ឲ្យគេមួយណែន[៩]ម្នាក់ៗ ទាំងផ្ដាំថា "ចូរយកប្រាក់នេះទៅរកស៊ី
រហូតដល់ខ្ញុំត្រឡប់មកវិញ"។ ១៤រីឯអ្នកស្រុកនោះស្អប់លោក បាន
ជាគេចាត់អ្នកតំណាងឲ្យទៅតាមក្រោយនាំពាក្យថា "យើងខ្ញុំមិន
ចង់ឲ្យលោកនេះធ្វើស្ដេចលើយើងខ្ញុំជាដាច់ខាត"។
១៥លុះបានទទួលរាជាភិសេកហើយ ព្រះរាជាក៏យាងត្រឡប់
មកវិញ។ ទ្រង់កោះហៅអ្នកបម្រើទាំងដប់នាក់ ដែលទ្រង់បាន
ប្រគល់ប្រាក់ណែននោះមកសួរ ដើម្បីឲ្យដឹងថា ម្នាក់ៗរកស៊ី
ចំណេញបានប៉ុន្មាន។ ១៦អ្នកបម្រើទីមួយ ចូលមកគាល់ទូលថា
"បពិត្រព្រះអម្ចាស់! ប្រាក់ដែលព្រះអង្គប្រទានមកទូលបង្គំ ចំណេញ
បានដប់ណែន"។ ១៧ព្រះរាជាមានរាជឱង្ការទៅអ្នកនោះថា "ល្អ
ហើយ! អ្នកបម្រើដ៏ប្រសើរអើយ យើងតែងតាំងអ្នកឲ្យគ្រប់គ្រង
លើក្រុងដប់ ដ្បិតអ្នកបានស្មោះត្រង់នឹងកិច្ចការមួយដ៏តូចនេះ"។
១៨អ្នកបម្រើទីពីរចូលមកទូលថា "បពិត្រព្រះអម្ចាស់! ប្រាក់ដែល
ព្រះអង្គប្រទានមកទូលបង្គំ ចំណេញបានប្រាំណែន"។ ១៩ព្រះ
រាជាមានរាជឱង្ការទៅគាត់ថា "យើងតែងតាំងអ្នកឲ្យគ្រប់គ្រង
លើក្រុងប្រាំ"។ ២០អ្នកបម្រើម្នាក់ទៀតចូលមកទូលថា "បពិត្រ
ព្រះអម្ចាស់ នេះនែ៎ ប្រាក់របស់ព្រះអង្គទូលបង្គំបានវេចទុកក្នុង
កន្សែង។ ២១ទូលបង្គំនឹកខ្លាចព្រះអង្គ ដ្បិតទ្រង់ប្រិតប្រៀងណាស់។
ព្រះអង្គតែងប្រមូលយកអ្វីៗ ដែលមិនមែនជារបស់ព្រះអង្គ ហើយ
តែងច្រូតយកផលពីស្រែ ដែលទ្រង់មិនបានសាបព្រោះ"។ ២២ព្រះ
រាជាមានរាជឱង្ការទៅអ្នកបម្រើនោះថា "នែ៎ អ្នកបម្រើអាក្រក់!

---

៩, «ប្រាក់ណែន» សូមអានសេចក្ដីពន្យល់នៅម៉ាថាយ ២៥,១៥។

យើងនឹងកាត់ទោសអ្នក ឲ្យស្របតាមពាក្យសម្ដីរបស់អ្នក។ អ្នក
ដឹងស្រាប់ហើយថា យើងជាមនុស្សប្រិតប្រៀង យើងប្រមូល
យកអ្វីៗ ដែលមិនមែនជារបស់យើង ហើយច្រូតយកផលពីស្រែ
ដែលយើងមិនបានសាបព្រោះ ២៣ហេតុដូចម្ដេច បានជាអ្នកមិន
យកប្រាក់របស់យើងទៅចងការ ដើម្បីឲ្យយើងអាចទទួលទាំង
ដើមទាំងការ នៅពេលយើងត្រឡប់មកវិញ?"។ ២៤បន្ទាប់មក
ព្រះរាជាបញ្ជាទៅអ្នកដែលនៅទីនោះថា "ចូរយកប្រាក់ពីអ្នកនេះ
ប្រគល់ឲ្យអ្នកដែលមានដប់ណែនទៅ"។ ២៥អ្នកទាំងនោះ ទូល
ស្ដេចថា "បពិត្រព្រះអម្ចាស់! គាត់មានប្រាក់ដប់ណែនហើយ"។
២៦ព្រះរាជាមានរាជឱង្ការតបថា "យើងសុំប្រាប់អ្នករាល់គ្នាថា អ្នក
ណាមានហើយ អ្នកនោះនឹងទទួលថែមទៀត។ រីឯអ្នកដែលគ្មាន
វិញ គេនឹងដកហូតនូវអ្វីៗដែលអ្នកនោះមាន សូម្បីតែបន្តិចបន្តួច
ក៏មិនសល់ផង។ ២៧ម្យ៉ាងទៀត ពួកខ្មាំងសត្រូវដែលមិនចង់ឲ្យ
យើងគ្រងរាជ្យលើគេទេនោះ ចូរនាំគេមក ហើយសម្លាប់ចោល
នៅមុខយើងចុះ"»។

## ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

(ម៉ាថាយ ២១,១-១១ ម៉ាកូស ១១,១-១១ យ៉ូហាន ១២,១២-១៩)

២៨កាលព្រះយេស៊ូមានព្រះបន្ទូលដូច្នោះ ហើយព្រះអង្គក៏
យាងនាំមុខបណ្ដាជន ឡើងទៅក្រុងយេរូសាឡឹម។ ២៩លុះព្រះអង្គ
យាងជិតដល់ភូមិបេតផាសេ និងភូមិបេតថានី ដែលនៅចង្កេះភ្នំ
ដើមអូលីវ ព្រះអង្គចាត់សាវ័ក*ពីររូបឲ្យទៅមុន ៣០ដោយមាន
ព្រះបន្ទូលថា៖ «ចូរទៅភូមិខាងមុខនោះ ពេលអ្នកទៅដល់ អ្នក
នឹងឃើញកូនលាមួយដែលគេចងនៅទីនោះ ពុំទាន់មាននរណា

ជិះនៅឡើយទេ ចូរស្រាយវាដឹកមក។ ៣១ប្រសិនបើមានគេសួរ
ថា "ហេតុអ្វីបានជាអ្នកស្រាយវា?" ចូរឆ្លើយទៅគេថា "ព្រះអម្ចាស់
ត្រូវការវា"»។ ៣២សាវ័កទាំងពីរក៏ចេញទៅ ហើយឃើញដូចព្រះ
យេស៊ូមានព្រះបន្ទូលប្រាប់គេមែន។ ៣៣ពេលគេកំពុងស្រាយកូន
លា ម្ចាស់វាសួរថា៖ «ហេតុអ្វីបានជាអ្នកស្រាយលានេះ?» ៣៤សាវ័ក
ឆ្លើយថា៖ «ព្រះអម្ចាស់ត្រូវការវា»។ ៣៥បន្ទាប់មក អ្នកទាំងពីរដឹក
កូនលាយកមកថ្វាយព្រះយេស៊ូ ហើយក្រាលអាវធំរបស់ខ្លួនលើ
ខ្នងវា ថ្វាយព្រះអង្គគង់។ ៣៦នៅពេលព្រះអង្គយាងទៅមុខ មនុស្ស
ម្នាយកអាវធំរបស់ខ្លួនមកក្រាលតាមផ្លូវ។ ៣៧កាលព្រះយេស៊ូ
យាងតាមផ្លូវ ដែលចុះពីភ្នំដើមអូលីវ មកជិតដល់ក្រុងយេរូសាឡឹម



មានសាវ័កច្រើនកុះកររអរសប្បាយ នាំគ្នាបន្លឺសំឡេងសរសើរ
តម្កើងព្រះជាម្ចាស់ អំពីការអស្ចារ្យទាំងប៉ុន្មាន ដែលគេបានឃើញ។
៣៨គេពោលថា៖

«សូមព្រះជាម្ចាស់ប្រទានពរដល់
ព្រះមហាក្សត្រដែលយាងមក
ក្នុងព្រះនាមព្រះអម្ចាស់!

សូមសន្តិភាពកើតពីស្ថានបរមសុខ *មក
សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត!»[ឆ]។
៣៩មានអ្នកខាងគណៈផារីស៊ី *ខ្លះ ដែលនៅក្នុងចំណោមបណ្ដា
ជនទូលព្រះយេស៊ូថា៖ «លោកគ្រូ សូមឃាត់សិស្សរបស់លោក
ឲ្យនៅស្ងៀមផង!»។ ៤០ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ខ្ញុំ
សុំប្រាប់ឲ្យអ្នករាល់គ្នាដឹងថា ប្រសិនបើអ្នកទាំងនេះនៅស្ងៀម
ដុំថ្មមុខជាស្រែកជំនួសគេវិញមិនខាន»។

## ព្រះយេស៊ូសោកសៅស្រណោះក្រុងយេរូសាឡឹម

៤១កាលព្រះយេស៊ូយាងជិតដល់ក្រុងយេរូសាឡឹម ព្រះអង្គទត
ឃើញទីក្រុង ហើយទ្រង់ព្រះកន្សែងនឹកអាណិតក្រុងនោះ ទាំង
មានព្រះបន្ទូលថា៖ ៤២«យេរូសាឡឹមអើយ! គួរឲ្យស្ដាយពេក នៅ
ថ្ងៃនេះ អ្នកពុំបានយល់ហេតុការណ៍ដែលផ្ដល់សេចក្ដីសុខសាន្ត
មកអ្នកសោះ ដោយអត្ថន័យនៅលាក់កំបាំងនៅឡើយ អ្នកពុំអាច
មើលឃើញបានទេ។ ៤៣នៅពេលខាងមុខខ្មាំងសត្រូវនឹងមកបោះ
ទ័ពឡោមព័ទ្ធជុំវិញអ្នក ហើយវាយប្រហារអ្នកពីគ្រប់ទិស ៤៤គេ
នឹងកម្ទេចអ្នកចោល ព្រមទាំងសម្លាប់អ្នកក្រុងឲ្យវិនាសបង់ ផង។
គេមិនទុកឲ្យដុំថ្មនៅត្រួតពីលើគ្នាក្នុងក្រុងទៀតឡើយ ដ្បិត អ្នកពុំ
បានទទួលស្គាល់ពេលកំណត់ ដែលព្រះជាម្ចាស់បានយាងមក
សង្គ្រោះអ្នកទេ»។

**ឆ**, ទំនុកតម្កើង ១១៨,២៦។

## ព្រះយេស៊ូដេញអ្នកលក់ដូរចេញពីព្រះវិហារ*

(ម៉ាថាយ ២១,១២-១៧ ម៉ាកុស ១១,១៥-១៩ យ៉ូហាន ២,១៣-២២)

៤៥ព្រះយេស៊ូយាងចូលព្រះវិហារ ហើយដេញអ្នកលក់ដូរចេញ
ពីទីនោះ ៤៦ដោយមានព្រះបន្ទូលទៅគេថា៖ «ក្នុងគម្ពីរមានចែង
ថា "ដំណាក់របស់យើង ជាកន្លែងសម្រាប់អធិដ្ឋាន"[ឆ] តែអ្នករាល់
គ្នា បែរជាយកធ្វើសំបុកចោរ[ជ]ទៅវិញ»។
៤៧ព្រះយេស៊ូបានបង្រៀនគេនៅក្នុងព្រះវិហារជារៀងរាល់ថ្ងៃ។
ក្រុមនាយកបូជាចារ្យ* ពួកធម្មាចារ្យ* និងពួកមន្ត្រីនាំគ្នារកមធ្យោបាយ
ធ្វើគុតព្រះអង្គ។ ៤៨ប៉ុន្តែ គេមិនដឹងជាត្រូវប្រើវិធីណាឡើយ ដ្បិត
ប្រជាជនទាំងមូល ប្រឹងស្ដាប់ព្រះបន្ទូលព្រះអង្គ ដោយយកចិត្ត
ទុកដាក់។

## អំណាចរបស់ព្រះយេស៊ូ

(ម៉ាថាយ ២១,២៣-២៧ ម៉ាកុស ១១,២៧-៣៣)

២០ ១ថ្ងៃមួយ ព្រះយេស៊ូកំពុងតែបង្រៀនប្រជាជន
នៅក្នុងព្រះវិហារ ព្រមទាំងផ្សព្វផ្សាយដំណឹង
ល្អ* មានក្រុមនាយកបូជាចារ្យ* និងពួកធម្មាចារ្យ*នាំគ្នាមកជាមួយ
ពួកព្រឹទ្ធាចារ្យ ២ទូលសួរព្រះអង្គថា៖ «សុំលោកប្រាប់ឲ្យយើងដឹង
ផង លោកធ្វើការទាំងនេះ ដោយអាងលើអំណាចអ្វី? តើនរណា
ប្រគល់អំណាចឲ្យលោក?»។ ៣ព្រះយេស៊ូមានព្រះបន្ទូលតបថា៖
«ខ្ញុំសុំសួរសំណួរមួយដល់អស់លោកដែរ សូមប្រាប់ខ្ញុំមើល៍ ៤តើ
នរណាចាត់លោកយ៉ូហានឲ្យមកធ្វើពិធីជ្រមុជទឹក*? ព្រះជាម្ចាស់
ឬមនុស្ស?»។ ៥គេពិគ្រោះគ្នាថា៖ «បើយើងឆ្លើយថា "ព្រះជាម្ចាស់

ឆ, អេសាយ ៥៦,៧។ • ជ, យេរេមី ៧,១១។

ចាត់លោកយ៉ូហានឲ្យមក" គាត់មុខជាសួរយើងថា "ហេតុអ្វីបាន
ជាអ្នករាល់គ្នាមិនជឿលោកយ៉ូហាន?"។ [6]បើយើងឆ្លើយថា "មនុស្ស
ចាត់លោកឲ្យមក" ប្រជាជនទាំងមូលមុខជាយកដុំថ្មគប់សម្លាប់
យើងមិនខាន ដ្បិតគេជឿជាក់ថា លោកយ៉ូហានពិតជាព្យា
ការី*មែន»។ [7]ដូច្នេះ គេឆ្លើយទៅព្រះយេស៊ូថា៖ «យើងមិនដឹង
ទេ មិន ដឹងជាអ្នកណាចាត់លោកយ៉ូហានឲ្យមកធ្វើពិធីជ្រមុជទឹក
ឡើយ»។ [8]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «រីឯខ្ញុំវិញ ខ្ញុំក៏មិន
ប្រាប់អស់ លោកថា ខ្ញុំធ្វើការទាំងនេះ ដោយអាងលើអំណាចអ្វី
ដែរ»។

## ប្រស្នាអំពីអ្នកថែរក្សាចម្ការទំពាំងបាយជូរ

(ម៉ាថាយ ២១,៣៣-៤៦ ម៉ាកុស ១២,១-១២)

[9]បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅប្រជាជនជាប្រស្នា
ដូចតទៅ៖ «មានបុរសម្នាក់បានដាំទំពាំងបាយជូរមួយចម្ការ ហើយ
ប្រវាស់ឲ្យពួកកសិករមើលថែទាំ រួចចេញដំណើរពីស្រុកនោះ
អស់រយៈពេលយ៉ាងយូរ។ [10]លុះដល់ទំពាំងបាយជូរទុំ គាត់ចាត់
អ្នកបម្រើម្នាក់ ឲ្យមកជួបពួកអ្នកថែចម្ការ ដើម្បីទទួលយកផល
ដែលជាចំណែករបស់គាត់ ប៉ុន្តែ ពួកកសិករបានវាយដំអ្នកបម្រើ
ហើយបណ្ដេញឲ្យត្រឡប់ទៅវិញដៃទទេ។ [11]ម្ចាស់ចម្ការក៏ចាត់
អ្នកបម្រើម្នាក់ទៀតឲ្យមក ប៉ុន្តែ ពួកកសិករបានវាយដំអ្នកនេះ
ដែរ ហើយជេរបណ្ដេញឲ្យត្រឡប់ទៅវិញដៃទទេ។ [12]គាត់ក៏ចាត់
អ្នកបម្រើម្នាក់ទៀត ឲ្យមកជាលើកទីបី។ អ្នកថែចម្ការបានវាយដំ
អ្នកបម្រើនេះឲ្យរបួស ហើយបោះទៅខាងក្រៅចម្ការ។ [13]ម្ចាស់
ចម្ការគិតថា "តើខ្ញុំត្រូវធ្វើដូចម្ដេច? ខ្ញុំនឹងចាត់កូនប្រុសដ៏ជាទី

ស្រឡាញ់របស់ខ្ញុំឲ្យទៅម្ដង គេមុខជាគោរពកោតខ្លាចកូនខ្ញុំពុំ
ខាន។ ¹⁴ប៉ុន្តែ ពេលពួកកសិករឃើញកូនប្រុសម្ចាស់ចម្ការមក
ដល់ គេពិគ្រោះគ្នាថា "អ្នកនេះជាអ្នកទទួលកេរមត៌កពីម្ចាស់
ចម្ការទៅថ្ងៃក្រោយ បើយើងសម្លាប់វាចោល ចម្ការនេះនឹងធ្លាក់
មកជាសម្បត្តិរបស់យើង"។ ¹⁵គេក៏បោះកូនប្រុសម្ចាស់ចម្ការទៅ
ខាងក្រៅ ហើយសម្លាប់ចោល។ តើម្ចាស់ចម្ការនឹងធ្វើយ៉ាងដូច
ម្ដេចដល់អ្នកទាំងនោះ?។ ¹⁶គឺគាត់មុខជាមកសម្លាប់អ្នកថែរក្សា
ចម្ការទាំងនោះមិនខាន រួចប្រគល់ចម្ការទំពាំងបាយជូរទៅឲ្យ
អ្នកផ្សេងទៀត»។ កាលបានឮព្រះបន្ទូលនេះគេពោលថា៖ «ទេ!
ឲ្យកើតមានដូច្នោះឡើយ»។ ¹⁷ព្រះយេស៊ូទតសម្លឹងទៅគេហើយ
មានព្រះបន្ទូលថា៖ «ក្នុងគម្ពីរមានចែងថា៖

"ថ្មដែលពួកជាងសង់ផ្ទះបោះចោល
បានត្រឡប់មកជាថ្មគ្រឹះដ៏សំខាន់បំផុត"[ប]

តើពាក្យនេះមានន័យដូចម្ដេច?។ ¹⁸អ្នកណាដួលលើថ្មនេះ
អ្នកនោះមុខជាត្រូវបាក់បែកខ្ទេចខ្ទាំមិនខាន។ បើថ្មនេះសង្កត់លើ
អ្នកណា មុខជាកិនកម្ទេចអ្នកនោះឲ្យស្លាប់ជាប្រាកដដែរ»។

## អំពីពន្ធដារ

(ម៉ាថាយ ២២,១៥-២២ ម៉ាកុស ១២,១៣-១៧)

¹⁹ពេលនោះ ពួកធម្មាចារ្យ* និងពួកនាយកបូជាចារ្យ* រក
មធ្យោបាយចាប់ព្រះយេស៊ូ ដ្បិតគេយល់ថា ព្រះអង្គមានព្រះបន្ទូល
ជាពាក្យប្រស្នាសំដៅទៅលើពួកគេ ប៉ុន្តែពួកគេខ្លាចប្រជាជន។
²⁰ពួកគេនាំគ្នាឃ្លាំមើលព្រះយេស៊ូ ហើយចាត់មនុស្សឲ្យទៅតាម
ដានយកការណ៍ពីព្រះអង្គ។ អ្នកទាំងនោះតាំងខ្លួនជាមនុស្សប្រកាន់

ប, ទំនុកតម្កើង ១១៨,២២។

ឬកពាត្រឹមត្រូវ ចាំចាប់កំហុសព្រះយេស៊ូនៅពេលព្រះអង្គមាន
ព្រះបន្ទូល ដើម្បីចាប់បញ្ជូនព្រះអង្គទៅអាជ្ញាធរ និងទៅក្នុងអំណាច
របស់លោកទេសាភិបាល។ ២១គេទូលសួរព្រះអង្គថា៖ «លោក
គ្រូ! យើងខ្ញុំដឹងថា ពាក្យទាំងប៉ុន្មានដែលលោកគ្រូមានប្រសាសន៍
និងពាក្យដែលលោកគ្រូប្រៀនប្រដៅ សុទ្ធតែត្រឹមត្រូវទាំងអស់។
លោកគ្រូប្រៀនប្រដៅសេចក្ដីពិត អំពីរបៀបរស់នៅដែលគាប់
ព្រះហឫទ័យព្រះជាម្ចាស់ ដោយពុំរើសមុខនរណាឡើយ។ ២២សូម
លោកប្រាប់យើងខ្ញុំផង តើវិន័យ *របស់យើងអនុញ្ញាតឲ្យបង់ពន្ធដារ
ថ្វាយព្រះចៅអធិរាជរ៉ូម៉ាំងឬទេ?»។
២៣ព្រះយេស៊ូឈ្វេងយល់ពុតត្បុតរបស់ពួកគេ ទើបព្រះអង្គ
មានព្រះបន្ទូលថា៖ ២៤«ចូរបង្ហាញប្រាក់មួយកាក់ឲ្យខ្ញុំមើលមើល៍
តើលើកាក់នេះមានរូបនរណា ឈ្មោះនរណា?»។ គេឆ្លើយថា៖
«រូប និងឈ្មោះព្រះចៅអធិរាជ»។ ២៥ព្រះយេស៊ូក៏មានព្រះបន្ទូល
ទៅគេថា៖ «អ្វីៗដែលជារបស់ព្រះចៅអធិរាជ ចូរថ្វាយទៅព្រះចៅ
អធិរាជវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅ
ព្រះជាម្ចាស់វិញដែរ»។
២៦អ្នកទាំងនេះ ពុំអាចចាប់កំហុសព្រះអង្គ នៅពេលដែល
ព្រះអង្គមានព្រះបន្ទូល នៅមុខប្រជាជនបានឡើយ។ ផ្ទុយទៅ
វិញ ព្រះបន្ទូលឆ្លើយតបរបស់ព្រះអង្គធ្វើឲ្យគេងឿងឆ្ងល់ ហើយ
គេក៏នៅស្ងៀម។

## អំពីមនុស្សស្លាប់នឹងរស់ឡើងវិញ

(ម៉ាថាយ ២២,២៣-៣៣ ម៉ាកុស ១២,១៨-២៧)

២៧មានអ្នកខាងគណៈសាឌូស៊ី *ខ្លះ ចូលមកគាល់ព្រះអង្គ។

ពួកសាឌូស៊ីមិនជឿថា មនុស្សស្លាប់នឹងរស់ឡើងវិញទេ។ គេទូល
សួរព្រះយេស៊ូថា៖ ២៨«លោកគ្រូ! លោកម៉ូសេ *បានចែងច្បាប់
ទុកឲ្យយើងថា បើបុរសណាមានប្រពន្ធ ហើយស្លាប់ទៅ តែគ្មាន
កូនសោះ ត្រូវឲ្យប្អូនប្រុសរបស់បុរសនោះរៀបការនឹងបងថ្លៃ ដើម្បី
បន្តពូជឲ្យបងប្រុសរបស់ខ្លួន[ផ]។ ២៩ឧបមាថា មានបងប្អូនប្រុសៗ
ប្រាំពីរនាក់ បុរសបងបង្អស់បានរៀបការ ហើយស្លាប់ទៅ តែគ្មាន
កូនសោះ។ ៣០ប្អូនបន្ទាប់ រួចប្អូនទីបីក៏រៀបការនឹងបងថ្លៃមេម៉ាយ
នោះ ហើយស្លាប់ទៅទាំងឥតមានកូន។ ៣១បន្ទាប់មក បងប្អូន
ទាំងប្រាំពីរនាក់បានរៀបការនឹងស្ត្រីនោះ ហើយគ្រប់គ្នាបានស្លាប់
ទៅតែគ្មានកូនទេ។ ៣២នៅទីបំផុតស្ត្រីក៏ស្លាប់ទៅដែរ។ ៣៣លុះ
ដល់ពេលមនុស្សស្លាប់នឹងរស់ឡើងវិញ តើនាងនោះបានទៅជា
ប្រពន្ធនរណា បើបងប្អូនទាំងប្រាំពីរនាក់ សុទ្ធតែបានយកនាង
ធ្វើជាប្រពន្ធគ្រប់គ្នាដូច្នេះ?» ៣៤ព្រះយេស៊ូមានព្រះបន្ទូលតបថា៖
«មនុស្សក្នុងលោកនេះ តែងយកគ្នាជាប្ដីប្រពន្ធ ៣៥ប៉ុន្តែ អស់អ្នក
ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យប្រោសឲ្យរស់ឡើងវិញ នៅ
លោកខាងមុខ គេមិនរៀបការប្ដីប្រពន្ធទៀតឡើយ។ ៣៦អ្នកទាំង
នោះលែងស្លាប់ទៀតហើយ គឺគេបានដូចទេវទូត *។ គេជាបុត្រា
បុត្រីរបស់ព្រះជាម្ចាស់ ដ្បិតគេមានជីវិតរស់ឡើងវិញ។ ៣៧លោក
ម៉ូសេបានចែងទុកយ៉ាងច្បាស់ថា មនុស្សស្លាប់នឹងរស់ឡើងវិញ
នៅត្រង់អត្ថបទស្ដីអំពីគុម្ពបន្លា គឺលោកហៅព្រះអម្ចាស់ថា ជា
ព្រះរបស់លោកអប្រាហាំ ជាព្រះរបស់លោកអ៊ីសាក និងជាព្រះ
របស់លោកយ៉ាកុប[ព]។ ៣៨ព្រះជាម្ចាស់មិនមែនជាព្រះរបស់មនុស្ស
ស្លាប់ទេ ជាព្រះរបស់មនុស្សដែលមានជីវិត។ ចំពោះព្រះអង្គ
មនុស្សទាំងអស់សុទ្ធតែនៅរស់»។ ៣៩ពួកធម្មាចារ្យ *ខ្លះ ទូលព្រះអង្គ
ថា៖ «លោកគ្រូ លោកមានប្រសាសន៍ត្រឹមត្រូវល្អណាស់»។ ៤០បន្ទាប់

ផ, ទុតិយកថា ២៥,៥-៦។ • ព, សេរីភាព ( និក្ខមនំ ) ៣, ៦។

មក គេលែងហ៊ានចោទសួរសំណួរព្រះអង្គអំពីរឿងអ្វីទៀតឡើយ។

## ព្រះគ្រីស្ដជាព្រះអម្ចាស់លើស្ដេចដាវីឌ

(ម៉ាថាយ ២២,៤១-៤៦ ម៉ាកុស ១២,៣៥-៣៧)

៤១ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ហេតុដូចម្ដេចបានជា
មនុស្សម្នាថា ព្រះគ្រីស្ដ *ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌដូច្នេះ?
៤២ដ្បិតក្នុងគម្ពីរទំនុកតម្កើងព្រះបាទដាវីឌមានរាជឱង្ការថា៖

*"ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ព្រះអម្ចាស់*
*របស់ខ្ញុំថា សូមគង់នៅខាងស្ដាំយើង*
៤៣ *ទម្រាំដល់យើងបង្ក្រាបខ្មាំងសត្រូវរបស់ព្រះអង្គ*
*មកដាក់ក្រោមព្រះបាទាព្រះអង្គ"*[ឝ]។

៤៤បើព្រះបាទដាវីឌ ហៅព្រះគ្រីស្ដថា ព្រះអម្ចាស់ដូច្នេះ តើ
ឲ្យព្រះគ្រីស្ដត្រូវជាព្រះរាជវង្សរបស់ព្រះបាទដាវីឌដូចម្ដេចកើត!»។

## ព្រះយេស៊ូមានព្រះបន្ទូលឲ្យប្រយ័ត្ននឹងពុតត្បុតរបស់ពួកធម្មាចារ្យ

(ម៉ាថាយ ២៣,១-៣៦ ម៉ាកុស ១២,៣៨-៤០)

៤៥នៅពេលប្រជាជនទាំងមូលកំពុងស្ដាប់ព្រះអង្គ ព្រះយេស៊ូ
មានព្រះបន្ទូលទៅកាន់ពួកសាវ័កថា៖ ៤៦«ចូរប្រយ័ត្ននឹងពួកធម្មាចារ្យ*
ឲ្យមែនទែន ពួកនោះចូលចិត្តពាក់អាវវែង ដើរចុះដើរឡើង ហើយ
ចូលចិត្តឲ្យគេឱនកាយគោរពនៅតាមផ្សារ ព្រមទាំងរើសកន្លែង
អង្គុយនៅមុខគេក្នុងធម្មសាលា* និងចូលចិត្តកន្លែងកិត្តិយស នៅ
ពេលជប់លៀង។ ៤៧អ្នកទាំងនោះតែងនាំគ្នាឆបោកយកទ្រព្យ

---
**ឝ**, ទំនុកតម្កើង ១១០,១។

សម្បត្តិរបស់ស្ត្រីមេម៉ាយ ដោយធ្វើឫកជាសូត្រធម៌យ៉ាងយូរ។ ពួកគេមុខជាត្រូវទទួលទោសយ៉ាងធ្ងន់បំផុត»។

## តង្វាយរបស់ស្ត្រីមេម៉ាយ

(ម៉ាកុស ១២,៤១-៤៤)

២១ ១ព្រះយេស៊ូទតឃើញពួកអ្នកមាន យកប្រាក់
មកដាក់ក្នុងហិប ថ្វាយព្រះជាម្ចាស់។ ២ព្រះអង្គ
ទតឃើញស្ត្រីមេម៉ាយក្រីក្រម្នាក់ យកប្រាក់ពីរសេនមកដាក់ក្នុង
ហិបនោះដែរ។ ៣ព្រះអង្គមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះ បានដាក់ប្រាក់ច្រើន
ជាងគេទាំងអស់ ៤ដ្បិតអ្នកទាំងនោះ បានយកប្រាក់សំណល់របស់
ខ្លួនមកដាក់ក្នុងហិប។ រីឯស្ត្រីមេម៉ាយនេះវិញ ទោះបីនាងក្រីក្រ
យ៉ាងណាក៏ដោយ ក៏នាងយកប្រាក់ទាំងអស់ដែលនាងត្រូវការជា
ចាំបាច់សម្រាប់ចិញ្ចឹមជីវិត មកដាក់ក្នុងហិបថ្វាយព្រះជាម្ចាស់ដែរ»។

## ព្រះយេស៊ូមានព្រះបន្ទូលអំពីការបំផ្លាញព្រះវិហារ និងហេតុការណ៍នៅគ្រាចុងក្រោយ

(ម៉ាថាយ ២៤, ១-១៤ ម៉ាកុស ១៣, ១-១៣)

៥អ្នកខ្លះកំពុងនិយាយសរសើរលំអរបស់ព្រះវិហារ ដែលគាត់
តែងឡើងដោយថ្មយ៉ាងល្អប្រណីត និងមានតាំងវត្ថុផ្សេងៗ ដែល
គេយកមកថ្វាយព្រះជាម្ចាស់។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ ៦
«នៅពេលខាងមុខ អ្វីៗដែលអ្នករាល់គ្នាឃើញនៅពេលនេះ នឹង
ត្រូវរលំបាក់បែកអស់ជាមិនខាន លែងមានថ្មត្រួតពីលើថ្មទៀត

ហើយ»។
   ៧គេទូលសួរព្រះអង្គថា៖ «ព្រះគ្រូអើយ! ហេតុការណ៍ទាំង
នោះនឹងកើតមាននៅពេលណា? តើមានទីសម្គាល់អ្វីឲ្យយើង
ដឹងថា ព្រឹត្តិការណ៍ទាំងនោះជិតមកដល់?»។ ៨ព្រះយេស៊ូមាន
ព្រះបន្ទូលឆ្លើយថា៖ «ចូរប្រុងប្រយ័ត្ន កុំបណ្ដោយនរណាបញ្ឆោត
អ្នករាល់គ្នាឲ្យវង្វេងបានឡើយ ដ្បិតនឹងមានមនុស្សជាច្រើន យក
ឈ្មោះខ្ញុំមកប្រើដោយពោលថា "ខ្ញុំនេះហើយជាព្រះគ្រីស្ដ*" ឬ
ថា "ពេលកំណត់មកដល់ហើយ" កុំតាមអ្នកទាំងនោះឲ្យ
សោះ។ ៩កាលណាអ្នករាល់គ្នាឮគេនិយាយអំពីសង្គ្រាម ឬអំពី
ការបះបោរ មិនត្រូវភ័យតក់ស្លុតឡើយ ដ្បិតហេតុការណ៍ទាំង
នេះ ត្រូវតែកើតឡើងជាមុន ប៉ុន្តែមិនទាន់ដល់អវសានកាលនៃ
ពិភពលោកភ្លាមៗទេ»។ ១០ព្រះអង្គមានព្រះបន្ទូលថែមទៀតថា៖
*«ប្រជាជាតិ មួយនឹងធ្វើសង្គ្រាមតទល់នឹងប្រជាជាតិមួយទៀត
ប្រទេសមួយតទល់នឹងប្រទេសមួយទៀត*[ម] ១១នឹងមានរញ្ជួយផែន
ដីជាខ្លាំង នៅ តាមតំបន់ផ្សេងៗ ហើយនឹងមានកើតទុរ្ភិក្ស ជំងឺ
រាតត្បាត ព្រមទាំងមានអព្ភូតហេតុផ្សេងៗ បណ្ដាលឲ្យភ័យតក់
ស្លុត និងមានទីសម្គាល់យ៉ាងធំនៅលើមេឃផង។ ១២ប៉ុន្តែ មុន
នឹងហេតុការណ៍ ទាំងនោះកើតឡើង គេនឹងចាប់ចងអ្នករាល់គ្នា
គេបៀតបៀន ហើយបញ្ជូនអ្នករាល់គ្នាទៅកាត់ទោសក្នុងធម្ម
សាលា* យកអ្នក រាល់គ្នាទៅឃុំឃាំង។ គេនាំអ្នករាល់គ្នាទៅ
ឲ្យស្ដេច និងលោកទេសាភិបាលកាត់ទោស ព្រោះតែនាមខ្ញុំ។
១៣ប៉ុន្តែការនេះ ប្រែជាហុចឱកាសឲ្យអ្នករាល់គ្នាផ្ដល់សក្ខីភាព
ទៅវិញ។ ១៤ត្រូវចងចាំក្នុងចិត្តថា កុំភ័យបារម្ភជាមុននឹងពាក្យ
និយាយការពារខ្លួនធ្វើអ្វី ១៥ដ្បិតខ្ញុំនឹងផ្ដល់ឲ្យអ្នករាល់គ្នាមាន
ថ្វីមាត់ និងប្រាជ្ញាមិនឲ្យពួកប្រឆាំងអាចប្រកែកតទល់នឹងអ្នក

---
ម, អេសាយ ១៩,២។

រាល់គ្នាបានឡើយ។ ១៦សូម្បីតែឪពុកម្ដាយបងប្អូនញាតិសន្ដាន
និងមិត្តភក្ដិរបស់អ្នករាល់គ្នាក៏បញ្ជូនអ្នករាល់គ្នាមួយចំនួន ទៅឲ្យ
គេសម្លាប់ផងដែរ។ ១៧មនុស្ស គ្រប់ៗរូបនឹងស្អប់អ្នករាល់គ្នា ព្រោះ
តែនាមខ្ញុំ។ ១៨ប៉ុន្ដែ សូម្បីតែសក់អ្នករាល់គ្នាមួយសរសៃក៏មិនត្រូវ
បាត់ឡើយ។ ១៩អ្នករាល់គ្នា នឹងបានរួចជីវិត ព្រោះអ្នករាល់គ្នា
មានចិត្តស៊ូទ្រាំ»។

## ព្រះយេស៊ូមានព្រះបន្ទូលអំពីការបំផ្លាញក្រុងយេរូសាឡឹម

(ម៉ាថាយ ២៤,១៥-២១ ម៉ាកុស ១៣,១៤-១៩)

២០«កាលណាអ្នករាល់គ្នា ឃើញមានកងទ័ពមកឡោមព័ទ្ធ
ក្រុងយេរូសាឡឹម ចូរដឹងថាក្រុងនេះជិតវិនាសហើយ។ ២១ពេល
នោះអស់អ្នកនៅស្រុកយូដា ត្រូវតែរត់ទៅជ្រកនៅតាមភ្នំ រីឯអស់
អ្នកនៅក្រុងយេរូសាឡឹម ត្រូវរត់ចេញឲ្យឆ្ងាយពីក្រុង ហើយអស់
អ្នកដែលនៅស្រុកស្រែ មិនត្រូវចូលទៅក្រុងឡើយ។ ២២គ្រានោះ
ជាគ្រាដែលព្រះជាម្ចាស់ធ្វើទោសប្រជារាស្ដ្រព្រះអង្គស្របតាម
សេចក្ដីដែលមានចែងទុកក្នុងគម្ពីរ។ ២៣គ្រានោះ ស្ដ្រីមានផ្ទៃពោះ
និងស្ដ្រីបំបៅកូនមុខជាវេទនាពុំខាន ដ្បិតនឹងកើតមានទុក្ខលំបាក
យ៉ាងខ្លាំងនៅក្នុងស្រុក ហើយព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសប្រជា
រាស្ដ្រនេះ។ ២៤គេនឹងត្រូវស្លាប់ដោយមុខដាវ ហើយខ្មាំងសត្រូវ
នឹងកៀរគេយកទៅធ្វើជាឈ្លើយសង្គ្រាម ឲ្យរស់នៅកណ្ដាល
ចំណោមជាតិសាសន៍ទាំងអស់ សាសន៍ដទៃនឹងជាន់ឈ្លីក្រុង
យេរូសាឡឹមរហូតដល់ពេលកំណត់របស់គេ»។

## បុត្រមនុស្សយាងត្រឡប់មកវិញ

(ម៉ាថាយ ២៤, ២៩-៣១ ម៉ាកុស ១៣, ២៤-២៧)

២៥«គ្រានោះនឹងមានទីសម្គាល់នៅក្នុងព្រះអាទិត្យ ក្នុងព្រះច័ន្ទ
និងក្នុងផ្កាយទាំងប៉ុន្មាន។ ប្រជាជាតិទាំងអស់នៅលើផែនដីនឹងតឹង
ទ្រូង ព្រួយបារម្ភពេលឮសូរសន្ធឹករលកសមុទ្របក់បោក ២៦មនុស្ស
ម្នាភ័យស្លុតបាត់ស្មារតី នៅពេលគិតអំពីហេតុការណ៍ដែលនឹង
កើតមាននៅលើផែនដី ដ្បិតឫទ្ធិបារមីនានានៅលើមេឃនឹងកក្រើក
រំពើក។ ២៧ពេលនោះ គេនឹង _ឃើញបុត្រមនុស្ស *យាងមកក្នុង
ពពក_*[យ] ប្រកបដោយឫទ្ធានុភាព និងសិរីរុងរឿងពន់ពេកក្រៃ។
២៨កាលណាព្រឹត្តិការណ៍ទាំងនេះ ចាប់ផ្តើមកើតមាន ចូរអ្នករាល់
គ្នាងើបមើលទៅលើ ពីព្រោះព្រះជាម្ចាស់ជិតរំដោះអ្នករាល់គ្នាហើយ»។

## ព្រះបន្ទូលអំពីដើមឧទុម្ពរ

(ម៉ាថាយ ២៤,៣២-៣៥ ម៉ាកុស ១៣,២៨-៣១)

២៩បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នានេះថា៖
«ចូរមើលដើមឧទុម្ពរ* និងដើមឈើទាំងអស់ចុះ! ៣០កាលណា
អ្នករាល់គ្នាឃើញស្លឹកវាលាស់ អ្នករាល់គ្នាដឹងថារដូវប្រាំង[រ] ជិត
មកដល់ហើយ។ ៣១ដូច្នេះ កាលណាអ្នករាល់គ្នាឃើញព្រឹត្តិការណ៍
ទាំងនោះកើតឡើង ត្រូវដឹងថា ព្រះរាជ្យ*របស់ព្រះជាម្ចាស់មក
ជិតបង្កើយហើយ។ ៣២ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ហេតុ
ការណ៍ទាំងនោះនឹងកើតឡើង នៅពេលដែលមនុស្សជំនាន់នេះ
មានជីវិតរស់នៅឡើយ។ ៣៣ផ្ទៃមេឃ និងផែនដីនឹងរលាយបាត់
ទៅ តែពាក្យដែលខ្ញុំនិយាយមិនរលាយបាត់ទេ»។

---

**យ**, ដានីអែល ៧,១៣។ •**រ**, ពាក្យដើម«រដូវក្តៅ»។

## ការត្រៀមខ្លួនប្រុងប្រយ័ត្ន

៣៤«ចូរអ្នករាល់គ្នាប្រុងប្រយ័ត្នឲ្យមែនទែន! កុំបណ្ដោយឲ្យ
ចិត្តរបស់អ្នករាល់គ្នា វក់វីនឹងគ្រឿងសប្បាយ គ្រឿងស្រវឹង ឬក៏
ខ្វល់ខ្វាយអំពីរឿងជីវិតនេះឡើយ ក្រែងលោថ្ងៃនោះមកដល់ តែ
អ្នករាល់គ្នាពុំបានប្រុងប្រៀបខ្លួន ៣៥ដ្បិតថ្ងៃនោះមកដល់ប្រៀប
បាននឹងសំណាញ់ ដែលគ្របពីលើមនុស្សទាំងអស់នៅលើផែនដី
ទាំងមូល។ ៣៦ចូរប្រុងស្មារតី និងទូលអង្វរគ្រប់ពេលវេលា ដើម្បី
ឲ្យអ្នករាល់គ្នាមានកម្លាំង ឆ្លងផុតពីហេតុការណ៍ទាំងអស់ ដែល
ត្រូវកើតមាន ហើយដើម្បីឲ្យអ្នករាល់គ្នាអាចឈរនៅមុខបុត្រមនុស្ស»។
៣៧ពេលថ្ងៃព្រះយេស៊ូតែងប្រៀនប្រដៅគេនៅក្នុងព្រះវិហារ *
ហើយនៅពេលយប់ ព្រះអង្គយាងចេញទៅសម្រាកនៅលើភ្នំដើម
អូលីវ។ ៣៨ប្រជាជនទាំងមូលនាំគ្នាមកតាំងពីព្រលឹម ស្ដាប់ព្រះអង្គ
មានព្រះបន្ទូលនៅក្នុងព្រះវិហារ *។

## ការឃុបឃិតចាប់ព្រះយេស៊ូ

(ម៉ាថាយ ២៦ ,១-៥,១៤-១៦ ម៉ាកុស ១៤,១-២, ១០-១១ យ៉ូហាន ១១, ៤៥-៥៣)

# ២២

១ពិធីបុណ្យនំបុ័ងឥតមេ ដែលហៅថាបុណ្យ
ចម្លង *នោះកាន់តែជិតដល់ហើយ ២ពួកនាយក
បូជាចារ្យ និងពួកធម្មាចារ្យ រិះរកមធ្យោបាយធ្វើគុតព្រះយេស៊ូ ដ្បិត
គេខ្លាចប្រជាជន។ ៣ពេលនោះ មារសាតាំងបានចូលយូដាស ហៅ
អ៊ីស្ការីយ៉ុត ជាសាវ័កម្នាក់ ក្នុងក្រុមទាំងដប់ពីររូប។៤យូដាស បាន
ទៅពិគ្រោះជាមួយពួកនាយកបូជាចារ្យ និងមេក្រុមរក្សាព្រះ វិហារ *
អំពីឧបាយកលដែលត្រូវបញ្ជូនព្រះអង្គទៅក្នុងកណ្ដាប់ដៃ របស់

ពួកគេ។ ៥លោកទាំងនោះសប្បាយចិត្តណាស់ ហើយព្រម ព្រៀង
គ្នាសន្យាថានឹងឲ្យប្រាក់គាត់។ ៦យូដាសយល់ព្រម ហើយរក
ឱកាសល្អ ដើម្បីនាំគេទៅចាប់ព្រះយេស៊ូមិនឲ្យបណ្ដាជនដឹងឡើយ។

## ព្រះយេស៊ូឲ្យគេរៀបចំធ្វើបុណ្យចម្លង *

(ម៉ាថាយ ២៦,១៧-២៥ ម៉ាកូស ១៤,១២-២១ យ៉ូហាន ១៣,២១-៣០)

៧លុះដល់ថ្ងៃបុណ្យនំបុ័ងឥតមេ* ជាថ្ងៃដែលគេត្រូវសម្លាប់
កូនចៀមធ្វើយញ្ញបូជាសម្រាប់បុណ្យចម្លង ៨ព្រះយេស៊ូបានចាត់
លោកសិលា និងលោកយ៉ូហានឲ្យទៅមុន ដោយមានព្រះបន្ទូល
ថា៖ «ចូរទៅរៀបចំពិធីជប់លៀងសម្រាប់យើងនៅក្នុងពេលបុណ្យ
ចម្លង *»។ ៩អ្នកទាំងពីរទូលសួរព្រះអង្គថា៖ «តើព្រះគ្រូចង់ឲ្យ
យើងខ្ញុំរៀបចំជប់លៀងនៅកន្លែងណា?»។ ១០ព្រះយេស៊ូមាន
ព្រះបន្ទូលតបថា៖ «ពេលចូលទៅដល់ក្នុងទីក្រុង អ្នកនឹងជួប
បុរសម្នាក់លីក្អមទឹក។ ចូរដើរតាមគាត់រហូតដល់ផ្ទះដែលគាត់
ចូល ១១ហើយនិយាយនឹងម្ចាស់ផ្ទះថា "លោកគ្រូចាត់យើងឲ្យ
មកសួរអ្នកថា បន្ទប់ដែលលោកនឹងជប់លៀងជាមួយសិស្ស ក្នុង
ពេលបុណ្យចម្លងនៅឯណា?"។ ១២ម្ចាស់ផ្ទះនឹងបង្ហាញបន្ទប់មួយ
យ៉ាងធំ នៅជាន់ខាងលើដែលរៀបចំជាស្រេច។ ចូររៀបចំម្ហូប
អាហារសម្រាប់បុណ្យចម្លង នៅក្នុងបន្ទប់នោះចុះ»។ ១៣អ្នកទាំង
ពីរក៏ចេញទៅ ហើយបានឃើញដូចព្រះយេស៊ូមានព្រះបន្ទូល
ប្រាប់មែន។ គេរៀបចំម្ហូបអាហារសម្រាប់បុណ្យចម្លង *។

## ពិធីជប់លៀងរបស់ព្រះអម្ចាស់

(ម៉ាថាយ ២៦, ២៦-៣០ ម៉ាកុស ១៤, ២២-២៦ ១កូរិនថូស ១១, ២៣-២៥)

១៤លុះដល់ពេលកំណត់ហើយ ព្រះយេស៊ូក៏រួមតុជាមួយក្រុម
គ្រីស្តទូត* ១៥ព្រះអង្គមានព្រះបន្ទូលថា៖ «មុនពេលខ្ញុំរងទុក្ខលំបាក
ខ្ញុំចង់បរិភោគម្ហូបអាហារក្នុងឱកាសបុណ្យចម្លង*នេះជាមួយអ្នក
រាល់គ្នាណាស់!។ ១៦ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ខ្ញុំនឹងមិនបរិភោគ
ម្ហូបអាហារបុណ្យចម្លងនេះទៀតទេ លុះត្រាតែពិធីបុណ្យនេះបាន
សម្រេចសព្វគ្រប់ នៅក្នុងព្រះរាជ្យ*ព្រះជាម្ចាស់»។ ១៧ព្រះអង្គ
យកពែងមួយមកកាន់ ហើយអរព្រះគុណព្រះជាម្ចាស់ រួចព្រះអង្គ
មានព្រះបន្ទូលថា៖ «ចូរយកទៅចែកគ្នាពិសាចុះ។ ១៨ខ្ញុំសុំប្រាប់
អ្នករាល់គ្នាថា ចាប់ពីពេលនេះតទៅ ខ្ញុំមិនទទួលទានស្រាទំពាំង
បាយជូរទៀតឡើយ លុះត្រាតែព្រះរាជ្យ*ព្រះជាម្ចាស់មកដល់»។
១៩បន្ទាប់មកព្រះអង្គយកនំប៉័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់
រួចព្រះអង្គកាច់ប្រទានឲ្យគេទាំងមានព្រះបន្ទូលថា៖ «នេះជារូប
កាយខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ចូរធ្វើដូច្នេះ ដើម្បីនឹក
រំឭកដល់ខ្ញុំ»។ ២០លុះជប់លៀងរួចហើយ ព្រះអង្គធ្វើតាមបែប
ដដែល ទ្រង់យកពែងមកកាន់ ទាំងមានព្រះបន្ទូលថា៖ «នេះជា
ពែងនៃសម្ពន្ធមេត្រី*ថ្មី ចងឡើងដោយសារលោហិតខ្ញុំ ដែល
ត្រូវបង្ហូរសម្រាប់អ្នករាល់គ្នា។ ២១ប៉ុន្តែតោងដឹងថា អ្នកដែលនឹង
បញ្ជូនខ្ញុំ ក៏នៅរួមតុជាមួយខ្ញុំដែរ។ ២២បុត្រមនុស្សត្រូវតែស្លាប់
តាមព្រះជាម្ចាស់បានកំណត់ទុកមក តែអ្នកដែលបញ្ជូនបុត្រមនុស្ស
មុខជាត្រូវវេទនាពុំខាន»។ ២៣ពេលនោះពួកសាវ័ក*សួរគ្នាទៅវិញ
ទៅមក ចង់ដឹងថាក្នុងចំណោមពួកគេ តើនរណាមានបំណង
ប្រព្រឹត្តដូច្នេះ។

## អ្នកធំត្រូវបម្រើអ្នកតូច

២៤ខណៈនោះ ពួកសាវ័ក*ជជែកទាស់ទែងគ្នា ចង់ដឹងថា
ក្នុងចំណោមពួកគេ នរណាមានឋានៈធំជាងគេ។ ២៥ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេថា៖ «ស្ដេចទាំងឡាយតែងតែត្រួតត្រាលើ
ប្រជារាស្ត្រ ហើយអ្នកកាន់អំណាចតែងឲ្យគេហៅខ្លួនថា អ្នកមាន
គុណ។ ២៦រីឯអ្នករាល់គ្នាវិញ មិនត្រូវធ្វើដូច្នោះឡើយ។ ក្នុងចំណោម
អ្នករាល់គ្នា អ្នកដែលធំជាងគេ ត្រូវធ្វើតូចជាងគេ ហើយអ្នកដែល
ដឹកនាំគេ ត្រូវបម្រើគេវិញ។ ២៧អ្នកដែលអង្គុយនៅតុ និងអ្នក
បម្រើតុ តើអ្នកណាធំជាង? ធម្មតាអ្នកអង្គុយតុ ធំជាងអ្នកបម្រើតុ។
រីឯខ្ញុំ ខ្ញុំនៅកណ្ដាលចំណោមអ្នករាល់គ្នា ខ្ញុំធ្វើជាអ្នកបម្រើទៅ
វិញ។ ២៨គ្រប់ពេលខ្ញុំជួបទុក្ខលំបាក អ្នករាល់គ្នាស៊ូទ្រាំនៅជាមួយ
ខ្ញុំជានិច្ច។ ២៩ហេតុនេះហើយ បានជាខ្ញុំប្រគល់ព្រះរាជ្យ* ឲ្យអ្នក
រាល់គ្នា ដូចព្រះបិតាបានប្រគល់មកឲ្យខ្ញុំដែរ។ ៣០ក្នុងព្រះរាជ្យ
របស់ខ្ញុំ អ្នករាល់គ្នានឹងបរិភោគរួមតុជាមួយខ្ញុំ ហើយអ្នករាល់គ្នា
នឹងអង្គុយលើបល្ល័ង្ក ដើម្បីគ្រប់គ្រងលើកុលសម្ព័ន្ធ*ទាំងដប់ពីរ
នៃជនជាតិអ៊ីស្រាអែល»។

## ព្រះយេស៊ូមានព្រះបន្ទូលអំពីលោកសិលា បដិសេធមិនស្គាល់ព្រះអង្គ

(ម៉ាថាយ ២៦,៣១-៣៥ ម៉ាកូស ១៤,២៧-៣១ យ៉ូហាន ១៣,៣៦-៣៨)

៣១«ស៊ីម៉ូន! ស៊ីម៉ូនអើយ! មារសាតាំង*បានទាមទារសុំរែង
អ្នករាល់គ្នា ដូចគេរែងអង្ករ។ ៣២ប៉ុន្តែ ខ្ញុំបានអង្វរព្រះជាម្ចាស់
សូមកុំឲ្យអ្នកបាត់ជំនឿឡើយ។ លុះដល់ពេលអ្នកប្រែចិត្តមកវិញ
ចូរជួយបងប្អូនរបស់អ្នក ឲ្យមានជំនឿមាំមួនផង»។ ៣៣លោក
សិលាទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! ទូលបង្គំត្រៀមខ្លួន

ជាស្រេច ទោះបីត្រូវជាប់ឃុំឃាំង ឬត្រូវស្លាប់ក៏ដោយ ទូលបង្គំ
សុខចិត្តទៅជាមួយព្រះអង្គរហូត»។ ៣៤ព្រះយេស៊ូមានព្រះបន្ទូល
តបទៅគាត់ថា៖ «សិលាអើយ! ខ្ញុំសុំប្រាប់អ្នកថា នៅយប់នេះ
មុនមាន់រងាវ អ្នកនឹងបដិសេធបីដងថា មិនស្គាល់ខ្ញុំ»។
៣៥បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលសួរសាវ័ក*ថា៖ «កាល
ដែលខ្ញុំចាត់អ្នករាល់គ្នាទៅ ដោយគ្មានថង់ប្រាក់ ថង់យាម ឬ
ស្បែកជើង[ឈ] តើអ្នករាល់គ្នាមានខ្វះខាតអ្វីទេ?»។ គេទូលថា៖
«យើងខ្ញុំគ្មានខ្វះខាតអ្វីទេ»។ ៣៦ព្រះអង្គមានព្រះបន្ទូលទៀតថា៖
«ឥឡូវនេះ អ្នកណាមានថង់ប្រាក់ ត្រូវយកទៅជាមួយ ហើយអ្នក
ណាមានថង់យាម ក៏ត្រូវយកទៅជាមួយដែរ។ រីឯអ្នកដែលគ្មាន
ដាវ ត្រូវលក់អាវធំរបស់ខ្លួនទិញដាវមួយទៅ។ ៣៧ខ្ញុំសុំប្រាប់អ្នក
រាល់គ្នាថា ក្នុងគម្ពីរមានចែងទុកអំពីខ្ញុំថា "គេបានរាប់លោកទុក
ដូចជាអ្នកមានទោសឧក្រិដ្ឋ"[ញ]។ ហេតុការណ៍នោះត្រូវតែកើតមាន
ស្របតាមគម្ពីរ»។ ៣៨ពួកសាវ័កទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់!
យើងមានដាវពីរ»។ ព្រះអង្គមានព្រះបន្ទូលឆ្លើយតបវិញថា៖ «ប៉ុណ្ណឹង
គ្រប់គ្រាន់ហើយ»។

## ព្រះយេស៊ូអធិដ្ឋាននៅលើភ្នំដើមអូលីវ

(ម៉ាថាយ ២៦, ៣៦-៤៦ ម៉ាកុស ១៤, ៣២-៤២)

៣៩ព្រះយេស៊ូយាងចេញពីផ្ទះនោះ ឆ្ពោះទៅភ្នំដើមអូលីវ តាម
ទម្លាប់របស់ព្រះអង្គ សាវ័ក*ក៏នាំគ្នាតាមព្រះអង្គទៅដែរ។ ៤០កាល
យាងទៅដល់ហើយ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ចូរអធិដ្ឋាន*
កុំឲ្យចាញ់ការល្បួងឡើយ»។ ៤១បន្ទាប់មកព្រះអង្គយាងទៅឆ្ងាយ
ពីពួកសាវ័ក ចម្ងាយប្រហែលគេចោលដុំថ្មមួយទំហឹងដៃ។ ព្រះអង្គ

**ឈ**, សូមអានលូកា ៩,៣។ • **ញ**, អេសាយ ៥៣,១២។

លុតជង្គង់ចុះ ទូលអង្វរថា៖ ៤២«ឱព្រះបិតាអើយ! ប្រសិនបើព្រះអង្គ
សព្វព្រះហឫទ័យ សូមដកយកពែងនៃទុក្ខលំបាកនេះចេញឲ្យ
ឆ្ងាយពីទូលបង្គំទៅ។ ប៉ុន្តែ សូមកុំឲ្យសម្រេចតាមចិត្តទូលបង្គំ
ឡើយ គឺឲ្យសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ»។ ៤៣ពេល
នោះមានទេវទូត *មួយរូបចុះពីស្ថានបរមសុខ *មកឲ្យព្រះអង្គ
ឃើញ ដើម្បីលើកទឹកចិត្តព្រះអង្គ។ ៤៤ព្រះយេស៊ូព្រួយអន្ទះអន្ទែង
ពន់ប្រមាណ ព្រះអង្គទូលអង្វរកាន់តែខ្លាំងឡើងៗ តំណក់ញើស
របស់ ព្រះអង្គ ដូចជាតំណក់ឈាមស្រក់ចុះដល់ដី។ ៤៥កាល
ព្រះអង្គទូលអង្វររួចហើយ ទ្រង់ក្រោកឡើងត្រឡប់ទៅរកពួកសាវ័ក
ឃើញ គេកំពុងដេកលក់ដោយព្រួយចិត្ត។ ៤៦ព្រះអង្គមានព្រះ
បន្ទូលទៅ គេថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាដេកលក់ដូច្នេះ?
ចូរក្រោកឡើងអធិដ្ឋាន * កុំឲ្យចាញ់ការល្បួង»។

## គេចាប់ព្រះយេស៊ូ

(ម៉ាថាយ ២៦,៤៧-៥៦ ម៉ាកុស ១៤,៤៣-៥០ យ៉ូហាន ១៨,៣-១១)

៤៧នៅពេលព្រះអង្គកំពុងតែមានព្រះបន្ទូលនៅឡើយ ស្រាប់
តែបណ្ដាជនមកដល់ នាំមុខដោយឈ្មោះយូដាស ជាសាវ័ក*
មួយរូបក្នុងក្រុមទាំងដប់ពីរ។ គាត់ចូលមកជិតព្រះយេស៊ូ ហើយ
ថើបព្រះអង្គ។ ៤៨ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «យូដាស
អើយ! អ្នកធ្វើជាថើប ដើម្បីបញ្ជូនបុត្រមនុស្ស *ឬអី?»។ ៤៩ពួក
អ្នកនៅជាមួយព្រះយេស៊ូ ឃើញហេតុការណ៍ដែលហៀបនឹងកើត
ឡើង ក៏ទូលសួរព្រះអង្គថា៖ «ព្រះអម្ចាស់! តើឲ្យយើងខ្ញុំហូត
ដាវកាប់គេឬ?»។ ៥០សាវ័កម្នាក់បានកាប់អ្នកបម្រើរបស់លោក
មហាបូជាចារ្យ *មួយដាវ ដាច់ស្លឹកត្រចៀកស្ដាំ។ ៥១ព្រះយេស៊ូ

មានព្រះបន្ទូលថា៖ «ប៉ុណ្ណឹងបានហើយ!»។ ព្រះអង្គក៏ពាល់
ត្រចៀកបុរសនោះ ហើយប្រោសគាត់ឲ្យបានជាដូចដើមវិញ។
[៥២]បន្ទាប់មកព្រះអង្គមានព្រះបន្ទូលទៅពួកនាយកបូជាចារ្យ*
មេក្រុមរក្សាព្រះវិហារ និងពួកព្រឹទ្ធាចារ្យ* ដែលមកចាប់ព្រះអង្គ
នោះថា៖ «ខ្ញុំជាចោរព្រៃឬ បានជាអស់លោកកាន់ដាវកាន់ដំបង
មកចាប់ខ្ញុំដូច្នេះ?។ [៥៣]ខ្ញុំនៅក្នុងព្រះវិហារ*ជាមួយអស់លោកជា
រៀងរាល់ថ្ងៃ តែអស់លោកពុំបានចាប់ខ្ញុំទេ។ ឥឡូវនេះ ជាពេល
របស់អស់លោកហើយ គឺជាពេលដែលម្ចាស់នៃសេចក្ដីងងឹត
បញ្ចេញអំណាច»។

## លោកសិលាបដិសេធមិនស្គាល់ព្រះយេស៊ូ

(ម៉ាថាយ ២៦,៥៧-៥៨,៦៩-៧៥ ម៉ាកុស ១៤,៥៣-៥៤,៦៦-៧២
យ៉ូហាន ១៨, ១២-១៨, ២៥-២៧)

[៥៤]ពួកគេចាប់ព្រះយេស៊ូ បណ្ដើរនាំចូលទៅក្នុងដំណាក់របស់
លោកមហាបូជាចារ្យ*។ លោកសិលាដើរតាមព្រះអង្គពីចម្ងាយ។



៥៥គេបានដុតភ្លើងនៅកណ្ដាលទីលាន ហើយអង្គុយជុំវិញ លោក
សិលាក៏អង្គុយនៅកណ្ដាលចំណោមពួកគេដែរ។ ៥៦ស្ដ្រីបម្រើម្នាក់
ឃើញគាត់អង្គុយនៅមុខពន្លឺភ្លើង សម្លឹងមើលគាត់ ហើយពោល
ថា៖ «ម្នាក់នេះជាបក្សពួករបស់យេស៊ូ!»។ ៥៧លោកសិលាប្រកែក
ថា៖ «ទេនាងអើយ! ខ្ញុំមិនដែលស្គាល់គាត់ទេ»។ ៥៨មួយស្របក់
ក្រោយមក មានម្នាក់ទៀតឃើញគាត់ក៏ពោលថា៖ «អ្នកឯងជា
បក្សពួកគាត់ដែរ»។ លោកសិលាឆ្លើយទៅអ្នកនោះថា៖ «ទេ!
មិនមែនខ្ញុំទេ!»។ ៥៩ប្រហែលមួយម៉ោងក្រោយមក មានម្នាក់ទៀត
និយាយបែបប្រាកដប្រជាថា៖ «អ្នកនេះពិតជាបក្សពួករបស់យេស៊ូ
មែន ព្រោះគាត់ជាអ្នកស្រុកកាលីឡេដូចគ្នា»។ ៦០លោកសិលា
ឆ្លើយថា៖ «ខ្ញុំមិនដឹងជាអ្នកចង់និយាយអំពីរឿងអ្វីសោះ»។ គាត់
កំពុងតែនិយាយនៅឡើយ ស្រាប់តែមាន់រងាវឡើង។ ៦១ព្រះអម្ចាស់
បែរព្រះភ័ក្ត្រទតមកលោកសិលា។ លោកសិលាក៏នឹកឃើញព្រះ
បន្ទូលរបស់ព្រះអង្គថា៖ «យប់នេះ មុនមាន់រងាវ អ្នកនឹងបដិសេធ
បីដងថា មិនស្គាល់ខ្ញុំ»។ ៦២លោកសិលាចាកចេញពីទីនោះ ហើយ
យំសោកយ៉ាងខ្លោចផ្សា។

## គេវាយដំជេរប្រមាថព្រះយេស៊ូ

(ម៉ាថាយ ២៦,៦៧-៦៨ ម៉ាកុស ១៤,៦៥)

៦៣ពួកអ្នកយាមព្រះយេស៊ូ ចំអកដាក់ព្រះអង្គ ហើយវាយតប់
ព្រះអង្គផង។ ៦៤គេយកក្រណាត់គ្របព្រះភ័ក្ត្រព្រះអង្គ ហើយសួរ
ថា៖ «ទាយមើល៍អ្នកណាវាយឯង?»។ ៦៥រួចគេជេរប្រមាថព្រះអង្គ
ជាច្រើនថែមទៀតផង។

## ព្រះយេស៊ូនៅមុខក្រុមប្រឹក្សាជាន់ខ្ពស់

(ម៉ាថាយ ២៦, ៥៩-៦៦ ម៉ាកុស ១៤, ៥៥-៦៤ យ៉ូហាន ១៨, ១៩-២៤)

៦៦លុះព្រឹកឡើង ពួកព្រឹទ្ធាចារ្យ *របស់ប្រជាជន ពួកនាយក
បូជាចារ្យ* និងពួកបណ្ឌិតខាងវិន័យ* ជួបជុំគ្នាបង្គាប់ឲ្យគេនាំ
ព្រះយេស៊ូចូលមកឈរនៅខាងមុខក្រុមប្រឹក្សាជាន់ខ្ពស់ *របស់
គេ។ ៦៧ពួកគេសួរព្រះអង្គថា៖ «ប្រាប់យើងមកមើល៍ តើអ្នកជា
ព្រះគ្រិស្ដ *ឬ?»។ ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា៖ «បើខ្ញុំ
ប្រាប់អស់លោកក៏អស់លោកពុំជឿខ្ញុំ ៦៨ហើយបើខ្ញុំសួរអស់លោក
វិញ ក៏អស់លោកមិនឆ្លើយនឹងខ្ញុំដែរ។ ៦៩ប៉ុន្តែ អំណើះតទៅ បុត្រ
មនុស្សនឹងអង្គុយនៅខាងស្ដាំព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព[ស]។
៧០ពេលនោះ គេសួរព្រមគ្នាឡើងថា៖ «បើដូច្នេះ អ្នកជាព្រះបុត្រា
របស់ព្រះជាម្ចាស់ឬ?»។ ព្រះអង្គមានព្រះបន្ទូលតបថា៖ «អស់
លោកមានប្រសាសន៍ត្រូវមែន គឺខ្ញុំនេះហើយ»។ ៧១គេក៏និយាយ
ឡើងថា៖ «យើងមិនបាច់រកសាក្សីឯណាទៀតទេ ដ្បិតយើងបាន
ឮពាក្យរបស់អ្នកនេះផ្ទាល់តែម្ដង!»។

## ព្រះយេស៊ូនៅមុខលោកពីឡាត

(ម៉ាថាយ ២៧, ១-២, ១១-១៤ ម៉ាកុស ១៥,១-១៥ យ៉ូហាន ១៨, ២៨-៣៨)

២៣ ១ក្រុមប្រឹក្សាជាន់ខ្ពស់ *ក្រោកឡើងទាំងអស់
គ្នា ហើយបញ្ជូនព្រះយេស៊ូទៅលោកពីឡាត។
២គេនាំគ្នាចោទប្រកាន់ព្រះអង្គថា៖ «យើងខ្ញុំឃើញអ្នកនេះ កំពុង
តែបំបះបំបោរប្រជារាស្ដ្រយើង គឺហាមគេមិនឲ្យបង់ពន្ធថ្វាយ
ព្រះចៅអធិរាជ ហើយគាត់អះអាងខ្លួនថា ជាព្រះគ្រិស្ដ* គឺជា
ស្ដេច»។ ៣លោកពីឡាតសួរព្រះអង្គថា៖ «តើអ្នកជាស្ដេចសាសន៍

**ស**, ដានីអែល ៧,១៣ ; ទំនុកតម្កើង ១១០,១។

យូដាមែនឬ?»។ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «លោកទេ
តើដែលមានប្រសាសន៍ដូច្នេះ»។ ៤លោកពីឡាតក៏ពោលទៅកាន់
ពួកនាយកបូជាចារ្យ* និងបណ្ដាជនថា៖ «ខ្ញុំពុំឃើញអ្នកនេះមាន
ទោសអ្វីឡើយ!»។ ៥ប៉ុន្ដែ គេរឹតតែចោទប្រកាន់ខ្លាំងឡើងៗថា៖
«អ្នកនេះបានបំបះបំបោរប្រជាជន ដោយបង្រៀនគេចាប់តាំងពី
ស្រុកកាលីឡេរហូតមកដល់ទីនេះ»។

## ព្រះយេស៊ូនៅមុខស្ដេចហេរ៉ូដ

៦លោកពីឡាតឮដូច្នោះក៏សួរថា៖ «តើអ្នកនេះជាអ្នកស្រុក
កាលីឡេឬ?»។ ៧កាលលោកពីឡាតដឹងថា ព្រះយេស៊ូជាអ្នក
ស្រុកនៅក្រោមអំណាចរបស់ព្រះបាទហេរ៉ូដ លោកក៏បញ្ជូនព្រះ
អង្គទៅព្រះបាទហេរ៉ូដ ដែលស្នាក់នៅក្រុងយេរូសាឡឹម ពេល
នោះដែរ។ ៨ពេលឃើញព្រះយេស៊ូ ព្រះបាទហេរ៉ូដសប្បាយ
ព្រះហឫទ័យក្រៃលែង ដ្បិតទ្រង់ចង់ជួបព្រះយេស៊ូតាំងពីយូរយារ
មកហើយ ព្រោះទ្រង់តែងឮគេនិយាយអំពីព្រះអង្គ ហើយសង្ឃឹម
ថា នឹងបានឃើញព្រះយេស៊ូធ្វើការអស្ចារ្យអ្វីមួយ។ ៩ទ្រង់ទូល
សួរសំណួរជាច្រើន តែព្រះយេស៊ូពុំមានព្រះបន្ទូលឆ្លើយតបទាល់
តែសោះ។ ១០ពួកមហាបូជាចារ្យ* និងពួកបណ្ឌិតខាងវិន័យ*
ក៏នៅទីនោះដែរ គេបានចោទប្រកាន់ព្រះយេស៊ូយ៉ាងខ្លាំងបំផុត។
១១ព្រះបាទហេរ៉ូដ និងពួកទាហានចំអកឲ្យព្រះយេស៊ូ ព្រមទាំង
ជេរប្រមាថ មើលងាយព្រះអង្គផង។ គេយកអាវដ៏ល្អវិសេសមក
ពាក់ឲ្យព្រះអង្គ រួចបញ្ជូនទៅលោកពីឡាតវិញ។ ១២កាលពីមុន
ព្រះបាទហេរ៉ូដ និងលោកពីឡាតជាសត្រូវនឹងគ្នា។ ប៉ុន្តែ ចាប់ពី
ថ្ងៃនោះមក លោកទាំងពីរត្រឡប់ទៅជាមិត្តសម្លាញ់នឹងគ្នាវិញ។

# លោកពីឡាតកាត់ទោសប្រហារជីវិតព្រះយេស៊ូ

(ម៉ាថាយ ២៧,១៥-២៦ ម៉ាកុស ១៥,៦-១៥ យ៉ូហាន ១៨,៣៩-១៩,១៦)

១៣លោកពីឡាតបានកោះហៅពួកនាយកបូជាចារ្យ *ពួកមន្ត្រី
និងប្រជាជនមកជួបជុំគ្នា។ ១៤លោកមានប្រសាសន៍ថា៖ «អស់
លោកបាននាំបុរសនេះមកឲ្យខ្ញុំកាត់ទោស ដោយចោទប្រកាន់
ថា គាត់បំបះបំបោរប្រជារាស្ត្រ។ ខ្ញុំបានសួរចម្លើយគាត់នៅមុខ
អស់លោក តែមិនឃើញមានទោសអ្វី ដូចអស់លោកចោទប្រកាន់
សោះ។ ១៥សូម្បីតែស្ដេចហេរ៉ូដក៏មិនឃើញគាត់មានទោសអ្វីដែរ
ហេតុនេះហើយ បានជាទ្រង់បញ្ជូនគាត់មកវិញ។ បុរសនេះមិន
បានប្រព្រឹត្តអ្វីគួរឲ្យប្រហារជីវិតឡើយ។ ១៦ខ្ញុំគ្រាន់តែឲ្យគេវាយ
ប្រដៅគាត់ រួចលែងគាត់ឲ្យទៅវិញ»។ {១៧ជារៀងរាល់ឆ្នាំ ក្នុង
ឱកាសបុណ្យចម្លង លោកពីឡាតត្រូវលែងអ្នកទោសម្នាក់}។
១៨គេស្រែកឡើងព្រមគ្នាថា៖ «សូមសម្លាប់អ្នកនេះទៅ! លែង
បារ៉ាបាសឲ្យយើងខ្ញុំវិញ!»។ ១៩ឈ្មោះបារ៉ាបាសនេះជាប់ឃុំឃាំង
ព្រោះគាត់បានបង្កចលាចលក្នុងទីក្រុង ព្រមទាំងបានសម្លាប់
មនុស្សផង។ ២០លោកពីឡាតចង់ដោះលែងព្រះយេស៊ូ លោក
ក៏មានប្រសាសន៍ទៅគេម្ដងទៀត។ ២១ប៉ុន្តែគេស្រែកឡើងថា៖
«ឆ្កាងទៅ! ឆ្កាងទៅ!»។ ២២លោកពីឡាតមានប្រសាសន៍ទៅគេ
ជាលើកទីបីថា៖ «តើអ្នកនេះបានប្រព្រឹត្តអំពើអាក្រក់អ្វី? ខ្ញុំមិន
ឃើញគាត់មានទោសអ្វីគួរឲ្យប្រហារជីវិតឡើយ។ ខ្ញុំគ្រាន់តែឲ្យ
គេវាយប្រដៅគាត់ រួចលែងគាត់ឲ្យទៅវិញ»។ ២៣ប៉ុន្តែគេចេះតែ
ស្រែកខ្លាំងឡើងៗ ទាមទារឲ្យឆ្កាងព្រះយេស៊ូ សម្រែករបស់គេ
មានប្រៀបជាង។ ២៤លោកពីឡាតក៏យល់ព្រមតាមពាក្យទាមទារ
របស់ពួកគេ ២៥លោកដោះលែងបារ៉ាបាស ជាអ្នកជាប់ឃុំឃាំង
មកពីបានបង្កចលាចល និងបានសម្លាប់មនុស្ស។ រីឯព្រះយេស៊ូ
វិញ លោកប្រគល់ឲ្យគេយកទៅធ្វើតាមអំពើចិត្ត។

# គេឆ្កាងព្រះយេស៊ូ

(ម៉ាថាយ ២៧,៣២-៤៤ ម៉ាកុស ១៥,២១-៣២ យ៉ូហាន ១៩,១៧-២៧)

២៦នៅពេលបណ្ដើរព្រះយេស៊ូទៅ គេជួបបុរសម្នាក់ឈ្មោះ
ស៊ីម៉ូនជាអ្នកស្រុកគីរេន ដែលត្រឡប់មកពីចម្ការ។ គេចាប់បង្ខំ
គាត់ឲ្យលីឈើឆ្កាងដើរតាមក្រោយព្រះយេស៊ូ។ ២៧ប្រជាជនច្រើន



កុះករដើរតាមព្រះអង្គទៅ ព្រមទាំងមានពួកស្ត្រីគក់ទ្រូងយំសោក
អាណិតព្រះអង្គផង។ ២៨ព្រះយេស៊ូងាកមក មានព្រះបន្ទូលនឹង
ស្ត្រីទាំងនោះថា៖ «ស្ត្រីក្រុងយេរូសាឡឹមអើយ! កុំយំសោកអាណិត
ខ្ញុំធ្វើអ្វី ចូរយំសោកអាណិតខ្លួននាង និងកូននាងវិញ ២៩ដ្បិតនៅ
ថ្ងៃក្រោយនឹងមានគេពោលថា "ស្ត្រីណាឥតកូន[ហ] ស្ត្រីណាមិន
បង្កើតកូន និងស្ត្រីណាមិនដែលបំបៅកូន ស្ត្រីនោះពិតជាមាន
សុភមង្គលមែន"។ ៣០នៅពេលនោះ គេនឹងនិយាយទៅភ្នំថា *"ចូរ
រលំសង្កត់ពីលើយើងខ្ញុំមក! ចូរជួយលាក់ខ្លួនយើងខ្ញុំផង!"*[ឡ]។
៣១បើគេធ្វើបាបឈើស្រស់យ៉ាងហ្នឹងទៅហើយ ចុះទម្រាំបើឈើ

---

**ហ**, ពាក្យដើម: ស្ត្រីអារ។ • **ឡ**, ហូសេ១០,៨។

ងាប់វិញ តើគេនឹងធ្វើបាបដល់កម្រិតណាទៅ!»។ ៣២គេបាននាំអ្នកទោស[ឞ]ពីរនាក់ទៀត មកសម្លាប់ជាមួយព្រះយេស៊ូដែរ។

៣៣លុះមកដល់កន្លែងមួយ ដែលគេហៅថា "ភ្នំលលាដ៍ក្បាល" គេឆ្កាងព្រះយេស៊ូនៅទីនោះ ហើយគេក៏ឆ្កាងអ្នកទោសទាំងពីរនាក់នោះដែរ ម្នាក់នៅខាងស្ដាំព្រះអង្គ ម្នាក់ទៀតនៅខាងឆ្វេងព្រះអង្គ។ ៣៤ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ឱព្រះបិតាអើយ! សូមព្រះអង្គអត់ទោសឲ្យអ្នកទាំងនេះផង ដ្បិតគេមិនដឹងថា គេកំពុងធ្វើអ្វីឡើយ»។ គេយកសម្លៀកបំពាក់របស់ព្រះអង្គមកចាប់ឆ្នោតចែកគ្នា។ ៣៥ប្រជាជននាំគ្នាឈរមើល រីឯពួកនាម៉ឺននិយាយចំអកមើលងាយព្រះអង្គថា៖ «គាត់បានសង្គ្រោះមនុស្សឯទៀតៗ បើគាត់ជាព្រះគ្រីស្ដ*របស់ព្រះជាម្ចាស់ ហើយជាអ្នកដែលព្រះអង្គបានជ្រើសរើសមែននោះ ឲ្យគាត់សង្គ្រោះខ្លួនឯងទៅ!»។ ៣៦ពួកទាហានក៏បានចំអកដ◌ាក់ព្រះអង្គដែរ គេយកទឹកខ្មេះមកថ្វាយព្រះអង្គសោយ ៣៧ទាំងពោលថា៖ «បើអ្នកជាស្ដេចជនជាតិយូដាមែន ចូរសង្គ្រោះខ្លួនអ្នកទៅ!»។ ៣៨នៅពីលើព្រះអង្គ មានសរសេរអក្សរថា «អ្នកនេះជាស្ដេចជនជាតិយូដា»។ ៣៩អ្នកទោសម្នាក់ដែលជាប់ឆ្កាងពោលប្រមាថព្រះយេស៊ូថា៖ «បើអ្នកជាព្រះគ្រីស្ដមែន ចូរសង្គ្រោះខ្លួនអ្នកទៅ ហើយសង្គ្រោះយើងផង!»។ ៤០ប៉ុន្តែ អ្នកទោសម្នាក់ទៀតស្ដីឲ្យអ្នកនោះថា៖ «ឯងមិនកោតខ្លាចព្រះជាម្ចាស់ទេឬ? ឯងត្រូវគេកាត់ទោសដូចលោកដែរ។ ៤១គេធ្វើទោសយើងនេះត្រូវហើយ យើងទទួលទោសតាមអំពើដែលយើងបានប្រព្រឹត្ត។ រីឯលោកវិញ លោកមិនបានធ្វើអំពើអាក្រក់អ្វីសោះ»។ ៤២បន្ទាប់មក គាត់ទូលព្រះអង្គថា៖ «ឱព្រះយេស៊ូអើយ! ពេលព្រះអង្គយាងមកគ្រងរាជ្យ សូមកុំភ្លេចទូលបង្គំ»។ ៤៣ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងច្បាស់ថា ថ្ងៃនេះ អ្នកបានទៅនៅស្ថានបរមសុខ*ជាមួយខ្ញុំ»។

---

ឞ, យើងអាចបកប្រែថា «មនុស្សប្រព្រឹត្តអាក្រក់ ឬ ទុជ៌ន» ក៏បាន។

## ព្រះយេស៊ូចូលទិវង្គត

(ម៉ាថាយ ២៧, ៤៥-៥៦ ម៉ាកុស ១៥, ៣៣-៤១ យ៉ូហាន ១៩,២៨-៣០)

៤៤ពេលនោះ ប្រហែលជាថ្ងៃត្រង់ ផែនដីទាំងមូលងងឹតសូន្យ
រហូតដល់ម៉ោងបីរសៀល ៤៥ព្រះអាទិត្យបាត់រស្មី វាំងនននៅក្នុង
ព្រះវិហារ* រហែកជាពីរ ចំពាក់
កណ្ដាល។ ៤៦ព្រះយេស៊ូបន្លឺព្រះ
សូរសៀងខ្លាំងៗថា៖ «ព្រះបិតា!
ទូលបង្គំសូមប្រគល់វិញ្ញាណរបស់
ទូលបង្គំ ទៅក្នុងព្រះហស្ដព្រះអង្គ
វិញ[ក]»។ ព្រះអង្គមានព្រះបន្ទូល
ដូច្នោះរួចហើយ ក៏រលត់វិញ្ញាណ
ទៅ។ ៤៧នាយទាហានរ៉ូម៉ាំង ដែល
បានឃើញហេតុការណ៍កើតឡើង
ក៏លើកតម្កើងសិរីរុងរឿងរបស់ព្រះ
ជាម្ចាស់ ហើយពោលថា៖ «បុរសនេះពិតជាសុចរិតមែន!»។ ៤៨រីឯ
បណ្ដាជនទាំងប៉ុន្មាន ដែលមកមើល កាលបានឃើញហេតុការណ៍
ទាំងនេះ គេនាំគ្នាត្រឡប់ទៅវិញទាំងគក់ទ្រូង។ ៤៩អ្នកជិតដិត
នឹងព្រះយេស៊ូទាំងប៉ុន្មាន ព្រមទាំងពួកស្ដ្រីដែលដើរតាមព្រះអង្គ
តាំងពីស្រុកកាលីឡេមក នាំគ្នាឈរមើលហេតុការណ៍ទាំងអស់
ពីចម្ងាយ។



## ការបញ្ចុះសពព្រះយេស៊ូ

(ម៉ាថាយ ២៧,៥៧-៦១ ម៉ាកុស ១៥,៤២-៤៧ យ៉ូហាន ១៩,៣៨-៤២)

៥០មានសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់*មួយរូប ឈ្មោះយ៉ូសែប។

ក, ទំនុកតម្កើង ៣៦,១។

លោកជាអ្នកក្រុងអារីម៉ាថេ ជាក្រុងមួយរបស់ជនជាតិយូដា។ លោក
ជាមនុស្សល្អសុចរិត* ហើយទន្ទឹងរង់ចាំព្រះរាជ្យ*របស់ព្រះជា
ម្ចាស់។ ៥១លោកពុំបានយល់ស្របជាមួយគេ លើការសម្រេចចិត្ត
ធ្វើគុតព្រះយេស៊ូទេ ហើយក៏មិនបានចូលរួមក្នុងអំពើដែលគេប្រព្រឹត្ត
នោះដែរ។ ៥២លោកបានទៅជួបលោកពីឡាត សុំយកព្រះសព
ព្រះយេស៊ូ។ ៥៣លោកយកព្រះសពព្រះយេស៊ូចុះពីឈើឆ្កាង ហើយ
រុំនឹងក្រណាត់ផាឌិប រួចដាក់ក្នុងរូងថ្មមួយ ដែលគេដាប់ធ្វើជាផ្នូរ។
ផ្នូរនេះពុំទាន់មានដាក់សពណាមួយនៅឡើយទេ។ ៥៤ថ្ងៃនោះ ជា
ថ្ងៃរៀបចំបុណ្យចម្លង* ហើយថ្ងៃសប្ប័ទ*ជិតមកដល់។ ៥៥ពួក
ស្ត្រីដែលមកតាមព្រះអង្គ តាំងពីស្រុកកាលីឡេក៏ទៅជាមួយលោក
យ៉ូសែបដែរ។ នាងបានឃើញផ្នូរ ហើយឃើញរបៀបដែលគេដាក់
ព្រះសពព្រះយេស៊ូផង។
៥៦បន្ទាប់មក ស្ត្រីទាំងនោះវិលត្រឡប់ទៅវិញរៀបចំគ្រឿង
ក្រអូប និងទឹកអប់។ នៅថ្ងៃសប្ប័ទ នាងនាំគ្នាឈប់សម្រាកតាម
វិន័យចែងទុក។

## ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

(ម៉ាថាយ២៨,១-១០ ម៉ាកុស១៦,១-៨ យ៉ូហាន ២០,១-២០)

២៤ ១នៅថ្ងៃអាទិត្យ[ខ] ពេលព្រលឹមស្រាងៗស្ត្រីៗនាំ
គ្នាទៅផ្នូរ ដោយយកគ្រឿងក្រអូបដែលគេបាន
រៀបចំទុកទៅជាមួយផង។ ២ពួកនាងសង្កេតឃើញថា ថ្មបាន
រមៀលចេញពីមាត់ផ្នូរ។ ៣នាងក៏នាំគ្នាចូលទៅក្នុងផ្នូរ តែពុំឃើញ
ព្រះសពរបស់ព្រះអម្ចាស់យេស៊ូទេ។ ៤ស្ត្រីទាំងនោះមិនដឹងជា
ត្រូវគិតយ៉ាងណា ស្រាប់តែមានបុរសពីរនាក់ស្លៀកពាក់ភ្លឺចិញ្ចែង

---

ខ, ពាក្យដើម «នៅថ្ងៃទីមួយក្នុងសប្ដាហ៍»។ ថ្ងៃទីមួយ គឺថ្ងៃអាទិត្យ។

ចិញ្ចាច មកឈរជិតនាង។ ៥នាងភ័យខ្លាចជាខ្លាំង ហើយឱនមុខ
ចុះ។ បុរសទាំងពីរនាក់នោះ និយាយមកកាន់នាងថា៖ «ហេតុអ្វី
បានជានាងនាំគ្នាមករកព្រះអង្គ ដែលមានព្រះជន្មរស់ក្នុងចំណោម
មនុស្សស្លាប់ដូច្នេះ? ៦{ទ្រង់មិនគង់នៅទីនេះទេ ព្រះជាម្ចាស់បាន
ប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញហើយ។} ចូរនឹកចាំ
អំពីព្រះបន្ទូល ដែលព្រះអង្គបានប្រាប់អ្នករាល់គ្នាកាលនៅស្រុក
កាលីឡេថា ៧"បុត្រមនុស្ស*នឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃ
របស់មនុស្សបាប គេនឹងឆ្កាងព្រះអង្គ តែបីថ្ងៃក្រោយមក ព្រះអង្គ
មានព្រះជន្មរស់ឡើងវិញ"[ឆ]»។ ៨ពួកនាងក៏នឹកឃើញព្រះបន្ទូល
របស់ព្រះយេស៊ូ។ ៩ពួកនាងនាំគ្នាត្រឡប់មកពីផ្នូរវិញ រៀបរាប់
ហេតុការណ៍ទាំងនោះប្រាប់ក្រុមសាវ័កទាំងដប់មួយនាក់ ព្រម
ទាំងអ្នកឯទៀតៗដែរ។ ១០ស្ត្រីទាំងនោះមាន នាងម៉ារីជាអ្នកស្រុក
ម៉ាដាឡា នាងយ៉ូហាណា និងនាងម៉ារីជាម្ដាយរបស់យ៉ាកុប។
ស្ត្រីឯទៀតៗ ដែលបានទៅជាមួយនាងទាំងនោះ ក៏រៀបរាប់
ហេតុការណ៍ប្រាប់ក្រុមគ្រីស្តទូតដែរ ១១ពួកគេពុំជឿពាក្យសម្ដីនាង
ទេ ព្រោះគេថា នាងទាំងនោះនិយាយរឿងផ្ដេសផ្ដាស។ ១២ប៉ុន្តែ
លោកសិលាស្ទុះរត់ទៅផ្នូរ គាត់ឱនមើលទៅឃើញតែក្រណាត់
រុំ ព្រះសពប៉ុណ្ណោះ គាត់វិលត្រឡប់មកផ្ទះវិញ ទាំងងឿងឆ្ងល់
អំពីហេតុការណ៍ដែលកើតមាននោះ។

## សាវ័កពីរនាក់ធ្វើដំណើរទៅភូមិអេម៉ាអ៊ូស

(ម៉ាកូស ១៦, ១២-១៣)

១៣នៅថ្ងៃដដែលនោះ មានសាវ័ក*ពីរនាក់ ធ្វើដំណើរឆ្ពោះ
ទៅភូមិអេម៉ាអ៊ូស ចម្ងាយប្រមាណដប់មួយគីឡូម៉ែត្រពីក្រុង

---
**ឆ**, សូមអានលូកា ៩,២២;១៨,៣២-៣៣។

យេរូសាឡឹម។ ១៤គេនិយាយគ្នា អំពីហេតុការណ៍ទាំងប៉ុន្មាន
ដែលកើតមាន។ ១៥នៅពេលដែលគេកំពុងតែពិភាក្សាគ្នា ព្រះយេស៊ូ
យាងមកជិតគេ ហើយធ្វើដំណើរជាមួយគេទៅ។ ១៦គេឃើញ
ព្រះយេស៊ូផ្ទាល់នឹងភ្នែក តែគេមិនអាចស្គាល់ព្រះអង្គបានឡើយ។



១៧ព្រះយេស៊ូមានព្រះបន្ទូលសួរគេថា៖ «អ្នករាល់គ្នាដើរបណ្ដើរ
ជជែកគ្នាបណ្ដើរ តើនិយាយគ្នាអំពីរឿងអ្វីហ្នឹង?»។ គេក៏ឈប់
ដើរ ឈរស្ងៀមមានទឹកមុខស្រងូត។ ១៨ម្នាក់ឈ្មោះក្លេអូប៉ាស
ទូលព្រះអង្គថា៖ «ប្រជាជនទាំងអស់នៅក្រុងយេរូសាឡឹម ដឹង
ហេតុការណ៍ដែលកើតឡើងប៉ុន្មានថ្ងៃមុននេះគ្រប់ៗគ្នា ម្ដេចក៏
លោកមិនដឹង?»។ ១៩ព្រះអង្គសួរទៅគេថា៖ «តើរឿងអ្វី?»។
គេទូលឆ្លើយថា៖ «គឺរឿងលោកយេស៊ូជាអ្នកភូមិណាសារ៉ែត។
ព្រះជាម្ចាស់ និងប្រជាជនទាំងមូលទទួលស្គាល់ថា លោកជា
ព្យាការី* មានឫទ្ធានុភាពក្នុងគ្រប់កិច្ចការដែលលោកបានធ្វើ និង
គ្រប់ពាក្យសម្ដីដែលលោកបានថ្លែង។ ២០ពួកនាយកបូជាចារ្យ*
និងពួកមន្ត្រីរបស់យើងបានបញ្ជូនលោក ទៅឲ្យគេកាត់ទោស
ប្រហារជីវិត ហើយគេឆ្កាងលោកផង។ ២១យើងបានសង្ឃឹមថា
លោកនេះហើយដែលនឹងរំដោះជនជាតិអ៊ីស្រាអែល តែហេតុ
ការណ៍ទាំងនោះបានកន្លងផុតទៅបីថ្ងៃហើយ។ ២២មានស្ត្រីខ្លះ

ក្នុងចំណោមពួកយើងបានធ្វើឲ្យយើងឆ្ងល់យ៉ាងខ្លាំង គឺនាងនាំ
គ្នាទៅផ្នូរតាំងពីព្រលឹម ២៣តែមិនបានឃើញសពលោកទេ។ នាង
ត្រឡប់មកវិញរៀបរាប់ថា នាងបានឃើញទេវទូត*មកប្រាប់ថា
លោកមានជីវិតរស់។ ២៤មានពួកយើងខ្លះនាំគ្នាទៅផ្នូរដែរ ហើយ
បានឃើញដូចពាក្យស្ត្រីទាំងនោះនិយាយមែន ប៉ុន្តែ ពុំមាននរណា
បានឃើញលោកសោះ»។ ២៥ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«មនុស្សខ្វះប្រាជ្ញាអើយ! អ្នករាល់គ្នាមិនងាយជឿពាក្យទាំងប៉ុន្មាន
ដែលពួកព្យាការីបានថ្លែងសោះ!។ ២៦ព្រះគ្រិស្ត*ត្រូវតែរងទុក្ខ
លំបាកបែបនេះសិន មុននឹងចូលទៅទទួលសិរីរុងរឿងរបស់
ព្រះអង្គ»។ ២៧បន្ទាប់មក ព្រះយេស៊ូបកស្រាយសេចក្ដីដែលមាន
ចែងទុកអំពីព្រះអង្គនៅក្នុងគម្ពីរទាំងមូល ចាប់ពីគម្ពីរលោកម៉ូសេ*
រហូតដល់គម្ពីរព្យាការីទាំងអស់។
២៨លុះមកជិតដល់ភូមិ ដែលសាវ័កទាំងពីរបម្រុងនឹងទៅ
ព្រះយេស៊ូធ្វើហាក់ដូចជាចង់យាងបន្តទៅមុខទៀត។ ២៩គេឃាត់
ព្រះអង្គថា៖ «សូមលោកស្នាក់នៅជាមួយយើងខ្ញុំទីនេះហើយ
ដ្បិតថ្ងៃកាន់តែទាប ហើយជិតយប់ផង» ព្រះយេស៊ូក៏ចូលទៅ
ស្នាក់នៅជាមួយគេ។ ៣០ព្រះអង្គគង់រួមតុជាមួយគេ ហើយយក
នំប៉័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចកាច់ប្រទានឲ្យគេ។
៣១ពេលនោះ ភ្នែកគេបានភ្លឺឡើង មើលព្រះអង្គស្គាល់ ប៉ុន្តែ
ព្រះអង្គបាត់ពីមុខគេទៅ។ ៣២គេនិយាយគ្នាថា៖ «កាលព្រះអង្គ
មានព្រះបន្ទូលមកកាន់យើង ព្រមទាំងបកស្រាយគម្ពីរឲ្យយើង
ស្ដាប់នៅតាមផ្លូវ យើងមានចិត្តរំភើបយ៉ាងខ្លាំង!»។ ៣៣គេក៏ក្រោក
ឡើងវិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញភ្លាម ឃើញក្រុមសាវ័ក*
ទាំងដប់មួយនាក់ នៅជុំគ្នាជាមួយពួកគេឯទៀតៗ ៣៤គេប្រាប់
អ្នកទាំងពីរថា៖ «ព្រះអម្ចាស់មានព្រះជន្មរស់ឡើងវិញ ពិតប្រាកដ

មែន ហើយទ្រង់បានបង្ហាញខ្លួនឲ្យស៊ីម៉ូនឃើញ!»។ ៣៥សាវ័ក
ទាំងពីរនាក់រៀបរាប់ហេតុការណ៍ដែលកើតឡើងនៅតាមផ្លូវ ហើយ
គេបានស្គាល់ព្រះអង្គនៅពេលព្រះអង្គកាច់នំបុ័ង។

## ពួកសាវ័កបានឃើញព្រះយេស៊ូ

(ម៉ាថាយ ២៨ ,១៦-២០ ម៉ាកុស ១៦, ១៤-១៨ យ៉ូហាន ២០, ១៩-២៣
កិច្ចការ ១, ៦-៨)

៣៦នៅពេលសាវ័កទាំងពីរនាក់កំពុងតែនិយាយរៀបរាប់ ព្រះ
អម្ចាស់យាងមកគង់នៅកណ្ដាលចំណោមសាវ័កទាំងអស់ ហើយ
មានព្រះបន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្ដីសុខ
សាន្ត ៣៧គេភ័យតក់ស្លុតញ័ររន្ធត់យ៉ាងខ្លាំង ព្រោះស្មានថាខ្មោច
លង។ ៣៨ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់
គ្នារន្ធត់ចិត្តដូច្នេះ? ម្ដេចក៏អ្នករាល់គ្នា នៅសង្ស័យ? ៣៩ចូរមើល
ដៃជើងខ្ញុំ គឺពិតជាខ្ញុំមែន! ចូរស្ទាបមើល៍ខ្មោចគ្មានសាច់ គ្មាន
ឆ្អឹងដូចខ្ញុំទេ»។ ៤០ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ក៏បង្ហាញ
ព្រះហស្ដ និងព្រះបាទាឲ្យគេឃើញ។ ៤១សាវ័កពុំទាន់ជឿនៅ
ឡើយទេ ព្រោះគេអរផង ហើយងឿងឆ្ងល់ផង។ ដូច្នេះ ព្រះយេស៊ូ
មានព្រះបន្ទូលសួរគេថា៖ «នៅទីនេះ តើអ្នករាល់គ្នាមានអ្វីបរិភោគ
ឬទេ?»។ ៤២គេយកត្រីអាំងមួយដុំមកថ្វាយព្រះអង្គ ៤៣ព្រះអង្គ
ទទួលយក ហើយសោយនៅមុខពួកគេទាំងអស់គ្នា។ ៤៤បន្ទាប់
មកព្រះអង្គមានព្រះបន្ទូលថា៖ «កាលខ្ញុំនៅជាមួយអ្នករាល់គ្នា
នៅឡើយ ខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នាថា សេចក្ដីទាំងអស់
ដែលមានចែងទុកអំពីខ្ញុំ ក្នុងធម្មវិន័យ*របស់លោកម៉ូសេក្នុងគម្ពីរ
ព្យាការី* និងក្នុងគម្ពីរទំនុកតម្កើង*ត្រូវតែកើតមាន»។ ៤៥ព្រះអង្គ

ក៏បំភ្លឺចិត្តគំនិតគេឲ្យយល់អត្ថន័យគម្ពីរ ៤៦ព្រះអង្គមានព្រះបន្ទូល
ថាៈ «ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្ដីដែលមាន
ចែងទុកក្នុងគម្ពីរមែន គឺព្រះគ្រីស្ដ*ត្រូវរងទុក្ខលំបាក ហើយមាន
ព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី។ ៤៧អ្នករាល់គ្នាត្រូវប្រកាសក្នុង
ព្រះនាមព្រះអង្គ ឲ្យមនុស្សគ្រប់ជាតិសាសន៍កែប្រែចិត្តគំនិត ដើម្បី
ឲ្យបានរួចពីបាប គឺត្រូវប្រកាសចាប់តាំងពីក្រុងយេរូសាឡឹមតទៅ។
៤៨អ្នករាល់គ្នាជាសាក្សីអំពីហេតុការណ៍ទាំងនេះ។ ៤៩ខ្ញុំនឹងចាត់
ព្រះវិញ្ញាណមកសណ្ឋិតលើអ្នករាល់គ្នា តាមព្រះបន្ទូលសន្យារបស់
ព្រះបិតាខ្ញុំ។ អ្នករាល់គ្នាត្រូវនៅក្នុងក្រុងយេរូសាឡឹមនេះ រហូត
ដល់ព្រះជាម្ចាស់ប្រទានឲ្យអ្នករាល់គ្នាមានឫទ្ធានុភាព។

## ព្រះយេស៊ូយាងឡើងទៅស្ថានបរមសុខ

(ម៉ាកុស ១៦,១៩-២០ កិច្ចការ ១,៩-១១)

៥០បន្ទាប់មក ព្រះយេស៊ូនាំពួកសាវ័ក*ចេញពីទីក្រុងទៅភូមិ
បេថានី។ ពេលទៅដល់ ព្រះអង្គលើកព្រះហស្ដឡើង ហើយ
ប្រទានពរឲ្យគេ។ ៥១នៅពេលដែលព្រះអង្គកំពុងតែប្រទានពរ
ព្រះជាម្ចាស់លើកយកព្រះអង្គចេញពីគេ ឡើងទៅស្ថានបរមសុខ*។
៥២ក្រោយពីបានក្រាបថ្វាយបង្គំព្រះអង្គរួចហើយ គេក៏វិលត្រឡប់
ទៅក្រុងយេរូសាឡឹមវិញ ប្រកបដោយអំណរដ៏លើសលប់។ ៥៣គេ
នៅក្នុងព្រះវិហារ* ហើយនាំគ្នាលើកតម្កើងព្រះជាម្ចាស់ជានិច្ចនិរន្តរ៍។

# សេចក្ដីពន្យល់
# វាក្យស័ព្ទ

**ក្រុមប្រឹក្សាជាន់ខ្ពស់៖** គឺជាសភាប្រជាជនយូដា ដែលមានភារកិច្ចវិនិច្ឆ័យរឿងខាងសាសនា។ ក្រុមព្រឹក្សាជាន់ខ្ពស់មានសមាជិក៧១រូប ហើយលោកមហាបូជាចារ្យធ្វើជាប្រធាន។

**គណៈផារីស៊ី៖** គឺជនជាតិយូដាមួយក្រុមដែលយកចិត្តទុកដាក់គោរពធម៌វិន័យរបស់លោកម៉ូសេ ដោយហ្មត់ចត់។ ពួកគេចូលចិត្តប្រតិបត្តិតាមប្រពៃណីដូនតា ហើយគិតស្មានថានឹងបានទៅជាមនុស្សសុចរិតដោយការប្រតិបត្តិតាមវិន័យយ៉ាងហ្មត់ចត់បែបនេះ។

**គណៈសាឌូស៊ី៖** គឺជាជនជាតិយូដាមួយក្រុមដែលតែងតែពន្យល់គម្ពីរវិន័យ តាមបែបផ្សេងពីខាងគណៈផារីស៊ី គឺពួកគេមិនជឿថាមានទេវទូត មានខ្មោច ហើយមិនជឿថាមនុស្សស្លាប់នឹងរស់ឡើងវិញឡើយ ។

**គ្រីស្ដ** (ព្រះ)៖ ជាពាក្យក្រិក មានន័យថា «អ្នកដែលព្រះជាម្ចាស់ចាក់ប្រេងអភិសេក តាំងជាស្ដេច»។ ជនជាតិយូដាតែងហៅស្ដេចស្រុកអ៊ីស្រាអែលថា «ព្រះគ្រីស្ដ» ដូច្នេះដែរ គឺមានព្រះបាទដាវីឌជាដើម។ ប៉ុន្តែ ពាក្យ «ព្រះគ្រីស្ដ» នេះ សំដៅទៅលើស្ដេចមួយអង្គ ដែលអ្នកស្រុកយូដាទន្ទឹងរង់ចាំយាងមកសង្គ្រោះពួកគេតាមភាសាហេប្រឺពាក្យនេះហៅថា «ព្រះមេស្ស៊ី»។

**គ្រីស្ដទូត៖** ជាសាវ័កមួយក្រុមដែលព្រះយេស៊ូតែងតាំងឲ្យធ្វើជាតំណាងព្រះអង្គ ហើយចាត់ឲ្យទៅប្រកាសផ្សាយដំណឹងល្អអំពីព្រះអង្គ។ កាលពីមុនយើងបកប្រែពាក្យនេះថា *សាសន*

*ទូត*។ គ្រីស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យ *សាវ័ក* ឬ *អគ្គសាវ័ក* ។

**គង្វាល**៖ ធម្មតាគង្វាលជាអ្នកមិនចេះគម្ពីរ មិនចូលធម្មសាលានៅថ្ងៃសប្ប័ទទេ។ល។ សរុបសេចក្តីទៅ គង្វាលជា "ជនក្រីក្រ" មិនសូវមានបុណ្យជាទីពឹងផ្អែក ជា "អ្នកតូចតាច" ឬជា "អ្នកបាប"។ ពួកផារីស៊ី និងអ្នកកាន់ធម្មវិន័យយ៉ាងហ្មត់ចត់ តែងតែមើលងាយពួកគង្វាល ព្រោះគ្មានលទ្ធភាពនឹងកាន់តាមវិន័យបានដូចពួកគេ។ គេតែងចោទថា ពួកគង្វាលជាចោរដូចអ្នកទារពន្ធ ជាមនុស្សថោកទាប។ ប៉ុន្តែពួកគង្វាលនេះហើយ ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេទទួលដំណឹងល្អពីពួកទេវទូត រួចទៅប្រកាសដំណឹងនេះឲ្យអ្នកឯទៀតដឹង ពួកគេជាអ្នកប្រកាសដំណឹងល្អអំពីព្រះយេស៊ូមុនគេ។

**ចម្លង** (បុណ្យ) ៖ រៀងរាល់ឆ្នាំ ជនជាតិយូដានាំគ្នាធ្វើបុណ្យធំ ដើម្បីរំឭកពេលព្រះជាម្ចាស់ រំដោះប្រជារាស្ត្រព្រះអង្គឲ្យរួចផុតពីប្រទេសអេស៊ីប។ តាមភាសាហេប្រឺគេតែងហៅបុណ្យនេះថា «បុណ្យប៉ាក» ដែលប្រែជាភាសាខ្មែរថា «បុណ្យចម្លង»។ គ្រីស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យ «បុណ្យរំលង» ខ្លះទៀត ធ្លាប់ប្រើពាក្យ «បុណ្យឆ្លងកាត់»។ ក្នុងឱកាសបុណ្យចម្លងនោះ ជនជាតិអ៊ីស្រាអែលតែងធ្វើពិធីជប់លៀង និងបរិភោគសាច់កូនចៀម។ ជនជាតិអ៊ីស្រាអែលតែងហៅបុណ្យនេះតាមឈ្មោះផ្សេងថា «បុណ្យនំប៉័ងឥតមេ» ព្រោះក្នុងពេលបុណ្យនោះ ពួកគេនឹកដល់សម័យដែលបុព្វបុរសរបស់គេរត់ចេញពីស្រុកអេស៊ីប។ ពេលនោះគេបានដុតនំប៉័ងដោយមិនដាក់មេ ស្របតាមបញ្ជារបស់ព្រះជាម្ចាស់។

**ជ្រមុជទឹក**៖ ជាពិធីមួយដែលជនជាតិយូដាធ្លាប់ធ្វើ ដើម្បីបញ្ជាក់ថាគេទទួលសារភាពនូវអំពើបាបរបស់ខ្លួន ហើយសម្រេចចិត្តកែប្រែចិត្តគំនិត។ ដោយសារពិធីនេះ ជនជាតិយូដាគិតថា

គេបានរួចពីបាប ហើយអាចចូលរួមជាមួយអ្នកដទៃធ្វើពិធីបុណ្យផ្សេងៗតាមវិន័យចែងទុកមក។ រីឯគ្រីស្តបរិស័ទជឿថា ពេលទទួលពិធីជ្រមុជទឹក គេចូលរួមរស់ជាមួយព្រះយេស៊ូជាព្រះសង្គ្រោះ។

**ដាក់ដៃ**៖ ជាកាយវិការមួយ សម្រាប់តែងតាំងមនុស្សម្នាក់ឲ្យបំពេញមុខងារអ្វីមួយ ឬទូលសូមព្រះជាម្ចាស់ប្រទានព្រះអំណោយទានរបស់ព្រះវិញ្ញាណ និងជារបៀបទូលសូមព្រះអង្គប្រោសនរណាម្នាក់ឲ្យបានជាពីជំងឺ ឬសូមព្រះអង្គប្រទានពរដល់នរណាម្នាក់ ។

**ដួខ** (ប្រាក់)៖ ជាប្រាក់ខ្មែរពីបូរាណ។ យើងសន្មត់ប្រើពាក្យបុរាណនេះសំដៅទៅលើប្រាក់ឈ្នួលដែលកម្មករជនជាតិយូដាទទួលពេលធ្វើការពេញមួយថ្ងៃ ។

**ដំណឹងល្អ**៖ គឺសេចក្តីចែងអំពីព្រះជាម្ចាស់ប្រោសប្រណីប្រជារាស្ត្រអ៊ីស្រាអែល តាមព្រះបន្ទូលសន្យានឹងបុព្វបុរស។ គ្រីស្តបរិស័ទប្រើពាក្យដំណឹងល្អនេះ ដើម្បីបញ្ជាក់ថា ព្រះជាម្ចាស់ប្រោសប្រណីមនុស្សលោកទាំងអស់តាមរយៈព្រះយេស៊ូជាព្រះគ្រីស្ត និងជាព្រះបុត្រារបស់ព្រះអង្គ ។

**ថ្ងៃសប្ប័ទ**៖ ជាថ្ងៃសៅរ៍។ ក្នុងគម្ពីរសម្ពន្ធមេត្រីចាស់វិន័យបានបង្គាប់ឲ្យប្រជាជនអ៊ីស្រាអែល ញែកថ្ងៃទីប្រាំពីរក្នុងសប្តាហ៍ដែលហៅថាថ្ងៃសប្ប័ទនេះទុកដោយឡែក ដើម្បីគោរពបម្រើព្រះជាម្ចាស់ និងដើម្បីរំឭកពីគ្រាដែលព្រះអង្គបង្កើតពិភពលោក។ នៅថ្ងៃសប្ប័ទ ជនជាតិអ៊ីស្រាអែលមិនត្រូវប្រព្រឹត្តកិច្ចការអ្វីឡើយ។ ពីមុនយើងបកប្រែពាក្យនេះថា ថ្ងៃឈប់សម្រាក ក៏ប៉ុន្តែ ដើម្បីចៀសវាងការភ័ន្តច្រឡំ គឺខ្លាចអ្នកអានយល់ថា ថ្ងៃឈប់សម្រាកនេះ ជាថ្ងៃសម្រាកការងារ ឬថ្ងៃវិស្សមកាលធម្មតា ដែលឥតទាក់ទាមអ្វីនឹងជំនឿ យើងក៏សន្មតយកពាក្យដើមជាភាសាហេប្រឺ

«សប្ប័ទ» នេះមកប្រើវិញ។ គ្រីស្តបរិស័ទខ្លះនិយមប្រើពាក្យ «ថ្ងៃសីល »។

**ទារពន្ធ** (អ្នក)៖ នៅសម័យព្រះយេស៊ូ ជនជាតិរ៉ូម៉ាំងត្រួតត្រាស្រុកអ៊ីស្រាអែល និងមជ្ឈិមបូព៌ាទាំងមូល។ «អ្នកទារពន្ធ» ជាជនជាតិយូដាដែលទារពន្ធអាករពីអ្នកស្រុកយកទៅជូនរាជប្រតិភូអធិរាជរ៉ូម៉ាំង។ ជនជាតិយូដាចាត់ទុកពួកគេជា «អ្នកមិនបរិសុទ្ធ» ព្រោះពួកគេធ្វើការឲ្យខ្មាំង ហើយប៉ះពាល់ប្រាក់ដែលមានព្រះឆាយាលក្ខណ៍របស់ព្រះចៅអធិរាជ។

**ទេវទូត**៖ គឺអ្នកនាំដំណឹង ឬនាំព្រះបន្ទូលពីព្រះជាម្ចាស់មកមនុស្សលោក។ កាលពីមុនគ្រីស្តបរិស័ទខ្មែរនិយមប្រើពាក្យ «ទេវតា»។

**នំបុ័ងឥតមេ**៖ (មើលពាក្យបុណ្យ «ចម្លង»)។

**បណ្ឌិតខាងវិន័យ**៖ គ្រូអាចារ្យដែលតែងតែរៀនគម្ពីរទាំងមូល ជាពិសេស គម្ពីរវិន័យលោកម៉ូសេ ដោយពិនិត្យពិច័យនូវការប្រៀនប្រដៅដែលមានចែងទុកក្នុងគម្ពីរ ហើយយកចំណេះចេះដឹងរបស់ខ្លួនទៅបង្រៀនអ្នកស្រុក។ គ្រីស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យអាចារ្យ ខ្លះទៀតប្រើពាក្យធម្មាចារ្យ ។

**បរិសុទ្ធ**៖ ជនជាតិអ៊ីស្រាអែលតែងកាន់តាមវិន័យជាច្រើនប្រការ។ អ្នកដែលវិន័យចាត់ទុកជា «មនុស្សមិនបរិសុទ្ធ» គឺស្ត្រីសម្រាលកូន អ្នកប៉ះពាល់សាកសព មនុស្សឃ្លង់ អ្នកបរិភោគសាច់ជ្រូក និងសត្វឯទៀតៗដែលវិន័យហាមឃាត់ អ្នកទាក់ទងសាសន៍ដទៃ និងអ្នកទារពន្ធជាដើម។ អ្នកទាំងនោះគ្មានសិទ្ធិចូលរួមជាមួយប្រជាជន ទៅគោរពព្រះជាម្ចាស់ជាដាច់ខាត។ គេត្រូវតែធ្វើពិធីជ្រមុជទឹក បាចទឹកលើខ្លួន ឬពិធីផ្សេងៗជាមុនសិន ទើបអាចចូលរួមបាន។ ជនជាតិអ៊ីស្រាអែលគ្មានសិទ្ធិទាក់

ទងជាមួយ «អ្នកមិនបរិសុទ្ធ» ទាំងនោះទេ ព្រោះខ្លាចទៅជាមិនបរិសុទ្ធដូចគេដែរ ។

**បុត្រមនុស្ស៖** ពាក្យ «បុត្រមនុស្ស» មានន័យថា «មនុស្សសាមញ្ញធម្មតា»។ គម្ពីរព្យាការីអេសេគីអែល (អេសេគាល) ២.១ ប្រើពាក្យនេះ ដើម្បីសម្ដែងឲ្យដឹងថា ព្រះជាម្ចាស់ និងមនុស្សយើងខុសប្លែកពីគ្នាឆ្ងាយណាស់។ គម្ពីរព្យាការីដានីអែល ( ៧.១៣) ប្រើពាក្យនេះសំដៅទៅលើមនុស្សម្នាក់ ដែលមកពីស្ថានបរមសុខ ហើយទទួលអំណាចលើប្រជាជនក្នុងពិភពលោកទាំងមូល។ ព្រះយេស៊ូប្រើពាក្យ «បុត្រមនុស្ស» នេះសំដៅទៅលើព្រះអង្គផ្ទាល់តែម្ដង ដើម្បីសម្ដែងឲ្យដឹងថា ព្រះអង្គជាមនុស្សធម្មតាដែលទន់ខ្សោយផង ហើយព្រះអង្គជាព្រះគ្រីស្ដដែលយាងមកពីស្ថានបរមសុខ ដើម្បីសង្គ្រោះមនុស្សលោកផង (ម៉ាថាយ ៩.៦,២៦-៦៤)។

គ្រីស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យ*កូនមនុស្ស* ខ្លះទៀតប្រើពាក្យ *បុត្រនៃមនុស្ស* ។

**បូជាចារ្យ៖** ជាអាចារ្យដែលទទួលមុខងាររៀបចំតង្វាយ ឬធ្វើបូជាយញ្ញថ្វាយព្រះជាម្ចាស់ តាមវិន័យរបស់លោកម៉ូសេ។ លោកបូជាចារ្យមានភារកិច្ចប្រៀនប្រដៅអ្នកស្រុកអំពីគម្ពីរវិន័យផងដែរ។ នៅជំនាន់ព្រះយេស៊ូ ពួក*នាយកបូជាចារ្យ* ជាមេរបស់អស់លោកបូជាចារ្យ ហើយលោក*មហាបូជាចារ្យ* ជាប្រមុខលើពួកបូជាចារ្យទាំងអស់។ គ្រីស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យ *«សង្ឃ»* សម្រាប់បូជាចារ្យ *«សម្ដេចសង្ឃ»* សម្រាប់មហាបូជាចារ្យ។ ខ្លះទៀតប្រើពាក្យ *«សង្ឃរាជ»*។

**ព្យាការី៖** ជាអ្នកបម្រើព្រះជាម្ចាស់ និងថ្លែងព្រះបន្ទូលក្នុងព្រះនាមព្រះអង្គប្រាប់ប្រជាជន។ ព្យាការីអេលី (ដែលរស់នៅសតវត្សទី៩ មុន គ.ស.) និងព្យាការីអេសាយ (ដែលរស់នៅ

សតវត្សទី៨ មុន គ.ស) មានឈ្មោះល្បីជាងគេ ក្នុងចំណោមព្យាការីទាំងអស់។ គ្រីស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យ *ហោរា*។ សម្រាប់ស្ត្រីប្រើព្យាការិនី ។

**ព្រឹទ្ធាចារ្យ**៖ ជាចាស់ទុំដែលមានមុខងារណែនាំប្រជាជនយូដាខាងសាសនា។ មានចាស់ទុំខ្លះ ចូលរួមក្នុងក្រុមប្រឹក្សាជាន់ខ្ពស់។ ក្រោយមក គ្រីស្តបរិស័ទប្រើពាក្យនេះសំដៅទៅលើអ្នកទទួលខុសត្រូវក្រុមជំនុំ / ព្រះសហគមន៍។ គ្រីស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យចាស់ទុំ។

**មារ**៖ ជាមេប្រឆាំងនឹងព្រះជាម្ចាស់ នាំឲ្យមនុស្សប្រព្រឹត្តអំពើអាក្រក់។ ភាសាហេប្រឺ ហៅថា «សាតាំង»។

គ្រីស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យ «អារក្ស»។ តាមគម្ពីរពួកខ្មោចជាបរិវាររបស់មារ ។

**ម៉ូសេ** (លោក)៖ លោកម៉ូសេជាអ្នកបានណែនាំប្រជារាស្ត្រអ៊ីស្រាអែល ចេញពីប្រទេសអេស៊ីប កាលពីដើម (១២៥០ឆ្នាំ មុន គ.ស.) ហើយជាអ្នកបានទទួលវិន័យពីព្រះជាម្ចាស់ ។

**យញ្ញបូជា**៖ ជាពិធីមួយដែលជនជាតិអ៊ីស្រាអែលយកសត្វសម្លាប់បូជាថ្វាយព្រះជាម្ចាស់ ដើម្បីទូលសូមព្រះអង្គលើកលែងទោសឲ្យរួចពីបាប ឬដើម្បីអរព្រះគុណព្រះអង្គ។ យញ្ញបូជាមួយចំនួន ជាពិសេស **យញ្ញបូជាមេត្រីភាព** គេដុតសាច់មួយផ្នែករបស់សត្វដែលគេថ្វាយនៅលើអាសនៈ មួយផ្នែកទៀតគេជូនបូជាចារ្យ ហើយមួយផ្នែកធំដែលនៅសល់ អ្នកថ្វាយទុកបរិភោគខ្លួនឯង។ ចំពោះយញ្ញបូជាមួយប្រភេទទៀតគឺ **តង្វាយដុតទាំងមូល** គេដុតសត្វទាំងមូលនៅលើអាសនៈ។

**រាជ្យ** (ព្រះ)៖ ពាក្យនេះមានអត្ថន័យទូលំទូលាយគឺ «ព្រះជាម្ចាស់សោយរាជ្យ» ឬ«ពិភពលោកថ្មីដែលស្ថិតនៅក្រោមឥទ្ធិពល

របស់ព្រះជាម្ចាស់»។ ក្នុងគម្ពីរដំណឹងល្អ ពាក្យព្រះរាជ្យសំដៅលើរបៀបរស់នៅតាមការប្រៀនប្រដៅរបស់ព្រះយេស៊ូ។ គ្រីស្តបរិស័ទត្រូវយកចិត្តទុកដាក់លាតសន្ធឹង ព្រះរាជ្យនេះដល់មនុស្សលោកទាំងអស់រហូតដល់អវសានតកាលនៃពិភពលិលោក។គ្រីស្តបរិស័ទខ្លះនិយមប្រើពាក្យ*នគរព្រះ*។

**វិន័យ**៖ ច្បាប់ប្រៀនប្រដៅជនជាតិយូដាឲ្យប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានប្រទានវិន័យឲ្យប្រជារាស្ត្រអ៊ីស្រាអែល តាមរយៈលោកម៉ូសេ វិន័យទាំងអស់នោះមានចងក្រងទុកក្នុងគម្ពីរប្រាំក័ណ្ឌ ដែលហៅថា «គម្ពីរវិន័យ»។ គ្រីស្តបរិស័ទខ្លះនិយមប្រើពាក្យ «ធម៌វិន័យ» ខ្លះទៀតប្រើពាក្យ «ក្រឹត្យវិន័យ»។

**វិសុទ្ធ**៖ គឺជានិស្ស័យ ឬគុណពិសេសរបស់ព្រះជាម្ចាស់ខុសប្លែកពីសត្វលោកដែលព្រះអង្គបង្កើតមក។ មនុស្សលោក ឬអ្វីៗទាំងអស់ដែលនៅជាប់នឹងព្រះអង្គ ព្រះអង្គប្រោសប្រទានឲ្យបានវិសុទ្ធដែរ។ ក្រុមគ្រីស្តបរិស័ទខ្លះប្រើពាក្យ « បរិសុទ្ធ» ខ្លះទៀតប្រើពាក្យ «សន្តវិសុទ្ធ» ។

**វិហារ** (ព្រះ)៖ ជនជាតិអ៊ីស្រាអែលធ្លាប់ធ្វើបូជនិយេសចរណ៍ទៅគោរពព្រះជាម្ចាស់នៅក្រុងយេរូសាឡឹម។ នៅក្រុងនោះ គេរៀបលានមួយធំ។ នៅលាននោះ មានចែកជាធ្លាពីរគឺ « ធ្លាខាងក្រៅ» សម្រាប់ឲ្យជនជាតិដទៃទៀតចូល ធ្លាមួយទៀតហៅថា «ធ្លាខាងក្នុង» សម្រាប់ឲ្យជនជាតិអ៊ីស្រាអែលចូល។ នៅកណ្ដាលធ្លាខាងក្នុង គេសង់អាគារមួយពីថ្មដ៏ល្អប្រណីត ដែលមានវាំងននមួយខ័ណ្ឌជាពីរចំណែកគឺ «ទីសក្ការៈ» និង «ទីសក្ការៈបំផុត»។ ពួកគេធ្លាប់គោរពទីសក្ការៈបំផុតនោះជាដំណាក់របស់ព្រះជាម្ចាស់ មានតែលោកមហាបូជាចារ្យប៉ុណ្ណោះ ដែលមាន

សិទ្ធចូលទីសក្ការៈបំផុតនោះមួយឆ្នាំម្ដង។ អស់លោកបូជាចារ្យធ្លាប់ធ្វើយញ្ញបូជាថ្វាយព្រះជាម្ចាស់នៅធ្លាខាងមុខ។ យើងសន្មតហៅទីនោះ ទាំងធ្លាខាងក្រៅ ទាំងធ្លាខាងក្នុង ទាំងព្រះដំណាក់របស់ព្រះជាម្ចាស់ថា «ព្រះវិហារ»។

**វាលរហោស្ថាន**៖ ពាក្យនេះមិនគ្រាន់តែសំដៅទៅលើកន្លែងមួយដែលហួតហែងគ្មានអ្វីដុះឡើង ឬគ្មានមនុស្សនៅប៉ុណ្ណោះទេ តែមានអត្ថន័យពិសេស។ តាំងពីជំនាន់ជនជាតិអ៊ីស្រាអែលចេញពីប្រទេសអេស៊ីបមក ពួកគេតែងតែនឹកគិតថា ក្នុង "វាលរហោស្ថាន" ក្រៅពីព្រះជាម្ចាស់ គ្មានអ្វីធ្វើជាទីពឹងទេ គឺជាកន្លែងសម្រាប់ប្រែចិត្តគំនិតវិលត្រលប់មកពឹងលើព្រះជាម្ចាស់វិញ។ នៅទីនោះ ព្រះជាម្ចាស់ក៏មានព្រះហឫទ័យមេត្តាករុណា ស្រឡាញ់គេយ៉ាងលើសលប់ដូចស្វាមីថ្មោងថ្មីធ្លាប់ស្រឡាញ់ភរិយាដែរ។

**សាលាប្រជុំ**៖ ជាកន្លែងដែលជនជាតិយូដាតែងតែជួបជុំគ្នាជារៀងរាល់ថ្ងៃសៅរ៍ ដើម្បីស្ដាប់ព្រះគម្ពីរ និងច្រៀងទំនុកតម្កើងផង។ គណៈគ្រីស្ដបរិស័ទខ្លះនិយមប្រើពាក្យ «ធម្មសាលា» ឬ «សាលាធម៌»។

**សាវ័ក**៖ ជាអ្នកស្ដាប់គ្រូ។ សាវ័ករបស់ព្រះយេស៊ូ គឺអ្នកដែលស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ និងប្រព្រឹត្តតាម។

**សុចរិត**៖ ក្នុងគម្ពីរ ពាក្យ «សុចរិត» សំដៅទៅលើចិត្តដែលចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់យ៉ាងស្មោះស្ម័គ្រ។

**ស្ថានបរមសុខ**៖ គឺកន្លែងសុខក្សេមក្សាន្តបំផុត ដោយចូលរួមរស់ជាមួយព្រះជាម្ចាស់។ កាលពីមុន ក្នុងគម្ពីរ គេប្រើពាក្យ «ស្ថានសួគ៌»។

តាមលទ្ធិពុទ្ធសាសនា ពាក្យស្ថានសួគ៌ សំដៅលើទេវលោក គឺស្ថានទេវតា ដែលជាប់ទាក់ទងនឹងលោកនេះនៅឡើយ គឺត្រូវ

រិលកើតរិលស្លាប់ក្នុងវាលវដ្តសង្សារដ៏ធំធេង។ ដោយខ្លាចអ្នកអានយល់ថាខុសអត្ថន័យ ហើយស្មានថា ព្រះជាម្ចាស់ត្រូវរិលប្រសូតរិលសោយទិវង្គត ដូចទេវតាដែរ នោះយើងក៏បានសន្មតប្រើពាក្យ «ស្ថានបរសុខ» ជំនួសវិញ។

**អធិដ្ឋាន**៖ មានន័យថាតាំងចិត្ត។ គ្រីស្តបរិស័ទសន្មតប្រើពាក្យនេះសំដៅទៅលើការទូលព្រះអង្គ ដោយចិត្តស្រឡាញ់ ដើម្បីសរសើរតម្កើងព្រះអង្គ អរព្រះគុណព្រះអង្គ សូមអង្វរព្រះអង្គសូមព្រះអង្គលើកលែងទោស។ល។

**ឯកឧត្តមថេអូភីល**៖ ឈ្មោះនេះមានន័យថា អ្នកស្រឡាញ់ព្រះជាម្ចាស់។ លោកប្រហែលជាមន្ត្រីរាជការជាន់ខ្ពស់ម្នាក់ "ដែលទទួលសេចក្តីប្រៀនប្រដៅ" អំពីព្រះគ្រីស្ត។ អ្នកវិភាគខ្លះសន្និដ្ឋានថា លោកជានិមិត្តរូបអំពីគ្រីស្តបរិស័ទទាំងអស់។ អ្នកខ្លះសន្និដ្ឋានថា លោកជាអ្នករាជការម្នាក់ដែលមិនជឿ អ្នកនិពន្ធគម្ពីរផ្ញើសៀវភៅនេះ ដើម្បីបង្ហាញជំនឿរបស់គ្រីស្តបរិស័ទ ព្រមទាំងដោះសារពាក្យចោទប្រកាន់ចំពោះគ្រីស្តសាសនា។

**ឧទុម្ពរ**៖ ឈ្មោះដើមល្វាម៉្យាង ដុះនៅមជ្ឈឹមបូព៌ាប្រទេស ដែលផ្លែវាមានរសជាតិផ្អែម ឆ្ងាញ់ពិសា។ ក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ ដើមឧទុម្ពរជានិមិត្តរូបនៃភាពចម្រុងចម្រើន និងសន្តិសុខ។




បោះពុម្ពនៅភ្នំពេញ ឆ្នាំ ២០១២
©មណ្ឌលអប់រំជំនឿកាតូលិកកម្ពុជា (CCCC)
ផ្ទះលេខ ៥៧ ផ្លូវលេខ ១០១ សង្កាត់បឹងត្របែក រាជធានីភ្នំពេញ, E-mail : 4c@online.com.kh

